សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អំពើអនីត្យានុកូល របស់មន្ត្រីរាជការ

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ

សមណនិស្សិត : **នួន រស្មី**

សមណនិស្សិត : **គីម ចាន់ឌី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត : **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាព នាម **ឆួន រស្មី** និង **តម ចាន់ឌី** ជាសមណនិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសា-ស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច សូមសម្តែងអំណរគុណជាអនេកប្បមាណ ថ្វាយ ប្រគេន ជូនចំពោះ :

- **ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់ជាមគ្គុទេសក៍ដ៏ឆ្នើម ក្នុងការចូលរួមចំណែកថែរក្សាស្ថិរភាព សន្តិភាព ជូនប្រជានុរាស្រ្តខ្មែរ។
- **រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** ចាប់ពីអាណត្តិទី១ រហូតដល់បច្ចុប្បន្ន ដែលលោកបានខិតខំថែរក្សា សុខសន្តិភាពជូនប្រជាពលរដ្ឋខ្មែរ បានបញ្ចៀសមាតុភូមិកម្ពុជា ចាកសង្គ្រាមផ្សេងៗ ពីភាពអសន្តិសុខ កុបកម្ម អបគមន៍ និង ភេរវកម្មនានា ហើយបាននាំមាតុភូមិកម្ពុជា ឆ្ពោះទៅរកវឌ្ឍនភាព វិបុលភាព និង ភាពក្សេមក្សាន្ត រស់ជាសន្តិសហវិជ្ជមាន ដូចប្រទេសនានា ក្នុងសតវត្សទីម្ភៃមួយនេះ។
- **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យា-សាស្រ្តសេដ្ឋកិច្ច ដែលលោកបានគ្រប់គ្រងសាកលវិទ្យាល័យឱ្យទទួលបានកេរ្តិ៍ឈ្មោះល្អប្រសើរ និងមានការរីកចម្រើន។
- **ព្រឹទ្ធបុរស** និង **ព្រឹទ្ធបុរសរង** ព្រមទាំងសហការីគ្រប់រូបនៃមហាវិទ្យាល័យនីតិសាស្រ្ត ដែលខិតខំបំពេញការងារយ៉ាងស្វាហាប់។
- សាស្រ្តាចារ្យបណ្ឌិត **ឈុន ណារ៉េត** ជាសាស្រ្តាចារ្យណែនាំ បានខិតខំយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ក្នុងការបណ្តុះបណ្តាលណែនាំពន្យល់ ផ្តល់នូវបច្ចេកទេស ដល់អាត្មាភាព ក្នុងការសរសេរសារណានេះរហូតទទួលជោគជ័យជាស្ថាពរ។
- **សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ ឧបជ្ឈាយាចារ្យ** គ្រប់រូបដែលលោកខិតខំអប់រំបង្ហាត់បង្រៀនដល់អាត្មាភាព ទុកសម្រាប់ជាពន្លក នៃសសរទ្រូងប្រទេសជាតិទៅថ្ងៃអនាគត។
- **មាតាបិតា** ជាអ្នកមាននូវអនន្តគុណដ៏ធំធេង ក្នុងការផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងឱ្យអាត្មាភាព អាចមានលទ្ធភាពសិក្សារៀនសូត្យ ដល់ថ្នាក់បរិញ្ញាបត្រ រហូតដល់បានសរសេរសារណាបញ្ចប់ការសិក្សា នាពេលនេះ។

សូមអស់លោកអ្នកមានគុណទាំងឡាយ ចូបប្រទះនឹងសេចក្តីចម្រើន និង ទទួលបានជោគជ័យគ្រប់ភារកិច្ច។

# ឧទ្ទិសកថា

## អាត្មាភាពសូមឧទ្ទិស នូវអត្ថមនុញ្ញផល ដែលកើតឡើង ពីការខិតខំប្រឹងប្រែង ដើម្បីឧទ្ទួលបាននូវវណ្ណកម្មដ៏ថ្មីនេះ សូមថ្វាយ ប្រគេន ជូនចំពោះ ៖

ព្រះមហាក្សត្រ វីរសមណៈ វីរបុរស និង និស្សិតបញ្ញវន្តគ្រប់រូប ដែលបានធ្វើពលិកម្មជូនជាតិមាតុភូមិដ៏កម្សត់នេះ ព្រមទាំងជនរួមជាតិទាំងឡាយ ដែលមានចិត្តសោមនស្សរីករាយ រាប់អានប្រាថ្នាចង់សិក្សាស្រាវជ្រាវទុកជាដើមទុននៃចំណេះដឹង សូមឱ្យស្នាដៃនេះ នឹងបានជាប្រទីបនាំផ្លូវដល់ជនរួមជាតិខ្មែរគ្រប់ៗរូប ដែលចង់ឈ្វេងយល់ និង មានបំណងចូលរួមវិភាគទាន ក្នុងកិច្ចអភិវឌ្ឍន៍ធនធានបញ្ញាញាណ ក្នុងកម្ពុជរដ្ឋ។ សូមឱ្យស្នាដៃនេះ បានជាបច្ច័យនាំមកនូវកិរិយាអស់ទៅនូវស្បែអន្ធការ ដែលជាគ្រឿងឃាត់ឃាំងវឌ្ឍនភាព និង វិបុលភាព ចេញឱ្យផុតពីមាតុភូមិ កម្ពុជា។

សូមឱ្យលោកអ្នកទាំងឡាយ ទទួលបាននូវសេចក្ដីសុខ រួចចាកទុក្ខសោកទាំងពួង និង ឱ្យបានសម្រេចតាមបំណងប្រាថ្នារៀងៗខ្លួន ជានិច្ចនិរន្តរ៍តរៀងទៅ។

# បុព្វកថា

សារណាក្រោមប្រធានបទស្តីពី "**អំពើអនីត្យានុកូល របស់មន្ត្រីរាជការ**" ដែលអាត្មាភាពទាំងពីររូប ចាប់អារម្មណ៍ធ្វើការស្រាវជ្រាវនេះ ជាវិភាគទានមួយ សម្រាប់មន្ត្រីរាជការ និស្សិត ព្រមទាំងប្រជាពលរដ្ឋទាំងអស់ ដើម្បីទទួលបាននូវពុទ្ធិបន្ថែមទៀត លើការបណ្តុះបណ្តាលផ្នែកគតិច្បាប់។ ការអនុវត្តកន្លងមក របស់តុលាការ ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ ហាក់នៅមានចំណុចខ្វះខាតច្រើន ទាំងផ្នែកគតិច្បាប់ និង យុត្តិសាស្ត្រ ចំណែកភាគីខាងប្រជាពលរដ្ឋវិញ ក៏ហាក់នៅមានការញញើតរដ្ឋផងដែរ ក្នុងការប្តឹងទាមទារសំណងផ្សេងៗ ពីភាគីរដ្ឋ។

កត្តាអសកម្មរបស់រូបវន្តបុគ្គល នៃស្ថាប័នរដ្ឋ ឬ អង្គការរដ្ឋកន្លងមក បានបណ្តាលឱ្យមានការខូចខាតដល់ប្រជាពលរដ្ឋ ដោយការធ្វេសប្រហែសរបស់បុគ្គលិក។ ចំណែកបុគ្គលជាមន្ត្រីរាជការភាគច្រើន ពុំទទួលខុសត្រូវនូវកំហុស របស់ខ្លួនឡើយ ដោយអាងថា ខ្លួនជាបុគ្គលិករបស់រដ្ឋមានអំណាចសាធារណៈក្នុងការបម្រើសាធារណជន ម៉្យាងទៀត មន្ត្រីរាជការមួយចំនួនតូច ដែលមានចេតនាទុច្ចរិត បានយកតួនាទីរបស់ខ្លួន ជាមន្ត្រីរាជការទៅប្រព្រឹត្តសកម្មភាពបំពារបំពានលើប្រជាពលរដ្ឋ ដោយផ្ទុយនឹងច្បាប់ រួចឆ្លើយថាជាការសម្រេចរបស់ស្ថាប័នរដ្ឋ ឬ អង្គការរដ្ឋទៅវិញ ក្នុងចេតនាទុច្ចរិតពុំទទួលខុសត្រូវ នូវកំហុសរបស់ខ្លួនផ្ទាល់នោះឡើយ។

ចំណែកប្រជាពលរដ្ឋវិញ បានប្រព្រឹត្តឱ្យមានព្យសនកម្មដល់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋក្តី ដល់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្តី ដោយចេតនាក្តី ឬ អចេតនាក្តី ជាឧក្រិដ្ឋត្រូវជួសជុល និងសងនូវការខូចខាតនោះចំពោះរដ្ឋ។

បាតុភាព អតុល្យភាពរវាងមន្ត្រីរាជការ និង ប្រជាពលរដ្ឋនេះហើយ ជាកត្តាជំរុញឱ្យអាត្មាភាពទាំងពីររូប សម្រេចចិត្តជ្រើសរើសយកប្រធានបទ "**អំពើអនីត្យានុកូល របស់មន្ត្រីរាជការ**" ជាប្រធានបទ ក្នុងការសរសេរសារណា បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឯកទេសនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ ក្នុងគោលបំណងចង់ឱ្យមន្ត្រីរាជការ មានលក្ខណៈទទួលខុសត្រូវ នូវសកម្មភាពផ្ទុយច្បាប់ ចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

សារណានេះ ត្រូវបានផ្តួចផ្តើមជាពន្លកស្រាវជ្រាវ និង ប្រមូលចងក្រងឡើង ដោយអាត្មាភាពទាំងពីររូប ជាសមណនិស្សិត ថ្នាក់បរិញ្ញាបត្រជំនាន់ទី១៨ ឯកទេសនីតិសាស្ត្រ មហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការណែនាំដ៏ថ្លៃថ្លា ពីសម្នាក់លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ព្រមទាំងមានការផ្តល់យោបល់ជាច្រើន ពីលោកសាស្ត្រាចារ្យជាច្រើនរូបទៀត។ នេះគឺ ជាការផ្ទេរនូវចំណេះដឹង និង បទពិសោធន៍ ពីលោក

សាស្ត្រាចារ្យ ដល់និស្សិត ដែលជាការចូលរួមលើកស្ទួយធនធានមនុស្សនៅកម្ពុជា ឱ្យកាន់តែប្រសើរឡើង។

អាត្មាភាពទាំងពីររូប មានក្តីសង្ឃឹមយ៉ាងកក់ក្តៅថា វណ្ណកម្មនៃការស្រាវជ្រាវនេះ នឹងជួយជាព័ត៌មាន ពុទ្ធិ និង បទពិសោធន៍ជាយុត្តិសាស្ត្រនានា ដល់និស្សិត និង អ្នកអានគ្រប់រូប។ មិនត្រឹមតែប៉ុណ្ណោះ វណ្ណកម្មនេះ អាចជាគតិស្រាវជ្រាវ ដល់ចៅក្រម និង មន្ត្រីទទួលបន្ទុកដោះស្រាយវិវាទនានា ដើម្បីទាញយកបទពិសោធន៍បន្ថែម មកពិចារណាក្នុងការវិនិច្ឆ័យសេចក្តី លើរឿងក្តីមួយចំនួនដែលពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូលនេះ។ ក្នុងសារណានេះ មានការសិក្សាស្រាវជ្រាវ ដោយលំបាករហូតដល់សាលដីកាតុលាការកំពូល ដែលបានវិនិច្ឆ័យលើរឿងក្តី រវាងរដ្ឋ និង ប្រជារាស្ត្រ នារយៈកាលកន្លងមក ដែលសុទ្ធសឹងតែជាយុត្តិសាស្ត្រល្អៗ សម្រាប់មន្ត្រីចៅក្រមជំនាន់ក្រោយ។

ទោះបីជា មានការត្រួតពិនិត្យជាច្រើនដងច្រើនសា ដោយអាត្មាភាពទាំងពីររូប និង សាស្ត្រាចារ្យ ណែនាំក្តី ក៏សារណានេះ នៅតែមិនបានល្អឥតខ្ចោះដែរ។ កំហុសទាំងផ្នែកអក្ខរាវិរុទ្ធ និង ទាំងផ្នែកការរៀបចំប្រយោគឃ្លាផ្សេងៗ ព្រមទាំងការស្វែងរកប្រភពឯកសារមិនគ្រប់គ្រាន់ តែងកើតមានឡើង ដោយពុំអាចចៀសបាន។ ដូច្នេះ អាត្មាភាពទាំងពីររូប សូមទទួលយកនូវមតិរិះគន់ ដើម្បី ស្ថាបនា ដោយក្តីសោមនស្សរីករាយ ពីសម្នាក់សាស្ត្រាចារ្យ និង និស្សិត អ្នកអាន។ ការរិះគន់ទាំងនេះ គឺជាថ្មសំលៀង ជួយឱ្យសារណានេះ កាន់តែមានភាពមុតស្រួច ក្នុងការប្រើប្រាស់បានយ៉ាងល្អប្រសើរជាងមុនថែមទៀត។

# មាតិកា

**ទំព័រ**

**អក្សរកាត់** ........................................ V
**សេចក្ដីផ្ដើម** ........................................ **០១**

## ជំពូកទី១
## សញ្ញាណទូទៅ និង ប្រភពនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ

**ផ្នែកទី១** : **សញ្ញាណទូទៅ នៃមន្ត្រីរាជការ** ........................................ **០៦**
**ផ្នែកទី២** : **ប្រភព នៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ** ........................................ **០៧**
**កថាភាគទី១** : **ប្រភពអន្តរជាតិ** ........................................ **០៨**
**ក.ប្រភពនៃអំពើអនីត្យានុកូល ប្រទេសបារាំង** ........................................ **០៨**
**ខ.ប្រភពផ្សេងៗ** ........................................ **១០**
ខ.១.សេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស ........................................ ១០
ខ.២.អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ........................................ ១១
ខ.៣.លក្ខន្តិកៈតុលាការអន្តរជាតិ (សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ៨២៧ (១៩៩៣) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣) ........................................ ១២
**កថាភាគទី២** : **ប្រភពជាតិ** ........................................ **១៣**
**ក.សម័យមុនអាណានិគមបារាំង និង សម័យអាណានិគមបារាំង** ........................................ **១៤**
ក.១. សម័យអង្គរ ........................................ ១៤
ក.២. សម័យក្រោយអង្គរ ........................................ ១៥
**ខ.សម័យក្រោយអាណានិគមបារាំង** ........................................ **២០**
ខ.១.សម័យសង្គមរាស្ត្រនិយម ........................................ ២១
ខ.២.សម័យសាធារណរដ្ឋខ្មែរ ........................................ ២១
ខ.៣.សម័យកម្ពុជាប្រជាធិបតេយ្យ ........................................ ២១
ខ.៤.សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា ........................................ ២១
ខ.៥.សម័យបច្ចុប្បន្ន ........................................ ២៣

# ជំពូកទី២
# ការទទួលខុសត្រូវ លើអំពើអនីត្យានុកូល របស់មន្ត្រីរាជការ


**ផ្នែកទី១ : លក្ខខណ្ឌនៃការទទួលខុសត្រូវ** ........ **២៧**

**កថាភាគទី១ : កំហុសរបស់មន្ត្រីរាជការ** ........ **២៧**

**ក.កំហុសក្រសួង** ........ **២៨**

**ខ.កំហុសផ្ទាល់ខ្លួន** ........ **២៩**

ខ.១.កំហុសប្រព្រឹត្តឡើងក្រៅឱកាសនៃការងារ ........ ៣០

ខ.២.កំហុសប្រព្រឹត្តឡើងនាឱកាសនៃការងារប៉ុន្តែមិនមែនបំពេញមុខងារ........ ៣០

ខ.៣.កំហុសដែលប្រព្រឹត្តឡើងនាពេលបំពេញសេវាប៉ុន្តែជាប់ពាក់ព័ន្ធខ្លាំងនឹងមូលហេតុជាបុគ្គលចំពោះមន្ត្រីរាជការ ........ ៣១

**គ.កំហុសត្រួតគ្នា** ........ **៣២**

គ.១.ករណីនៃការត្រួតគ្នា ........ ៣២

គ.២.ផលវិបាកនៃការត្រួតគ្នា ........ ៣៣

**កថាភាគទី២ : ព្យសនកម្ម** ........ **៣៤**

**ក.ព្យសនកម្ម លើបេតិកភណ្ឌ** ........ **៣៤**

**ខ.ព្យសនកម្ម ក្រៅបេតិកភណ្ឌ** ........ **៣៥**

ខ.១.ព្យសនកម្មផ្លូវចិត្ត ........ ៣៥

ខ.២.ព្យសនកម្មរូបរាងកាយ ........ ៣៥

**កថាភាគទី៣ : ទំនាក់ទំនង រវាងកំហុស និង ព្យសនកម្ម** ........ **៣៧**

**ក.ចំណងហេតុផលពិតប្រាកដ** ........ **៣៨**

**ខ.ចំណងហេតុផលត្រូវតែផ្ទាល់** ........ **៣៨**

**ផ្នែកទី២ : បណ្តឹងរបស់ជនរងគ្រោះ** ........ **៣៨**

**កថាភាគទី១ : ភាគីក្នុងរឿងបណ្តឹង** ........ **៣៨**

**ក.ភាគីជនរងគ្រោះ** ........ **៣៩**

ក.១.អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ ........ ៤០

ក.២.ជននៅក្រោមហិតូបត្ថម្ភកៈ ........ ៤០

ក.៣.ជនបរទេស ........ ៤០

ក.៤.អ្នកតំណាងដោយអាណត្តិ ........ ៤១

**ខ.ភាគី បង្កអំពើ** ........ **៤២**

ខ.១.បុគ្គលសាធារណៈដែលភ្ជាប់ទៅនឹងសមូហភាព ........ ៤៣

ខ.២.ភ្នាក់ងារសាធារណៈធ្វើសកម្មភាពជាប្រយោជន៍របស់រដ្ឋបាល .................. ៤៣
ខ.៣.បុគ្គលឯកជនដែលគ្រប់គ្រងសេវាសាធារណៈ ........................................ ៤៣
**កថាភាគទី២ : នីតិវិធីនៃបណ្ដឹងក្នុងការទទួលខុសត្រូវ ........................................ ៤៣**
**ក.ស្ថាប័នមានសមត្ថកិច្ច ដោះស្រាយលើពាក្យបណ្ដឹង ........................................ ៤៣**
ក.១.សមត្ថកិច្ចក្នុងអង្គការនីតិបញ្ញត្តិ ........................................ ៤៥
ក.២.សមត្ថកិច្ចក្នុងអង្គការនីតិប្រតិបត្តិ........................................ ៤៧
ក.៣.សមត្ថកិច្ចក្នុងអង្គការតុលាការ ........................................ ៤៩
**ខ.ការជួសជុលព្យសនកម្មដល់ជនរងគ្រោះ ........................................ ៥០**
ខ.១.រូបមន្ត និង វិធីគណនាសំណងការខូចខាត ........................................ ៥០
ខ.២.ការទាមទារសំណងរបស់បុគ្គល ក្រៅពីជនរងគ្រោះ ........................................ ៥៦
ខ.៣.កាលបរិច្ឆេទនៃការវាយតម្លៃសំណង និង អាជ្ញាយុកាល........................................ ៥៩
ខ.៤.ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ ........................................ ៦១
**គ.លក្ខខណ្ឌ នៃការបន្ថយការទទួលខុសត្រូវ ........................................ ៦១**
គ.១.ការធានារ៉ាប់រងសង្គម និង ប្រាក់ចំណេញ........................................ ៦២
គ.២.កំហុសរួមរបស់រដ្ឋ និង ជនរងគ្រោះ........................................ ៦២
គ.៣.កំហុសរួមរបស់រដ្ឋ និង តតិយជន ........................................ ៦២
**ឃ.លក្ខខណ្ឌ នៃការមិនសងការខូចខាត........................................ ៦៣**
ឃ.១.កំហុសទាំងស្រុងរបស់ជនរងគ្រោះ ........................................ ៦៣
ឃ.២.អំពើរបស់តតិយជន ........................................ ៦៤
ឃ.៣.កិច្ចការពារជាធម្មានុរូប........................................ ៦៤
ឃ.៤.ករណីប្រធានសក្ដិ ........................................ ៦៥
ឃ.៥.ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ........................................ ៦៥
ឃ.៦.ស្ថានភាពចាំបាច់........................................ ៦៦
ឃ.៧.ការយល់ព្រមពីជនរងគ្រោះ ........................................ ៦៧
ឃ.៨.ការយល់ព្រមពីភយន្តរាយ ........................................ ៦៨
ឃ.៩.ករណីពើបពះ ........................................ ៦៨
ឃ.១០.អំពើរបស់មន្ត្រីរាជការ ជាកំហុសបុគ្គល ........................................ ៦៨
ឃ.១១.ផុតអាជ្ញាយុកាល........................................ ៦៩
ឃ.១២.ការខូចខាតបណ្ដាលមកពីកងទ័ពបរទេសស្នាក់នៅក្នុងប្រទេស............ ៦៩

ឃ.១៣.ការខូចខាតដោយសារសង្គ្រាមបរទេស ........................................................ ៦៩
**ង.ទំនាក់ទំនងរវាងរដ្ឋ និង មន្ត្រីរាជការ ក្រោយសំណងការខូចខាត...........................៧២**
ង.១.កំហុសធ្ងន់ធ្ងរ ........................................................................................ ៧២
ង.២.កំហុសព្រហ្មទណ្ឌ ....................................................................................៧៣
**ផ្នែកទី៣ : សាលដីកា ទាក់ទងនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ.........................៧៤**
**កថាភាគទី១ : សាលដីកាតុលាការកំពូល ផ្នែករដ្ឋប្បវេណី ....................................................៧៥**
**ក.សាលដីកាតុលាការកំពូល សំណុំរឿងរដ្ឋប្បវេណី..........................................................៧៥**
ក.១.សាលដីការដ្ឋប្បវេណី លេខ២៧៥...........................................................៧៥
ក.២.សាលដីការដ្ឋប្បវេណី លេខ១០ ...............................................................៧៦
ក.៣.សាលដីការដ្ឋប្បវេណី លេខ៣០...............................................................៧៧
ក.៤.សាលដីការដ្ឋប្បវេណី លេខ៧៣ ...............................................................៧៨
**ខ.សាលដីកាតុលាការកំពូល ផ្នែករដ្ឋប្បវេណី ទាក់ទងនឹងរដ្ឋបាល ...............................៧៩**
ខ.១.សាលដីការដ្ឋប្បវេណី លេខ៧៣ ...............................................................៧៩
ខ.២.សាលដីការដ្ឋប្បវេណី លេខ១០ ............................................................... ៨០
**កថាភាគទី២ : សាលដីកាតុលាការកំពូល ផ្នែកព្រហ្មទណ្ឌ ..................................................... ៨០**
**ក.រឿងក្តីដែលនាំឱ្យរដ្ឋទទួលខុសត្រូវ ..................................................................................... ៨១**
**ខ.រឿងក្តីដែលនាំឱ្យរដ្ឋរួចផុតពីការទទួលខុសត្រូវ........................................................... ៨២**
ខ.១.សាលដីកាព្រហ្មទណ្ឌ លេខ០៨ ............................................................... ៨២
ខ.២.សាលដីកាព្រហ្មទណ្ឌ លេខ១៣............................................................... ៨៣
**សេចក្តីសន្និដ្ឋាន** ..........................................................................................................
**គន្ថនិទ្ទេស** ...................................................................................................................
**ឧបសម្ព័ន្ធ**.......................................................................................................................

# អក្សរកាត់

| | | |
|---|---|---|
| កុងសីដេតា | = | តុលាការកំពូលរដ្ឋបាលបារាំង ឬ ក្រុមប្រឹក្សារដ្ឋ |
| ក្រ.ច. | = | ក្រឹត្យ-ច្បាប់ |
| គ.រ. | = | ទីចាត់ការគយ និង រដ្ឋាករ |
| គ.ស. | = | គ្រិស្តសករាជ |
| ជ.ស. | = | ជា ស៊ីម |
| ន.ស. | = | នរោត្តមសីហនុ |
| ប.ស.ខ. | = | ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ |
| ប្រ.ក | = | ប្រកាស |
| ព.ស. | = | ពុទ្ធសករាជ |
| រ.ក.ម | = | រាជក្រម |
| រ.ក.ត | = | រាជក្រឹត្យ |
| C.E. | = | មកពីពាក្យ Conseil d'État |
| Conseil d'État | = | តុលាការកំពូលរដ្ឋបាលបារាំង |
| T.C. | = | មកពីពាក្យ Tribunal des Conflits ប្រែថា សាលាជម្រះសមត្ថកិច្ច |
| UNTAC | = | United Nation Transitional Authority in Cambodia (អាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា) |

# សេចក្តីផ្តើម

ចាប់តាំងពីសតវត្សរ៍ទីមួយ រហូតដល់សតវត្សរ៍ទីម្ភៃ ប្រទេសកម្ពុជា ជាប្រទេសប្រកាន់យករបបរាជានិយមផ្តាច់ការ អំណាចទាំងឡាយជារបស់ព្រះមហាក្សត្រ ស្ថាប័នកំពូលៗ ស្ថិតក្រោមកណ្តាប់ព្រះហស្តរបស់ព្រះមហាក្សត្រ។ ក្នុងចំណោមស្ថាប័នកំពូលៗ ក្នុងនោះស្ថាប័នតុលាការ ក៏ស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះមហាក្សត្រផងដែរ ហើយព្រះមហាក្សត្រ មាន តួនាទីជាចៅក្រម ក្នុងការកាត់សេចក្តីលើរឿងគ្រប់យ៉ាង រួមទាំងរឿងក្តីពាក់ព័ន្ធទៅនឹងមន្ត្រីរាជការផងដែរ។ មន្ត្រីរាជការដែលប្រព្រឹត្តខុស ក៏មិនអាចរួចទោសដែរ ដូចក្នុងរឿងទុំទាវ ជាទឡ្ហីករណ៍ស្រាប់។ ព្រះមហាក្សត្របានធ្វើការកាត់ទោសលើមន្ត្រីរាជការ ដែលបានប្រើអំណាចរបស់ខ្លួន បំបែកបំបាក់ ម៉ឺនងឯក (ទុំ) និងនាងទាវ ឱ្យព្រាត់ប្រាស ស្លាប់ វិនាសអន្តរាយ។ ក្នុងសម័យរាជានិយមផ្តាច់ការ ទោសក៏មានលក្ខណៈឃោរឃៅដែរ ដូចជាកាត់ដៃ កាត់ជើង ប្រហារជីវិតជាដើម ក្រៅពីទោសទាំងនេះ គេកម្រឃើញការដាក់ទោសដល់មន្ត្រីរាជការណា ដែលបង្គាប់ឱ្យ សងជាប្រាក់ណាស់ ហើយម៉្យាងវិញទៀត ទោសដែលបង្កឡើងដោយមន្ត្រីរាជការនាសម័យនោះគឺ សុទ្ធតែជាកំហុសផ្ទាល់របស់មន្ត្រីរាជការ ពោលគឺ គ្មានការចូលរួម ឬ ពាក់ព័ន្ធនឹងរាជការឡើយ។ នៅសម័យរាជានិយមផ្តាច់ការ រាល់ការសម្រេចអ្វីៗ របស់ព្រះមហាក្សត្រគឺ សុទ្ធតែជាការត្រឹមត្រូវទាំងអស់ ពោលគឺ គ្មានកំហុសឡើយ ដូច្នេះ ប្រជារាស្ត្រខ្មែរ ពុំទទួលបានយុត្តិធម៌ នៅពេលដែលការខូចខាតកើតចេញ ពីកំហុសរបស់រាជការឡើយ។ រហូតដល់ឆ្នាំ១៩៤៧ ប្រទេសកម្ពុជា បានអនុម័តរដ្ឋធម្មនុញ្ញមួយ បានកែប្រែពីរបបរាជានិយមផ្តាច់ការ ទៅជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញវិញ ហើយសម័យកាលនោះ មិនបានប៉ុន្មានឆ្នាំផង ក៏ចូលដល់សម័យមួយទៀតគឺ សម័យសាធារណរដ្ឋខ្មែរ ពេលនោះ ប្រជារាស្ត្រខ្មែរបានទទួលការ វិនិច្ឆ័យដ៏យុត្តិធម៌មួយ តាមរយៈការបង្កើតឱ្យមាននូវ**"ក្រុមប្រឹក្សារដ្ឋ"** ជាស្ថាប័នធ្វើការវិនិច្ឆ័យលើរឿងក្តី រដ្ឋបាល។ **"ក្រុមប្រឹក្សារដ្ឋ"** ពុំបានដំណើរការល្អឡើយ ព្រោះមានសង្គ្រាមច្រើន ហើយមិនយូរប៉ុន្មានកម្ពុជាបានឈានជើងចូល ដល់សម័យដ៏ខ្មៅងងឹតមួយ គឺសម័យកម្ពុជាប្រជាធិបតេយ្យ ពេលនោះសិទ្ធិប្តឹងរដ្ឋគឺ លែងមានសោះតែម្តង។ ក្រោយសម័យនេះ កម្ពុជា បានឆ្លងកាត់សម័យកាលពីរទៀត (សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា) ទើបកម្ពុជា ចូលដល់សម័យកាលមួយ ដែលមានការរួបរួមគ្នារវាងអ្នកនយោបាយ ទាំងឡាយ។

## ១.លំនាំបញ្ហា

ក្រោយការរួបរួមគ្នារវាងអ្នកនយោបាយទាំងឡាយ កម្ពុជាបានបង្កើតឱ្យមាននូវវិធានគតិយុត្តពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ របស់មន្ត្រីរាជការជាបន្តបន្ទាប់ ដូចជា ក្រឹត្យ-ច្បាប់លេខ៣៨ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ជាដើម។ ក៏ប៉ុន្តែ ការកើតឡើងនូវវិធានគតិយុត្តទាំងនេះ ពុំទាន់គ្រប់គ្រាន់ និង ពុំទាន់ឆ្លើយតបទៅនឹងបញ្ហា ដែលបានកើតឡើងជាក់ ស្តែងឡើយ។

ម៉្យាងវិញទៀត ប្រទេសកម្ពុជា នៅពុំទាន់មានតុលាការរដ្ឋបាលមួយដាច់ដោយឡែក ពីតុលាការស៊ីវិលឡើយ នេះ គឺជាបញ្ហាដ៏សំខាន់មួយ ដែលជាហេតុធ្វើឱ្យដំណើរការ នៃការអនុវត្តមានលក្ខណស្មុគស្មាញ។

**២.ចំណោទបញ្ហា**

ការសិក្សាស្រាវជ្រាវនេះ បានផ្តោតសំខាន់ទៅលើ**អំពើអនីត្យានុកូល របស់មន្ត្រីរាជការ**ពោលគឺការទទួលខុសត្រូវលើអំពើរបស់មន្ត្រីរាជការ ពីសម្នាក់រដ្ឋ ឬ ស្ថាប័នសាមី។ ប្រធានបទខាងលើនេះ បានចោទជាបញ្ហាចំនួនពីរធំៗ គឺ៖

១.តើមាននីតិវិធីអ្វីខ្លះ បន្ទាប់ពីមានការខូចខាតកើតចេញពីអំពើរបស់មន្ត្រីរាជការ?

២.តើការអនុវត្តជាក់ស្តែងកន្លងមក បានឆ្លុះបញ្ចាំងទៅនឹងវិធានច្បាប់ដែរ ឬ ទេ?

**៣.គោលបំណង**

ការទទួលខុសត្រូវលើអំពើរបស់មន្ត្រីរាជការ គឺជាបញ្ហាដ៏ចម្រូងចម្រាសមួយ ដែលបានកើតឡើងជាយូរមកហើយ ហើយក៏ជាប្រធានបទដ៏ក្តៅគគុក នាពេលបច្ចុប្បន្នផងដែរ។ ក្នុងពេលរដ្ឋមួយហ៊ានប្រឈមមុខចំពោះកំហុសរបស់ខ្លួនជាសាធារណៈ នាំឱ្យរដ្ឋនោះ ត្រូវមហាជនវាយតម្លៃថា ជារដ្ឋគំរូ ឬ ជារដ្ឋមានទំនួលខុសត្រូវខ្ពស់ ហើយម៉្យាងវិញទៀត នាំឱ្យប្រមុខដឹកនាំនៃរដ្ឋដទៃទៀត ព្រមទាំងអ្នកវិនិយោគទុនធំៗ របស់បរទេសចាប់ផ្តើមមានការទុកចិត្ត លើរដ្ឋនោះ ហ៊ានចុះកិច្ចព្រមព្រៀងផ្សេងៗ និង បោះវិនិយោគទុនជាច្រើន ក្នុងរដ្ឋនោះជាក់ជាមិនខាន។ អ្វីដែលជាប្រយោជន៍ក្រោយពីនេះ គឺនាំឱ្យរដ្ឋនោះ ទទួលបានការអភិវឌ្ឍមួយ ដែលនឹកស្មានមិនដល់ ហើយជាងនេះទៅទៀតប្រជាពលរដ្ឋក្នុងស្រុក ក៏ចាប់ផ្តើមមានទំនុកចិត្តខ្ពស់លើរដ្ឋ មានកម្លាំងចិត្ត យកគំរូតាមរដ្ឋ ហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួនដូចរដ្ឋដែរ។ ដូច្នេះ ការលើកយកប្រធានបទស្តីពី ៖ **អំពើអនីត្យានុ-កូល របស់មន្ត្រីរាជការ** មានគោលបំណងចំនួនពីរសំខាន់ៗគឺ៖

ទី១-រំលេចឱ្យឃើញអំពីប្រភព និង សញ្ញាណនៃកំហុសរបស់មន្ត្រីរាជការ លក្ខខណ្ឌនៃការទទួលខុសត្រូវ ព្រមទាំងដំណើរការនីតិវិធីនៃបណ្តឹង។

ទី២-ប្រៀបធៀបរវាងធាតុនីត្យានុកូល និង ការអនុវត្តជាក់ស្តែង ដែលបានកើតឡើង នាពេលកន្លងមក ពាក់ព័ន្ធនឹងមន្ត្រីរាជការ ដោយភ្ជាប់មកជាមួយនឹងសាលដីការបស់តុលាការកំពូលមកធ្វើជាអំណះអំណាង។

**៤.វិសាលភាពនៃការស្រាវជ្រាវ**

ទោះបីជានៅក្នុងខ្លឹមសារនៃសារណា បានលើកយករឿងរ៉ាវ តាំងពីសម័យមហានគរយ៉ាងណាក្តី បានលើកយកវិធានរបស់បរទេសក្តី វាគ្រាន់តែជាការលើកយកមក ដើម្បីធ្វើការប្រៀបធៀប

និង បង្ហាញពីប្រភពប៉ុណ្ណោះ តែផាតុពិតដែនវិសាលភាពនៃសារណា គឺកំណត់យកឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន។

ប្រធានបទស្តីពី : "**អំពើអនីត្យានុកូល របស់មន្ត្រីរាជការ**" បើរៀបរាប់ដោយពិស្តារ គឺ មានទំហំធំធេងណាស់ ដូច្នេះ គ្រាន់តែបង្ហាញ ពីការទទួលខុសត្រូវរបស់មន្ត្រីរាជការទូទៅប៉ុណ្ណោះ ដោយមិនលម្អិតទៅលើមន្ត្រីរាជតាមផ្នែកនីមួយៗ ដូចជា ផ្នែកនីតិបញ្ញត្តិ ប្រតិបត្តិ និង តុលាការឡើយ។ នេះជាចន្លោះប្រហោងមួយ ដែលអាចឱ្យនិស្សិតជំនាន់ក្រោយ ធ្វើការពុះច្រៀកសារណានេះ ជាចម្រៀកៗ ក្នុងការបន្តការស្រាវជ្រាវឱ្យបានកាន់តែលម្អិតថែមទៀត។

ដោយសារតែសារណានេះ បានយកមាត្រា៧៤៩ នៃក្រមរដ្ឋប្បវេណីជាចម្បង ដូចនេះកំហុសរបស់មន្ត្រីរាជការគឺ គ្រាន់តែជាកំហុសដែលកើតចេញ ពីអំពើអនីត្យានុកូលប៉ុណ្ណោះ ពោលគឺកំហុសផ្នែករដ្ឋប្បវេណី មានការសងការខូចខាតជាប្រាក់ មិនបានផ្តោតឱ្យស៊ីជម្រៅទៅ លើកំហុសផ្នែកព្រហ្មទណ្ឌ និង ផ្នែករដ្ឋបាលឡើយ គ្រាន់តែលើកជាសញ្ញាណបន្តិចបន្តួចប៉ុណ្ណោះ ដូចជា កំហុសបុគ្គល និង កំហុសព្រហ្មទណ្ឌជាដើម។

សារណានេះមានទំហំ៨៨ ទំព័រ ដែលបានលើកបង្ហាញផងដែរ អំពីសាលដីការបស់តុលាការកំពូលចាប់ពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០០៦ ដែលបានធ្វើការសិក្សាស្រាវជ្រាវ នូវសាលដីការបស់តុលាការកំពូល សំណុំរឿងព្រហ្មទណ្ឌចំនួន២៥៥ សំណុំរឿងរដ្ឋប្បវេណីចំនួន៧៦៥ សរុបទាំងអស់ចំនួន១.០២០ សាលដីកា។ សាលដីកា ដែលត្រូវយកមកធ្វើការស្រាវជ្រាវមានចំនួន០៧ សាលដីកា។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

### ក.ការប្រមូលទិន្នន័យ

ទិន្នន័យផ្ទាល់ : បានលើកយកបណ្តាវិធានគតិយុត្តនានាដែលពាក់ព័ន្ធ ក្នុងនោះរួមមានដូចជា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ ច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីអស្សាមិករណ៍ និង សាលដីកាតុលាការកំពូល ពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០០៦ ព្រមទាំងវិធានច្បាប់ដទៃផ្សេងៗ។

ទិន្នន័យប្រយោល : សារណានេះ ក៏បានធ្វើការប្រមូលទិន្នន័យ ពីបណ្តាឯកសារដែលសរសេរឡើង ដោយសាស្ត្រាចារ្យនានាផងដែរ មានជាអាទិ៍ សាស្ត្រាចារ្យ សាយ បូរី នីតិរដ្ឋបាលទូទៅ, វិទ្យាសាស្ត្ររដ្ឋបាល សាស្ត្រាចារ្យ ឌៀក ពិដោរ នីតិរដ្ឋបាលទូទៅ ទ្រឹស្តីរដ្ឋបាលសាធារណៈ, សាស្ត្រាចារ្យ ហៃល ចំរើន មរតកយុត្តិធម៌ខ្មែរ, សាស្ត្រាចារ្យ ញឹក វុធ្ធី នីតិកាតព្វកិច្ចភាគ២ (អំពើអនីត្យានុកូល) ជាដើម ព្រមទាំងឯកសារ របស់សាស្ត្រាចារ្យបន្ទាប់បន្សំដទៃទៀត ដែលត្រូវបានប្រមូលដើម្បីជាដើមទុនក្នុងការរៀបចំនូវសារណានេះ។

**ខ.ការវាយតម្លៃទិន្នន័យ៖** ខ្លឹមសារនៃសារណា អាចមានលក្ខណៈបែបវិទ្យាសាស្ត្រទៅបានលុះត្រាតែ ការសិក្សាស្រាវជ្រាវនោះ ទទួលបានការណែនាំពីសាស្ត្រាចារ្យនានា ជាពិសេសគឺសាស្ត្រាចារ្យដឹកនាំ និង ចេះតម្រង់ទិសឯកសារពិគ្រោះ ដែលប្រមូលបានពីការស្រាវជ្រាវ ព្រមទាំងឯកសារដែលប្រមូលបានទាំងនោះ គឺជាឯកសារពិតប្រាកដ និង ផ្លូវការ ពោលគឺ មានការទទួលស្គាល់ពីសាធារណជនច្រើន ទើបធ្វើឱ្យសារណានេះ មានទម្ងន់ ឬ មានលក្ខណៈបែបវិទ្យាសាស្ត្រ។ ឆ្លងតាមការស្រាវជ្រាវកន្លងមកនេះ អាចឱ្យយើងឃើញថា សារណានេះ ពិតជាមានលក្ខណៈបែបវិទ្យាសាស្ត្រមួយ ដែលជាការសិក្សាស្រាវជ្រាវទៅតាមការណែនាំរបស់សាស្ត្រាចារ្យ ទៅតាមប្រភពជាមូលដ្ឋាននានា ដូចជា៖ ស្រាវជ្រាវតាមប្រព័ន្ធព័ត៌មានវិទ្យា (Google) គេហៈទំព័រផ្លូវការរបស់រដ្ឋសភា ក្រសួងមហាផ្ទៃ តុលាការកំពូលជាដើម។ តាមរយៈសេចក្តីពន្យល់របស់សាស្ត្រាចារ្យ នៅសាកលវិទ្យាល័យ ស្រាវជ្រាវតាមបណ្ណាល័យ និង តាមប្រភពជា របាយការណ៍ កាសែត ទស្សនាវដ្តី។ល។

**គ.ការវិភាគទិន្នន័យ៖** ឯកសារដែលប្រមូលបានពីការសិក្សាស្រាវជ្រាវរួមមានដូចជា ៖ ប្រភពច្បាប់ចម្បងៗ ដែលបានអនុម័តទទួលស្គាល់ជាផ្លូវការដោយរដ្ឋសភា។ ស្នាដៃនិពន្ធរបស់សាស្ត្រាចារ្យផ្នែកច្បាប់ ទាំងជាតិ និង ទាំងបរទេស។ ស្នាដៃទាំងអស់នេះសុទ្ធសឹងតែមានការទទួលស្គាល់ជាផ្លូវការ ប៉ុន្តែ ស្នាដៃដូចជាតាមរយៈគេហៈទំព័រខ្លះ អាចនឹងមានការប្រែប្រួល។

### ៦.សារៈប្រយោជន៍នៃការស្រាវជ្រាវ

យើងមានចក្ខុវិស័យថា ផលប្រយោជន៍ដែលបានមកពីការស្រាវជ្រាវនេះ នឹងនាំឱ្យមានការផ្លាស់ប្តូរដ៏ធំមួយទៅលើផ្នត់គំនិតរបស់និស្សិត និង អ្នកអានទាំងឡាយ ឱ្យបានដឹងកាន់តែច្បាស់ពីសញ្ញាណនៃការទទួលខុសត្រូវលើកំហុសរបស់មន្ត្រីរាជការ ញែកឱ្យបានកាន់តែច្បាស់ រវាងកំហុសបុគ្គល និង កំហុសរបស់រដ្ឋ។ ជួយឱ្យប្រជាពលរដ្ឋ ស្គាល់អំពីសិទ្ធិរបស់ខ្លួនក្នុងការទាមទារ ហ៊ានតវ៉ាក្នុងការបំពានសិទ្ធិ ដែលបង្កដោយមន្ត្រីរាជការ ដោយឈរលើគោលការណ៍សមភាព។ ម៉្យាងវិញទៀត សារណានេះ អាចជាឯកសារសំខាន់មួយ ជួយសម្រួលដល់ភាពខ្វះខាតនានា ដល់និស្សិត មន្ត្រីរាជការ និង អ្នកស្រាវជ្រាវដទៃផ្សេងទៀត ដែលមានបំណងចង់ពង្រីកខ្លឹមសារនៃសារណានេះ ឬ ចង់ស្រាវជ្រាវអំពីរឿងរ៉ាវណាមួយ ដែលមានការពាក់ព័ន្ធទៅនឹងបញ្ហាទាំងនេះ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងខាងលើនេះ យើងពិតជាសង្ឃឹមទុកថា នឹងបានចូលរួមចំណែក ក្នុងការធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាល និង ជាត្រីវិស័យសម្រាប់និស្សិត និង អ្នកស្រាវជ្រាវទាំងឡាយដើម្បីទុកជាដើមទុនដ៏ស្តួចស្តើង ក្នុងការស្រាវជ្រាវបន្តទៀត។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ពន្ធក្នុងការស្រាវជ្រាវសារណានេះ គឺមានលក្ខណៈជាទម្រង់បែបអាស៊ី ដោយមានការបែងចែកជា ជំពូក ផ្នែក កថាភាគ អនុលោមទៅតាមទម្រង់ច្បាប់របស់ប្រទេសកម្ពុជា ដូចជាទៅតាមទម្រង់នៃក្រមព្រហ្មទណ្ឌ និង ក្រមរដ្ឋប្បវេណីជាដើម។ សារណានេះ បានធ្វើការបែងចែកចេញជាពីរជំពូក ដែលមានកម្រាស់ដល់ទៅ៨៨ ទំព័រ។ ជំពូកទាំងនោះមានដូចជា៖

ជំពូកទី១ ៖ សញ្ញាណទូទៅ និង ប្រភពនៃអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ : យើងធ្វើការបែងចែកចេញជាពីរផ្នែកថែមទៀត គឺផ្នែកទី១ រៀបរាប់អំពីសញ្ញាណទូទៅ នៃមន្ត្រីរាជការ ដែលក្នុងនោះនិយាយអំពីនិយមន័យ របស់មន្ត្រីរាជការ។ ចំណែកផ្នែកទី២ រៀបរាប់អំពីប្រភព នៃអំពើអនីត្យា-នុកូល របស់មន្ត្រីរាជការ ដែលមានទាំងប្រភពជាតិ និង ប្រភពបរទេស។

ជំពូកទី២ ៖ ការទទួលខុសត្រូវ លើអំពើអនីត្យានុកូល របស់មន្ត្រីរាជការ : ជំពូកនេះមានបីផ្នែកធំៗ គឺផ្នែកទី១ បរិយាយអំពីលក្ខខណ្ឌនៃការទទួលខុសត្រូវ។ ផ្នែកទី២ រៀបរាប់អំពីបណ្ដឹងរបស់ជនរងគ្រោះ អំពីការទទួលខុសត្រូវ ក្នុងនោះមានដូចជា ភាគីក្នុងរឿងបណ្ដឹង និង នីតិវិធីនៃបណ្ដឹងក្នុងការទទួលខុសត្រូវ។ ចំណែកផ្នែកទី៣ វិញ បានអត្ថាធិប្បាយអំពីសាលដីកា ទាក់ទងនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការកន្លងមក ដែលរួមមានទាំងសំណុំរឿង រដ្ឋប្បវេណី និង សំណុំរឿងផ្នែកព្រហ្មទណ្ឌ។

# ជំពូកទី១
# សញ្ញាណទូទៅ និង ប្រភពនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ

មុនឈានចូល ដល់ការបកស្រាយពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការ គប្បីយល់ពីសញ្ញាណទូទៅ នៃអំពើអនីត្យានុកូលជាមុនសិន។ យើងសូមធ្វើការបែងចែកកន្សោមពាក្យ "សញ្ញាណទូទៅ និង ប្រភពនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ" ជាពីរ គឺសញ្ញាណទូទៅ នៃមន្ត្រីរាជការ (ផ្នែកទី១) និង ប្រភពនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ (ផ្នែកទី២) ដើម្បីយកមកបកស្រាយ ដូចតទៅនេះ។

## ផ្នែកទី១
## សញ្ញាណទូទៅ នៃមន្ត្រីរាជការ

ក្នុងវចនានុក្រមខ្មែរ ពុំមានការឱ្យនិយមន័យ ទៅលើពាក្យ**មន្ត្រីរាជការ**ឡើយ ប៉ុន្តែ មានការឱ្យនិយមន័យដាច់ដោយឡែក រវាងពាក្យ**មន្ត្រី** និង ពាក្យ**រាជការ**។

**មន្ត្រី ៖** "អ្នកមានគំនិត, ពួកអ្នកមានសេចក្តីដឹងរាក់ជ្រៅ, អ្នកប្រឹក្សាការផែនដី, សេវកាមាត្យ" អ្នករាជការដែលមានសក្តិយស, នាម៉ឺន[១]។

**រាជការ ៖** រាជការ ឬ-ការ្យ ការរបស់ព្រះរាជា; ការផែនដី, ការរក្សាប្រទេស ធ្វើរាជការ; អ្នករាជ-ការ, ខ្ញុំរាជការ, គំនិតរាជការ[២] ។

**អ្នករាជការសាធារណៈ:** " អ្នកធ្វើការ ក្នុងស្ថាប័នរដ្ឋ រួមមានស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និង ស្ថាប័នតុលាការ[៣]។ តាមន័យក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា៣០ **អ្នករាជការសាធារណៈ:** គឺ[៤]

ក-បុគ្គលដែលបម្រើការងារនៅ ក្នុងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ ទោះជាបណ្តោះអាសន្នក្តី ទោះជាបានទទួលប្រាក់ឈ្នួលក្តី ឬ ទោះជាមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុវ័យរបស់បុគ្គលនោះឡើយ។

---

[១] សម្តេចសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ, (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ភាគ១, ទំព័រ៨៥៣

[២] សម្តេចសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ, (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ភាគ២, ទំព័រ១០៣៤

[៣] ហ៊ីង ធីឫទ្ធិ, វចនានុក្រមច្បាប់, បោះពុម្ពលើកទី៣, (ភ្នំពេញ៖ ២០១០), ទំព័រ៤៧៦

[៤] វចនានុក្រមច្បាប់របស់លោក ហ៊ីង ធីឫទ្ធិ ទំព័រ៤៧៦ និង សទ្ទានុក្រមច្បាប់ រៀបរៀងដោយ បណ្ឌិតឆយ អួន, ឥន យឿន, ងួន យ៉ាណា , អ៊ិត មល្លិកា, សៀន វិសាល បោះពុម្ពឆ្នាំ២០១២ ទំព័រ៣០៨ ព្រមទាំង សទ្ទានុក្រមបច្ចេកសព្ទ រៀបរៀងដោយ បណ្ឌិត ឆយ អួន, ជា ចន្ថា , អ៊ិត មល្លិកា, នួន ធីរិទ្ធ បោះពុម្ពឆ្នាំ២០១៨ ទំព័រ៥៣២ បានឱ្យនិយមន័យនៃពាក្យនេះ ស្របនឹងមាត្រា៣០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ដែរ

ខ-បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

គ-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។

ចំពោះសទ្ទានុក្រមបច្ចេកសព្ទ បានឱ្យនិយមន័យទៅលើពាក្យ **មន្ត្រីរាជការ**[៥]ថា៖ " ភ្នាក់ងារ-សាធារណៈដែលបម្រើការងារអចិន្ត្រៃយ៍ នៅតាមក្រសួងស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា និង មានលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌរបស់ខ្លួន ដូចជា មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ (ស្ថិតក្រោមយុត្តាធិការតុលាការ) មន្ត្រីរាជការស្ថិតក្រោមស្ថាប័ននីតិបញ្ញត្តិ និង មន្ត្រីស្ថិតក្រោមលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌផ្សេងៗ (Eng. State employees) ។

យោងតាមព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ បានចែងថា : ក្របខណ្ឌមន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា៤ ប្រភេទ **ក ខ** និង ដែលកំណត់ឡើង ដោយយោងទៅតាមលក្ខខណ្ឌអប្បបរមា នៃការបណ្តុះបណ្តាល សម្រាប់បញ្ចូលក្នុងក្របខណ្ឌ និង កម្រិតឋានានុក្រម នៃតំណែងរបស់ក្របខណ្ឌ (មាត្រា២)[៦]។

ការស្គាល់ពីសញ្ញាណនៃមន្ត្រីរាជការ អាចធ្វើឱ្យយើងស្គាល់ពីប្រភពរបស់មន្ត្រីរាជការថែម-ទៀត។ ប្រភពនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការក៏អាចស្តែងចេញពីបរទេសផងដែរ ព្រោះវាជាប្រភពចម្បង និង មានលក្ខណៈច្បាស់លាស់។

## ផ្នែកទី២

## ប្រភព នៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ

អំពើអនីត្យានុកូល របស់មន្ត្រីរាជការ ជាសញ្ញាណមួយ ដែលបានចាប់កំណើតឡើង តាំងពីរាប់រយឆ្នាំមុនមកម្ល៉េះ។ អំពើអនីត្យានុកូល របស់មន្ត្រីរាជការ ដែលមានវ័យចំណាស់ជាងគេ ភាគច្រើន គឺជាប្រភពមកពីអន្តរជាតិ (កថាភាគទី១) ព្រោះវាមានសញ្ញាណ និង គោលការណ៍ច្បាស់លាស់ ចំណែកឯប្រភពជាតិ (កថាភាគទី២) ក៏មានតាំងពីយូរមកហើយដែរ ពោលគឺសម័យមហានគរ ប៉ុន្តែ សញ្ញាណនេះ ហាក់បីដូចជា ពុំសូវច្បាស់លាស់សោះ។

---

[៥] ឆយអូន និង ផ្សេងទៀត, សទ្ទានុក្រមបច្ចេកសព្ទ, (ភ្នំពេញ, ២០១៨), ទំព័រ៥៣៥

[៦] សាយ បូរី, វិទ្យាសាស្ត្ររដ្ឋបាល, (ភ្នំពេញ៖ បណ្ណាគារអង្គរ,២០០៧), ទំព័រ១៣៥

## កថាភាគទី១
## ប្រភពអន្តរជាតិ

នៅប្រទេសលោកខាងលិច ក៏ដូចជាប្រទេសជឿនលឿនមួយចំនួន ប្រជាពលរដ្ឋចាប់ផ្តើមទាមទារនូវសិទ្ធិរបស់ខ្លួនច្រើនឡើងៗ ជាពិសេសសិទ្ធិទទួលបានសំណង ពីការខូចខាត ដែលកើតចេញពីអំពើរបស់មន្ត្រីរាជការ ឬ មន្ត្រីរដ្ឋការ។ ស្ថិតក្នុងបរិបទបែបនេះ ថ្នាក់ដឹកនាំនៃប្រទេសទាំងនោះ ដែលមានដូចជា ប្រទេសបារាំង (ក) និង ប្រទេសមួយចំនួនទៀត បាននឹងកំពុងរៀបចំតាក់តែងច្បាប់ និង ស្ថាប័ន ដើម្បីធ្វើការវិនិច្ឆ័យលើព្យសនកម្មនៃជនរងគ្រោះ ដែលកើតចេញពីកំហុសរបស់មន្ត្រីរាជការ ឬ មន្ត្រីរដ្ឋការ។ ប្រភពនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ មិនមែនមានតែក្នុងប្រទេសមួយចំនួនប៉ុណ្ណោះទេ តែវាមានប្រភពផ្សេងៗទៀត (ខ) ដែលបានកើតចេញ ពីស្ថាប័នអន្តរជាតិធំៗ។

### ក.ប្រភពនៃអំពើអនីត្យានុកូលប្រទេសបារាំង

ប្រទេសបារាំង រហូតដល់ពាក់កណ្តាលសតវត្សទី១៩ គេមានគោលការណ៍ធំមួយ ដែលបញ្ញត្តថា *រដ្ឋមិនត្រូវមានការទទួលខុសត្រូវអ្វីទាំងអស់ ដែលជាអំពើរបស់ខ្លួន ជាមួយរាស្ត្រប្រជា*។ ពីព្រោះអ្វី? ពីព្រោះថា រដ្ឋជាតំណាងអធិបតេយ្យជាតិ ពុំអាចស្ថិតនៅក្រោមអំណាចណាមួយឡើយ។ រដ្ឋមិនអាចបន្ទាបខ្លួនឱ្យមកស្មើនឹងរាស្ត្រប្រជា ដើម្បីសងការខូចខាត ដែលរដ្ឋបានបង្កឡើងនោះទេ។ រដ្ឋជា "ស្តេច" ស្តេចជា "រដ្ឋ" គ្មានអ្នកណាធំជាងឡើយ។ រដ្ឋការ ធ្វើការសម្រាប់រដ្ឋ និង ក្នុងនាមរដ្ឋ គឺថា ក្នុងនាមអធិបតេយ្យជាតិ។ ឧទាហរណ៍ រដ្ឋមិនអាចធ្វើអាក្រក់ (ធ្វើខុស)។

ប៉ុន្តែ ចាប់ពីឆ្នាំ១៨៧៣ មកមានការវិវត្តខាងផ្លូវគំនិត ដោយគេយល់ថា ក្នុងវិស័យគ្រប់គ្រងរដ្ឋបាល រដ្ឋត្រូវមានការទទួលខុសត្រូវ ចំពោះកំហុសរបស់ខ្លួន។ គំនិតថ្មីនេះ មិនបានចេញមកតាមរយៈច្បាប់ (សភា) គឺចេញដោយយុត្តិសាស្ត្រក្នុងរឿងក្តី "ប្លង់កូ" (Blanco)[៧] ដែលយើងសូមលើកយកមកសិក្សា ដោយសង្ខេបក្នុងទីនេះ។

កូនស្រីតូចរបស់ "ប្លង់កូ" មានឈ្មោះថា "អាញែស ប្លង់កូ" (Angnes Blanco) បានត្រូវកូនទូអយស្ម័យយាន របស់កម្មន្តសាលធ្វើថ្នាំជក់ បុកដួល ហើយមានរបួស។ កម្មន្តសាលនោះ ជារបស់រដ្ឋ។ ប្លង់កូ ដែលជាឪពុកកុមារនោះ ក៏ប្តឹងទៅតុលាការស៊ីវិល សុំឱ្យរដ្ឋទទួលខុសត្រូវនូវផ្នែករដ្ឋប្បវេណី តាមមាត្រានៃក្រមរដ្ឋប្បវេណី ដោយហេតុថា កម្មកររបស់កម្មន្តសាល ជាអ្នកធ្វើឱ្យមានគ្រោះថ្នាក់នេះ។ ប៉ុន្តែ (អភិបាលខេត្ត) "ប្រេហ្វេ" (ខេត្ត) បានជំទាស់អំពីសមត្ថកិច្ច របស់តុលាការស៊ីវិល ហើយរឿងក្តីនេះ ក៏ឡើងទៅដល់សាលាជម្រះសមត្ថកិច្ច (Tribunal des Conflits) ។ ស្នងការរដ្ឋាភិបាលមួយឈ្មោះ "ដាវិត" (David) នៃសាលាជម្រះសមត្ថកិច្ច បានធ្វើការសន្និដ្ឋានក្នុងមូលបទថា:

---

[៧] សូមមើលក្នុងឧបសម្ពន្ធទី៣ ចំណុច ៣.២.

*"យល់ឃើញថា ការទទួលខុសត្រូវដែលអាចទម្លាក់មកលើរដ្ឋ ចំពោះការខូចខាតដល់អ្នកដទៃ ដែលបណ្ដាលមកពីទង្វើរបស់មនុស្សដែលរដ្ឋប្រើ ក្នុងសេវាកម្មសាធារណៈ មិនអាចស្ថិតនៅក្រោមគោលការណ៍ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ដែលសម្រាប់តែរឿងក្ដីបុគ្គលឯកជន និងបុគ្គលឯកជនបានឡើយ។"*

*"យល់ឃើញថា ការទទួលខុសត្រូវនេះទៀតសោត ក៏មិនមែនជាទូទៅនឹងត្រូវតែជាដាច់ខាតនោះដែរ"។*

*"យល់ឃើញថា ការទទួលខុសត្រូវនេះ មានវិធានពិសេសរបស់វា ដែលប្រែប្រួលទៅតាមតម្រូវការរបស់សេវាកម្មសាធារណៈ និង ទៅតាមការចាំបាច់ដែលត្រូវសម្រុះសម្រួល រវាងសិទ្ធិរបស់រដ្ឋ និង សិទ្ធិរបស់ឯកជន។"*

*"យល់ឃើញថា បើយ៉ាងដូច្នេះ ហើយនឹងយោងទៅតាមច្បាប់ខាងលើ មានតែតុលាការ រដ្ឋបាលមួយគត់ ដែលមានសមត្ថកិច្ច ក្នុងការជំនុំជម្រះរឿងនេះ។"*

សាលាជម្រះសមត្ថកិច្ច បានចេញសាលដីកាមួយ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៨៧៣ ស្របតាមសេចក្ដីសន្និដ្ឋាន របស់ស្នងការរដ្ឋាភិបាលឈ្មោះ "ដាវិដ" នេះ[៧]។

សាលដីកានេះ ជាជំហានដំបូង ក្នុងនីតិរដ្ឋបាលបារាំង ដែលបញ្ចេញនូវគោលការណ៍ថ្មី គឺរដ្ឋអាចទទួលខុសត្រូវបាន ប៉ុន្តែ តាមវិធានពិសេសប្លែក ពីវិធាននៃនីតិរដ្ឋប្បវេណី ដោយហេតុថា រដ្ឋបម្រើសេវាសាធារណៈ ដែលជាផលប្រយោជន៍ទូទៅ។ "វិធានពិសេស" បានមកពីបុព្វសិទ្ធិនៃអំណាចសាធារណៈ (គោលការណ៍មួយទៀត)។ ការទទួលខុសត្រូវរបស់រដ្ឋ "មិនមែនទូទៅ" គឺថាមិនមែនគ្រប់ករណីទាំងអស់នោះទេ ហេតុដូច្នេះហើយ បានជាមានពាក្យបន្ថែមមួយថា៖ "មិនមែនត្រូវតែមានជាដាច់ខាត"។ រដ្ឋអាចទទួលខុសត្រូវបាន ក្នុងលក្ខណពិសេសមួយចំនួន។ សាលដីកា "ប្លង់កូ" នេះ ជាសសរខ្លោងមួយ នៃនីតិរដ្ឋបាលបារាំង។

ប្រទេសបារាំង យោងតាមសាលដីកា "ប្លង់កូ" ការទទួលខុសត្រូវរបស់រដ្ឋការ ស្ថិតនៅក្នុងសមត្ថកិច្ច របស់តុលាការរដ្ឋបាល ក្រោមវិធានពិសេស ដែលស្ថិតក្នុងនីតិរដ្ឋបាលសាធារណៈ។

កាលពីដើម គេមិនចាត់ទុកសមូហភាពវិមជ្ឈការដូចជា (ឃុំ) និង (ខេត្ត) ជាដើម ថា ជានីតិបុគ្គលសាធារណៈ ដែលមានបុព្វសិទ្ធិពិសេសដូចរដ្ឋទេ ពីព្រោះសមូហភាពវិមជ្ឈការ ពុំមែនតំណាងអធិបតេយ្យរបស់ប្រទេសឡើយ។ ដូច្នេះ ការទទួលខុសត្រូវ ផ្នែករដ្ឋប្បវេណី របស់សមូហភាពវិមជ្ឈការត្រូវស្ថិតក្រោមនីតិរដ្ឋប្បវេណីធម្មតា។ ប៉ុន្តែ ចាប់ពីមានសាលដីកា "ប្លង់កូ" (Blanco) មក គេក៏ទទួលស្គាល់ថា ឱ្យតែចំពោះនីតិបុគ្គលសាធារណៈ ដែលបម្រើសេវាកម្មសាធារណៈ ការទទួលខុស-

---

[៧] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៥២ និង ៣៥៣

ត្រូវរបស់រដ្ឋបាល (មិនមែនក្នុងវិស័យពាណិជ្ជកម្ម និង ឧស្សាហកម្ម) ត្រូវស្ថិតក្នុងសមត្ថកិច្ច របស់តុលាការរដ្ឋបាលដែរ។ (ឃុំ) និង (ខេត្ត) ជានីតិបុគ្គលសាធារណៈដូច្នេះ ការទទួលខុសត្រូវរដ្ឋបាលរបស់ (ឃុំ) និង (ខេត្ត) ត្រូវខាងតុលាការរដ្ឋបាលជាអ្នកជំនុំជម្រះ ទៅតាមវិធាននៃនីតិរដ្ឋបាល។

ប៉ុន្តែ យើងត្រូវធ្វើការកត់សម្គាល់ជាសំខាន់មួយ គឺតុលាការរដ្ឋបាលមានសមត្ថកិច្ចក្នុងការងាររដ្ឋបាល ចំណែកឯកិច្ចការពាណិជ្ជកម្ម និង កិច្ចការឧស្សាហកម្មរបស់នីតិបុគ្គលសាធារណៈ ដូចជា ក្រុមហ៊ុនរដ្ឋ ឬ សហគ្រាសសាធារណៈផ្សេងៗ ត្រូវស្ថិតនៅក្រោមវិធាន នៃនីតិឯកជន ដែលជាសមត្ថកិច្ចរបស់តុលាការស៊ីវិល[៧]។

នេះគឺជាប្រភពដ៏ចំណាស់មួយ នៃប្រទេសបារាំង ដែលជាការកកើតឱ្យមាននូវការទទួលខុសត្រូវរបស់រដ្ឋ លើភ្នាក់ងាររដ្ឋ។ សញ្ញាណពុំនេះមែនមានត្រឹមតែប្រទេសបារាំងទេ ពោលគឺ មានប្រភពផ្សេងៗដទៃទៀត។

### ខ.ប្រភពផ្សេងៗ

ប្រភពផ្សេងៗនេះ ចង់សំដៅទៅលើ ប្រភពដែលកើតចេញ ពីគំនិតផ្តួចផ្តើម របស់ស្ថាប័នអន្តរជាតិមួយចំនួន ដូចជា អង្គការសហប្រជាជាតិជាដើម ដែលបានខ្វល់ខ្វាយ ចំពោះសកម្មភាពរបស់រដ្ឋមួយចំនួន ក្នុងការរំលោភលើសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ តាមរយៈទង្វើរបស់មន្ត្រី នៃរដ្ឋនោះ។ ដូចនេះ អង្គការអន្តរជាតិ បានអនុម័តបទប្បញ្ញត្តិមួយចំនួន ហាមឃាត់ចំពោះមន្ត្រីរាជការ/រដ្ឋការ ក្នុងការរំលោភសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ មានដូចជា ៖ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (ខ.១.) អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ (ខ.២.) លក្ខន្តិកៈតុលាការអន្តរជាតិ (ខ.៣.) ព្រមទាំងបទដ្ឋានពាក់ព័ន្ធដទៃផ្សេងទៀត។

#### ខ.១.សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

នៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស គឺជាបណ្តុំនៃសិទ្ធិ ហើយក៏ជាប្រភពមួយយ៉ាងសំខាន់ ស្តីពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការផងដែរ។ ដែលជាវិធានសម្រាប់យកមកធ្វើជាអំណះអំណាង ដើម្បីការពារលើសិទ្ធិរបស់បុគ្គល ក្នុងករណីដែលមានការបំពាន លើសិទ្ធិណាមួយ ដែលប្រព្រឹត្តឡើង ដោយមន្ត្រីរាជការ។ ក្នុងមាត្រា១ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានបញ្ញត្តថា "*មនុស្សទាំងអស់កើតមកមានសេរីភាព និង មានសមភាព ទាំងសេចក្តីថ្លៃថ្នូរទាំងសិទ្ធិ។ មនុស្សទាំងនោះមានវិចារណញ្ញាណ និង សតិសម្បជញ្ញៈជាប់ពីកំណើតមក។ ហើយគប្បីប្រព្រឹត្តរវាងគ្នា និង គ្នា ក្នុងស្មារតីភាតរភាពជាបងប្អូន។*"

---

[៧]សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លូស្ស៊ំ ឡូទឹស,២០១២), ទំព័រ៣៥៤ និង ៣៥៥

មនុស្សគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និង មានសន្តិសុខដល់ខ្លួន[១០]។ រដ្ឋ ឬ អាជ្ញាធរ មានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ដែលជាសមាជិក នៃសេចក្តីថ្លែងការណ៍នេះ មិនមានសិទ្ធិអំណាចណាមួយ ក្នុងការប្រើតួនាទីរបស់ខ្លួន ដើម្បីធ្វើនូវវិច្ឆេទកម្ម ដល់អាយុជីវិតបុគ្គលណាមួយឡើយ។ ប៉ុន្តែ បទប្បញ្ញត្តិនេះ អាចនឹងមានករណីអញ្ញត្រកម្ម។ រដ្ឋ ឬ អាជ្ញាធរមានសមត្ថកិច្ច ពុំអាចប្រើប្រាស់ នូវអំណាចរបស់ខ្លួន ប៉ះពាល់ដល់សេរីភាពរបស់បុគ្គល ដែលនាំឱ្យផ្ទុយទៅនឹងនីត្យានុកូលភាព នៃសេចក្តីប្រកាសខាងលើនេះឡើយ។ ហើយរដ្ឋ ឬ អាជ្ញាធរមានសមត្ថកិច្ច ក៏មិនអាចប្រើប្រាស់ នូវអំណាចរបស់ខ្លួនទាំងគ្រប់រូបភាព ដែលនាំឱ្យប៉ះពាល់ដល់សន្តិសុខ របស់បុគ្គលណាម្នាក់ឡើយ។

**ខ.២.អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍**

ព្រះរាជាណាចក្រកម្ពុជា ជាសមាជិកនៃអនុសញ្ញាអន្តរជាតិ ស្តីពី**ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** នៅឆ្នាំ១៩៨៣។ រដ្ឋភាគីនីមួយៗ សន្យាមិនធ្វើអំពើ ឬ ការអនុវត្តណាមួយនៃការរើសអើងពូជសាសន៍ប្រឆាំងនឹងមនុស្ស ក្រុមមនុស្ស ឬ ស្ថាប័ន និង ធានាថា អាជ្ញាធរ និង ស្ថាប័នសាធារណៈទាំងអស់ ទាំងថ្នាក់ជាតិ និង ទាំងថ្នាក់មូលដ្ឋាន ធ្វើស្របតាមកាតព្វកិច្ចនេះ[១១]។ សូម្បីតែញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ពីសម្នាក់រដ្ឋ ឬ អាជ្ញាធរថ្នាក់ជាតិ ឬ អាជ្ញាធរថ្នាក់មូលដ្ឋាន ក៏អនុសញ្ញានេះបានហាមឃាត់ផងដែរ[១២]។

សិទ្ធិមួយចំនួន មានចែងយ៉ាងច្បាស់ នៅក្នុងអនុសញ្ញានេះ ដែលបានធ្វើការហាមឃាត់ដល់អាជ្ញាធររដ្ឋ មិនឱ្យមានភាពលម្អៀង ដោយមូលហេតុពូជសាសន៍ឡើយ[១៣]។ សិទ្ធិមានសន្តិសុខបុគ្គល និង ការការពារដោយរដ្ឋប្រឆាំងនឹងការរំលោភ ឬ ការបំពារបំពានរាងកាយ ពីសម្នាក់មន្ត្រីរាជការ របស់រដ្ឋាភិបាល ឬ ពីសម្នាក់ក្រុមបុគ្គល ឬ ស្ថាប័នណាមួយ[១៤]។

ដូច្នេះ រដ្ឋជាសមាជិកនៃអនុសញ្ញានេះ មិនអាចប្រើសិទ្ធិអំណាចណាមួយ របស់ខ្លួនធ្វើឱ្យមានការបំពានសិទ្ធិរបស់ប្រជាពលរដ្ឋបានឡើយ។

---

[១០] សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស លេខ ២១៧A (III), ១០ ធ្នូ ១៩៤៨, មាត្រា៣

[១១] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, លេខ ២១០៦A (XX),០៤ មករា ១៩៦៩, មាត្រា១ ចំណុចក

[១២] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, លេខ ២១០៦A (XX),០៤ មករា ១៩៦៩, មាត្រា៤ ចំណុចគ

[១៣] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, លេខ ២១០៦A (XX),០៤ មករា ១៩៦៩, មាត្រា៥ ចំណុចក

[១៤] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, លេខ ២១០៦A (XX),០៤ មករា ១៩៦៩, មាត្រា៥ ចំណុចខ

**ខ.៣.លក្ខន្តិកៈតុលាការអន្តរជាតិ (សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ៨២៧ (១៩៩៣) ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣)**

ការទទួលខុសត្រូវ របស់អាជ្ញាធររដ្ឋ អាចនឹងមានការទទួលខុសត្រូវដែលមានលក្ខណៈជាចង្កោម ឬ ជាប្រព័ន្ធ ក្នុងលក្ខខណ្ឌមួយ ដែលប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំជាតិទាំងមូល បានរំលោភបំពានដ៏ធ្ងន់ធ្ងរ លើច្បាប់មនុស្សធម៌អន្តរជាតិ មានជាអាទិ៍៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៥] ឧក្រិដ្ឋកម្មសង្គ្រាម[១៦] ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[១៧] ឧក្រិដ្ឋកម្មឈ្លានពាន។

មាត្រា៧ នៃលក្ខន្តិកៈតុលាការអន្តរជាតិ បានបញ្ញត្តស្តីពីការទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋ ដូច្នេះថា៖

*១-បុគ្គលដែលបានរៀបចំផែនការនាំអាទិ៍ បញ្ជា ប្រព្រឹត្ត ឬ ជួយ និង ជំរុញដល់ការរៀបចំផែនការ ការប្រុងប្រៀប ឬ ការប្រព្រឹត្តបទឧក្រិដ្ឋដូចមានចែងក្នុងមាត្រា២ និង មាត្រា៥ នៃលក្ខន្តិកៈបច្ចុប្បន្ន ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះបទឧក្រិដ្ឋនោះ។*

*២-មុខតំណែងជាផ្លូវការរបស់ជនជាប់ចោទ ទោះបីជាប្រមុខរដ្ឋ ឬ ជានាយករដ្ឋមន្ត្រី ឬ ជាមន្ត្រីទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលក៏ដោយ មិនត្រូវបានយកមកប្រើប្រាស់ដើម្បីសម្រាលការទទួលខុសត្រូវលើបទឧក្រិដ្ឋ ឬ ដើម្បីបន្ថយទណ្ឌកម្មរបស់បុគ្គលនោះឡើយ។*

*៣-ការទទួលខុសត្រូវលើបទឧក្រិដ្ឋពុំអាច សម្រាលបានឡើយ ចំពោះចៅហ្វាយនាយ ដែលមានអ្នកនៅក្រោមឱវាទប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើ ចៅហ្វាយនាយនោះបានដឹង ឬ មានមូលហេតុដែលត្រូវដឹងថា អ្នកនៅក្រោមឱវាទរបស់ខ្លួន បម្រុងនឹងប្រព្រឹត្តអំពើនោះ ឬក៏ បានប្រព្រឹត្តអំពើនោះរួចទៅហើយ ដើម្បីកុំឱ្យចៅហ្វាយនាយរបស់ខ្លួនអាចចាត់វិធានការចាំបាច់ និង សមស្រប ដើម្បីទប់ស្កាត់អំពើនោះ ឬ ដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តអំពើនោះ។*

*៤-ជនជាប់ចោទដែលបានប្រព្រឹត្តអំពើបទឧក្រិដ្ឋ តាមការបញ្ជារបស់រដ្ឋាភិបាល ឬ ចៅហ្វាយនាយមិនអាចត្រូវបានសម្រាលការទទួលខុសត្រូវ ចំពោះបទឧក្រិដ្ឋនោះឡើយ ប៉ុន្តែ ការបន្ថយទណ្ឌកម្មអាច លើកយកមកពិចារណា ប្រសិនបើ តុលាការអន្តរជាតិកំណត់ឃើញថា យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ។*

បទដ្ឋានអន្តរជាតិ ដែលបានធ្វើនិប្បរិយាយខាងលើនេះ គឺសបញ្ជាក់ឱ្យឃើញពីបណ្តុំនៃសិទ្ធិបុគ្គលនីមួយៗ ដែលពុំមានបុគ្គលដទៃ សូម្បីតែអាជ្ញាធររដ្ឋ ដែលមានសិទ្ធិបុព្វក្រែ ក៏ពុំអាចរំលោភ-

[១៥] លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, ទីក្រុងរ៉ូម, ១៧/កក្កដា/១៩៩៨, មាត្រា៥

[១៦] លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, ទីក្រុងរ៉ូម, ១៧/កក្កដា/១៩៩៨, មាត្រា៣

[១៧] លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, ទីក្រុងរ៉ូម, ១៧/កក្កដា/១៩៩៨, មាត្រា៤

បំពានបានឡើយ។ បទដ្ឋានអន្តរជាតិ ចែងពីសិទ្ធិបុគ្គលនេះ មានច្រើនទៀត ដែលពុំបានលើកឡើងដូចជា:

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌។
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។
- អនុសញ្ញាស្តីពីការបង្ការ និង ផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។
- អនុសញ្ញាប្រឆាំងទារុណកម្ម និង ការផ្តន្ទាទោស ឬ ការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬ ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស។
- អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។
- អនុសញ្ញាស្តីពីកុមារ។
- អនុសញ្ញាអន្តរជាតិស្តីពីជនភៀសខ្លួន។
- ពិធីសារទាក់ទងនឹងស្ថានភាពរបស់ជនភៀសខ្លួន។
- ឧបករណ៍កម្រិតបទដ្ឋានឯទៀតៗ[១៨]។

## កថាភាគទី២

## ប្រភពជាតិ

អំពើអនីត្យានុកូល របស់មន្ត្រីរាជការ ឬ ហៅថា ការទទួលខុសត្រូវរបស់រដ្ឋលើកំហុសរបស់មន្ត្រីរាជការ ក្នុងសង្គមខ្មែរ មានសញ្ញាណជាយូរមកហើយ ពោលគឺ មានតាំងពីសម័យអង្គរមកម្ល៉េះ ដែលសញ្ញាណខ្លះ ពុំសូវជាមានការជាក់លាក់ប៉ុន្មានឡើយ ព្រោះទោសប្បញ្ញត្តិ សម្រាប់ពួកមន្ត្រីរាជការនាសម័យនោះ មានភាពខុសប្លែកពីទោសប្បញ្ញត្តិនាសម័យទំនើប។ ប្រភពខ្លះ មានលក្ខណៈពុំសូវប្រាកដប្រជា ប៉ុន្តែ វាជាសញ្ញាណមួយ ធ្វើឱ្យយើងអាចឆ្លុះបញ្ចាំងទិដ្ឋភាព នៃសញ្ញាណមន្ត្រីរាជការនាសម័យនោះ ជាក់ស្តែងដូចជា**រឿងទុំទាវ** មតិខ្លះថា ជារឿងពិត មតិខ្លះទៀតថា ជារឿងប្រតិដ្ឋ បើទោះបីជារឿងនោះ ពិតក្តី ប្រឌិតក្តី តែយើងអាចធ្វើការសន្និដ្ឋាន ពីផ្នត់គំនិតរបស់អ្នកនិពន្ធចង់បង្ហាញពីតថភាពសង្គម ក្នុងការអនុវត្តច្បាប់ កាត់ទោសមន្ត្រីរាជការនាសម័យនោះយ៉ាងប្រាកដ។ សញ្ញាណនៃការទទួលខុសត្រូវ របស់រដ្ឋនេះ ក៏ស្តែងឱ្យឃើញតាមរយៈរឿងព្រេងបុរាណខ្មែរផងដែរ មានជាអាទិ៍ ដូចរឿង ឈ្មួញចតទូកនៅមាត់ច្រាំង ច្រាំងបាក់សង្កត់លិចទូក[១៩]។

ប្រភពពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ មានដូចជាក្នុងសម័យមុនអាណានិគមបារាំង និង សម័យអាណានិគមបារាំង (ក) ព្រមទាំងសម័យក្រោយអាណានិគមបារាំង (ខ)។

---

[១៨] លេខាធិការដ្ឋានអង្គការសហប្រជាជាតិ, សិទ្ធិមនុស្ស៖ កម្រងឯកសារ នៃឧបករណ៍អង្គការសហប្រជាជាតិ (ប្រែជាភាសាខ្មែរ)

[១៩] ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ, ប្រជុំរឿងព្រេងខ្មែរ ភាគ៣, (ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ) ទំព័រ៧៧ ៧៨

**ក.សម័យមុនអាណានិគមបារាំង និង សម័យអាណានិគមបារាំង**

មិនថាសម័យអង្គរ (ក.១.) ឬ សម័យក្រោយអង្គរ (ក.២.) វិធានច្បាប់ទាំងឡាយ ដែលចេញដោយព្រះមហាក្សត្រភាគច្រើន គឺមានលក្ខណៈផ្ដាច់ការ ហើយទោសកំហុសដែលប្រព្រឹត្ត ដោយមន្ត្រីរាជការមួយចំនួន ពុំសូវដាក់ឱ្យពិន័យជាប្រាក់ឡើយ ភាគច្រើន គឺជាទោសខាងទណ្ឌកម្ម វាយនឹងខ្សែតី ទោសអស់ជីវិត។ល។ ហើយអ្វីដែលកាន់តែពិសេសទៅទៀតនោះ គឺទោសដែលមានគំនាបដល់ផ្លូវចិត្ត ពោលគឺ ការដាក់បណ្ដាសា ឬ ការស្បថ តាមផ្លូវសាសនាជាដើម។

**ក.១. សម័យអង្គរ**

នៅក្នុងសម័យអង្គរ ជាសម័យកាលមួយ ដែលអ្នកប្រវត្តិសាស្ត្រទាំងថ្នាក់ជាតិ និង ទាំងថ្នាក់អន្តរជាតិ បានទទួលស្គាល់ថា ជាសម័យដ៏រុងរោចន៍ សម្បូណ៌ដោយ ព្រះមហាក្សត្រមានទសពិធរាជធម៌ អ្នកប្រាជ្ញ បណ្ឌិត កវី ។ ក្នុងប្រទេសជាតិ សម្បូណ៌ដោយវិធាន ឬ នីតិ និង ច្បាប់ ដែលមានលក្ខណៈបែបរាជាធិបតេយ្យ។ ដោយឡែក បច្ចុប្បន្ននេះគេពិបាកនឹងធ្វើការស្វែងរក ក្បួនខ្នាត-ច្បាប់ដែលមានក្នុងសម័យកាលនោះណាស់ ប៉ុន្តែ គេសង្កេតឃើញមាននៅ តាមសិលាចារឹក និង ចម្លាក់មួយចំនួន នៅតាមផ្ទាំងប្រាសាទ ដែលមានចែងដាក់ទោសទណ្ឌ ទៅលើបុគ្គលណា ដែលបានប្រព្រឹត្តខុស។ ចំពោះមន្ត្រីរាជការ ក្នុងសម័យនោះ ដែលប្រព្រឹត្តខុស ត្រូវបានព្រះរាជាធ្វើការដាក់ទោស ដល់មន្ត្រីនោះ តាមរយៈអំណាចអាជ្ញាសឹក និង ទោស តាមរយៈសាសនា។

ទោសអាជ្ញាសឹកនេះ មានជាប្រត្យក្ស ដែលបានឆ្លាក់លើប្រាសាទបន្ទាយឆ្មារ នាសម័យព្រះបាទជ័យវរ្ម័នទី៧។ តាមតថភាពនៃចម្លាក់នោះ បានឱ្យដឹងថា "មេទ័ពខ្មែរណា ដែលក្បត់ក្នុងអំឡុងសង្គ្រាមជាមួយទ័ពចាម ពួកគេនឹងត្រូវទទួលទោសប្រហារជីវិត ដោយកាត់ក្បាលថ្វាយព្រះមហាក្សត្រ"[២០]។

ទោសខាងសាសនា ជាទោសដែលមានលក្ខណៈ ជាគំនាបខាងផ្លូវចិត្ត។ ទោសប្រភេទនេះ មានឃើញនៅលើទ្វារ នៃព្រះបរមរាជវាំង របស់ព្រះបាទសូរ្យវរ្ម័នទី១ ដែលមានខ្លឹមសារថា "*គ្រប់មន្ត្រីរាជការទាំងអស់ត្រូវតែធ្វើសម្បថថា នឹងមានភក្ដីភាពជាមួយនឹងព្រះមហាក្សត្រ។ មន្ត្រីរាជការទាំងឡាយណាដែលបំពានសម្បថនឹងត្រូវធ្លាក់នរក៣២ ជាន់*"[២១]។ បវេណី នៃការធ្វើសម្បថនេះ នៅតែមានឥទ្ធិពលលើសង្គមខ្មែរ នាពេលបច្ចុប្បន្ន ដែលការប្រើប្រាស់ពាក្យ**សម្បថ**នេះ មានសទិសន័យនឹងពាក្យ **សច្ចាប្រណិធាន**។

[២០] មីសែល ត្រាណេ, ប្រវត្តិនៃព្រះរាជាណាចក្រកម្ពុជា ការគ្រប់គ្រងរដ្ឋនាសម័យអង្គរ ពីស.វ.ទី៩ ដល់ទី១៤, បោះពុម្ពលើកទី២, (ភ្នំពេញ, ២០១៤), ទំព័រ១៣៤

[២១] កាន ច័ន្ទមេត្តា និង ផ្សេងទៀត, សេចក្ដីផ្ដើមនៃនីតិកម្ពុជា, (ភ្នំពេញ៖ ក្រុមសហប្រតិបត្តិការសកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង), ទំព័រ៨២

បន្ទាប់ពីសម័យអង្គរនេះ គឺជាសម័យក្រោយអង្គរ។ សញ្ញាណ នៃអំពើអនីត្យានុកូល ហាក់មានលក្ខណៈកាន់តែច្បាស់ជាងមុន។

**ក.២. សម័យក្រោយអង្គរ**

សម័យក្រោយអង្គរនេះ មានសម័យទូលបាសាន និង សម័យចតុម្មុខ សម័យកាលបន្តបន្ទាប់មកទៀត មានដូចជា សម័យលង្វែក (ក.២.១.) សម័យឧដុង្គ និង សម័យអាណានិគមបារាំង (ក.២.២.)។

**ក.២.១.សម័យលង្វែក**

សម័យលង្វែកនេះ កម្ពុជាបានគេចផុតពីក្រញាំសត្រូវមួយរយៈ។ គេប្រទះឃើញ វិធានមួយចំនួនដែលបានចែង ពីការទទួលទោស របស់មន្ត្រីរាជការនាសម័យនោះ មានដូចជា រាជប្រកាសស្តីពីការធ្វើសង្គ្រាម (ក.២.១.១.) និង ក្រមច្បាប់ផ្សេងៗ ដែលបានស្តែងឡើងតាមរយៈស្នាដៃ អក្សរសិល្ប៍រឿងទុំទាវ (ក.២.១.២.)។

**ក.២.១.១.រាជប្រកាស ស្តីពីការធ្វើសង្គ្រាម**

សម័យលង្វែក គេសង្កេតឃើញមាន ក្បួន-ច្បាប់មួយចំនួន ដែលមានចែងទាក់ទងទៅនឹងមន្ត្រីរាជការ នាសម័យនោះ។ ជាក់ស្តែង ក្នុងសម័យកាល ដណ្តើមរាជ្យ រវាងព្រះបាទចន្ទរាជា និង ស្តេចកន គេសង្កេតឃើញមាន រាជប្រកាសមួយចំនួនចែងក្នុងការធ្វើចម្បាំង ដូចជា ហាមប្រាមមិនឱ្យទាហានទៅរំលោភជិះជាន់ ប្លន់យកទ្រព្យសម្បត្តិ ពីប្រជារាស្ត្រឡើយ បើមានជនណាល្មើសច្បាប់ ធ្វើឱ្យប្រជារាស្ត្រក្តៅក្រហាយនោះ នឹងត្រូវផ្តន្ទាទោស ឱ្យទទួលទណ្ឌកម្មរហូត ដល់ត្រូវប្រហារជីវិត[២២]

រាជប្រកាសខាងលើនេះ ជាប្រភពមួយ នៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការ នាសម័យនោះ។ ក៏ប៉ុន្តែ ប្រភពខាងលើនេះ ហាក់ដូចជានៅពុំមានភាពមិនច្បាស់លាស់ជាច្រើន ទាក់ទងទៅនឹងសញ្ញាណ នៃមន្ត្រីរាជការ នាសម័យនោះ ព្រោះយើងមិនដឹងថា តើទាហាន ត្រូវបានគេ រាប់បញ្ចូលជាមន្ត្រីរាជការដែរឬ? ព្រោះនៅសម័យនោះ ទាហានអាចជា ទាហានកើតឡើង ដោយមានប្រាក់បៀវត្ស ហើយទាហានខ្លះទៀត កើតចេញដោយកេណ្ឌភ្លាមៗ(ទាហានស៊ីវិល)។

ការកំណត់អំពីសញ្ញាណ នៃទាហានយ៉ាងណាៗនោះ ត្រូវទុកឱ្យនៅមួយឡែកសិន អ្វីដែលសំខាន់ គឺរាជប្រកាសខាងលើនេះ បានទុកសិទ្ធិដល់ប្រជារាស្ត្រប្តឹងផ្តល់ ដល់ទាហានណា ដែលបានរំលោភយកទ្រព្យសម្បត្តិខ្លួន មកផ្តន្ទាទោសតាមផ្លូវតុលាការ។

**ក.២.១.២.រឿងទុំទាវ**

នៅក្នុងសម័យលង្វែក មានប្រភពមួយទៀត ស្តែងឱ្យឃើញ ពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការនោះគឺ **រឿងទុំទាវ**។ រឿងទុំទាវ ជាវណ្ណកម្មរបស់ព្រះបទុមត្ថេរ **សោម** ដែលនិពន្ធឡើងក្នុង

[២២] ពៅ សារឿន, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, (ភ្នំពេញ, ២០១០), ទំព័រ៧៨

ឆ្នាំ១៩១៥ ក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ។ រឿងនេះ ពុំមែនជារឿងព្រេង ហើយក៏មិនមែនជារឿងជាតកដែរគឺ ជារឿងពិត ដែលកើតឡើង នៅក្នុងសង្គមខ្មែរ នាសម័យលង្វែក ក្នុងរជ្ជកាលព្រះបាទរាមាជើងព្រៃ ដែលមានកាលបរិច្ឆេទមិនច្បាស់លាស់[២៣]។

វណ្ណគតិអក្សរសាស្ត្រខាងលើនេះ ជាសក្ខីភាព នៃព្រឹត្តការណ៍មហាសោកនាដកម្ម នៃគូស្នេហ៍មួយគូ ដែលរងគ្រោះ ដោយការពង្រាត់បង្រាស ពីម្តាយខាងស្រី និង ដោយមានការសមគំនិតជាមួយនឹង ឧកញ៉ាអរជូន ដែលជាចៅហ្វាយខេត្តត្បូងឃ្មុំ (នៅក្នុងសម័យកាលនោះ) គឺជាបទឧក្រិដ្ឋមួយ ដែលប្រព្រឹត្តឡើង ដោយមន្ត្រីរាជការ (ឧកញ៉ាអរជូន) និង ប្រជារាស្ត្រសាមញ្ញម្នាក់ (ម្តាយទាវ) ។ ឧកញ៉ាអរជូន ជាមន្ត្រីរាជការម្នាក់ ក្នុងសម័យនោះ ដែលបានប្រព្រឹត្តអំពើជាកំហុស មានដូចជា[២៤] ៖ ការពង្រាត់ទាវទៅការជាមួយម៉ឺនងួន, អំពើប្រឆាំងនឹងសេចក្តីសម្រេច របស់ព្រះរាជាដែលទ្រង់បានប្រទានមង្គលការដល់ទុំ និង ទាវ, ការសម្លាប់ទុំ, អំពើបង្កឱ្យទាវ និង នោសម្លាប់ខ្លួនឯងឱ្យស្លាប់តាមទុំ, ការប្រឆាំងព្រះរាជបញ្ជាដែលព្រះអង្គប្រទានឱ្យទុំទៅកាន់ស្រុកត្បូងឃ្មុំ។ អំពើជាកំហុសដ៏ធ្ងន់ធ្ងរទាំងនេះ មិនមែនប្រព្រឹត្តដោយឧកញ៉ាអរជូនតែម្នាក់ទេ គឺរួមមានម៉ឺនងួន, ម្តាយទាវ ជាមេគំនិត និង ញាតិសន្តានបក្សពួកឯទៀត ដែលចូលរួម ក្នុងការប្រព្រឹត្តអំពើទាំងនោះដែរ។

ចំពោះទោសវិញ ត្រូវបាននាម៉ឺនសព្វមុខមន្ត្រី បានយកសេចក្តីនេះ ទៅជំនុំយ៉ាងយកចិត្តទុកដាក់ និង យ៉ាងល្អិតល្អន់ ហើយក៏សម្រេចបែងចែកពិរុទ្ធជនជាពីរពួកគឺ៖ ពួកទីមួយ អរជូន កូនប្រពន្ធ បងប្អូនជីដូនជីតា ព្រមទាំងម្តាយទាវ ដែលជាមេផ្តើមគំនិត ត្រូវមានទោសធ្ងន់ជាងគេគឺ ត្រូវកាប់ គាស់រាស់ ឬ ភ្ជួរ បោះស្មោរក្នុងខ្ទះ។ ចំណែកឯ ពួកអ្នកទោសទីពីរគឺ មនុស្សទាំងឡាយ ដែលមកតាមគេតាមឯងចូលរួមក្នុងពិធីនេះ ដែលស្ថិតក្រោមឥទ្ធិពល របស់អរជូននោះ ត្រូវបញ្ជូនជាអ្នកងារ[២៥]។

វណ្ណកម្មខាងលើនេះ សបង្ហាញឱ្យឃើញ ពីការទទួលខុសត្រូវព្រហ្មទណ្ឌ របស់មន្ត្រីរាជការក្នុងសម័យលង្វែក ដែលមានលក្ខណៈមួយ ព្រៃផ្សៃយ៉ាងខ្លាំង។ ក្រៅពីទោសព្រហ្មទណ្ឌ គេមិនបានឃើញការកាត់ក្តីក្នុងរឿងទុំទាវ បង្គាប់ឱ្យមន្ត្រីណាមួយ ដែលមានពិរុទ្ធ ត្រូវបង់ជាសំណងរដ្ឋប្បវេណីឡើយ។ ការកាត់ទោសនេះ មានលក្ខណៈជាប្រព័ន្ធ ពោលគឺ តាំងពីប្រពន្ធ កូន បង ប្អូន ជីដូន ជីតា ត្រូវទទួលរងទោសប្រហារជីវិតទាំងអស់ ដែលផ្ទុយពីគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ[២៦] ក្នុងច្បាប់ជាធរមាននៅកម្ពុជា។

---

[២៣] ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ២៤០

[២៤] ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ២៤៨

[២៥] ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ២៤៣

[២៦] មាត្រា២៤ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ក.២.២.សម័យឧដុង្គ និង សម័យអាណានិគមបារាំង

នៅក្នុងរជ្ជកាលព្រះបាទអង្គឌួង និង ព្រះបាទនរោត្តម បានបញ្ញត្តក្រម-ច្បាប់ជាហូរហែ។ ចំពោះការទទួលខុសត្រូវ របស់មន្ត្រីរាជការ នាសម័យនោះ មានចែងដោយផ្នែក និង ដោយដុំ នៅក្នុងក្រមច្បាប់នីមួយៗ មានជាអាទិ៍ ៖ ក្រំមុន្ទីរបាល ឬ ក្រមមន្ទីរបាល (ក.២.២.១.) ក្រំទំរុងស័ក្ខតិ៍ ឬ ក្រមទម្រង់សក្តិ(ក.២.២.២.) ក្រំមក្បដ្ឋសិក់ ឬ ក្រមក្បត់សឹក (ក.២.២.៣.) ក្រំមត្រលាការ៍ ឬ ក្រមត្រ-លាការ (ក.២.២.៤.), ក្រំមពូក ឬ ក្រមពូក (ក.២.២.៥.)។ល។

#### ក.២.២.១.ក្រំមមុន្ទីរបាល ឬ ក្រមមន្ទីរបាល

ក្រមនេះមាន១៩៣ មាត្រា និង ត្រូវបានតាក់តែងឡើងនៅចុល្លសករាជ១២៣៧ ដែលត្រូវនឹង គ.ស .១៨៧៥ ក្នុងរជ្ជកាលព្រះបាទ**នរោត្តម**។ ក្រមនេះត្រូវបានបោះពុម្ពក្នុងសម័យអាណាព្យាបាលបារាំង នាថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១ តាមសេចក្តីត្រាស់បង្គាប់ របស់ព្រះបាទសម្តេចព្រះនរោត្តម[២៧]។ មាត្រាមួយចំនួន នៃក្រមនេះចែងពីទោសដែលប្រព្រឹត្ត ដោយមន្ត្រីរាជការ មានជាអាទិ៍ មាត្រា១៤ ៖ *"ក្នុងព្រះរាជវាំងជាន់ក្នុង ទោះវេលាយប់ថ្ងៃ មានព្រះរាជបញ្ញត្តិហាមកុំឱ្យស្តេចគ្រប់ ព្រះអង្គដែលគង់នៅក្រៅ និង អស់នាម៉ឺនមុខមន្ត្រី ខ្ញុំរាជការធំ-តូច ដែលនៅខាងក្រៅចេញចូលឯង នៅក្នុងព្រះ-រាជវាំងដោយអំពើចិត្ត បើចូលទៅមិនដល់ប្រាសាទរាជស្ថានពិមានមណ្ឌលដំណាក់ចៅជិតចៅចមនៅ ចូលដល់តែឧទ្យានទីស្ថានឯណាស្ងាត់ ត្រូវទោសវាយ៣០ ខ្វាប់ដាក់គ្នឹ៣ ខែ បើចូលដល់ប្រាសាទពេងរាជស្ថាន ពិមានមណ្ឌល ដំណាក់ចៅជិតចៅចមនៅ ត្រូវទោសវាយ៦០ ខ្វាប់ ដាក់គ្នឹ៦ ខែ បើចូលទៅជាសហាយស្មន់អន្ទករនឹងចៅជិតចៅចម ស្រីក្នុងវាំងក្តី ពិភាក្សាដោយសត្យឱ្យសម្លាប់បង់"*។

បទបញ្ញត្តិខាងលើនេះ អនុវត្តចំពោះក្សត្រគ្រប់ព្រះអង្គ រួមទាំងនាម៉ឺនមុខមន្ត្រីខ្ញុំរាជការធំ តូច ដែលនៅក្រៅវាំង និង ក្សត្រី ចៅជិតចៅចម ស្រីទាំងឡាយ ដែលនៅក្នុងវាំង។ ចំពោះទោស ដែលបំពានលើបម្រាមនេះ មានចាប់វាយនឹងរំពាត់ រហូតដល់ប្រហារជីវិត អាស្រ័យលើគោលបំណងទុច្ចរិត របស់អ្នកប្រព្រឹត្ត មានដូចជា គោលបំណងទៅស្មន់អន្ទករ ប្រមាថមហាក្សត្រជាដើម[២៨]។ មាត្រា៤២ ចែងពីមន្ត្រីក្រុមវាំងមានករណីយកិច្ចថែថួនស្ងួនគ្រងរក្សាការពារព្រះបរមរាជវាំង ដូចគហបតីមហានាលព្យាបាលបុត្រភរិយា និង សម្បត្តិទ្រព្យនៃខ្លួន ដែលមានសេចក្តីថា៖ *"ឯអ្នកដ៏ជាអធិបតីសិរីក្សវដ្តគោធ្វារឈេនាបរមមហានិវេសនដ្ឋាន ចូរមានចិត្តសុចរិត ពីភ័ក្តិរក្សាព្រះស្នមក្រមការបណ្តាមានក្នុងព្រះរាជវាំង ដូចគហបតីមហានាលព្យាបាលបុត្រភរិយា សម្បត្តិទ្រព្យនៃខ្លួនថែថួនស្ងួនគ្រងរក្សាការ ភ័យអន្តរាយ ហើយប្រមូលចូលទុកដាក់បាក់បែកជួសជុលទុលទ្រឱ្យគង់ល្អប្រការម្តេច ឱ្យក្រុមវាំងតាំងចិត្ត គិតកតញ្ញូដល់អម្ចាស់ជីវិតលើត្បូងប្រមូលអាករយកពន្ធចង្កបរបេ*

[២៧] ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៣៨៩ និង ៣៩០

[២៨] ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៣៩១ និង ៣៩២

*សួយវែរិះរកយកតាមច្បាប់សណ្តាប់វេណីពីបូរាណ ឱ្យបានមកដាក់ព្រះឃ្លាំងរាំងទ្វាររក្សាការពារភ័យអន្តរាយ កុំឱ្យខ្វាត់ខ្វាយអសារធានាឥតការជាផលប្រយោជន៍ក្នុងរាជការ ហើយស្លួតស្វាមីភក្តិពិភ័ក្តិរក្សាសារសុរ៉ាំងនាងនាថជាបាទបរិច្ចាគផង ស្នងព្រះនេត្រព្រះការម៍ឱ្យប្រកបនូវសេចក្តីឧស្សាហ៍ត្រួតត្រាដើរល្បាតលាត់ក្រវែល ក្នុងព្រះរាជវាំងសព្វយប់-ថ្ងៃ រំពៃមើលសត្រូវទិសទាំង៨ កុំឱ្យធ្វេសប្រហែស ហើយឱ្យបង្គាប់ភ្នាក់ងារក្រុមព្រះនគរបាល ឱ្យមានកង្វារដែកខ្វែរដែក បង្គាប់ភ្នាក់ងារក្រុមក្រឡាហោម ឱ្យមានបោយបាចទឹក បង្គាប់ភ្នាក់ងារក្រុមចក្រី ឱ្យមានអំបោសដងវែងសម្រាប់ទុកក្នុងព្រះរាជវាំងប្រយត្នប្រយោជន៍ និង ការភ្លើងផ្សែងឱ្យមានទឹកតម្កល់ទុកក្នុងព្រះរាជវាំងកុំឱ្យដាច់ បើក្រុមវាំងកន្តើយព្រងើយពុំត្រួតត្រាការតាមព្រះរាជបញ្ញត្តិនេះ ត្រូវទោសល្មើសព្រះរាជអាជ្ញាឱ្យវាយ ៥០ ខ្វាប់*(២៩) ។

### ក.២.២.២.ក្រំទំរុខស័ក្ខតី ឬ ក្រមទម្រង់សក្តិ

ក្រមទម្រង់សក្តិ ពុំមានបែងចែកជាមាត្រាទេ និង បានតាក់តែងឡើងនៅចុល្លសករាជ១២១៤ ដែលត្រូវនឹងគ.ស.១៨៥២ ក្នុងរជ្ជកាលព្រះបាទអង្គឌួង និង ត្រូវបានបោះពុម្ពក្នុងរោងពុម្ពប្រូតិកគុរ៉ា ក្រោមសេចក្តីត្រាស់បង្គាប់ របស់ព្រះបាទនរោត្តម(៣០)។ ក្រមនេះបានរៀបរាប់ អំពីរបៀបសរសេរសំបុត្រឆ្លើយឆ្លងគ្នារវាងមន្ត្រីរាជការ ដែលមានបណ្តាសក្តិតូចធំ ទៅតាមទម្រង់មួយជាក់លាក់ ដោយគោរពឋានានុក្រមនៃសក្តិ។ ការបំពានវិធាននេះ ត្រូវទទួលរងពិន័យ ទៅតាមចំនួនសក្តិ ដែលបានបន្ទាប ឬ លើកដំឡើង ដោយបំពានខុស ពីការណ៍ពិត(៣១)។

### ក.២.២.៣.ក្រំមក្សរដ្ឋសិក់ ឬ ក្រមក្បត់សឹក

ក្រមក្បត់សឹកមាន៩៩ មាត្រា និង បានតាក់តែងឡើងនៅគ.ស.១៨៧៣ ក្នុងរជ្ជកាលព្រះបាទនរោត្តម(៣២)។ ក្នុងក្រមនេះ មានមាត្រាមួយចំនួន ចែងពីទោសកំហុស របស់មន្ត្រីរាជការ ដូចជាចៅហ្វាយស្រុក ឬ ចៅហ្វាយខេត្ត ដែលខកខានមិនបាននាំ រាជបណ្ណាការមកថ្វាយ និង ធ្វើចលាចលក្នុងដែនដី ត្រូវមានទោសដល់ស្លាប់។ មាត្រា៩"*ចៅហ្វាយស្រុកខេត្តជើងទឹក ចៅហ្វាយស្រុកខេត្តជើងគោក ដែលឡើងក្រុងម្ពុជាធិបតី ពុំបាននាំផ្កាមាសផ្កាប្រាក់ នូវគ្រឿងរាជបណ្ណាការមកថ្វាយតាមប្រវេណីអំពីដើមឡើយតាំងទីនិរគុណ រឹងត្អឹងតម្អឹងអាងអំណាច ពុំខ្លាចព្រះរាជអាជ្ញា និង ធ្វើចលាចលវឹកវរលក្នុងដែនដី ត្រូវទោសដល់ស្លាប់*"(៣៣)។

(២៩) ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៣៩៣

(៣០) ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៣៩៩

(៣១) ខ្លឹមសារនៃច្បាប់នេះ មាននៅក្នុងសៀវភៅ មរតកយុត្តិធម៌ខ្មែរ បណ្ឌិត ហ៊ែល ចំរើន (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០)

(៣២) ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤០០

(៣៣) ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤០៦

**ក.២.២.៤.ក្រំមត្រលាការ ឬ ក្រមត្រលាការ**

ក្រមត្រលាការមាន៩៩ មាត្រា និង ត្រូវបានតាក់តែងឡើងជាពីរលើក គឺលើកទី១ គ.ស. ១៨៥៣ ក្នុងរជ្ជកាលព្រះបាទអង្គឌួង និង លើកទី២ គ.ស.១៨៧២ ក្នុងរជ្ជកាលព្រះបាទនរោត្តម(៣៣)។ យើងសង្កេតឃើញនៅក្នុងក្រមនេះ មានមាត្រាមួយចំនួន ចែងពាក់ព័ន្ធទៅនឹងអំពើល្មើស និង ការទទួលទោសរបស់មន្ត្រីរាជការ (មន្ត្រីតុលាការ) មានជាអាទិ៍ មាត្រា៣៧៖ ចែងពីត្រលាការដែលផ្តន្ទា-ទោសលើសពីកំហុស ត្រូវទទួលរងពិន័យ, មាត្រា៣៨៖ ត្រលាការ ឬ អាជ្ញាសាលា ដែលកំហែងចាប់កូនក្តីជាប្រពន្ធគេ មកសេពសន្ថវៈ ត្រូវពិន័យតាមលក្ខណៈកំហែងចាប់ប្រពន្ធគេ និង ដកយសសក្តិចេញដាក់ទៅជារាស្ត្រមាត្រា៧៨៖ ទោសអាជ្ញាសាលាក្នុងកាមគុណ ពេលបំពេញភារកិច្ច។

"*មាត្រា៣៧៖ ទោះទោសកូនក្តីឯណាមិនត្រូវដាក់ឃ្នាងដាក់ខ្នោះ ហើយត្រលាការដាក់ឃ្នាងដាក់ខ្នោះគេក្តី មិនត្រូវដាក់ច្រវាក់អន្ទាក់ណែងណងចងវាយ ហើយត្រលាការដាក់ច្រវាក់អន្ទាក់ណែងណងចងវាយក្តី ទោសមិនដល់ទះមាត់ចងហាលថ្ងៃត្រាំទឹក ចងព្យួរជើងគេក្តី យកកូនក្តីស្រីស្រដីលេញ្ញាឱ្យអាស្រូវភាសខ្មាសអ្នកផងក្តី ចាប់ដៃចាប់ដោះឱបថើបចាប់ស្មា ប្រលោមស្នេហាប្រការម្តេចៗក្តី ត្រូវទោសល្មើសព្រះរាជអាជ្ញា ឱ្យពិន័យជាប្រាក់៣ អន្លឹង១៧ តម្លឹង ជាព្រះឃ្លាំងហ្លួង ហើយឱ្យធ្វើទោសតាមធ្វើគេ ដោយរូបសេចក្តី តាមព្រះក្រិត្តិការ*"(៣៤)។ "*មាត្រា៣៨ ៖ ទោះត្រលាការឃើញកូនក្តីស្រី ហើយទៅស្នន់អន្ទករផងក្តី ជួលពាត់សេពសន្ថវៈផង កំហែងចាប់កូនក្តីស្រីនោះសេពសន្ថវៈផងក្តី បើសេចក្តីខាងសហាយ ខាងជួលពាត់ ត្រលាការត្រូវទោសល្មើសព្រះរាជអាជ្ញាតែ១ គុណ បើសេចក្តីខាងកំហែងចាប់ ត្រូវទោសល្មើសព្រះរាជអាជ្ញាជា២ គុណ បើស្រីនោះក្រមុំ ឱ្យពិន័យតាមបណ្តាសក្តិថែមទៀត បានទៅអ្នកអាណាព្យាបាលស្រីនោះ១ ភាគ ជាព្រះឃ្លាំង១ ភាគ បើស្រីនោះមានប្តីមានសហាយ ឱ្យធ្វើទោសពិន័យ តាមលក្ខណៈកំហែងចាប់ប្រពន្ធគេ ហើយដកយសសក្តិចេញ ដាក់ទៅជារាស្ត្រ ឯស្រីនោះ បើចិត្តព្រមសហាយផងក្តី ព្រមចិត្តទទួលស៊ីឈ្នួលក្តី ឱ្យវាយ១០ ខ្វាប់ ហើយផ្ចាលដោយព្រះរាជក្រិត្តិការ*"(៣៥)។ "*មាត្រា៧៨៖ បើអាជ្ញាសាលាជាបម្រើត្រលា-ការទៅប្រកោះ ទៅហៅគេ នោះស្រដីលេងលលួងលោមចែចង់កូនក្រមុំ ក្មួយ-ចៅ-ប្អូនក្រមុំគេ ឱ្យពិន័យនឹងបណ្តាសក្តិ បើចាប់ដៃចាប់ដោះ ឱបថើបកូនក្រមុំ ក្មួយ-ចៅ-ប្អូនក្រមុំគេ ដោយពលក្តារឯងឱ្យពិន័យនឹងបណ្តាសក្តិ វាយ៣០ ខ្វាប់ បើចាប់ចងកូនក្រមុំគេ ក្មួយ-ចៅ-ប្អូនក្រមុំគេ ដល់បានខ្លួនឱ្យពិន័យនឹងបណ្តាសក្តិជា២ គុណ វាយ៦០ ខ្វាប់*"(៣៦)។

---

(៣៣) ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤១១

(៣៤) ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤១៦

(៣៥) ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤១៦

(៣៦) ហៃល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤១៧

**ក.២.២.៥.ក្រំមព្នក ឬ ក្រមព្ទក**

ក្រមពូកមាន៥៣ មាត្រា ដោយមានចុះ "មាត្រា១" នៅគ្រប់មាត្រាទាំងអស់ និង ត្រូវបាន តាក់តែងឡើងនៅ គ.ស.១៦៩៧ ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៤ និង ត្រូវបានបោះពុម្ព នាសម័យអាណានិគមបារាំង ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៨៩១ តាមសេចក្តីត្រាស់បង្គាប់ របស់ព្រះបាទសម្តេចនរោត្តម(៣៧)។ ក្រមនេះ ក៏មានចែងពីមន្ត្រីរាជការ ដែលធ្វើខុសក្នុងមុខងាររបស់ខ្លួនផងដែរ។ ក្រមនេះ សង្កត់ធ្ងន់ទៅលើចៅក្រម កាត់សេចក្តី ដែលមានភាពលម្អៀង ក្នុងច្បាប់បានបញ្ញត្តទោស ឱ្យធ្លាក់ជារាស្ត្រវិញ។

*មាត្រា១៖ "នរូអ្នកផងមានសារពើសេចក្តី ទៅជំនុំនឹងចៅក្រមមានពាក្យថាចៅក្រមជំនុំពុំត្រង់ជាន់ទូកលម្អៀង ឱ្យចៅក្រមក្រោយជំនុំឱ្យចៅក្រមដើម បើរកទៅជាពិតត្រង់ជាន់ទូកលម្អៀងពិតគេថាបានហោង។ ឯសេចក្តីនោះឱ្យចៅក្រមក្រោយជំនុំហើយឱ្យបន្តតចៅក្រមដើមនោះជា រាស្ត្រវិញហោង បើរកទៅពុំដូចអ្នកក្តៅថាឡើយ ចៅក្រមនោះត្រង់ពុំជាន់ទូកលម្អៀងឡើយ ព្រះក្រឹត្តិការថាឱ្យយកសក្តិពីចៅក្រមពិន័យ ឯសេចក្តីនោះឱ្យកាត់ជាចាញ់គេហោង ដ្បិតសេចក្តីនោះពិតជាតាមនឹងបានឈ្នះ សេចក្តីហេតុចៅក្រមត្រង់ពិតទើបទេព្តាមកបរាមុខ ឱ្យអ្នកក្តីនោះចាញ់ចៅក្រមហើយចាញ់ទាំងក្តីឯងផងហោង"*(៣៨)។

ផុតសម័យអាណានិគមនិយមបារាំង កម្ពុជាបានឆ្លងចូល សម័យកាលថ្មីមួយទៀត បទដ្ឋានគតិយុត្ត ដែលបញ្ញត្តស្តីពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការ គឺមានលក្ខណៈ ធូរស្រាលជាងមុន។

**ខ.សម័យក្រោយអាណានិគមបារាំង**

ក្រោយសម័យអាណានិគមបារាំង កម្ពុជាបានឆ្លងកាត់សម័យកាលជាច្រើនទៀត ដូចជា សម័យសង្គមរាស្ត្រនិយម (ខ.១.) សម័យសាធារណរដ្ឋខ្មែរ (ខ.២.) សម័យកម្ពុជាប្រជាធិបតេយ្យ (ខ.៣.) សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា (ខ.៤.) និង ពេលបច្ចុប្បន្ន (ខ.៥.)។

**ខ.១.សម័យសង្គមរាស្ត្រនិយម**

ឃើញមានមាត្រាមួយចំនួន នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៩ បានបញ្ញត្តពីសិទ្ធិដាក់ពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ។ មាត្រា១៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៩ បានចែងថា "*ខេមរជននីមួយៗ មានសិទ្ធិដាក់ពាក្យប្តឹងសុំទៅអ្នកកាន់អំណាចសាធារណៈបាន ដើម្បីនាំឱ្យមានការពិចារណាបញ្ហាទាំងឡាយដែលមានផលប្រយោជន៍ចំពោះបុគ្គល ឬ ដល់មហាជន*"។

(៣៧) ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤៦២

(៣៨) ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, (ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០), ទំព័រ៤៦៣

**ខ.២.សម័យសាធារណរដ្ឋខ្មែរ**

សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) សង្កេតឃើញថាមានស្ថាប័នមួយ ដែលដើរតួនាទីដូចទៅនឹងតុលាការរដ្ឋបាលនោះ គឺហៅថា **ក្រុមប្រឹក្សារដ្ឋ**។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ មានចែង ស្តីពីក្រុមប្រឹក្សារដ្ឋនេះ ត្រង់មាត្រា១០៤ និង ១០៥។ មាត្រា១០៤ *ក្រុមប្រឹក្សារដ្ឋ ជាតុលាការកាត់ក្តី ជាដាច់ខាតខាងវិស័យរដ្ឋបាល។ ក្រុមប្រឹក្សារដ្ឋ អាចកាត់អំពីនិយតភាព នៃគណនីចំណូល និង គណនីចំណាយកាន់ដោយគណនេយ្យករសាធារណៈ*។ មាត្រា១០៥ *"ច្បាប់រៀបចំអង្គការមួយ កំណត់នូវវិធាន ស្តីពីសមាសភាព ការរៀបចំនឹងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សារដ្ឋ"*។

**ខ.៣.សម័យកម្ពុជាប្រជាធិបតេយ្យ**

ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រជាពលរដ្ឋខ្មែរ ទទួលស្គាល់ថា សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ឋិតក្រោមអំណាចរបស់អង្គការ។ បទដ្ឋានមួយចំនួន ដែលចេញក្នុងសម័យនោះ មានដូចជា រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ មាន២១ មាត្រា។

មាត្រា៩ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងថា *"តុលាការ ជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌ របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោស ដល់គ្រប់សកម្មភាព ដែលប្រឆាំងនឹងរដ្ឋ របស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋ របស់ប្រជាជន។ តុលាការគ្រប់ជាន់ថ្នាក់ ត្រូវសភាតំណាងប្រជាជនជ្រើសរើស និង តែងតាំង"*។ មាត្រាខាងលើនេះ ឃើញថា ប្រសិនបើជនណា ប្តឹងទារសំណងពីរដ្ឋ ស្មើនឹងប្រឆាំងរដ្ឋ នោះត្រូវមានការផ្តន្ទាទោស។ សិទ្ធិប្តឹងរដ្ឋ ឱ្យទទួលខុសត្រូវពុំមានឡើយ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ នាសម័យនោះឃើញថា មានការអនុម័តរដ្ឋធម្មនុញ្ញឡើងក៏ពិតមែន ប៉ុន្តែមិនត្រូវបានយកមកអនុវត្តឡើយ។ រាល់សេចក្តីសម្រេចទាំងឡាយ ឋិតក្រោមការបញ្ជា ពីថ្នាក់ដឹកនាំកំពូលៗរបស់រដ្ឋ។

ក្រោយឆ្លងផុតសម័យកាលដ៏ជូរចត់នេះមក កម្ពុជាបានរំកិលខ្លួនចូលសម័យកាលមួយទៀត ដែលមានលក្ខណៈកុម្មុយនីស្តបែបសូវៀត។

**ខ.៤.សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា**

**ខ.៤.១.សាធារណរដ្ឋប្រជាមានិតកម្ពុជា**

សាធារណរដ្ឋប្រជាមានិតកម្ពុជា ជាសម័យមួយដែលកម្ពុជាទទួលរងឥទ្ធិពល ពីលោកកុម្មុយនីស្តបែបសូវៀត ប៉ុន្តែ ប្រព័ន្ធច្បាប់កម្ពុជា ហាក់ដូចជាបានផ្តល់សិទ្ធិសេរីភាពយ៉ាងច្រើន ដល់ប្រជាពលរដ្ឋ។ មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨២ បានបញ្ញត្តថា *"ពលរដ្ឋទាំងឡាយ ត្រូវគោរពគោលការណ៍ នៃការរស់នៅក្នុងសង្គម អនុវត្តគោលនយោបាយរបស់រដ្ឋ និង ការពារទ្រព្យសម្បត្តិរួម។ ពលរដ្ឋ មានសិទ្ធិប្តឹងទារសំណង ជួសជុលការខូចខាត ដែល*

*បណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិក នៃអង្គការទាំងនោះ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន"*។ ក្រៅពីរដ្ឋធម្មនុញ្ញ ដែលមានចែងពីសញ្ញាណនៃការទទួលខុសត្រូវរបស់រដ្ឋ នៅមានវិធានមួយចែងយ៉ាងច្បាស់ ពោលគឺក្រឹត្យច្បាប់-លេខ៣៨ ឆ្នាំ១៩៨៨ មាត្រា ១២៥ បានបញ្ញត្តថា៖ " *អង្គការរដ្ឋ អង្គការសង្គម អង្គការសមូហភាព សហគ្រាសត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលកម្មាភិបាល បុគ្គលិក កម្មកររបស់ខ្លួន បានធ្វើឱ្យកើតឡើងក្នុងពេល ឬ នៅពេលបំពេញភារកិច្ច របស់ជនទាំងនេះ "*។ បទបញ្ញត្តិទាំងនេះ បានផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ ក្នុងការប្តឹងទាមទារសំណងការខូចខាត ទៅកាន់តុលាការ ពាក់ព័ន្ធនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជ-ការ។ រដ្ឋបានផ្តល់សិទ្ធិនេះ ដល់ប្រជាពលរដ្ឋពិតមែន ប៉ុន្តែ ប្រជាពលរដ្ឋ ហាក់ដូចជាពុំសូវមានការយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ម្យ៉ាងទៀត នាសម័យកាលនោះ ជាសម័យក្រោយសង្គ្រាមស៊ីវិល ដូច្នេះប្រជាពលរដ្ឋ គ្មានពេលគិតរឿងទារសំណងពីរដ្ឋឡើយ។ បើទោះបី ជាមានការប្តឹងទាមទារសំណងព្យសនកម្ម ដែលកើតចេញពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការ នាសម័យនោះមែន ក៏រដ្ឋពុំមានលទ្ធភាពសងការខូចខាតដែរ ព្រោះសម័យនោះ ប្រទេសកម្ពុជាទើបរួចផុត ពីរបបកម្ពុជាប្រជាធិប-តេយ្យ ហើយបានធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ថែមទៀត។

ប្រាក់បៀវត្សរបស់មន្ត្រីរាជការនាសម័យនោះ (ឆ្នាំ១៩៧៩) មានឧបត្ថម្ភជាអង្ករ ក្នុងម្នាក់ៗទទួលបាន៧ គីឡូក្រាម ទៅ៨ គីឡូក្រាម ក្នុងមួយខែ ដោយមិនមានប្រាក់ខែឡើយ។ ចំពោះអ្នកដែលកាន់មុខតំណែង ជារដ្ឋមន្ត្រីក្រសួងការបរទេស ទទួលបាន១៦ គីឡូក្រាមក្នុងមួយខែ ក្នុងនោះមាន១០ គីឡូក្រាមជាអង្ករ៦ គីឡូក្រាមជាពោត[៤១]។

**ខ.៤.២.រដ្ឋកម្ពុជា**

រដ្ឋកម្ពុជា ជាសម័យកាលមួយដែលកម្ពុជា មាននិន្នាការទៅរកលទ្ធិប្រជាធិបតេយ្យ បន្តិចម្តងៗ។ សិទ្ធិសេរីភាពទាំងឡាយ របស់ប្រជាពលរដ្ឋ កាន់តែមានភាពទូលំទូលាយជាងមុន ដូចជារដ្ឋបានលុបបំបាត់ទោសប្រហារជីវិតជាដើម។

មាត្រា៣៩ កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញរដ្ឋកម្ពុជា ឆ្នាំ១៩៨៩ បានបញ្ញត្តថា៖ " *ពលរដ្ឋមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទាមទារសំណង ជួសជុលការខូចខាត ដែលបណ្តាលមក ពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន "*។ ក្នុងសម័យកាលរដ្ឋកម្ពុជានេះ មិនខុសគ្នាទៅនឹងសម័យសាធារណរដ្ឋប្រជាមា-និតកម្ពុជាទេ ពោលគឺរដ្ឋបានផ្តល់សិទ្ធិនេះ ដល់ប្រជាពលរដ្ឋ ប៉ុន្តែ ពុំសូវមានប្រជាពលរដ្ឋណាមួយហ៊ានធ្វើការប្តឹងផ្តល់ ចំពោះរដ្ឋឡើយ អាចមានមូលហេតុមួយចំនួនដូចជា ភាពពុំសូវមានការយល់ដឹង អំពីសិទ្ធិរបស់ខ្លួន ប្រជាពលរដ្ឋគ្មានពេលគិតរឿងទារសំណង ពីរដ្ឋដោយមូលហេតុសង្គ្រាមស៊ី-

[៤១] តន យឿន, នីតិមុខងារសាធារណៈ, (ភ្នំពេញ, ២០១១), ទំព័រ១២

វិល។ល។ បើទោះបី ជាមានការប្តឹងទាមទារសំណងព្យសនកម្ម ដែលកើតចេញពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការ នាសម័យនោះមែន ក៏រដ្ឋនៅតែពុំមានលទ្ធភាពសងការខូចខាតដែរ ព្រោះយើងឃើញថា ប្រាក់បៀវត្សរបស់មន្ត្រីរាជការបានផ្លាស់ប្តូរ ពីរបបឧបត្ថម្ភជាស្បៀង មកជាប្រាក់វិញ ដូចជាបុគ្គលិករដ្ឋ ទទួលបាន៦៥ រៀល ក្នុងមួយខែ[៤៧]។ ក្រោយកម្ពុជាបានចុះកិច្ចព្រមព្រៀងមួយនៅទីក្រុងប៉ារីស ដើម្បីបញ្ចប់សង្គ្រាមស៊ីវិល នឹងស្វែងរកការបង្រួបបង្រួមមួយ ហើយកម្ពុជាបានប្តូររបបនយោបាយ ពីកុម្មុយនីស្តមកជាលទ្ធិប្រជាធិបតេយ្យវិញ។

**ខ.៥.សម័យបច្ចុប្បន្ន**

វិធានច្បាប់ជាច្រើន ត្រូវបានបញ្ញត្តឡើង ក្នុងសម័យបច្ចុប្បន្ន ជាពិសេសវិធានច្បាប់ ពាក់ព័ន្ធនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ។ ប្រជាពលរដ្ឋមានសិទ្ធិពេញលេញ ក្នុងការប្តឹងតតាំងនឹងរដ្ឋ ដើម្បីទាមទារសំណងការខូចខាត ដែលបង្កដោយមន្ត្រីរាជការ។ សិទ្ធិនេះ ត្រូវប្រគល់ជូនប្រជាពលរដ្ឋ តាមរយៈរដ្ឋធម្មនុញ្ញ (ខ.៥.១.) និង ច្បាប់ដទៃទៀតដូចជា ក្រមរដ្ឋប្បវេណី (ខ.៥.២.) ក្រមព្រហ្មទណ្ឌ (ខ.៥.៣.) ច្បាប់ភូមិបាល (ខ.៥.៤.) ច្បាប់អស្សាមិករណ៍ (ខ.៥.៥.) ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា (ខ.៥.៦.) ព្រមទាំងវិធានដទៃច្រើនទៀត ដែលមិនបានលើកមក សុទ្ធសឹងតែបានផ្តល់សិទ្ធិពេញលេញដល់ប្រជាពលរដ្ឋ ក្នុងការប្តឹងទាមទារសំណងពីរដ្ឋ លើអំពើរបស់មន្ត្រីរាជការ។

**ខ.៥.១.រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រ ឡាយព្រះហស្តលេខា លើព្រះរាជក្រមប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ព្រមទាំងបានធ្វើវិសោធនកម្មចំនួន៨ លើក (ចុងឆ្នាំ២០១៥)។

មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តថា៖ "*ប្រជាពលរដ្ឋមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមក ពីអំពើខុសច្បាប់ របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និង សំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ*"។ បទបញ្ញត្តិខាងលើនេះ បានទុកសិទ្ធិឱ្យប្រជាពលរដ្ឋប្តឹងទៅរដ្ឋ លើកំហុសរបស់មន្ត្រីរាជការ ដើម្បីឱ្យមានការជួសជុលការខូចខាតផ្សេងៗ។ បទបញ្ញត្តិនេះ ជាបង្អែកមួយ សម្រាប់ប្រជាពលរដ្ឋ ធ្វើការប្តឹងទៅរដ្ឋ ក្នុងករណីដែលមានការមិនសុខចិត្តណាមួយ លើអំពើក្តី ឥតអំពើក្តី របស់មន្ត្រីរាជការ ដែលធ្វើមកលើខ្លួន។

ក្រៅពីរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល នៅមានវិធានមួយទៀត ដែលចែងយ៉ាងច្បាស់ផងដែរ នោះគឺក្រមរដ្ឋប្បវេណី។

---

[៤៧] ឥន យឿន, នីតិមុខងារសាធារណៈ, (ភ្នំពេញ, ២០១១), ទំព័រ១៣

**ខ.៥.២.ក្រមរដ្ឋប្បវេណី**

ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ និង ត្រូវបានប្រកាសឱ្យប្រើជាផ្លូវការ ក្នុងឆ្នាំ២០១១។

មាត្រា៧៤៩ នៃក្រមរដ្ឋប្បវេណី ចែងពីអំពើអនីត្យានុកូល របស់មន្ត្រីរាជការ ដែលមានសេចក្ដីដូច្នេះថា៖ *"១-បើមន្ត្រីរាជការដែលទទួលការអនុវត្ត នូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។ ២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការចៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន"*។ បទប្បញ្ញត្តិខាងលើ បានចែងយ៉ាងច្បាស់ ពីការទទួលខុសត្រូវរបស់រដ្ឋ លើកំហុសមន្ត្រីរាជការ ទោះបីកំហុសនោះ ចេតនាក្តី ឬ អចេតនាក្តី។ ក្រោយសងការខូចខាតហើយ បើរដ្ឋ ឬ ស្ថាប័នសាមី យល់ថា កំហុសនោះមើលទៅហាក់ធ្ងន់ធ្ងរខ្លាំង រដ្ឋក៏អាចទាមទារសំណង ពីមន្ត្រីរាជការនោះវិញ ដើម្បីជាថ្នូរនឹងការទូទាត់កំហុសធ្ងន់ធ្ងរនោះផងដែរ។

បទប្បញ្ញត្តិ នៃក្រមរដ្ឋប្បវេណីខាងលើនេះ ហាក់ទទួលរងឥទ្ធិពល ពីប្រទេសអ្នកចែងច្បាប់នេះឱ្យកម្ពុជា ដូចជាប្រទេសបារាំង (យុត្តិសាស្ត្រ ក្នុងរឿងប្លង់កូ (Blanco)) ប្រទេសជប៉ុន (មាត្រា១ នៃច្បាប់ស្តីពីសំណង នៃការខូចខាត ដោយរដ្ឋរបស់ជប៉ុន) និង អាល្លឺម៉ង់ (មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា៣៤ នៃច្បាប់មូលដ្ឋាន (Grundgesetz)[៤២] ជាដើម។

រដ្ឋ ឬ ស្ថាប័នសាធារណៈ ទទួលខុសត្រូវលើកំហុស របស់មន្ត្រីរាជការ ត្រឹមជាសំណងប៉ុណ្ណោះ ចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាការទទួលខុសត្រូវផ្ទាល់ របស់មន្ត្រីរាជការ ដែលបានបញ្ញត្តក្នុងក្រមព្រហ្មទណ្ឌ។

**ខ.៥.៣.ក្រមព្រហ្មទណ្ឌ**

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩។ មន្ត្រីរាជការ ប្រសិនបើធ្វើអំពើណាមួយ ដែលផ្ទុយនឹងច្បាប់ហើយ នាំឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដូចជាពលរដ្ឋស៊ីវិលដែរ ហើយបើការប្រព្រឹត្តអំពើនោះ ក្នុងពេលកំពុងបំពេញភារកិច្ច ថែមទៀតនោះ នាំឱ្យទោសទណ្ឌរបស់មន្ត្រីរាជការ ស្ថិតក្នុងស្ថានទម្ងន់ទោស ថែមមួយកម្រិតទៀត។ មានបទប្បញ្ញត្តិមួយចំនួន ក្នុងក្រមព្រហ្មទណ្ឌ ដែលចែងពិសេស សម្រាប់មន្ត្រី-

[៤២] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ភាគ៣ : គន្លឹទី៥, ទំព័រ១៨៨

រាជការ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត។ បទប្បញ្ញត្តិទាំងនោះ មានជាអាទិ៍៖

- មាត្រា៥៨៦ : បទបន្តអនុវត្តមុខងារដោយខុសច្បាប់
- មាត្រា៥៨៧ : បទចាត់វិធានការសំដៅរាំងការអនុវត្តច្បាប់
- មាត្រា៥៨៨ : បទប៉ះពាល់ដល់សេរីភាពបុគ្គល
- មាត្រា៥៨៩ : បទមិនព្រមដោះលែងបុគ្គល ដែលត្រូវបានឃុំដោយខុសច្បាប់
- មាត្រា៥៩០ : បទឃុំ ឬ ដោះលែងដោយខុសច្បាប់
- មាត្រា៥៩១ : បទអូសបន្លាយការឃុំខ្លួនដោយខុសច្បាប់
- មាត្រា៥៩២ : បទវិតិក្រម
- មាត្រា៥៩៤ : បទស៊ីសំណូក
- មាត្រា៥៩៥ : បទជំនួញឥទ្ធិពលអកម្ម
- មាត្រា៥៩៧ : បទកេងយកផលប្រយោជន៍ដោយខុសច្បាប់
- មាត្រា៥៩៩ : បទបក្ខានុគ្រោះ
- មាត្រា៦០១ : បទបំផ្លាញដោយចេតនា និង គៃបំបាត់ដោយទុច្ចរិត
- មាត្រា៦០២ : បទធ្វើឱ្យខូចខាត ឬ ឱ្យបាត់បង់ដោយអចេតនា

បទប្បញ្ញត្តិទាំងឡាយខាងលើនេះ សុទ្ធសឹងជាវិធានដោយឡែក សម្រាប់អនុវត្តលើមន្ត្រីរាជការ ឬ ពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោត ក្នុងពេលបំពេញមុខងាររបស់ខ្លួន។

បទល្មើសដែលពាក់ព័ន្ធនឹងមន្ត្រីរាជការ មិនមែនមានតែក្នុងក្រមព្រហ្មទណ្ឌនេះទេ ក្នុងច្បាប់ដទៃទៀត ដូចជាច្បាប់ភូមិបាល ក៏បានបញ្ញត្តផងដែរ។

**ខ.៥.៤.ច្បាប់ភូមិបាល**

ច្បាប់ភូមិបាល ត្រូវបានរដ្ឋសភា អនុម័តកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយត្រូវបានព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃ១៣ ខែសីហា ឆ្នាំ២០០១។ ច្បាប់នេះ បានធ្វើការបែងចែករវាងកម្មសិទ្ធិឯកជន និង កម្មសិទ្ធិសាធារណៈ។ រាល់ការប៉ះពាល់កម្មសិទ្ធិ និង សិទ្ធិស្របច្បាប់ផ្សេងៗ លើអចលនវត្ថុ អាចជាបទល្មើសព្រហ្មទណ្ឌ អនុលោមតាមបញ្ញត្តិនៃច្បាប់នេះ ហើយការខូចខាតទាំងឡាយ ដែលបណ្តាលមក ពីអំពើនេះត្រូវដោះស្រាយ ដោយសំណងរដ្ឋប្បវេណី។ បទប្បញ្ញត្តិមួយចំនួន នៃច្បាប់នេះ បានធ្វើការដាក់ទោសផ្នែកព្រហ្មទណ្ឌ និង ផ្នែករដ្ឋប្បវេណី ដល់មន្ត្រីរាជការយ៉ាងដាច់ណាត់ដូចជា មាត្រា២៤៩, មាត្រា២៥០, មាត្រា២៦១, មាត្រា២៦២, មាត្រា២៦៣, មាត្រា២៦៤, មាត្រា២៦៥។

**ខ.៥.៥.ច្បាប់អស្សាមិករណ៍**

ច្បាប់ស្តីពីអស្សាមិករណ៍ ត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គរដ្ឋសភា លើកទី៣ នីតិកាលទី៤។ អស្សាមិករណ៍ សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន ដី សំណង់ និង ដំណាំដាំដុះ សម្រាប់បម្រើការស្ថាបនា ស្តារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និង យុត្តិធម៌[៤៣]។ មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទបញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទបញ្ញត្តិជាធរមាន[៤៤]។

**ខ.៥.៦.ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា**

ច្បាប់ស្តីពីវិនិយោគ ត្រូវបានរដ្ឋសភា អនុម័តនាថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៤ ដែលមាន២៦ មាត្រា ចែកជា៩ ជំពូក។ ច្បាប់បានទុកសិទ្ធិ ដល់អ្នកវិនិយោគទាំងឡាយ ក្នុងការប្តឹងផ្តល់ ដល់មន្ត្រីរាជការណា ដែលបានធ្វើពុំសមគួរ ឬ ធ្វើខុសនឹងនីតិវិធីផ្សេងៗ ដែលបញ្ញត្តក្នុងច្បាប់។

មាត្រា៧ នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តថា *"ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល៤៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវ និង គ្រប់គ្រាន់។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណា ដែលប្រកែកមិនព្រមទទួលពិនិត្យ និង ឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោស តាមបញ្ញត្តិច្បាប់"*។

ការលើកឡើង នូវវិធានគតិយុត្តខាងលើនេះ គ្រាន់តែជាចំណែកដ៏តូចមួយ នៃប្រភពច្បាប់ដែលពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការប៉ុណ្ណោះ។ នៅមានវិធានច្បាប់ដ៏ច្រើនផ្សេងទៀត ដែលមិនបានលើកឡើងមកបង្ហាញក្នុងទីនេះ។

បន្ទាប់ពីបានជ្រាបច្បាស់ពីប្រភពជាតិ និង ប្រភពអន្តរជាតិ ក៏ដូចជាបណ្តាវិធានដែល ពាក់ព័ន្ធហើយ យើងគប្បីសិក្សា ពីការទទួលខុសត្រូវ លើអំពើអនីត្យានុកូល របស់មន្ត្រីរាជការ បន្ថែមទៀត ព្រោះជាចំណុចស្នូលដែលគប្បីដឹងថា មានលក្ខខណ្ឌអ្វីខ្លះ ដែលរដ្ឋត្រូវសងការខូចខាត ដល់ជនរងគ្រោះ និង មានលក្ខខណ្ឌអ្វីខ្លះ ដែលរដ្ឋមិនត្រូវសងការខូចខាត ព្រមទាំងនីតិវិធីនៃបណ្តឹងផ្សេងៗទៀត។

[៤៣] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៤ កថាខណ្ឌទី១

[៤៤] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០,មាត្រា៣៥

# ជំពូកទី២
# ការទទួលខុសត្រូវ លើអំពើអនីត្យានុកូល របស់មន្ត្រីរាជការ

ដើម្បីឱ្យរដ្ឋ ទទួលខុសត្រូវ លើអំពើរបស់មន្ត្រីរាជការបាន លុះត្រាតែអំពើនោះ បានបំពេញទៅតាមលក្ខខណ្ឌមួយចំនួន ដែលបានបញ្ញត្តនៅក្នុងច្បាប់(ផ្នែកទី១)។ ក្រោយពីអំពើដែលជាកំហុសបង្កដោយមន្ត្រីរាជការហើយ ឃើញថា បានបំពេញទៅតាមលក្ខខណ្ឌ នៃការទទួលខុសត្រូវហើយ ជនរងគ្រោះអាចដាក់ពាក្យបណ្ដឹងនេះ (ផ្នែកទី២) ទៅតុលាការរដ្ឋបាល ឬ តុលាការស៊ីវិលក៏បាន។ កន្លងមក មានរឿងក្ដីជាច្រើន នៅប្រទេសកម្ពុជា ដែលជនរងគ្រោះ មានការមិនសុខចិត្តហើយបានធ្វើការប្ដឹងផ្ដល់ និង ទារសំណងពាក់ព័ន្ធនឹងកំហុសទាំងនេះ ដែលយើងសូមលើកយករឿងក្ដីជាក់ស្ដែង (ផ្នែកទី៣) មួយចំនួនដើម្បីយកមកធ្វើការផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពខាងផ្លូវច្បាប់ ឱ្យបានកាន់តែច្បាស់លាស់ថែមទៀត។

## ផ្នែកទី១
## លក្ខខណ្ឌនៃការទទួលខុសត្រូវ

ព្យសនកម្មមួយ អាចឱ្យមានការទទួលខុសត្រូវពីរដ្ឋបាន ត្រូវគោរពទៅតាមលក្ខខណ្ឌ៣ យ៉ាងដូចខាងក្រោម៖ កំហុសរបស់មន្ត្រីរាជការ (កថាភាគទី១) ព្យសនកម្ម (កថាភាគទី២) ទំនាក់-ទំនងរវាង កំហុស និង ព្យសនកម្ម (កថាភាគទី៣)។

### កថាភាគទី១
### កំហុសរបស់មន្ត្រីរាជការ

ដើម្បីឱ្យមានការទទួលខុសត្រូវ លើអំពើអនីត្យានុកូល របស់មន្ត្រីរាជការ គេត្រូវរកឱ្យឃើញនូវអំពើ ឬ ហេតុការណ៍ ដែលបានបង្កឱ្យកើតមានការខូចខាត។ យើងដឹងហើយថា អំពើនោះ ត្រូវជាអំពើរបស់មន្ត្រីរាជការ។ ហេតុការណ៍នោះ ក៏ត្រូវតែជាហេតុការណ៍ ដែលនៅក្នុងរង្វង់ នៃការទទួលខុសត្រូវ របស់រាជការដែរ។

នៅក្នុងនីតិរដ្ឋប្បវេណី គេនិយាយអំពី " កំហុស " គឺមិនមែនគ្រប់តែទង្វើទាំងអស់នោះទេ។ ទង្វើណាដែលមិនមែនជា " កំហុស " មិនត្រូវយកមកគិតទេ។ ទង្វើ ដែលជាកំហុសមានទង្វើខ្លះ ជាទង្វើផ្ទាល់ ទង្វើខ្លះ ជាទង្វើមិនផ្ទាល់ ដូចមានចែងក្នុងមាត្រា១២១ នៃក្រឹត្យ-ច្បាប់ លេខ៣៨ ក្រច. ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨៖

- ឃ្លាទី១ : "*ជនណាបានធ្វើឱ្យមានការខូចខាតដល់អ្នកដទៃ ដោយកំហុសរបស់ខ្លួន*" សំដៅទង្វើផ្ទាល់របស់ជននោះ។
- ឃ្លាទី២ : "*ទោះបីការខូចខាតកើតមកពីអំពើប្រព្រឹត្ត ដោយអចេតនា ដូចជាការធ្វេស-ប្រហែស ឬ ការខ្វះការប្រុងប្រយត្ន ក្នុងការត្រួតមើលថែទាំក៏ដោយ*" សំដៅទង្វើមិនផ្ទាល់។

គេអាចប្ដឹងទារសំណង នៃការខូចខាតបាន លុះត្រាតែ ទង្វើផ្ទាល់ និង ទង្វើមិនផ្ទាល់ ជាទង្វើខុសច្បាប់ ឬ ជាកំហុស[៤៥]។ ដើម្បីឱ្យកំហុសមួយ មានការទទួលខុសត្រូវពីរដ្ឋ ជនរងគ្រោះត្រូវស្វែងរកលក្ខខណ្ឌ៣ យ៉ាង ដែលត្រូវតតាំង ដូចជា មានកំហុសពិតប្រាកដ អ្នកប្រព្រឹត្តកំហុសជា មន្ត្រីរាជការ ប្រព្រឹត្តកំហុសក្នុងមុខងាររបស់ខ្លួន។ ក្នុងសញ្ញាណផ្នែករដ្ឋបាល ក៏មានលក្ខណៈមិនខុសគ្នាដែរ គឺគេត្រូវញែកឱ្យដាច់ រវាងកំហុសក្រសួង (ក) និង កំហុសផ្ទាល់ខ្លួន (ខ) ហើយពេលខ្លះ កំហុសទាំងពីរនេះ ហាក់នៅលាយឡំជាមួយគ្នា ដែលហៅថា កំហុសត្រួតគ្នា (គ) ទាំងនេះ សុទ្ធសឹងតែត្រូវធ្វើការវែកញែក ឱ្យបានច្បាស់លាស់ ដូចតទៅនេះ។

**ក.កំហុសក្រសួង**

ជាទ្រឹស្តី គេអាចចែក "កំហុសក្រសួង" (អង្គការរដ្ឋ) ឱ្យប្លែកពី "កំហុសផ្ទាល់ខ្លួន" របស់បុគ្គលដែលជាភ្នាក់ងារសាធារណៈធ្វើការឱ្យក្រសួងបាន។

កំហុសក្រសួង ជាការខ្វះចន្លោះ ក្នុងដំណើរការធម្មតារបស់ក្រសួង ដើម្បីបម្រើសេវាកម្មសាធារណៈ ដែលអាចជាអំពើរបស់ភ្នាក់ងារសាធារណៈមួយរូប ឬ ច្រើនរូប ប៉ុន្តែ ដែលគេពុំអាចទម្លាក់កំហុសទៅលើនរណាម្នាក់ឡើយ។ ជាធម្មតា គេតែងមានធម្មនិយាមស្តង់ដារសម្រាប់សម្គាល់ឱ្យដឹងថា នេះជាដំណើរការធម្មតា នោះជាដំណើរការខុសពីធម្មតា។ ការខុសពីស្តង់ដារនេះគេហៅថា *កំហុសក្រសួង*។

ការខ្វះចន្លោះរបស់ក្រសួង ដែលមិនមែនជាកំហុសផ្ទាល់របស់ភ្នាក់ងារណាមួយ និង ការខុសពីស្តង់ដារ នៃដំណើរការរបស់ក្រសួងជា "កំហុសក្រសួង"។

យុត្តិសាស្ត្ររដ្ឋបាលបារាំង ស្តីពីការបែងចែករវាង *កំហុសក្រសួង* និង *កំហុសផ្ទាល់ខ្លួន* បានកើតឡើងដំបូងបង្អស់ នៅក្នុងរឿងក្តីឈ្មោះ "ប៉ែឡឺទ្យេ" (Pelletier) ក្នុងឆ្នាំ១៨៧៣។ ឈ្មោះ "ប៉ែឡឺទ្យេ" បានបោះពុម្ពជាលើកទី១ សារព័ត៌មានច្បាប់លេខ១ ចេញថ្ងៃទី១៨ ខែមករា ឆ្នាំ១៨៧៣។ ក្នុងក្របខណ្ឌនៃអំណាចច្បាប់ស្តីពីភាពវិក្រឹតកាល អាជ្ញាធរយោធាបានបញ្ជាឱ្យ រឹបអូសយកសារព័ត៌មាន របស់"ប៉ែឡឺទ្យេ" ចេញពីផ្សារ។ ឈ្មោះនេះក៏ប្តឹងទៅតុលាការស៊ីវិល ដើម្បីសុំឱ្យលុបសេចក្តីសម្រេច របស់អាជ្ញាធរយោធាដែលខុសច្បាប់នោះចោល និង ទាមទារយកសារព័ត៌មានរបស់ខ្លួនវិញ ព្រមទាំងសំណង នៃការខូចខាត និង ជំងឺចិត្តតម្លៃ២,០០០ ហ្វ្រង់។ អាជ្ញាធរ បានធ្វើការលើក អំពីអសមត្ថកិច្ច នៃតុលាការស៊ីវិល ទៅសាលាជម្រះសមត្ថកិច្ច (T.C.)។ សាលាជម្រះសមត្ថកិច្ចយល់ថា ក្នុងរឿងនេះ "ប៉ែឡឺទ្យេ" ប្តឹងពីសេចក្តីសម្រេច របស់អាជ្ញាធរ ដែលប្រើអំណាចប៉ូលីស មិនមែនពីបុគ្គលដែលជាមន្ត្រីនោះទេ ដូចនេះវាជាករណី ដែលស្ថិតនៅក្នុងសមត្ថកិច្ច នៃតុលាការរដ្ឋបាល។

[៤៥] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៦៤

សាលដីកា"ប៉ែឡឹទៀ" នេះ ជាឱកាសដែលបណ្ដាលឱ្យមានការវែកញែក រវាង*"កំហុសក្រសួង"* និង *"កំហុសផ្ទាល់ខ្លួន"*[៤៦]។

ជួនកាលកំហុសក្រសួង មាននៅក្នុងអំពើរបស់ភ្នាក់ងារ ដែលមានកំហុសព្រហ្មទណ្ឌ។ យុត្តិ-សាស្ត្របារាំងមួយ បានបំភ្លឺករណីនេះ។ អ្នកបើកបររថយន្តទាហានម្នាក់ឈ្មោះ"ម៉ារ៉ាបែល" (Mirabel) ជាពលទាហាន។ "ម៉ារ៉ាបែល" បើករថយន្ត ក្នុងក្បួនរថយន្តរបស់កងទ័ព ដោយល្បឿន២០ គីឡូម៉ែត្រ ក្នុង១ ម៉ោង គឺបើកបរយ៉ាងយឺតៗ។ ប៉ុន្តែ ក្នុងក្បួនរថយន្តខាងមុខ បានជាន់ហ្វ្រាំងជង្គុកបន្ថយល្បឿន ធ្វើឱ្យ "ម៉ារ៉ាបែល" ខំកាច់ចង្កូតគេចកុំឱ្យប៉ះរថយន្តនោះ ហើយទៅធ្វើឱ្យអ្នកជិះកង់ម្នាក់ឈ្មោះ "តេប៉ាស្គ" (Thépaz) ដួល និង មានរបួស។

ក្រសួងអយ្យការ បានប្ដឹងចោទប្រកាន់ពីបទព្រហ្មទណ្ឌ ទៅលើរូបពលទាហានឈ្មោះ "ម៉ារ៉ា-បែល" ហើយតុលាការព្រហ្មទណ្ឌ ក៏បានដាក់ទោសត្រឹមពិន័យតម្លៃ២៥ ហ្វ្រង់ រួចឱ្យសង ជាបណ្ដោះអាសន្នទៅអ្នករងគ្រោះ ឈ្មោះ"តេប៉ាស្គ" ទឹកប្រាក់ចំនួន៧,០០០ ហ្វ្រង់ សិនទម្រាំមានសេចក្ដីសម្រេចជាស្ថាពរ ពីតុលាការថ្នាក់លើ។ នៅចំពោះមុខសាលាឧទ្ធរណ៍ អាជ្ញាធរយោធា បានចូលធ្វើអន្តរាគមន៍ ដោយតាំងខ្លួនជាអ្នកទទួលខុសត្រូវ ខាងរដ្ឋប្បវេណី ជំនួសពលទាហាន "ម៉ារ៉ា-បែល" ពីព្រោះពលទាហាននេះ កំពុងបំពេញការងារតាមបញ្ជាក្រសួង ដូច្នេះ ជាកំហុសក្រសួង។ អាជ្ញាធរយោធា សុំឱ្យបង្វិលសំណុំរឿង មកតុលាការរដ្ឋបាលវិញ ពីព្រោះជាកំហុសក្រសួង។ សាលាជម្រះសមត្ថកិច្ច បានយល់ព្រមតាមសំណើសុំ របស់អាជ្ញាធរយោធានេះ ក្នុងដីកាមួយចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៣៥។

យុត្តិសាស្ត្រនេះ ជាឧទាហរណ៍មួយបង្ហាញថា ជួនកាលកំហុសព្រហ្មទណ្ឌ អាចមិនមែនជាកំហុសផ្ទាល់ខ្លួន របស់ភ្នាក់ងារសាធារណៈ ហើយទៅជាកំហុសក្រសួងទៅវិញ[៤៧]។

**ខ.កំហុសផ្ទាល់ខ្លួន**

ជាបឋមកំហុសជាបុគ្គល ឬ កំហុសផ្ទាល់ខ្លួន គឺជាកំហុសទាំងឡាយ ដែលប្រព្រឹត្តឡើង នៅក្រៅការបំពេញមុខងារ ជាកំហុសនៅក្រៅសេវាយ៉ាងដាច់ខាត។ កិច្ចដែលប្រព្រឹត្តឡើង ដោយមន្ត្រី-រាជការក្នុងក្របខណ្ឌ នៃជីវិតឯកជនរបស់ខ្លួនស្ថិតនៅក្នុងនីតិឯកជន មិនមែននីតិរដ្ឋបាលទេ[៤៨]។

កំហុសផ្ទាល់ខ្លួន របស់ភ្នាក់ងារសាធារណៈ ជាកំហុសមិនជាប់នឹងមុខងារ ហើយដែលគេអាចផ្ដាច់ចេញពីក្រសួងបាន។ កំហុសដែលប្រព្រឹត្តក្រៅកន្លែងធ្វើការ ក្នុងឋានៈជាបុគ្គលឯកជន ជាកំហុសផ្ទាល់ខ្លួន។ ជួនកាល នៅក្នុងកន្លែងធ្វើការមែន ប៉ុន្តែ ភ្នាក់ងារមិនបានតាំងចិត្តឱ្យមាំថា ឱ្យជា

[៤៦] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៦៤

[៤៧] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៦៤

[៤៨] ឡៅ ពិដោរ, ទ្រឹស្ដីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៦៦

មន្ត្រីធ្វើការឱ្យក្រសួងទេ ហើយប្រព្រឹត្តអំពើទៅតាមចិត្តផ្ទាល់ខ្លួនទៅវិញ ដូចជា ការគោះគយរកផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ការសងសឹកតាមគំនុំ ឬ ការឈ្លោះប្រកែកជាមួយនឹងភ្ញៀវជាដើម។ល។

ជាគោលការណ៍ទូទៅ កំហុសព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តក្នុងមុខងារ ជាកំហុសផ្ទាល់ខ្លួនរបស់មន្ត្រីរាជការ។ ប៉ុន្តែ ក្នុងករណីខ្លះ គេមិនអាចផ្តាច់ ពីកំហុសក្រសួងបាន កំហុសព្រហ្មទណ្ឌអាចទៅជាកំហុសក្រសួង ដូចក្នុងរឿង "តេប៉ាស្ហ" (Thépaz)[៤៩]។

កំហុសរបស់មន្ត្រីរាជការ ដែលនាំឱ្យរដ្ឋរួចផុត ពីការទទួលខុសត្រូវ ជាកំហុសប្រព្រឹត្តឡើងក្រៅឱកាសនៃការងារ (ខ.១) ពេលខ្លះកំហុសប្រព្រឹត្តឡើងនាឱកាសនៃការងារ ប៉ុន្តែ មិនមែនបំពេញមុខងារ (ខ.២) និង កំហុសដែលប្រព្រឹត្តឡើងនាពេលបំពេញសេវា ប៉ុន្តែ ជាប់ពាក់ព័ន្ធខ្លាំងនឹងមូលហេតុជាបុគ្គលចំពោះមន្ត្រីរាជការ (ខ.៣)

### ខ.១.កំហុសប្រព្រឹត្តឡើងក្រៅឱកាសនៃការងារ

ក្រោយពីពេលធ្វើសកម្មភាព ដែលជាសមត្ថកិច្ចរបស់ខ្លួន ក៏ប៉ុន្តែ កំហុសនេះ មិនមែនគ្មានទាក់ទិនគ្នានឹងក្រសួងនោះទេ។ **ឧទាហរណ៍១៖** នគរបាលម្នាក់ ធ្វើឱ្យមានរបួស ឬ ឱ្យស្លាប់ ដល់ជនម្នាក់ ដែលនៅផ្ទះជិតខ្លួន ដោយសារតែខ្លួនកាន់លេង ឬ ជូតសម្អាតកាំភ្លើងខ្លី ដែលក្រសួងឱ្យកាន់កាប់។ ការកើតហេតុនេះ បានកើតឡើងនៅក្រៅម៉ោងធ្វើការ។ **ឧទាហរណ៍២ ៖** អ្នកបើកបររថយន្តរបស់រដ្ឋបាលម្នាក់ បានបង្វែរយករថយន្តរបស់ក្រសួង នៅពេលដែលគេបញ្ជូនឱ្យទៅធ្វើបេសកម្មណាមួយ។ អ្នកបើកនោះ យករថយន្តរបស់រដ្ឋបាល ទៅប្រើសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ហើយក៏បានបើករថយន្តនោះ ទៅបុកគេឱ្យមានគ្រោះថ្នាក់។ ការកើតឡើងនៅក្រៅករណីបេសកម្ម ក៏ប៉ុន្តែដោយសាររថយន្តរបស់ក្រសួង[៥០]។

### ខ.២.កំហុសប្រព្រឹត្តឡើងនាឱកាសនៃការងារប៉ុន្តែមិនមែនបំពេញមុខងារ

ស្ថិតក្នុងស្ថានភាពមួយ កំហុសប្រព្រឹត្តឡើង នាឱកាសនៃការងារ ប៉ុន្តែ មិនមែនបំពេញមុខងារទេ។ ជាក់ស្តែង ដូចជាមន្ត្រីនគរបាលម្នាក់ ទទួលបន្ទុកតាមដានមើល ការរក្សាសណ្តាប់ធ្នាប់ សាធារណៈ ក្នុងពេលបុណ្យនៅតាមឃុំ បោះបង់ចោលកន្លែងការងាររបស់ខ្លួន ដើម្បីចូលទៅក្នុងហាងកាហ្វេមួយឈ្លោះគ្នាជាមួយនឹងអតិថិជន ដែលនគរបាលនេះ បានគំរាមគេនឹងកាំភ្លើងរបស់ខ្លួន ហើយនៅទីបំផុតធ្វើឱ្យរបួសជនម្នាក់ ដែលបានមកដកយកកាំភ្លើងពីខ្លួន[៥១]។

---

[៤៩] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៦៨ និង ៣៦៩

[៥០] ហៀង សាង, នីតិវិវាទរដ្ឋបាល, (ភ្នំពេញ៖ រោងពុម្ពក្រសួងព័ត៌មាន, ២០១៧), ទំព័រ២៩១

[៥១] ឡឿក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៦៧ ដល់ ទំព័រ២៦៩

**ខ.៣.កំហុសដែលប្រព្រឹត្តឡើងនាពេលបំពេញសេវាប៉ុន្តែជាប់ពាក់ព័ន្ធខ្លាំងនឹងមូលហេតុជាបុគ្គលចំពោះមន្ត្រីរាជការ**

កំហុសផ្ទាល់ខ្លួន របស់អ្នករាជការ គឺជាកំហុសដែលគ្មានការទាក់ទងអ្វីសោះជាមួយនឹងស្ថាប័នរដ្ឋ គឺជាកំហុសផ្ទាល់ខ្លួន របស់អ្នករាជការនោះសុទ្ធសាធតែម្តង។ ថ្វីត្បិតតែ ការបកស្រាយសន្និដ្ឋានកំហុសរបៀបនេះងាយស្រួលនោះ ក៏ប៉ុន្តែ ជួនកាលកំហុសនេះ មានសភាពប្រហាក់-ប្រហែល ទៅនឹងកំហុសផ្ទាល់ដែលមិនមែនមិនទាក់ទិនទៅនឹងស្ថាប័ន។ គឺជាទំហំធំធ្ងន់ធ្ងរនៃកំហុសដែលមាន និង ស្ថានភាពដែលមានចេតនា ក្នុងការប្រព្រឹត្តអំពើ អាចបញ្ជាក់ប្រាប់ឱ្យឃើញ នូវកំហុសផ្ទាល់របស់អ្នករាជការសុទ្ធសាធ។ **ឧទាហរណ៍៖** នគរបាលម្នាក់ ដែលមិនមែនកំពុងតែធ្វើសកម្មភាព ក្នុងសមត្ថកិច្ចរបស់ខ្លួនទេ ក៏ប៉ុន្តែ បានស្លៀកខោអាវ ដែលជាឯកសណ្ឋាន របស់កម្លាំងនគរបាល និង មានកាំភ្លើងរបស់ក្រសួង។ នគរបាលនេះ ប្រើពេលវេលា និង ម៉ោងក្រៅការងាររបស់ក្រសួង ដើម្បីទៅធ្វើការសងសឹកផ្ទាល់ខ្លួនមួយ ដោយធ្វើឱ្យមានរបួស ឬ ស្លាប់ដល់ជនម្នាក់ នៅក្នុងភោជនីយដ្ឋានមួយ ដោយផឹកស្រាស្រវឹង(៥២)។ កំហុសដែលប្រព្រឹត្តឡើង នាពេលបំពេញសេវា ប៉ុន្តែជាប់ពាក់ព័ន្ធខ្លាំងនឹងមូលហេតុ ជាបុគ្គលចំពោះមន្ត្រីរាជការ ឬ ជាកំហុសដែលបង្ហាញ ពីឥរិយាបថមិនធម្មតាយ៉ាងខ្លាំងខុសពីឥរិយាបថ ដែលសាធារណជនរង់ចាំ ពីភ្នាក់ងារសាធារណៈ។

ប្រសិនបើ កំហុសត្រូវប្រព្រឹត្តឡើង នៅក្រៅការបំពេញមុខងារកំហុសនេះ "អាចជាចំណងជាមួយនឹងមុខងារ"។ **ឧទាហរណ៍៖** កំហុសប្រព្រឹត្តឡើង ដោយសារការប្រើមធ្យោបាយរបស់ភ្នាក់ងារដើម្បីបំពេញមុខងាររបស់ខ្លួន។ នៅទីនេះត្រូវមានលក្ខខណ្ឌបី ឥរិយាបថ ដែលធ្វើឱ្យមានការខូច-ខាត ត្រូវមានលក្ខណៈ ជាការធ្វេសប្រហែសធម្មតា មិនប្រយត្នប្រយែង ឬ ឆ្គាំឆ្គង។ មធ្យោបាយការងារ ដែលទុកឱ្យភ្នាក់ងារប្រើ ត្រូវប្រើយ៉ាងទៀងទាត់ ដោយភ្នាក់ងារនេះ នៅទីបញ្ចប់មធ្យោបាយត្រូវបង្ហាញពីហានិភ័យដោយឡែកនៃការខូចខាត។

តួយ៉ាងករណី នៃភ្នាក់ងារដែលបង្ហាញភស្តុតាង នៃភាពទុច្ចរិត។ **ឧទាហរណ៍៖** ឆ្មាំគុកដែលរៀបចំការលួចជាមួយនឹងអ្នកជាប់ឃុំ ឬ កាលណាយោធាប្រព្រឹត្តអំពើប្លន់។ កាលណាយោធាម្នាក់ដែលដឹកនាំការហាត់ជិះសេះ បង្កគ្រោះថ្នាក់តាមកំហឹងជាបុគ្គល ចំពោះថ្នាក់ក្រោមបង្គាប់របស់ខ្លួន ឬ កាលណាអភិបាលក្រុង បង្គាប់ឱ្យផ្តល់បណ្ណអសុពលភាព ទៅឱ្យបុគ្គលម្នាក់ ហើយក្នុងពេលតែមួយចេញបញ្ជា ឱ្យតាមដានមើល ដើម្បីធ្វើឱ្យបុគ្គលនេះ ភ្ញាក់ផ្អើលនៅពេលបុគ្គលនេះប្រើវា។

ឥរិយាបថជ្រុលហួសហេតុ និង មិនធម្មតា គឺជាកំហុសជាបុគ្គល។ **ឧទាហរណ៍៖** នគរបាលម្នាក់បានដាល់ ឬ យកដំបងឆក់អ្នកដំណើរលើផ្លូវសាធារណៈ ដោយសារតែអ្នកដំណើរនេះ មិនបានឃើញសញ្ញាឱ្យឈប់។ ជាកំហុសជាបុគ្គលផងដែរ អំពើដែលគ្រូទទួលបន្ទុកបង់ថ្លៃ បានចាប់ដៃ

(៥២) ឥន យឿន, វិវាទរដ្ឋបាល, (ភ្នំពេញ, ២០១៦), ទំព័រ៣៣៥

និស្សិតស្រីចេញពីក្នុងថ្នាក់ ដើម្បីបង្ខំនាងឱ្យទៅតាមគាត់ ចូលទៅក្នុងការិយាល័យរបស់គាត់ ឬ ចំពោះភ្នាក់ងារប្រៃសណីយ៍ និង ទូរគមនាគមន៍ វាយលើអ្នកប្រើប្រាស់ម្នាក់។

ហិង្សាលើរាងកាយ មិនត្រឹមតែត្រូវបានបង្ក្រាបប៉ុណ្ណោះទេ ឥរិយាបថមិនធម្មតា អាចចេញមកពីការប្រើភាសាហួសហេតុ។ ប៉ុន្តែ ចៅក្រម គិតពិចារណា ពីកម្រិតនៃភាពធ្ងន់ធ្ងរ និង ការមិនគិតថ្លៃពីសេចក្តីសម្រេច និង កាលៈទេសៈដែលក្នុងនោះរឿងហេតុបានកើតឡើង។

នៅទីបញ្ចប់ ការមិនប្រុងប្រយត្ន ឬ ការធ្វេសប្រហែសធ្ងន់ធ្ងរ អាចជាកំហុសបុគ្គល។ គឺករណីនៃកំហុសប្រព្រឹត្តឡើង ដោយស្នងការនគរបាល ដែលបានបញ្ជូនត្រលប់ទៅផ្ទះវិញ នូវជនភៀស-ខ្លួនម្នាក់ ដែលស្នងការរូបនេះ បានដឹងថា ជីវិតរបស់គាត់ត្រូវបានគំរាមកំហែង ហើយត្រូវបានគេវាយដំតាមផ្លូវ។ អំពើគ្រូពេទ្យវះកាត់ម្នាក់ ដែលជាអនុព័ន្ធ នៃសេវាសាធារណៈរបស់មន្ទីរពេទ្យមួយ ដោយគ្មានហេតុផលត្រឹមត្រូវ មិនព្រមទៅកាន់ក្បាលគ្រែ របស់ជនម្នាក់ ដែលត្រូវក្បាលគ្រាប់កាំភ្លើងចំក្បាលពោះ ហើយជននោះ ត្រូវបានគេនាំមកឱ្យគ្រូពេទ្យនេះវះចេញ នាំឱ្យមានការចោទប្រកាន់ ពីការទទួលខុសត្រូវរបស់គាត់ នៅពេលជនត្រូវគ្រាប់កាំភ្លើងស្លាប់។ ត្រូវកត់សម្គាល់ថា ក្នុងវិស័យនៃការធ្វេសប្រហែស យុត្តិសាស្ត្របារាំង មានទស្សនៈចង្អៀតខ្លាំងណាស់ ពីកំហុសជាបុគ្គល[៥៣]។

នៅប្រទេសបារាំង តុលាការស៊ីវិល ជាយុត្តាធិការមានសមត្ថកិច្ចសម្រាប់ជម្រះក្តី ក្នុងរឿង "កំហុសផ្ទាល់ខ្លួន" របស់ភ្នាក់ងារសាធារណៈ ជាមួយនឹងជនរងគ្រោះ។ នៅប្រទេសកម្ពុជា តុលាការត្រូវអនុវត្តវិធាន នៃនីតិឯកជន ក្នុងករណីដូចគ្នានេះ[៥៤]។

**គ.កំហុសត្រួតគ្នា**

កំហុសត្រួតគ្នានេះ (គ.១.) អាចបង្កជាផលវិបាកផ្សេងៗ (គ.២.)ដែលកើតឡើងចំពោះជនរង-គ្រោះផ្ទាល់ ឬ ចំពោះរដ្ឋ ឬ ស្ថាប័នសាមី។

**គ.១.ករណីនៃការត្រួតគ្នា**

យុត្តិសាស្ត្ររដ្ឋបាលបារាំង បានទទួលស្គាល់ថា ជួនកាលមានកំហុសពីរត្រួតគ្នា គឺ កំហុសផ្ទាល់ខ្លួន របស់ភ្នាក់ងាររដ្ឋការផង និង កំហុសរបស់ក្រសួងផង។

គេច្រើនលើកយកករណីរឿងក្តី "អង់គ្វេត[៥៥]" (Anguet) មកធ្វើជាគោលនៃទ្រឹស្តីនេះ។ បុរសឈ្មោះ "អង់គ្វេត" បានចូលទៅការិយាល័យប្រៃសណីយ៍មួយ នៅពេលល្ងាច ដើម្បីបើកប្រាក់តាមអាណត្តិមួយ។ ដល់ពេលគាត់ចង់ចេញមកវិញ ច្រកទ្វារសម្រាប់សាធារណជន ត្រូវបិទជាប់មុនម៉ោងធម្មតាពីរបីនាទី ហើយតាមដៃចង្អុលរបស់ភ្នាក់ងារ ដែលធ្វើការនៅទីនោះ គាត់ក៏ដើរឆ្លងកាត់កន្លែង

[៥៣] ឌឿក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៦៧ ដល់ ទំព័រ២៦៩

[៥៤] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៦៨ និង ៣៦៩

[៥៥] សាលដីកាអង់ហ្គេ (Aguet) ថ្ងៃទី០៣ កុម្ភៈ ឆ្នាំ១៩១១

សម្រាប់ពួកបុគ្គលិក ដើម្បីសំដៅទៅទ្វារមួយទៀត។ ភ្នាក់ងារប្រៃសណីយ៍ពីរនាក់ដែលកំពុងធ្វើការនៅកន្លែងនោះឃើញ "អង់គ្លេត៍" ដូចជាមិនសូវប្រញាប់ប្រញាលចេញសោះ ហើយប្រហែលជានឹកក្នុងចិត្តថា បែបជាចោរទេដឹងក៏នាំគ្នា ទាំងពីរនាក់ ច្រានយ៉ាងខ្លាំង "អង់គ្លេត៍" ចេញទៅក្រៅ ទៅដល់ថ្នល់ បណ្ដាលឱ្យ "អង់គ្លេត៍" បាក់ជើងម្ខាង។ "អង់គ្លេត៍" ប្ដឹងទារសំណងដល់ "កុងសីដេតា" ពីក្រសួងប្រៃសណីយ៍។ រដ្ឋមន្ត្រីក្រសួងនេះ ប្រកែកមិនទទួលសងអ្វីទាំងអស់ ពីព្រោះរឿងនេះ ជាកំហុសផ្ទាល់ខ្លួនរបស់ភ្នាក់ងារ ហើយក្នុងសម័យនោះ គេនិយមទ្រឹស្ដី ដែលមិនទទួលស្គាល់កំហុសត្រួត (Non cumul des fautes) ។ "កុងសីដេតា" យល់ថា ក្រសួងប្រៃសណីយ៍មានកំហុសដែរ ពីព្រោះកុំតែបិទទ្វារមុនម៉ោង ក៏វាគ្មានរឿងរ៉ាវនេះដែរ។ ដូច្នេះ "កុងសីដេតា" បានទទួលស្គាល់កំហុសត្រួតគ្នា។ ជនរងគ្រោះ អាចប្ដឹងឱ្យសងការខូចខាតទាំងស្រុង ពីក្រសួងក៏បានពីភ្នាក់ងារក៏បាន។ ក្នុងរឿងនេះ "អង់គ្លេត៍" ប្ដឹងទារសំណងពីក្រសួង ទើបប្រាកដថា មានប្រាក់សង។

មានរឿងក្ដីមួយទៀត ដែលមានលក្ខណៈជាកំហុសត្រួតគ្នាផងដែរ គឺសាលដីកា **លុីលលី-យេ** (Lhuillier) នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩១៦ ឃាតកម្មមួយបានប្រព្រឹត្តឡើងដោយយោធាម្នាក់ស្រវឹងស្រាអង្គុយជាប់ ឬ នៅលើផ្ទះប្រជាជនម្នាក់ (កំហុសបុគ្គល)។ សោកនាដកម្មនេះបានបង្ហាញពីអវត្តមានដ៏ធ្ងន់ធ្ងរ នៃការតាមដានខាងរដ្ឋបាលយោធា (កំហុសមុខក្រសួង)។

គ្រោះថ្នាក់ដែលបណ្ដាលមកពីការបើកបររថយន្តសង្គ្រោះ ដែលត្រូវប្រើប្រាស់ក្នុងគោល-បំណងជាបុគ្គល ដោយសារមិនបានតាមដានមើល យោធាមិនព្រមបង់ថ្លៃកន្លែងអង្គុយ នៅក្នុងរថភ្លើង ដោយសារមិនបានតាមដានការបង្វែរមូលនិធិ ដោយនិយោជិតស្រីម្នាក់ដែលមានតួនាទីប្រមូល ដោយបានអនុញ្ញាតឱ្យទៅផ្ទះនៅពេលម៉ោងធ្វើការ ដោយយោធា៤ នាក់ ដែលបានចេញពីបន្ទាយខុសច្បាប់ ដោយសារមិនបានតាមដានមើល។ ការលួចទំពាំងបាយជូរ ដោយយោធា ដែលបានលួចចេញពីបន្ទាយដោយខុសច្បាប់ ដោយសារមិនបានតាមឃ្លាំមើល[៥៦]។

**គ.២.ផលវិបាកនៃការត្រួតគ្នា**

រាល់លើកនៅពេលមាន ការខូចខាតដែលកើតចេញ ពីស្ថានភាពនៃការត្រួតគ្នានៃការទទួលខុសត្រូវ ជនរងគ្រោះប្រើសិទ្ធិជ្រើសរើស ឬ មួយជនរងគ្រោះអាចចោទប្រកាន់ភ្នាក់ងារ ដែលត្រូវចោទប្រកាន់នៅចំពោះមុខតុលាការធម្មតា ដែលនឹងអនុវត្តវិធាននៃការទទួលខុសត្រូវ ផ្នែករដ្ឋ-ប្បវេណី ឬ មួយប្ដឹងទៅចៅក្រមរដ្ឋបាល ដើម្បីសុំឱ្យរដ្ឋបាលជួសជុលព្យសនកម្មរបស់ខ្លួន។ ដូច្នេះជនរងគ្រោះអាចជ្រើសរើសអ្នកទទួលខុសត្រូវដែលច្បាស់លាស់ជាមានប្រាក់សង។

សិទ្ធិជ្រើសរើសនេះមិនអនុញ្ញាតឱ្យមានសំណូកចិត្តត្រួតគ្នាទេ ជាប្រការដែលអាចទទួលយកការចំណេញបានដោយគ្មានហេតុផល។ ប៉ុន្តែ ជនរងគ្រោះអាចចោទប្រកាន់ ក្នុងពេលព្រមគ្នា

[៥៦] ឌៀក ពិដោរ, ទ្រឹស្ដីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈើទើមិុច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៧៣ ដល់ ២៧៤

នូវភ្នាក់ងារ និង សេវា នៅចំពោះមុខលំដាប់យុត្តាធិការមានសមត្ថកិច្ចរៀងខ្លួន។ ក្នុងករណីនេះ បុគ្គលសាធារណៈ អាចជំនួសជនរងគ្រោះ ក្នុងសិទ្ធិដែលជននេះមានជាយថាហេតុ ដោយសារការប្រកាសសាលក្រមដែលបានធ្វើឡើង ឬ នឹងធ្វើឡើងប្រឆាំងនឹងមន្ត្រីរាជការ/រដ្ឋការ[៥៧]។

មានត្រឹមតែធាតុកំហុសតែម៉្យាង ក៏ប្រជាពលរដ្ឋពុំអាចប្តឹងទាមទារសំណងពីរដ្ឋ ទាំងដែលខ្លួនគ្មានការខូចខាតអ្វីនោះឡើយ។ ត្រូវមានធាតុចម្បងមួយទៀតគឺ ព្យសនកម្ម។

## កថាភាគទី២

## ព្យសនកម្ម

ព្យសនកម្ម គឺជាការខូចខាតខាងសម្ភារៈ ដូចជាបាត់បង់នូវទ្រព្យសម្បត្តិ នូវស្ថានភាពវិជ្ជាជីវៈ ឬ ការខូចខាតខាងរាងកាយ ឬ ខាងផ្លូវចិត្ត ដូចជាការប៉ះពាល់ដល់ការរាប់អាន ដល់ការគោរពនូវជីវភាពឯកជន ដែលបុគ្គលណាម្នាក់បានទទួលរង បណ្តាលមកពីអំពើរបស់អ្នកដទៃ[៥៨]។

ព្យសនកម្ម ដែលបង្កឡើងដល់ជនរងគ្រោះ អាចជាព្យសនកម្ម លើបេតិកភណ្ឌ (ក) និង ព្យសនកម្ម ក្រៅបេតិកភណ្ឌ (ខ)។

### ក.ព្យសនកម្ម លើបេតិកភណ្ឌ

ព្យសនកម្ម លើបេតិកភណ្ឌ ជាព្យសនកម្មទាំងឡាយណា ដែលកើតឡើងលើសម្ភារៈ មានរូបរាង អាចកត់សម្គាល់បាន និង ការខកខានមិនបានចំណេញ។

**ព្យសនកម្មជាសម្ភារៈ៖** ជាការខូចខាតទាំងឡាយណា ដែលប៉ះពាល់ដល់បេតិកភណ្ឌរបស់បុគ្គល។ ព្យសនកម្មផ្នែកសម្ភារៈ អាចស្តែងឡើងក្រោមរូបភាព ជាការបាត់បង់ទ្រព្យសកម្មណាមួយនៃបេតិកភណ្ឌ ឬ ការខកខានមិនបានចំណេញ[៥៩]។

**ការខកខានមិនបានចំណេញ៖** ជាអំពើដែលរដ្ឋបង្កឡើង ហើយធ្វើឱ្យមានការខូចខាត ដល់ជនរងគ្រោះ ដោយការខកខានណាមួយ ដែលជនរងគ្រោះត្រូវទទួលបានប្រយោជន៍ តែដោយសារអំពើរបស់រដ្ឋ ធ្វើឱ្យប្រយោជន៍នោះបាត់បង់ទៅវិញ។ **ឧទាហរណ៍៖** រថយន្តក្រុងរបស់រដ្ឋ បានបុកទៅលើរថយន្ត របស់ជនរងគ្រោះបណ្តាលឱ្យមានការខូចខាត។ មុនពេលមានអំពើ រថយន្តរបស់ជនរងគ្រោះ អាចលក់បាន៥០,០០០ ដុល្លារ តែក្រោយការបង្កឱ្យមានព្យសនកម្មពីរដ្ឋ ធ្វើឱ្យរថយន្តរបស់ជនរងគ្រោះ លក់បានតែ១០,០០០ ដុល្លារ។

[៥៧] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៧៥

[៥៨] ញឹក វុធ្ធី, នីតិកាតព្វកិច្ច មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ១៩

[៥៩] ញឹក វុធ្ធី, នីតិកាតព្វកិច្ច មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ១៩

ព្យសនកម្មមិនត្រឹមតែមានលើបេតិកភណ្ឌនោះទេ វាអាចកើតឡើង ក្រៅបេតិកភណ្ឌផងដែរ ដូចជា ព្យសនកម្មខាងផ្លូវចិត្ត និង ផ្លូវកាយជាដើម។

**ខ.ព្យសនកម្ម ក្រៅបេតិកភណ្ឌ**

ព្យសនកម្ម ក្រៅបេតិកភណ្ឌនេះ ជាព្យសនកម្មដែលអាចកើតមានឡើងចំពោះផ្លូវចិត្ត (ខ.១) និង ផ្លូវកាយ (ខ.២.) របស់ជនរងគ្រោះ។

**ខ.១.ព្យសនកម្មផ្លូវចិត្ត**

ព្យសនកម្មផ្លូវចិត្ត ជាព្យសនកម្មដែលបង្កឱ្យមានខូចខាត ដល់កិត្តិយសកេរ្តិ៍ឈ្មោះ មនោសញ្ចេតនា។

**កិត្តិយសៈ** ដូចជាការបង្កឡើងដោយរដ្ឋ តាមរយៈ ការបរិហារកេរ្តិ៍ ជេរប្រមាថ មូលបង្កាច់។ល។ **ឧទាហរណ៍ៈ** ប្រជាពលរដ្ឋ ទៅសាលាឃុំ ដើម្បីសុំចុះបញ្ជីកំណើតដល់កូន ស្រាប់តែមន្ត្រីអា-ត្រានុកូលដ្ឋាន បានធ្វើការជេរប្រមាថ ដល់ប្រជាពលរដ្ឋនោះយ៉ាងខ្លាំង។

ចំពោះការទាមទារ ក្នុងករណីនេះ ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន[៦០] ឬ អាចទាមទារសំណងនៃការខូច-ខាតខាងសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម[៦១]។

**កេរ្តិ៍ឈ្មោះៈ** ជាការប៉ះពាល់ដល់ឈ្មោះឯកជនរបស់បុគ្គល។ **ឧទាហរណ៍ៈ** មន្ត្រីថ្នាក់មូល-ដ្ឋាន បានយកឈ្មោះរបស់ក្រុមហ៊ុនមួយ ទៅផ្សព្វផ្សាយជាសាធារណៈ ដោយគ្មានហេតុផល។

**មនោសញ្ចេតនាៈ** ជាការប៉ះពាល់ ដល់សតិអារម្មណ៍ខាងផ្លូវចិត្តដល់ជនរងគ្រោះ ដោយមូលហេតុ បណ្តាលមកពីការបាត់បង់ ឬ ខូចខាតអ្វីមួយ ដែលខ្លួនស្រឡាញ់។ **ឧទាហរណ៍ៈ** ពេលប្រតិបត្តិការចុះទៅបង្ក្រាបបទល្មើសគ្រឿងញៀនមួយកន្លែង មន្ត្រីនគរបាល បានធ្វើការបាញ់ប្រហារទៅលើ ជនល្មើសស្រាប់តែខុស ត្រូវសត្វឆ្កែមួយក្បាល ដែលជាទីស្រឡាញ់របស់ជនរងគ្រោះ។

**ខ.២.ព្យសនកម្មរូបរាងកាយ**

គឺជាការខូចខាតទាំងឡាយណា ដែលប៉ះពាល់ដល់រូបរាងកាយបុគ្គល ដូចជារបួស ឈឺចាប់រូបរាងកាយ និង ផ្លូវចិត្ត ព្យសនកម្មនៃប្រតិស្រពណ៍ ព្យសនកម្មនៃសោភ័ណភាព ឬ រហូតដល់អាយុជីវិតជនរងគ្រោះ[៦២]។

**របួសស្នាមៈ** ជាការខូចខាតផ្នែករូបរាងកាយ ដូចជាបែកមុខ បាក់ដៃ បាក់ជើង។ល។

---

[៦០] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៧៥៧ កថាខណ្ឌទី៣

[៦១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៧៦២

[៦២] ញឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ១៩

**អាយុជីវិត៖** រដ្ឋបានបង្កអំពើរបស់ខ្លួន ដោយចេតនាក្តី អចេតនាក្តី បណ្តាលឱ្យជនរងគ្រោះស្លាប់។ **ឧទាហរណ៍៖** មន្ត្រីពេទ្យ បានទុកអ្នកជំងឺចោល មិនបានព្យាបាល រហូតដល់ស្លាប់។

**រូបកាយ និង ផ្លូវចិត្ត៖** អំពើបង្កឱ្យមានព្យសនកម្មដល់រូបរាងកាយជនរងគ្រោះ។ ព្យសនកម្មលើរូបរាងកាយនេះ បានធ្វើឱ្យជនរងគ្រោះ ប៉ះពាល់ដល់ផ្លូវចិត្ត។

**ប្រតិស្រពណ៍៖** គឺជាព្យសនកម្មមួយ ដែលបង្កឡើងដោយរដ្ឋ ហើយធ្វើឱ្យជនរងគ្រោះមិនអាចធ្វើតាមចំណង់ចំណូលចិត្តកើត។ **ឧទាហរណ៍៖** រថយន្តរបស់រដ្ឋ បើកបរកៀរជនរងគ្រោះបណ្តាលឱ្យបាក់ជើង ដូចនេះ ជនរងគ្រោះមិនអាចទាត់បាល់ តាមចំណូលចិត្តខ្លួនបានឡើយ។

**សោភ័ណភាព៖** ជាការបង្ករបួសស្នាមប៉ះពាល់ដល់សោភ័ណភាពជនរងគ្រោះ។ **ឧទាហរណ៍៖** រថយន្តក្រុងរបស់រដ្ឋ បានជិះកៀរជនរងគ្រោះបណ្តាល ឱ្យបែកមុខបែកមាត់។ ធ្វើឱ្យជនរងគ្រោះខូចខាតសោភ័ណភាពលើរូបរាងកាយ។

មានលក្ខខណ្ឌមួយចំនួន ដើម្បីឱ្យព្យសនកម្ម អាចជួសជុសពីរដ្ឋ ឬ ស្ថាប័នសាមី បានដូចជា៖ ពិតប្រាកដ ចម្លែកពីធម្មតា និង ប៉ះចំស្ថានភាពដែលច្បាប់ការពារ។

• **ពិតប្រាកដ៖** មានន័យថា តាមជាក់ស្តែងព្យសនកម្មពិតជាមានអត្ថិភាព។ ចំពោះព្យសនកម្មមួយជាយថាហេតុ ដែលជាការប៉ាន់ស្មានមិនពិតប្រាកដ មិនត្រូវបានជួសជុលទេ[៦៣]។

ការខូចខាតពិតប្រាកដ អាចហៅម៉្យាងទៀតថា *"ការខូចខាតជាក់ស្តែង"* ដែលគេឃើញក្នុងពេលបច្ចុប្បន្ន ហើយនឹងការខូចខាតដែលច្បាស់ជាមាន ក្នុងពេលអនាគតជាមិនខាន ដូចជាការខូចខាតសុខភាព ដែលវេជ្ជបណ្ឌិតបានពិនិត្យ ហើយដឹងថានឹងត្រូវពិការភ្នែកជាមិនខាន ក្នុងពេលអនាគតដ៏ខ្លី។ ដូច្នេះ វាមិនមែនជាការខូចខាត ដោយស្មាន ឬ ជាយថាហេតុនោះទេ។ ការខូចខាតជាយថាហេតុ មិនចូលក្នុងលក្ខខណ្ឌ នៃការទទួលខុសត្រូវឡើយ។

• **ចម្លែកពីធម្មតា៖** ការខូចខាតត្រូវតែមានលក្ខណៈ *"ចម្លែកពីធម្មតា"* គឺថា ម៉ាស៊ីនអ្វីៗទាំងអស់ដែលគេត្រូវប្រើប្រាស់ សម្រាប់ដំណើរការរបស់សេវាសាធារណៈសុទ្ធតែមានខ្នាតបច្ចេកទេសរបស់វាដែលគេដឹងជាមុនថា វាត្រូវបង្កការរំខានប៉ុណ្ណា ជាធម្មតា។ បើការរំខានឡើងហួសកម្រិតនៃខ្នាតបច្ចេកទេស ពេលនោះវាជាការចម្លែកពីធម្មតា ដែលគេអាចលើកឡើង ដើម្បីសុំឱ្យមានការទទួលខុសត្រូវពីរដ្ឋ ឬ ពីសមូហភាពវិមជ្ឈការបាន។

• **ប៉ះចំស្ថានភាពដែលច្បាប់ការពារ៖ ឧទាហរណ៍៖** ដូចជាក្នុងរឿងដែលអាជ្ញាធរសាលាក្រុងភ្នំពេញ បានសម្រេចវាយកម្ទេចចោលរបងផ្ទះរបស់ឯកជនម្នាក់ ក្នុងខែមករា ឆ្នាំ២០០១។ ប្រសិនជាមានបណ្តឹងរបស់ឯកជននោះ ទាមទារសំណងនៃការខូចខាតឡើង ដល់តុលាការ ចៅក្រមត្រូវពិនិ-

[៦៣] ញ៉ឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ២០

ត្យមើលថា តើការសាងសង់របងផ្ទះនោះមានច្បាប់ត្រឹមត្រូវ ឬ ទេ? បើថៅក្រមធ្វើការស្រាវជ្រាវទៅឃើញថា គ្មានច្បាប់អនុញ្ញាតឱ្យសាងសង់ទេ ហើយបុគ្គលនោះមកហ៊ុមពទ្ធយកដីរដ្ឋថែមទៀត ពេលនោះថៅក្រមនឹងចាត់ទុកថា ជាស្ថានភាពដែលច្បាប់មិនការពារ ហើយអាជ្ញាធរក្រុងភ្នំពេញនឹងពុំមានការទទួលខុសត្រូវអ្វីឡើយ ក្នុងការវាយកម្ទេចរបងនោះ។ អាជ្ញាធរក្រុងភ្នំពេញ មានសិទ្ធិប្តឹងឱ្យជនល្មើសសងចំណាយសព្វសារពើ ក្នុងការវាយកម្ទេចរបងផ្ទះនេះថែមទៀតផងពីព្រោះបន្ទុកនេះ ត្រូវបានបង្កដោយជនល្មើស ដល់ថវិកាសាលាក្រុងភ្នំពេញ[៦៤]។

ព្យសនកម្មអាចកើតមានជាយថាហេតុ ដល់ប្រជាពលរដ្ឋគ្រប់ពេលវេលា។ រដ្ឋអាចរួចផុតពីការទទួលខុសត្រូវ ប្រសិនបើ ព្យសនកម្មនោះ ពុំមានទំនាក់ទំនងពិតប្រាកដជាមួយនឹងកំហុស។

## កថាភាគទី៣

## ទំនាក់ទំនង រវាងកំហុស និង ព្យសនកម្ម

ការទទួលខុសត្រូវ ចំពោះសំណងនៃការខូចខាត នៅពេលដែលមានទំនាក់ទំនងច្បាស់លាស់ជាក់លាក់ រវាងអំពើបំពានសិទ្ធិ និង ព្យសនកម្ម ដោយអ្នកទាមទារមានករណីយកិច្ចបង្ហាញ មានន័យថា ព្យសនកម្មត្រូវតែកើតចេញដោយផ្ទាល់ពីអំពើរបស់ចារី ចំពោះជនរងគ្រោះទៅលើទ្រព្យសម្បត្តិ ឬ ក្រៅទ្រព្យសម្បត្តិ[៦៥]។

អត្ថិភាពនៃកំហុស ឬ ការកើតឡើងនៃស្ថានភាពមួយ នៃការទទួលខុសត្រូវទាំងគ្មានកំហុសមិនគ្រប់គ្រាន់ទេ ដើម្បីឱ្យរដ្ឋបាលទទួលខុសត្រូវ ត្រូវមានចំណងស្អិតរមួតយ៉ាងគ្រប់គ្រាន់ថែមទៀតរវាងព្យសនកម្មដែលអះអាងថា នឹងមានសកម្មភាពរដ្ឋបាលដែលបង្កឱ្យមានការខូចខាត។ មានការទទួលខុសត្រូវដោយរដ្ឋ ប្រសិនបើសកម្មភាពនៃសេវាសាធារណៈមួយ បានជាបុព្វហេតុនៃការខូចខាត។ ថៅក្រមប្រកាន់យកបុព្វហេតុគ្មានបុព្វហេតុនេះការខូចខាតក៏មិនកើតឡើងដែរ។ ថៅក្រមពិចារណាលើកាលៈទេសៈនៃអង្គហេតុ។ ការផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ដល់ឪពុកម្តាយ ស្តីពីហានិភ័យនៃកំណើតរបស់ក្មេង គឺជាបុព្វហេតុ ផ្ទាល់នៃព្យសនកម្ម ចេញមកពីការកើតឡើងនេះ[៦៦]។

ដើម្បីឱ្យមានការទទួលខុសត្រូវកំហុសរបស់មន្ត្រីរាជការ ជនរងគ្រោះត្រូវរកឱ្យឃើញថាមានចំណងហេតុផលនឹងគ្នា។ ចំណងហេតុផលត្រូវតែពិតប្រាកដ (ក) ហើយផ្ទាល់ (ខ)[៦៧]។

---

[៦៤] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៥៥ ដល់ ៣៥៧

[៦៥] គម្រោងអភិវឌ្ឍន៍ច្បាប់ និង ផ្សេងទៀត, ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, (ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ, ២០១៦), ភាគ២, ទំព័រ២១៨

[៦៦] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៩៧

[៦៧] ញឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២,ទំព័រ២២

**ក.ចំណងហេតុផលពិតប្រាកដ**

គឺជនរងគ្រោះត្រូវបង្ហាញឱ្យឃើញអត្ថិភាព នៃទំនាក់ទំនងមួយយ៉ាងពិតប្រាកដពីហេតុទៅផលរវាងអំពើ និង ការខូចខាត[៦៨]។ មានន័យថា ព្យសនកម្មនេះ ពិតជាបានកើតចេញពីអំពើរបស់មន្ត្រីរាជការនោះប្រាកដមែន។

**ខ.ចំណងហេតុផលត្រូវតែផ្ទាល់**

ព្យសនកម្មដែលត្រូវជួសជុល គឺត្រូវបានបង្កឡើងដោយកំហុសចារីតែម្តង។ មានន័យថា ព្យសនកម្មដែលបានបង្កឡើងត្រូវបន្តភ្លាមៗ ហើយផ្ទាល់ពីអំពើនាំឱ្យមាន ការខូចខាតនោះ។ ហេតុនេះបើមានហេតុការណ៍ខាងក្រៅ ណាមួយចូលមកជ្រៀតជ្រែកនៅក្នុង បណ្តាអង្គហេតុនានានោះ ចំណងហេតុផលមានលក្ខណៈមិនផ្ទាល់[៦៩]។ **ឧទាហរណ៍៖** រថយន្តក្រុងរបស់រដ្ឋ បានបើកបុកទោចក្រយានយន្ត ដែលកំពុងបើកដោយលោក **សុខ**។ ឃើញហេតុការណ៍ដូចនេះ រថយន្តក្រុង បានបើកគេចយ៉ាងលឿន លោក **សុខ** បានលើក ទោចក្រយានយន្ត ហើយបើកតាមពីក្រោយយ៉ាងលឿន ពេលកំពុងបើក ស្រាប់តែថ្មភ្នំ បានរមៀលធ្លាក់ត្រូវ បណ្តាលឱ្យស្លាប់។ ក្នុងករណីនេះ រដ្ឋ ឬ ស្ថាប័នសាមីមិនទទួលខុសត្រូវលើការស្លាប់របស់ជនរងគ្រោះឡើយ។

បន្ទាប់ពីបានដឹងថា ការខូចខាតទាំងនោះ ពិតជាសមស្របទៅតាមលក្ខខណ្ឌដែលអាចឱ្យរដ្ឋទទួលខុសត្រូវបានហើយ ប្រជាពលរដ្ឋមានសិទ្ធិយ៉ាងបរិបូណ៌ ក្នុងការដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាតពីរដ្ឋ។

## ផ្នែកទី២
## បណ្តឹងរបស់ជនរងគ្រោះ

នៅក្នុងដំណើរការនីតិវិធីនៃបណ្តឹង ជនរងគ្រោះត្រូវកំណត់ឱ្យបានច្បាស់លាស់ ពីភាគីក្នុងរឿងបណ្តឹង (កថាភាគទី១) ថាតើមាននរណាខ្លះក្នុងរឿងបណ្តឹងនេះ។ ជាជំហានបន្ទាប់ ជនរងគ្រោះត្រូវធ្វើបណ្តឹងនោះ ទៅតាមនីតិវិធីនៃបណ្តឹង (កថាភាគទី២) ដែលកំណត់ក្នុងច្បាប់។

### កថាភាគទី១
### ភាគីក្នុងរឿងបណ្តឹង

ភាគីគឺជាជនដែលទាមទារនូវសាលក្រម ឬ សាលដីកាក្នុងនាមរបស់ខ្លួន ដើម្បីដោះស្រាយវិវាទព្រមទាំងជនដែលត្រូវបានទាមទារឱ្យចង្អុលឈ្មោះនៅក្នុងសាលក្រម ឬ សាលដីកានោះ ក្នុងនាមជា ភាគីម្ខាងទៀត។ ភាគីគេហៅថា ដើមចោទ និង ចុងចម្លើយ ក្នុងការជម្រះក្តីលើកទី១ ហើយដើមបណ្តឹងឧទ្ធរណ៍ និង ចុងបណ្តឹងឧទ្ធរណ៍ ក្នុងការជម្រះក្តីនៃបណ្តឹងឧទ្ធរណ៍ ហើយដើមបណ្តឹង

[៦៨] ញឹក វុធ្លី, នីតិកាតព្វកិច្ច មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២,ទំព័រ២២

[៦៩] ញឹក វុធ្លី, នីតិកាតព្វកិច្ច មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២,ទំព័រ២២

សាទុក្ខ និង ចុងបណ្តឹងសាទុក្ខក្នុងការជម្រះក្តីនៃបណ្តឹងសាទុក្ខ[៧០]។រូបវន្តបុគ្គល និង នីតិបុគ្គល មានសមត្ថភាពជាភាគីទាំងអស់ (មាត្រា៦,៤៦)។ ទារកក្នុងគភ៌ ក៏មានសមត្ថភាពទទួលសិទ្ធិស្តីពីពីបណ្តឹងទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល[៧១]។ ភាគីបណ្តឹង ក្នុងរឿងរដ្ឋប្បវេណីមានពីរ គឺភាគីជនរងគ្រោះ(ក) និង ភាគីបង្កអំពើ (ខ)។

**ក.ភាគីជនរងគ្រោះ**

ដើមបណ្តឹងក្នុងរឿងរដ្ឋប្បវេណី ជាធម្មតាគឺជនរងគ្រោះដែលបានរងនូវព្យសនកម្មដោយផ្ទាល់។ បុគ្គលដែលមានសមត្ថភាព អាចក្លាយជាភាគីក្នុងរឿងក្តីរដ្ឋប្បវេណី ចាំបាច់ត្រូវមានលក្ខណ-សម្បត្តិទូទៅ[៧២]។

សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាលក្ខណសម្បត្តិដែលភាគី ឬ បុគ្គលផ្សេងដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន ឱ្យមានអានុភាព ឬ អាចទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ និង ភាគីម្ខាងទៀតបាន។ ទោះជាភាគីមានសមត្ថភាពក៏ដោយ តែប្រសិនបើសាមីខ្លួនពុំមានសមត្ថភាពអាចយល់បាននូវគោលគំនិត ឬ អានុភាពនៃសកម្មភាពនៅពេលដែលធ្វើ ឬ ទទួលសកម្មភាពបណ្តឹងជាក់ស្តែងបានទេ បុគ្គលនោះមិនអាចការពារផល-ប្រយោជន៍របស់ខ្លួន តាមបណ្តឹងបានទេ ហើយអាចបាត់បង់នូវផលប្រយោជន៍ច្រើនបាន[៧៣]។

ពាក្យបណ្តឹងសុំការជួសជុលរមែងធ្វើឡើងដោយជនរងគ្រោះ ប៉ុន្តែ បេឡាសន្តិសុខសង្គម និយោជក ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនរកការងារឱ្យធ្វើ ក៏ត្រូវពាក់ព័ន្ធនឹងពាក្យបណ្តឹងនេះដែរ។ នៅទីនេះ គឺទាក់ទងនឹងការបង្គាប់ឱ្យសងតាវកាលិកទៅជនរងគ្រោះ។

ចៅក្រមធម្មតាមានសមត្ថកិច្ចទទួលពាក្យបណ្តឹង ប្តឹងជួសជុលធ្វើឡើងដោយក្រុមហ៊ុនធានារ៉ាប់រងប្រឆាំងទាស់នឹងក្រុមហ៊ុនធានារ៉ាប់រង របស់តតិយជនទទួលខុសត្រូវ ពីការខូចខាតបង្កឡើងចំពោះអ្នកដែលត្រូវធានា។

កាលណាជនរងគ្រោះស្លាប់ សិទ្ធិទទួលបានការជួសជុលត្រូវផ្ទេរទៅឱ្យសិទ្ធិវន្តរបស់ខ្លួនដែលអាចបង្ហាញពីព្យសនកម្មជាសម្ភារៈ។ ប៉ុន្តែ ព្យសនកម្មសីលធម៌រលាយបាត់នៅពេលជនរង-

[៧០] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញះ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២២

[៧១] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញះ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២៤

[៧២] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញះ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២៣

[៧៣] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញះ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២៥

គ្រោះទទួលមរណភាព ឥណទេយ្យមិនអាចផ្ទេរទៅឱ្យសិទ្ធិវន្តរបស់ជនរងគ្រោះបានទេ លើកលែងបានធ្វើមុនមរណភាពរបស់ជនរងគ្រោះ[៧៤]។

ក្រៅពីបុគ្គលខាងលើ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចជា អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ (ក.១.), ជននៅក្រោមហិតូបត្ថម្ភកៈ (ក.២.), ជនបរទេស (ក.៣.)និង អាចមានតំណាងដោយអាណត្តិ (ក.៤.)។

**ក.១.អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ**

ចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ ជាគោលការណ៍ ពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងទេ ហើយអាចធ្វើសកម្មភាពបណ្តឹងសុពលភាពបានលុះត្រាតែ ត្រូវបានធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា៣២ កថាខណ្ឌទី៣ វាក្យខណ្ឌទី១)។ សកម្មភាពបណ្តឹងដែលអនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោល គឺសកម្មភាពនោះជាមោឃៈដាច់ខាត[៧៥]។

**ក.២.ជននៅក្រោមហិតូបត្ថម្ភកៈ**

ដើម្បីធ្វើសកម្មភាពបណ្តឹង អ្នកនៅក្រោមហិតូបត្ថម្ភកៈត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ (ក្រមរដ្ឋប្បវេណី មាត្រា៣០ ចំណុចឃ) ។ ដូច្នេះ ដើម្បីដាក់បណ្តឹង ឬ ធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អ្នកនៅក្រោមហិតូបត្ថម្ភកៈត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ (ការយល់ព្រមនេះ ត្រូវធ្វើការបញ្ជាក់ដោយលិខិតជាលាយលក្ខណ៍អក្សរ មាត្រា៣៥ កថាខណ្ឌទី៣)។ក៏ប៉ុន្តែ ដើម្បីធ្វើសកម្មភាពតប ចំពោះបណ្តឹង ឬ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀត មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ (មាត្រា៣៣ កថាខណ្ឌទី១)។ ប្រសិនបើ ចាំបាច់ឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈទៅ ប្រសិនជាពុំបានទទួលការយល់ព្រមនោះទៅ ភាគីម្ខាងទៀតពុំអាចដាក់ពាក្យបណ្តឹង ឬ ប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ[៧៦]។

**ក.៣.ជនបរទេស**

ក្នុងករណីដែលជនបរទេសណាម្នាក់ មានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយយោងតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះជាជននោះពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយយោងតាមច្បាប់នៃប្រទេសរបស់ជនបរទេសនោះក៏ដោយ ក៏ត្រូវចាត់ទុកថា មានសមត្ថភាពក្នុងការ

---

[៧៤] ឡើក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៤ ដល់ ៣០៥

[៧៥] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២៥

[៧៦] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២៦

ធ្វើបណ្ដឹងនៅកម្ពុជាដែរ[៧៧]។ នៅក្នុងករណីខ្លះ បញ្ហាដែលកើតឡើងពាក់ព័ន្ធរវាងរដ្ឋ ជាមួយនឹងបុគ្គលបរទេសនេះ អាចក្លាយទៅជាករណីពិសេស ពោលគឺមានការលូកដៃចូលពីសម្នាក់រដ្ឋដទៃក្នុងការការពារលើប្រជាពលរដ្ឋរបស់ខ្លួន ហើយករណីនេះ អាចនឹងឈានដល់ការលែងប្រើប្រាស់នូវតុលាការនៃនីតិរួមថែមទៀត វាបានប្រែក្លាយទៅជាវិវាទរវាងរដ្ឋ និង រដ្ឋ ដែលត្រូវមានការដោះស្រាយដោយតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ នេះជាសញ្ញាណ នៃនីតិអន្តរជាតិសា-ធារណៈ ដែលតម្រូវឱ្យរដ្ឋគោរពទៅតាមគោលការណ៍នេះ ហើយត្រូវមានការទទួលខុសត្រូវលើអំពើរបស់ខ្លួន ដែលនាំឱ្យបាត់បង់អត្ថប្រយោជន៍នៃពលរដ្ឋ របស់រដ្ឋដទៃផ្សេងទៀត។ **ឧទាហរណ៍៖** រឿងក្ដី Barcelona Traction Light, and Power Company, Limited (Belgium vs Spain)[៧៨]។ ក្រុមហ៊ុន Barcelona Traction ជាក្រុមហ៊ុនផ្គត់ផ្គង់ភ្លើង និង ថាមពល នៅប្រទេសអេស្ប៉ាញ ក្រោយមកតុលាការនៃប្រទេសអេស្ប៉ាញ បានសម្រេចប្រកាសក្ស័យធនលើក្រុមហ៊ុននេះ។ ក្រោយមកទៀត រឿងក្ដីនេះ ត្រូវបានវិនិច្ឆ័យនៅតុលាការយុត្តិធម៌អន្តរជាតិ[៧៩]។

ក្រៅពីរឿងក្ដីខាងលើ នៅមានរឿងក្ដីមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងបុគ្គលឯកជន (ជន-បរទេស) និង រដ្ឋ ដូចជា៖ រឿងក្ដី "នតប៊ុម" (Nottebohm)[៨០] ជាដើម។

**ក.៤.អ្នកតំណាងដោយអាណត្តិ**

ជាគោលការណ៍ ជនដែលអាចក្លាយទៅជាអ្នកតំណាងដោយអាណត្តិ មានតែមេធាវីទេ (គោលការណ៍តំណាងដោយមេធាវី, មាត្រា៥៣ កថាខណ្ឌទី១)។ នេះគឺដើម្បីការពារផលប្រយោជន៍សាមីភាគីដែលជាអ្នកពឹងពាក់[៨១]។

[៧៧] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្ដីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ២៦

[៧៨] គេហៈទំព័រតុលាការICJ, web: www.icj-cij.org/en/case/50/judgments (ដកស្រង់ ២៤ មិថុនា ២០១៨)

[៧៩] គេហៈទំព័រវីគីភីឌា, Web: www.en.m.wikipedia.org/wiki/barcelona_traction (ដកស្រង់ ២៤ មិថុនា ២០១៨), សូមមើលក្នុងឧបសម្ពន្ធទី៣ លេខ ៣.១.

[៨០] ជុំ ចាន់វិត្ថា, កម្រងការងារប្រតិបត្តិ នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី២, (ភ្នំពេញ៖ គីម ឡុង,២០១១), សូមមើលក្នុងគេហៈទំព័រ, http://www.uniset.ca/naty/maternity/nottebohm.htm

[៨១] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្ដីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ៣០

អ្នកតំណាងដោយអាណត្តិ អាចធ្វើរាល់សកម្មភាពបណ្តឹង ដែលចាំបាច់ក្នុងការបន្តនីតិវិធី ដូចជាការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសាចំពោះបណ្តឹង ការប្តឹងតប ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ជាដើម ចំពោះរឿងក្តីដែលខ្លួនបានទទួលអាណត្តិ[៨២]។

ក្រៅពីដើមបណ្តឹង ក្នុងដំណើរការនៃនីតិវិធីរដ្ឋប្បវេណី មានភាគីមួយទៀត ហៅភាគីបង្កអំពើ ដែលជាភាគីចម្បងមួយ ក្នុងដំណើរការនីតិវិធីផងដែរ។ ប្រសិនបើ ក្នុងបណ្តឹងមួយ គ្មានភាគីបង្កអំពើ ឬ ហៅម៉្យាងទៀតថា ចុងចម្លើយ នាំឱ្យបណ្តឹងនោះមិនមានសុពលភាពឡើយ។

**ខ.ភាគីបង្កអំពើ**

ភាគីបង្កអំពើក្នុងទីនេះ គឺសំដៅទៅលើរដ្ឋ។ បុគ្គល ដែលបម្រើការងារក្នុងស្ថាប័នសាធារណៈ មាន មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត។ ដែលបុគ្គលខាងលើនេះ បិតក្រោមវិធានច្បាប់សាធារណៈ និង ច្បាប់ឯកជន។

ជាទូទៅ រដ្ឋត្រូវមានការទទួលខុសត្រូវលើអំពើរបស់មន្ត្រីរាជការ ដោយផ្អែកទៅតាមមាត្រា ៧៤៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ចំណែកឯ មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត ក៏ត្រូវបានរដ្ឋ ទទួលខុសត្រូវផងដែរ ប៉ុន្តែ មិនមែនបិតនៅក្នុងសញ្ញាណ នៃការទទួលខុសត្រូវអំពើ របស់មន្ត្រីរាជការឡើយ តែវាបិតនៅក្រោមវិធាននៃច្បាប់ការងារ ឆ្នាំ១៩៩៧ ទៅវិញ ព្រោះវាមានចរិតលក្ខណៈជា កិច្ចសន្យាការងារ ដែលមានការទទួលខុសត្រូវដោយនិយោជកលើអំពើរបស់និយោជិត (មាត្រា ៧៤៧,ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧)។

**មន្ត្រីរាជការ៖** មន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ អចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន រដ្ឋ ឬ ស្ថាប័នសាធារណៈ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត[៨៣]។

**មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត៖** មាត្រា៧៤៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តថា "*ការទទួលខុសត្រូវរបស់និយោជក៖ ១.បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ។ ២.បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គល*

[៨២] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តីពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១, ទំព័រ៣២

[៨៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៧៤៩ កថាខណ្ឌទី១

*នោះបានត្រួតពិនិត្យដោយត្រឹមត្រូវ។ ៣.និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុស របស់និយោជិតនោះ"។*

ក្នុងករណីខាងលើនេះ រដ្ឋបានដើរតួនាទីជានិយោជក ចំណែកឯមន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត ជានិយោជិត។

មានតែបុគ្គលទទួលខុសត្រូវទេ ដែលត្រូវប្តឹងឱ្យទទួលខុសត្រូវ។ ជាគោលការណ៍គឺសមូហភាពសាធារណៈ ដែលសម្រាប់ប្រយោជន៍របស់ខ្លួនអ្នកប្រព្រឹត្តការខូចខាត ប៉ុន្តែ វិធាននេះតែងតែស្មុគស្មាញក្នុងការដាក់ឱ្យអនុវត្ត។ បុគ្គលដែលត្រូវប្តឹងឱ្យទទួលខុសត្រូវរួមមានដូចជាៈ បុគ្គលសាធារណៈដែលភ្ជាប់ទៅនឹងសមូហភាព (ខ.១.) ភ្នាក់ងារសាធារណៈធ្វើសកម្មភាពជាប្រយោជន៍របស់រដ្ឋបាល (ខ.២.) បុគ្គលឯកជនដែលគ្រប់គ្រងសេវាសាធារណៈ (ខ.៣.)។

**ខ.១.បុគ្គលសាធារណៈដែលភ្ជាប់ទៅនឹងសមូហភាព**

មានបុគ្គលសាធារណៈច្រើនណាស់ដែលធ្វើប្រតិបត្តិការតែមួយ។ ដូច្នេះមានការលំបាក និង កំណត់ពីការទទួលខុសត្រូវរបស់សមូហភាពនីមួយៗ។ ភាគច្រើនគឺរដ្ឋ និង សមូហភាពមូលដ្ឋាន ដែលធ្វើអន្តរាគមន៍ដែងគ្នា។ **ឧទាហរណ៍ៈ** ខាងនគរបាល ទោះជាមានសកម្មភាពផ្សេងទៀតក៏ដោយ ក៏ឃុំត្រូវចេញវិធានការសមស្រប ដើម្បីធានាការការពារប្រឆាំងនឹងអគ្គិភ័យ ការតាមដានកន្លែងមុជទឹក កន្លែងលេងជិះស្គី[៨៩]។

**ខ.២.ភ្នាក់ងារសាធារណៈធ្វើសកម្មភាពជាប្រយោជន៍របស់រដ្ឋបាល**

កាលណាភ្នាក់ងារម្នាក់ធ្វើសកម្មភាពជាប្រយោជន៍របស់រដ្ឋបាលច្រើន ក្នុងករណីមានការខូចខាតត្រូវដឹងថា តើភ្នាក់ងារនេះស្ថិតនៅក្នុងរដ្ឋបាលណា ដែលជាហេតុបង្កការខូចខាតបានកើតឡើង។ សមូហភាពដែលភ្នាក់ងារធ្វើការ ឱ្យមានប្រាកដថា ជាសមូហភាពដែលផ្តល់លាភការឱ្យទេ ប៉ុន្តែ គឺសមូហភាពដែលភ្នាក់ងារអាស្រ័យលើការបំពេញភារកិច្ចរបស់ខ្លួន។ មេឃុំ (ភ្នាក់ងាររបស់រដ្ឋ និង របស់ឃុំ) និង Préfet (ភ្នាក់ងាររបស់រដ្ឋដែលអាចជំនួសមេឃុំ) ជាប្រភេទនៃភ្នាក់ងារបម្រើសមូហភាពច្រើន។ ក្នុងករណី Préfet ប្រើអំណាចជំនួសមេឃុំ កិច្ចនៃការប្រើអំណាចអាណាព្យាបាល ជាបន្ទុករបស់អាជ្ញាធរក្រោមអាណាព្យាបាល ការខូចខាតបង្កឡើងដោយអាណាព្យាបាលត្រូវតែជួសជុលដោយឃុំ។ ប៉ុន្តែ សមូហភាពក្រោមអាណាព្យាបាលមានសិទ្ធិ ធ្វើបណ្តឹងឧបាស្រ័យប្រឆាំងទាស់ នឹងអាជ្ញាធរអាណាព្យាបាល កាលណាអាជ្ញាធរនេះប្រព្រឹត្តនូវកំហុសធ្ងន់ក្នុងការប្រើអំណាចរបស់ខ្លួន។

---

[៨៩] ឡៅក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៣

ប្រសិនបើ អាជ្ញាធរអាណាព្យាបាលមិនធ្វើសកម្មភាព ឬ ទៅហួសពីអំណាចរបស់ខ្លួននឹងមានការលុបចោល ឬ ការបន្ទន់នៃការទទួលខុសត្រូវរបស់សមូហភាពមូលដ្ឋាន[៨៥]។

**ខ.៣.បុគ្គលឯកជនដែលគ្រប់គ្រងសេវាសាធារណៈ**

បុគ្គលដែលគ្រប់គ្រងសេវាសាធារណៈ ត្រូវចាត់ទុកថាទទួលខុសត្រូវពីសកម្មភាពនៃសេវា-សាធារណៈ។ ប៉ុន្តែក្នុងករណីអសាធនភាពនៃបុគ្គលឯកជន បុគ្គលសាធារណៈអន្តរាគមន៍ជាបន្ទាប់បន្សំ។ ខ ការងារសាងសង់បុគ្គលសាធារណៈជាម្ចាស់ការ្យ បានប្រគល់ទៅឱ្យអ្នកម៉ៅការ ពួកគេទាំងអស់គ្នាអាចត្រូវចោទប្រកាន់ដាច់ដោយឡែកពីគ្នា ឬ រួមគ្នា។ ជនរងគ្រោះមានជម្រើស[៨៦]។

ជំហានបន្ទាប់ គឺជាដំណាក់កាល នីតិវិធីបណ្ដឹងក្នុងការទទួលខុសត្រូវលើអំពើដែលជាកំហុសរបស់មន្ត្រីរាជការ។

## កថាភាគទី២

## នីតិវិធីនៃបណ្ដឹងក្នុងការទទួលខុសត្រូវ

ជនរងគ្រោះ អាចធ្វើការដាក់ពាក្យបណ្ដឹង ទៅកាន់ស្ថាប័នមានសមត្ថកិច្ចណាមួយ ដើម្បីឱ្យជួយដោះស្រាយនូវវិវាទរបស់ខ្លួន ប្រកបដោយតម្លាភាព និង យុត្តិធម៌។ បន្ទាប់ពីមានសេចក្ដី-សម្រេចរបស់ស្ថាប័នមានសមត្ថកិច្ច ដោះស្រាយលើពាក្យបណ្ដឹង (ក) រដ្ឋ ឬ ស្ថាប័នសាមី ត្រូវត្រួតពិនិត្យលើសេចក្ដីសម្រេច បើសេចក្ដីសម្រេចបង្ហាញថា កំហុសនោះ ជាកំហុសក្រសួង រដ្ឋ ឬ ស្ថាប័នសាមី ត្រូវទទួលខុសត្រូវលើសំណងសព្វសារពើ ដល់ជនរងគ្រោះ (ខ)។ មានអំពើខ្លះដែលបង្កដោយមន្ត្រីរាជការដែរ ប៉ុន្តែ នោះឱ្យមានការកាត់បន្ថយការទទួលខុសត្រូវ (គ) ដោយហេតុផ្សេងៗ ហើយអំពើខ្លះទៀត នាំឱ្យរដ្ឋគេចផុតពីការទទួលខុសត្រូវតែម្ដង (ឃ)។

បន្ទាប់ពីរដ្ឋ ឬ ស្ថាប័នសាមី សងការខូចខាតដល់ជនរងគ្រោះហើយ រដ្ឋ ឬ ស្ថាប័នសាមី អាចធ្វើការវិនិច្ឆ័យលើកំហុសរបស់មន្ត្រីរាជការនោះ បើជាកំហុសស្រាល នាំឱ្យមន្ត្រីរាជការ អាចគេចផុតពីការទទួលខុសត្រូវ ក្នុងការសងសំណងទៅរដ្ឋវិញ ផ្ទុយទៅវិញ ប្រសិនបើ ជាកំហុសធ្ងន់របស់មន្ត្រី-រាជការ ត្រូវប្រឈមមុខ នឹងសំណងទៅរដ្ឋ ឬ ស្ថាប័នសាមីវិញដែរ (ង)។

**ក.ស្ថាប័នមានសមត្ថកិច្ច ដោះស្រាយលើពាក្យបណ្ដឹង**

មាត្រា៥១ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល អនុញ្ញាតឱ្យមានការចោទប្រកាន់មន្ត្រីរាជការណាម្នាក់ ទទួលខុសត្រូវដោយបុគ្គលណាម្នាក់បាន លុះត្រាតែមានការយល់ព្រមពីក្រសួងសាមី។ ប្រព័ន្ធនេះហៅថា ជាការធានានៃមន្ត្រីរាជការ ដែលដាក់ព្រំដែនកំណត់យ៉ាងពិសេស។ល។ ការវិវត្តនៃច្បាប់ក្រោយមកទៀតបានញែកឱ្យដាច់រវាងកំហុសជាបុគ្គល និង កំហុស

---

[៨៥] ឡឿក ពិដោរ, ទ្រឹស្ដីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៣, ៣០៤

[៨៦] ឡឿក ពិដោរ, ទ្រឹស្ដីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៤

ចំពោះមុខក្រសួង ប៉ុន្តែ ក្នុងគោលដៅការពារជនរងគ្រោះ។ ហេតុនេះហើយ សញ្ញាណនៃកំហុសចំពោះមុខក្រសួង ត្រូវបានបកស្រាយយ៉ាងទូលំទូលាយខ្លាំងណាស់។ អាស្រ័យដូចនេះផងដែរ សិទ្ធិជ្រើសរើស ត្រូវបានទទួលស្គាល់ចំពោះជនរងគ្រោះ ក្នុងករណីមានការត្រួតគ្នានៃកំហុស ឬ ក្នុងករណីមានការត្រួតគ្នានៃការទទួលខុសត្រូវ។ ក្នុងសម្មតិកម្មទាំងនេះ ជនរងគ្រោះមានជម្រើសរវាងការចោទប្រកាន់ភ្នាក់ងារ នៅចំពោះមុខតុលាការដែលអនុវត្តនីតិឯកជន និង ការចោទប្រកាន់រដ្ឋបាលនៅចំពោះមុខតុលាការរដ្ឋបាលដែលអនុវត្តនីតិរដ្ឋបាល[៨៧]។

ស្ថាប័នមានសមត្ថកិច្ច ក្នុងការទទួលពាក្យបណ្តឹង ក៏ដូចជាដោះស្រាយលើពាក្យបណ្តឹង មានបីស្ថាប័ន[៨៨] គឺ៖ សមត្ថកិច្ចក្នុងអង្គការនីតិបញ្ញត្តិ (ក.១) សមត្ថកិច្ចក្នុងអង្គការនីតិប្រតិបត្តិ (ក.២) និង សមត្ថ-កិច្ចក្នុងអង្គការតុលាការ (ក.៣)។

**ក.១.សមត្ថកិច្ចក្នុងអង្គការនីតិបញ្ញត្តិ**

នៅក្នុងស្ថាប័ននីតិបញ្ញត្តិ មានអង្គភាពចំនួន២ ដែលមានភារកិច្ចទទួលពាក្យបណ្តឹងពីប្រជា-ពលរដ្ឋ ពាក់ព័ន្ធនឹងបញ្ហាមិនប្រក្រតីនានា ដែលបានកើតឡើង។ អង្គភាពនោះមានដូចជា ៖ គណៈ-កម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា (ក.១.១.) គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និង អង្កេតរបស់ព្រឹទ្ធសភា (ក.១.២.)។

**ក.១.១.គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

ចំណោមគណៈកម្មការទាំង១០ នៃរដ្ឋសភា គណៈកម្មការនេះ ជាគណៈកម្មការទី១។ គណៈ-កម្មការនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្របគ្នានឹងគណៈកម្មការនានានៃរដ្ឋសភាដែរ ដោយយោងតាមមាត្រា៩៤ នៃរដ្ឋធម្មនុញ្ញ និង ប្រការ៦ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា[៨៩]។ គណៈកម្មការទី១ នៃរដ្ឋសភា មានតួនាទីស្នូលសំខាន់ៗ មួយចំនួនដូចជា៖

- ពិនិត្យ សិក្សាសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ការងារទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ការអង្កេត និង កិច្ចការទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង កិច្ចការផ្សេងៗទៀត ដែលគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានប្រគល់ជូន។
- អញ្ជើញតំណាងរាជរដ្ឋាភិបាល ឬ អ្នកស្នើច្បាប់ ដែលជាម្ចាស់សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ឬ បញ្ហានានាដើម្បីចូលមកបំភ្លឺជូនគណៈកម្មការ។

---

[៨៧] ឡើក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ១៩៤

[៨៨] សួន ឱសថ, កិច្ចសន្យារដ្ឋបាល ជាមួយនីតិវិធីរដ្ឋបាល, (ភ្នំពេញ, ព.ស.២៥៥៥ គ.ស.២០១១), ទំព័រ៤៩៥

[៨៩] វ៉ាន់ ច័ន្ទតារា, នីតិសិទ្ធិមនុស្ស, (ភ្នំពេញ, ២០១៤), ទំព័រ២២០

- តាមដាន អង្កេត ការគោរពសិទ្ធិមនុស្សនៅកម្ពុជាឱ្យបានសមស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- ទទួលពាក្យបណ្ដឹង ធ្វើការសម្របសម្រួល ឬ អន្តរាគមន៍ទៅអាជ្ញាធរ និង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយជូនម្ចាស់បណ្ដឹង តាមរយៈប្រធានរដ្ឋសភា។
- ចំពោះពាក្យបណ្ដឹងទាំងឡាយណាដែលមានលក្ខណៈមិនត្រឹមត្រូវតាមច្បាប់ ឬ អាជ្ញាធរ និង ស្ថាប័នពាក់ព័ន្ធបាននឹងកំពុងដោះស្រាយនោះ គណៈកម្មការនឹងជូនដំណឹងនេះទៅម្ចាស់បណ្ដឹងវិញ។
- ចុះតាមដានលើពាក្យបណ្ដឹងដែលគណៈកម្មការបានអន្តរាគមន៍ និង បញ្ហាដែលប៉ះពាល់សិទ្ធិប្រជាពលរដ្ឋ ព្រមទាំងសំណូមពររបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននានា រួចធ្វើរបាយការណ៍ជូនប្រធានរដ្ឋសភា[៩០]។

យោងតាមសេចក្ដីសម្រេចខាងលើនេះ គណៈកម្មការទី១ នៃរដ្ឋសភា ក៏មានតួនាទីភារកិច្ចក្នុងការទទួលពាក្យបណ្ដឹង និង ដោះស្រាយពាក្យបណ្ដឹងជូនប្រជាពលរដ្ឋ ក្នុងករណីដែលមានបញ្ហាណាមួយ កើតចេញពីអំពើមិនសមរម្យរបស់រដ្ឋ។ មិនត្រឹមតែប៉ុណ្ណោះ គណៈកម្មការទី១ នៃរដ្ឋសភា អាចធ្វើការអញ្ជើញមន្ត្រីអនុវត្តន៍ ដែលពាក់ព័ន្ធមកធ្វើការស្រាយបំភ្លឺបញ្ហាផ្សេងៗ ជូនប្រជាពលរដ្ឋ។ ជាក់ស្ដែង កាលពីរសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ លោក អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រួមជាមួយមន្ត្រីមួយចំនួនទៀត បានចូលបំភ្លឺជូន គណៈកម្មការទី១ នៃរដ្ឋសភា ដែលមានលោក **អេង ឆៃអ៊ាង** ជាប្រធាន។ ក្នុងការបំភ្លឺ ប្រធានគណៈកម្មការទី១ នៃរដ្ឋសភា បានលើកប្រធានបទ៤ ដើម្បីសួរទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដូចជា: **១**-ការចាប់ ការឃុំខ្លួន និង ការផ្ដន្ទាទោសអនីតិជន **២**-ការឃុំខ្លួនលើសនីតិវិធីកំណត់ **៣**-កំហុសនៃការអនុវត្តនីតិវិធី និង ការមិនអនុវត្តតួនាទីរបស់ចៅក្រម និង ព្រះរាជអាជ្ញា ជុំវិញករណីវិវាទដីធ្លី និង វិវាទផ្សេងទៀត **៤**-ឯករាជ្យភាពរបស់តុលាការ និង ការជ្រៀតជ្រែកជាដើម[៩១]។

នៅមានករណីផ្សេងៗទៀត ដែលគណៈកម្មការទី១ នៃរដ្ឋសភា បានធ្វើការកោះអញ្ជើញរដ្ឋមន្ត្រី មួយចំនួនមកធ្វើការសាកសួរ ដូចជាកាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ រដ្ឋមន្ត្រីក្រសួងបរិស្ថាន លោក **សាយ សំអាល់** និង មន្ត្រីក្រោមឱវាទ បានចូលបំភ្លឺផ្ទាល់មាត់ជូនគណៈកម្មការទី១ នៃរដ្ឋសភា ដែលដឹកនាំដោយលោក **អេង ឆៃអ៊ាង** ប្រធានគណៈកម្មការទី១ នៃរដ្ឋសភា។ ជាចុងក្រោយគណៈកម្មការទី១ នៃរដ្ឋសភា បានស្នើសុំលោករដ្ឋមន្ត្រីលើ**៤ ចំណុច** : **១**-សុំឱ្យលោករដ្ឋមន្ត្រី

---

[៩០] សេចក្ដីសម្រេចស្ដីពី តួនាទី និង ភារកិច្ចរបស់គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤, ប្រការ៣

[៩១] គេហៈទំព័រ៖ http://freshnewsasia.com:81/index.php/en/localnews/20759-2016-03-25-07-43-25.html(ដកស្រង់ ១៥ ឧសភា ២០១៨)

ពិនិត្យលទ្ធភាពក្នុងការឈ្មៀលដីជូនប្រជាពលរដ្ឋដែលនៅសល់ប្រមាណ៣១៨ ហិចតា នៅស្រុកគីរីសាគរ ស្រុកបទុមសាគរ ដែលកំពុងវិវាទជាមួយប្រជាជន ហើយពួកគាត់មិនទាន់បានជួយទំនាក់ទំនង ហើយមិនទាន់បានចាកចេញ។ **២**-សូមកុំឱ្យមានការបង្ខិតបង្ខំ ឬក៏ ប្រើប្រាស់វិធានការគំរាមកំហែង ឬ ប្រើប្រាស់តុលាការចំពោះអ្នកដែលមិនទាន់ចាកចេញទាំង៣១៨ គ្រួសារនេះ គឺធ្វើយ៉ាងណាឱ្យមានការជជែកគ្នា រកដំណោះស្រាយដោយសន្តិវិធី តាមកិច្ចសន្យារវាងរដ្ឋាភិបាលជាមួយនឹងក្រុមហ៊ុន និង សេចក្តីជូនដំណឹងចុងក្រោយ របស់រាជរដ្ឋាភិបាលលេខ៣០៥។ **៣**-សុំឱ្យក្រសួងបរិស្ថានធ្វើការស៊ើបនូវភាពមិនប្រក្រតី ក្នុងការដោះស្រាយផលប៉ះពាល់កន្លងមក ព្រោះយោងតាមរបាយការណ៍ របស់សង្គមស៊ីវិលបានបង្ហាញឲ្យឃើញថា មានការពុករលួយមានការរើសអើង ទាក់ទងនឹងដំណោះស្រាយបញ្ហាផលប៉ះពាល់នោះ។ **៤**-សុំឱ្យមានរបាយការណ៍ឯកសារពាក់ព័ន្ធនឹង ប្រជាពលរដ្ឋ ដែលបានទទួលសំណងពីក្រុមហ៊ុនមកគណៈកម្មការទី១ រដ្ឋសភា[៩២]។

**ក.១.២.គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និង អង្កេតនៃព្រឹទ្ធសភា**

បណ្តាគណៈកម្មការទាំង១០ របស់ព្រឹទ្ធសភា គណៈកម្មការនេះ ជាគណៈកម្មការទីមួយរបស់ព្រឹទ្ធសភាដែលទទួលបន្ទុកការងារវិស័យសិទ្ធិមនុស្ស និង ច្បាប់។ គណៈកម្មការនេះ បង្កើតឡើងតាមសេចក្តីសម្រេចលេខ០៣៥/៨៩៩/ពស/សរ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩។ គណៈកម្មការមានតួនាទី និង ភារកិច្ចមួយចំនួនដូចជា៖

- ទទួលពាក្យបណ្តឹងទូទៅពីបុគ្គល អ្នកតំណាងពីក្រុមអង្គការ ឬ សមាគមនានា។
- ពិនិត្យពាក្យបណ្តឹងធ្វើការសម្របសម្រួលដើម្បីដោះស្រាយ រាល់ពាក្យបណ្តឹងដោយសហប្រតិបត្តិការជាមួយនឹងស្ថាប័ន ឬ សមត្ថកិច្ចនានា។
- ផ្តួចផ្តើមគំនិតធ្វើសវនាការជាសាធារណៈ ពីសេចក្តីព្រាងច្បាប់ ឬ បញ្ហានានា ពាក់ព័ន្ធវិស័យសិទ្ធិមនុស្ស[៩៣]។ល។

ក្រៅពីអង្គការនីតិបញ្ញត្តិ សមត្ថកិច្ចរបស់អង្គការនីតិប្រតិបត្តិ ក៏មានតួនាទីទទួល និង ដោះស្រាយពាក្យបណ្តឹងជូនប្រជាពលរដ្ឋដែរ។

**ក.២.សមត្ថកិច្ចក្នុងអង្គការនីតិប្រតិបត្តិ**

នៅក្នុងករណីរឿងវិវាទលើវិស័យកិច្ចសន្យារដ្ឋបាល ឬ រឿងក្តីរដ្ឋបាលផ្សេងទៀត ក៏មានធ្វើការដោះស្រាយក្នុងរដ្ឋអំណាចមូលដ្ឋានខេត្ត-ក្រុង រហូតដល់ថ្នាក់លើដែរ។ ក្នុងរដ្ឋាភិបាលគេឃើញមានកន្លែងទទួលដោះស្រាយពាក្យបណ្តឹងបរិហារ និង បណ្តឹងតវ៉ាផ្នែករដ្ឋបាលរបស់ប្រជាពលរដ្ឋមានបីកន្លែងគឺ៖ ១-រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា ក្នុងក្របខណ្ឌទីស្តីការគណៈរដ្ឋ-

[៩២] គេហៈទំព័រចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥៖ http://kampucheathmey.com/kpt/archives/6574(ដកស្រង់ ១៥ ឧសភា ២០១៨)

[៩៣] វ៉ាន់ ច័ន្ទតារា, នីតិសិទ្ធិមនុស្ស, (ភ្នំពេញ, ២០១៤), ទំព័រ២១៩ និង ទំព័រ២២០

មន្ត្រី; ២-ក្រសួងមហាផ្ទៃ (នាយកដ្ឋានអធិការកិច្ច); ៣-អគ្គលេខាធិការដ្ឋានអធិការកិច្ចរាជរដ្ឋាភិបាល ក្នុងក្របខណ្ឌទីស្ដីការគណៈរដ្ឋមន្ត្រី ចំណុះឱ្យរាជរដ្ឋាភិបាល មានភារកិច្ចទទួលដោះស្រាយពាក្យ-បណ្ដឹងបរិហាររបស់ប្រជាពលរដ្ឋដែលរដ្ឋាភិបាលប្រគល់ឱ្យ[៩៤]។

ក្រៅពីស្ថាប័នទាំងបីខាងលើនេះ ក្នុងអង្គការនីតិប្រតិបត្តិក៏មានស្ថាប័នមួយចំនួនទៀតទទួលដោះស្រាយលើពាក្យបណ្ដឹងជាពិសេសទាក់ទងនឹងសិទ្ធិមនុស្ស ដូចជា គណៈកម្មាធិការសិទ្ធិ-មនុស្សកម្ពុជា (ក.២.១.) ជាដើម។ ក្នុងក្របខណ្ឌនៃក្រសួងមហាផ្ទៃ ក៏មានផងដែរការិយាល័យប្រជា-ពលរដ្ឋ (ក.២.២.) ដែលមានសមត្ថកិច្ចទទួលពាក្យបណ្ដឹងតវ៉ា និង ផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ ក្រុមហ៊ុន សហគ្រាស និង អង្គការសង្គមស៊ីវិល ក្នុងករណីមានភាពមិនប្រក្រតី ឬ កំហុសឆ្គងរបស់បុគ្គលិកដែលបម្រើការងារក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ[៩៥]។

**ក.២.១.គណៈកម្មាធិការ សិទ្ធិមនុស្សកម្ពុជា**

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាគណៈកម្មាធិការមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកវិស័យសិទ្ធិមនុស្សត្រូវបានបង្កើតឡើង ដោយព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ និង ព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៦៣ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៨។

គណៈកម្មាធិការនេះ មានតួនាទីក្នុងការការពារលើកស្ទួយអភិវឌ្ឍន៍សិទ្ធិមនុស្ស លទ្ធិប្រជា-ធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និង ពាក្យបណ្ដឹងតវ៉ានានា។ មាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៦៣ ចែងថា គណៈកម្មាធិការសិទ្ធិមនុស្សមាន២ អគ្គនាយកដ្ឋាន ដែលក្នុងនោះ មានអគ្គនាយកដ្ឋានរដ្ឋបាល និង ពាក្យបណ្ដឹង ទទួលបន្ទុកការងាររដ្ឋបាល ហិរញ្ញវត្ថុគ្រប់គ្រង និង សេវានានាបម្រើឱ្យគណៈកម្មាធិការទំនាក់ទំនងសាធារណៈទទួលពាក្យបណ្ដឹងតវ៉ារៀបចំបណ្ដាញ និង បណ្ដុះបណ្ដាលមន្ត្រីឃ្លាំមើលសិទ្ធិមនុស្ស ពិសេសលើកទឹកចិត្តដោះស្រាយទំនាស់តាមរបៀបសម្រុះសម្រួល[៩៦]។

**ក.២.២.ការិយាល័យប្រជាពលរដ្ឋ**

សេចក្ដីសម្រេចលេខ១២ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ បានតម្រូវឱ្យបង្កើតឡើងនូវការិយាល័យប្រជាពលរដ្ឋ នៅក្នុងក្រុង ស្រុក ខណ្ឌទាំងអស់ដែលមានការិយាល័យច្រកចេញចូលតែមួយ។

[៩៤] សួន ឱសថ, កិច្ចសន្យារដ្ឋបាល ជាមួយនីតិវិធីរដ្ឋបាល, (ភ្នំពេញ, ព.ស.២៥៥៥ គ.ស.២០១១), ទំព័រ៤៩៨

[៩៥] ក្រសួងមហាផ្ទៃ, ការិយាល័យប្រជាពលរដ្ឋ, បោះពុម្ពលើកទី២, (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១០), ទំព័រ១

[៩៦] វ៉ាន់ ច័ន្ទតារា, នីតិសិទ្ធិមនុស្ស, (ភ្នំពេញ, ២០១៤), ទំព័រ២២១ និង ២២២

ការបង្កើតការិយាល័យប្រជាពលរដ្ឋនេះ គឺដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅក្រុង ស្រុក ខណ្ឌ ហើយមានសមត្ថកិច្ចទទួលពាក្យបណ្តឹងតវ៉ា និង ផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ អាជីវករ ពាណិជ្ជករ ក្រុមហ៊ុន សហគ្រាស និង អង្គការសង្គមស៊ីវិលនានា ក្នុងករណីមានភាពមិនប្រក្រតី ឬ កំហុសឆ្គងណាមួយរបស់មន្ត្រីរាជការ បុគ្គលិក ដែលបម្រើការងារក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនោះ[៩៧]។

ការិយាល័យប្រជាពលរដ្ឋ មានតួនាទីភារកិច្ច ក្នុងការដោះស្រាយវិវាទ របស់ប្រជាពលរដ្ឋ។ ក្រោយការដាក់ពាក្យបណ្តឹង ការិយាល័យនឹងដំណើរការនីតិវិធី ព្រមទាំងនីតិវិធីសម្រុះសម្រួល ដល់ប្រជាពលរដ្ឋ យ៉ាងល្អប្រសើរ។ ថ្វីត្បិតតែអង្គការនីតិប្រតិបត្តិជួយសម្រួលឱ្យមានភាពធូរស្រាល ដល់អង្គការតុលាការក៏ដោយ ការសម្រេចជាចុងក្រោយជាសមត្ថកិច្ចរបស់តុលាការដដែល។ ក្នុងករណីភាគីណាមួយមិនសុខចិត្តទទួលអនុវត្តសេចក្តីសម្រេច របស់អង្គការមានសមត្ថកិច្ចដោះស្រាយ។ ប៉ុន្តែ ក្នុងការងារជាក់ស្តែងកន្លងមក ការទទួលពិនិត្យ ដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហារ ជាលក្ខណៈចំហក្តី ជាអនាមិកក្តី នៅអគ្គលេខាធិការកិច្ច របស់រាជរដ្ឋាភិបាលទទួលការងារ ពីរាជរដ្ឋាភិបាលប្រគល់ឱ្យធ្វើការដោះស្រាយបានសម្រេចជាស្ថាពរ ដោយសុំយោបល់សម្រេចដ៏ខ្ពង់ខ្ពស់ ពីនាយករដ្ឋមន្ត្រី ទៅលើសំណូមពរដែលមានភស្តុតាង និង ឯកសារជាក់ស្តែង លើកឡើងដោយគណៈប្រតិភូចុះអង្កេតស្រាវជ្រាវ[៩៨]។

ក្រៅពីអង្គការនីតិប្រតិបត្តិ មានអង្គការតុលាការ មានតួនាទីដោះស្រាយពាក្យបណ្តឹងនានាជូនប្រជាពលរដ្ឋ ដែលស្របទៅតាមនីតិវិធីស៊ីវិលដែរ។

**ក.៣.សមត្ថកិច្ចក្នុងអង្គការតុលាការ**

ដូចបានបញ្ជាក់ខាងលើរួចហើយ ក្នុងមាត្រា៣៩ នៃរដ្ឋធម្មនុញ្ញថា " ការដោះស្រាយពាក្យបណ្តឹង និង ការជួសជុលការខូចខាត ត្រូវស្ថិតនៅលើសមត្ថកិច្ចរបស់តុលាការ "។ ការសន្មតមុខនាទីត្រូវពង្រីកបន្ថែមទៀតតាមបញ្ញត្តិនៃមាត្រា១០៨ និង ១១១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមមាត្រា១២៨ កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តថា ៖ *អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ*។ ក្នុងមាត្រា៤ នៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ ក៏បានបញ្ញត្តដែរថា៖ *សាលាជម្រះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ គ្របដណ្តប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង*។

[៩៧] ក្រសួងមហាផ្ទៃ, សៀវភៅណែនាំស្តីពី នីតិវិធី និង បែបបទនៃការសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ,បោះពុម្ពលើកទី២, (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១០), ទំព័រ១

[៩៨] សួន ឱសថ, កិច្ចសន្យារដ្ឋបាល ជាមួយនីតិវិធីរដ្ឋបាល, (ភ្នំពេញ, ព.ស.២៥៥៥ គ.ស.២០១១), ទំព័រ៤៩៨

ដោយអនុវត្តទៅតាមបញ្ញត្តិ រដ្ឋធម្មនុញ្ញច្បាប់ស្តីពីការកែតម្រូវ ការរៀបចំតុលាការនៅកម្ពុជា បានប្រគល់ឱ្យទៅតុលាការខេត្ត-ក្រុង គឺជាសាលាដំបូងមានសមត្ថកិច្ច ដើម្បីកាត់សេចក្តីជាអំណាចទីមួយចំពោះរឿងក្តីរដ្ឋបាល លើកលែងតែការប្តឹងតវ៉ាក្នុងការរំលោភអំណាច[៩៩]។

មាត្រា៨៩ វាក្យខណ្ឌទី៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការចែងថា " *នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ការជំនុំជម្រះក្តីរឿងរដ្ឋបាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពី នីតិវិធីរដ្ឋប្បវេណី និង បទប្បញ្ញត្តិច្បាប់ផ្សេងៗទៀតជាធរមាន* "។

**ខ.ការជួសជុលព្យសនកម្មដល់ជនរងគ្រោះ**

ការជួសជុលព្យសនកម្មដល់ជនរងគ្រោះ មានរូបមន្ត និង វិធីគណនាសំណងការខូចខាត (ខ.១.) មួយចំនួនត្រូវអនុលោមតាមក្រមរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជា។ ចំពោះការទាមទារសំណងនៃការខូចខាតនេះ បុគ្គលក្រៅពីជនរងគ្រោះ ក៏អាចធ្វើការទាមទារបានផងដែរ (ខ.២.) ដោយផ្អែកលើការប៉ះពាល់ផ្នែកសតិអារម្មណ៍។ កាលបរិច្ឆេទនៃការវាយតម្លៃសំណង និង អាជ្ញាយុកាល (ខ.៣.) ក៏ជាចំណុចសំខាន់ក្នុងដំណើរការនីតិវិធី នៃការប្តឹងទាមទាររបស់ជនរងគ្រោះផងដែរ។ រីឯការអនុវត្តសេចក្តីសម្រេចរបស់តុលាការ (ខ.៤.) មានលក្ខណៈដូចទៅនឹងតុលាការស៊ីវិលដែរ។

**ខ.១.រូបមន្ត និង វិធីគណនាសំណងការខូចខាត**

ប្រភេទនៃសំណង (ខ.១.១.) ដែលជនរងគ្រោះអាចទាមទារបាន អាចសំណងជាវត្ថុ ប្រាក់ ឬ ជានិមិត្តរូប ទៅតាមទំហំនៃព្យសនកម្ម ដែលជាលទ្ធផល ក្រោយនីតិវិធីគណនាសំណងការខូចខាត (ខ.១.៤.)។ ព្យសនកម្មទាំងអស់មិនមែនសុទ្ធតែត្រូវបានជួសជុលទេ គឺត្រូវមើលលើលក្ខណៈនៃការសងការខូចខាត (ខ.១.២.) ព្រមទាំងកំណត់ពីទម្រង់នៃការសង និង ការប្រាក់ (ខ.១.៣.)ឱ្យបានច្បាស់លាស់ផងដែរ។

**ខ.១.១.ប្រភេទនៃសំណង**

គេត្រូវរកបៀបណាដែលប្រសើរ សម្រាប់សងកាខូចខាត ឱ្យបានត្រឹមត្រូវ។ គេមានរូបមន្តបីយ៉ាង៖ សងជាវត្ថុ សងជាប្រាក់ សងជានិមិត្តរូប។ ការសងជាវត្ថុ សម្រាប់ការបាត់បង់វត្ថុ ការសងជាប្រាក់ សម្រាប់ការខូចខាតដល់រូបរាងកាយ ឬ ការខូចខាតដល់ផ្លូវចិត្ត។ ការសងជានិមិត្តរូប គឺសម្រាប់ផ្លូវចិត្តសុទ្ធ[១០០]។ យោងតាមមាត្រា៥៧៥ នៃក្រមរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តថា៖ "*គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង ១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់។ ២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះ ត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យ*

[៩៩] សួន ឱសថ, កិច្ចសន្យារដ្ឋបាល ជាមួយនីតិវិធីរដ្ឋបាល, (ភ្នំពេញ, ព.ស.២៥៥៥ គ.ស.២០១១), ទំព័រ៤៩៨

[១០០] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្ស៊ំ ឡូទឹស,២០១២), ទំព័រ៣៧៦ និង ៣៧៧

*ហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន។ ៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជា សាធារណៈបាន"។*

សញ្ញាណខាងលើនេះ តាមលក្ខណៈទូទៅ ដោយឡែកចំពោះរដ្ឋ ឬ ក្រសួងសាមីវិញ ជនរង-គ្រោះអាចទាមទារបានតែការសងសំណូកចិត្តជាប្រាក់ប៉ុណ្ណោះ។ តាមធម្មតាចៅក្រម មិនមានអំណាចបង្ខំរដ្ឋបាលឱ្យធ្វើ ឬ មិនឱ្យធ្វើអ្វីមួយបានទេ ជួនកាលតាមផ្លូវអធិបញ្ញា ជួនកាលតាមផ្លូវពិន័យបង្ខំ។ តាមពិតការប្រគល់ចំនួនទឹកប្រាក់ រមែងសម្រេចបានតាមការពិន័យបង្ខំដោយប្រយោលក្នុងករណីដែលការពិន័យបង្ខំ នេះជំរុញរដ្ឋបាលឱ្យបញ្ចប់ពេលនៃការធ្វើសកម្មភាពរបស់ខ្លួន(១០១)។

**ខ.១.២.លក្ខណៈនៃការសងការខូចខាត**

រាល់ព្យសនកម្មដែលទទួលរងត្រូវជួសជុល ប៉ុន្តែ ចំពោះតែព្យសនកម្ម ដែលបានទទួលរងយ៉ាងពិតប្រាកដប៉ុណ្ណោះ។ ការជួលជុលមិនត្រូវបណ្តាលឱ្យមានការចំណេញមានបានណាមួយដល់ជនរងគ្រោះទេ។

- ការត្រួតគ្នានៃសំណងអាចធ្វើទៅបាន ប្រសិនបើ ចំនួនសរុបរបស់វាមិនលើសពីព្យសន-កម្មដែលបានទទួលរងយ៉ាងពិតប្រាកដ។ ក្នុងករណីផ្ទុយ ចៅក្រមនឹងកាត់បន្ថយចំនួនសរុប បើកឱ្យបុគ្គលសាធារណៈ របួតដល់ចំនួនទឹកប្រាក់ប្រហាក់ប្រហែលពិតប្រាកដ នៃការខូចខាត។
- ការជួសជុលព្យសនកម្ម ដែលបានបង្កឡើង ដោយមន្ត្រីរាជការម្នាក់ មានការដកតំណែងខុសច្បាប់ និង គិតពីកំហុសរៀងខ្លួន ដែលបានប្រព្រឹត្តឡើងដោយមន្ត្រីនេះ និង រដ្ឋបាល ហើយម៉្យាងទៀត គាត់ត្រូវទទួលបានចំនួនទឹកប្រាក់ ដែលគេបានធ្វើការងារជួសគាត់។
- ចៅក្រមអាចកាត់បន្ថយសំណង កាលណាហេតុដែលឱ្យសងបាននាំមកនូវផលវិបាកអនុគ្រោះដល់ជនរងគ្រោះ។ **ឧទាហរណ៍៖** ប្រភពចំនួនលើសដោយផ្ទាល់ ឬ ដោយប្រយោល(១០២)។

**ខ.១.៣.ទម្រង់នៃការសងការខូចខាត និង ការប្រាក់**

ការសងសំណូកចិត្តតាមធម្មតា ត្រូវធានាដោយការលើកជាទឹកប្រាក់។ កាលពីដើមចៅក្រមចូលចិត្តកាត់សេចក្តីឱ្យជាធនលាភ ដោយសាររូបិយវត្ថុមានស្ថិរភាព។ សព្វថ្ងៃនេះ ធនលាភប្រើតែចំពោះកុមារប៉ុណ្ណោះ។ ក្នុងករណីចៅក្រម មិនអាចវាយតម្លៃលើការខូចខាតនៅពេល ដែលខ្លួនកាត់សេចក្តី ចៅក្រមបញ្ជូនជនរងគ្រោះឱ្យទៅជួបរដ្ឋបាល។ ប៉ុន្តែ វិធីនេះមិនពេញចិត្តទេ ព្រោះវានាំឱ្យមានការពន្យារនីតិវិធី ក្នុងស្ថានភាពជួបញ្ជីកញ្ជាប់ ដែលភាគីមិនយល់ព្រមលើចំនួនទឹកប្រាក់សរុប។

(១០១) ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៥

(១០២) ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៥, ៣០៦

ដោយឡែកចំពោះការប្រាក់វិញ ប្រសិនបើ មានការសងយឺត ត្រូវប៉ះប៉ូវដល់រយៈពេលដែលកន្លងផុតទៅ រវាងការដាក់ពាក្យបណ្តឹង និង ការទូទាត់។ ការប្រាក់យឺតយ៉ាវនេះ យល់ព្រម ផ្តល់ឱ្យតែប្រសិនបើ មានការស្នើសុំប៉ុណ្ណោះ។ អត្រាការប្រាក់ត្រូវកំណត់តាមការអនុវត្តវិធាន នៃក្រមរដ្ឋប្បវេណី តាមអត្រាអបហារនៃធនាគារកណ្តាល។

- ការលើកការប្រាក់ត្រូវបានយល់ព្រមផ្តល់ឱ្យទាល់តែមានការស្នើសុំ យ៉ាងហោចណាស់ក៏ការប្រាក់ត្រូវបង់ក្នុងមួយឆ្នាំហើយមិនបានបង់។ មូលធនកម្មចាប់មានអានុភាពនៅកាលបរិច្ឆេទដែលស្នើសុំ។
- ត្រូវយកការប្រាក់ប៉ះប៉ូវ កាលណារដ្ឋបាលយឺតយ៉ាវហួសហេតុពេកក្នុងការអនុវត្ត[១០៣]។

**ខ.១.៤.វិធីគណនាសំណងការខូចខាត**

វិធីគណនាសំណងព្យសនកម្មនៃអំពើអនីត្យានុកូល របស់មន្ត្រីរាជការមានពីរគឺ៖ ព្យសនកម្មលើវត្ថុ (ខ.១.២.១.) និង ព្យសនកម្មលើរូបរាងកាយ (ខ.១.២.២.)។

**ខ.១.៤.១.ព្យសនកម្មលើវត្ថុ**

វត្ថុ សំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង[១០៤] វត្ថុ អាចជាចលនវត្ថុ និង អចលនវត្ថុ។ **អចលនវត្ថុ**សំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អគារ សំណង់ នាវា (មានចំណុះ២០តោនឡើង) ដំណាំ រុក្ខជាតិ ជាអាទ៍។ **ចលនវត្ថុ** សំដៅទៅលើ វត្ថុក្រៅពីអចលនវត្ថុ[១០៥] ។

ព្យសនកម្ម អាចកើតឡើង ចំពោះវត្ថុដែលបង្កឡើង ដោយមន្ត្រីរាជការ ដែលតម្រូវឱ្យរដ្ឋ ឬ ស្ថាប័នសាមី ត្រូវចេញមកទទួលខុសត្រូវ សងការខូចខាត ដែលបណ្តាលមកពីអំពើ របស់មន្ត្រីរាជការ។ សំណងការខូចខាតនេះ អាចជួសជុលតាមសភាពរបស់វត្ថុ ឬ សងជាប្រាក់។

**ការជួសជុលតាមសភាពវត្ថុ៖** រដ្ឋ ឬ ស្ថាប័នសាមី ត្រូវទទួលខុសត្រូវក្នុងការជួលជុលវត្ថុនោះ ឱ្យទៅតាមសភាពដើម ឬ រដ្ឋ ត្រូវចេញសោហ៊ុយជួសជុលវត្ថុនោះ ទៅតាមទំហំនៃព្យសនកម្ម[១០៦] ។

**ការសងជាប្រាក់៖** ក្នុងករណីដែលវត្ថុ ពុំអាចធ្វើបដិទានបាន រដ្ឋត្រូវទទួលខុសត្រូវ ចេញសងដែលជាតម្លៃតបស្នង នៃវត្ថុដែលបានខូចខាត ឬ បាត់បង់នោះ[១០៧] ។

---

[១០៣] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៧, ៣០៨

[១០៤] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៩

[១០៥] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១២០

[១០៦] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៧៥៩

[១០៧] ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៩

**ការសងជាវត្ថុ៖** ការសងជាវត្ថុ សម្រាប់ការបាត់វត្ថុ[១០៨]។ រដ្ឋ ឬ ស្ថាប័នសាមីមានជម្រើសមួយទៀត ដែលជាមធ្យោបាយតបស្នងព្យសនកម្ម ពោលគឺ រដ្ឋ ឬ ស្ថាប័នសាមី អាចចេញសងជាវត្ថុ ដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដើម។ **និទស្សន៍៖** បុគ្គលិកដឹកជញ្ជូន រថយន្ត-ក្រុងរបស់រដ្ឋម្នាក់ បានដឹកអ្នកដំណើរ ព្រមជាមួយនឹងអំបិល១ តោន ដែលជាសម្ភារៈរបស់អ្នកដំណើរនោះ។ ពេលកំពុងបើកបរ ដោយការធ្វេសប្រហែស របស់បុគ្គលិករដ្ឋ បានបណ្តាលឱ្យរថយន្តជ្រុលចង្កូតចូលទន្លេ ហើយធ្វើឱ្យអំបិលខូចខាតទាំងអស់។

ក្នុងករណីខាងលើនេះ រដ្ឋ ឬ ស្ថាប័នសាមី ពុំអាចធ្វើបដិទានអំបិលនោះបានទេ ដូច្នេះ រដ្ឋត្រូវចេញសងការខូចខាត ឬ សងជាអំបិល១ តោន ដែលមានប្រភេទ និង គុណភាពដូចដើម ឬ ប្រហាក់-ប្រហែល ដល់អ្នកដំណើរ។

ក្រៅពីព្យសនកម្មលើវត្ថុ រដ្ឋ ឬ ស្ថាប័នសាមី ក៏ត្រូវទទួលខុសត្រូវផងដែរ ទៅលើរូបរាងកាយរបស់ជនរងគ្រោះ។

#### ខ.១.៤.២. ព្យសនកម្មលើរូបរាងកាយ

ព្យសនកម្មលើរូបរាងកាយរបស់ជនរងគ្រោះ ដែលបង្កដោយមន្ត្រីរាជការ អាចនាំឱ្យប៉ះ-ពាល់ដល់ផ្លូវកាយ (ខ.១.៤.២.១.) និង ផ្លូវចិត្ត (ខ.១.៤.២.២.) នៃជនរងគ្រោះ។

##### ខ.១.៤.២.១.ផ្លូវកាយ

ព្យសនកម្មផ្លូវកាយ គឺជាការខូចខាតទាំងឡាយណា ដែលប៉ះពាល់ដល់រូបរាងកាយបុគ្គលដូចជា របួស ឈឺចាប់រូបកាយ និង ផ្លូវចិត្ត ព្យសនកម្មនៃប្រតិស្រពណ៍ ព្យសនកម្មនៃសោភ័ណភាព ឬ រហូតដល់អាយុជីវិតរបស់ជនរងគ្រោះ[១០៩]។

យោងតាមមាត្រា៧៦១ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តថា៖ "*បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់ក្នុងមាត្រានេះ ត្រូវរួមទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាល ដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននាពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល ជាអាទិ៍។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅ*

[១០៨] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្អូស្សុំ ឡូទីស,២០១២), ទំព័រ៣៧៧៩

[១០៩] ញឹក វុធ្និ, នីតិកាតព្វកិច្ច មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២,ទំព័រ ១៩

*ពេលព្យាបាល និង ពេលអនាគត*។ មាត្រាខាងលើនេះ បង្ហាញពីការខាតបង់របស់ជនរងគ្រោះផ្សេងៗ នៅពេលមានព្យសនកម្ម។ នៅមានការចំណាយផ្សេងទៀត ដូចជា៖ សោហ៊ុយព្យាបាល សោហ៊ុយធ្វើដំណើរទៅមន្ទីរពេទ្យ ការចំណាយផ្សេងៗអំឡុងពេលសម្រាកនៅពេទ្យ សោហ៊ុយមើលថែរក្សា របស់គិលានុបដ្ឋាក សោហ៊ុយបុណ្យសព សោហ៊ុយព្យាបាលនានា ដែលអាចកើតមានឡើង នាពេលអនាគតជាអាទិ៍[១១៧]។

**សោហ៊ុយព្យាបាល៖** រាល់ការចំណាយទាំងឡាយណា ដែលពាក់ព័ន្ធនឹងស្ថានភាព នៃព្យសនកម្ម កើតចេញពីកំហុសផ្ទាល់របស់មន្ត្រីរាជការ រដ្ឋ ឬ ស្ថាប័នសាមី ត្រូវធានារ៉ាប់រងលើសោហ៊ុយព្យាបាលទាំងអស់។ ក្នុងករណីដែលព្យសនកម្មទាំងឡាយណា កើតឡើងមិនផ្ទាល់ជាមួយអំពើរបស់មន្ត្រីរាជការ រដ្ឋ ឬ ស្ថាប័នសាមី មិនទូទាត់សងឡើយ។ **ឧទាហរណ៍៖** មុនពេលមានព្យសនកម្ម ជនរងគ្រោះបាក់ធ្មេញ៣ ដើម ក្រោយពេលមានព្យសនកម្ម ជនរងគ្រោះបាក់ថែម៣ ដើមទៀត ពេលព្យាបាល ជនរងគ្រោះបានរាប់គិតទាំងការបាក់ធ្មេញមុនបង្កអំពើ ក្នុងករណីនេះ រដ្ឋ ឬ ស្ថាប័នសាមី មិនទទួលរ៉ាប់រង សំណងដែលបានកើតមិនផ្ទាល់ឡើយ។

**សោហ៊ុយធ្វើដំណើរទៅមន្ទីរពេទ្យ៖** ក៏ជាការទទួលខុសត្រូវរបស់រដ្ឋ ឬ ស្ថាប័នសាមីផងដែរ ដូចជាថ្លៃធ្វើដំណើរទាំងទៅ និង មក ម្តង ឬ ពីរដង ទៅតាមចំនួននៃការធ្វើដំណើរនោះ។

**ការចំណាយផ្សេងៗអំឡុងពេលសម្រាកនៅពេទ្យ៖** គឺជាការចំណាយទាំងឡាយណា ដែលប្រើប្រាស់ដល់ប្រយោជន៍ របស់ជនរងគ្រោះ ក្នុងអំឡុងពេលសម្រាកព្យាបាល។

**សោហ៊ុយព្យាបាលនានាដែលអាចកើតមានឡើងនាពេលអនាគត៖** ព្យសនកម្មដែលកើតឡើងនាពេលអនាគត ក៏ជាការទទួលខុសត្រូវរបស់រដ្ឋ ឬ ស្ថាប័នសាមីផងដែរ។ **ឧទាហរណ៍៖** គ្រោះ-ថ្នាក់បែកក្បាល។ រយៈពេល១ ខែក្រោយមក ព្យសនកម្មដែលកើតចេញពីអំពើរបស់រដ្ឋនេះ បានបណ្តាលឱ្យក្លាយទៅជា ជំងឺមហារីកខួរក្បាល ដូច្នេះ រដ្ឋ ឬ ស្ថាប័នសាមី ត្រូវធានារ៉ាប់រង លើការចំណាយ ការព្យាបាល នាពេលអនាគតនេះ។

**ប្រាក់ចំណូលដែលមិនអាចទទួលបាន នៅពេលអនាគត ដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល៖** ត្រង់ចំណុចនេះ មានលក្ខណស្មុគស្មាញ ដែលក្រមរដ្ឋប្បវេណី ចង់បង្ហាញ ពីការបាត់បង់សមត្ថភាពការងារ បន្ទាប់ពីមានព្យសនកម្ម។

ស្ថានភាពនេះលំបាកក្នុងការគណនាអនុបាត នៃការបាត់បង់សមត្ថភាពក្នុងការធ្វើការ ប្រសិនបើ ជនរងគ្រោះមិនអាចធ្វើចលនាបាន និង មិនអាចធ្វើការបានទាំងស្រុង យើងអាចចាត់ទុកថា ការបាត់បង់សមត្ថភាពធ្វើការទាំងស្រុង។ ប៉ុន្តែ ប្រសិនបើ ជនរងគ្រោះ អាចធ្វើចលនាដោយ

[១១៧] ក្រសួងយុត្តិធម៌ ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ផ្នែកសិក្ខាសាលគណៈមេធាវី (តូច) លើកទី២ ប្រធានបទ: អំពើអនីត្យានុកូលការគណនាសំណងនៃការខូចខាត ថ្ងៃទី០៥ មិថុនា ឆ្នាំ២០១៤, ទំព័រ២២០

លំបាក ហើយគាត់អាចបន្តការងាររបស់គាត់ និង ទទួលបានប្រាក់ខែធម្មតា តើអនុបាតនៃការបាត់បង់សមត្ថភាពធ្វើការត្រូវគណនា ដូចម្តេច? ចំពោះដំណោះស្រាយនៃបញ្ហានេះ គឺយុត្តិសាស្ត្រនៅប្រទេសជប៉ុន បានប្រើប្រាស់មូលដ្ឋានបុព្វលាភធានារ៉ាប់រង សម្រាប់ករណីបាត់បង់សមត្ថភាពធ្វើការនេះ ដូចជា ប្រសិនបើ ដាច់ម្រាមដៃទាំងអស់ ត្រូវចាត់ទុកថា ៥៦% ប្រសិនបើនិយាយពួតិចៗ ត្រូវចាត់ទុកថា ២៧%។ ចំពោះស្ថានភាពនេះ នៅក្នុងបទប្បញ្ញត្តិស្តីពីធានារ៉ាប់រងកម្ពុជា ក៏មានផងដែរ ដូចមានកំណត់ក្នុងប្រការ៣ នៃប្រកាសស្តីពីការធានារ៉ាប់រងទៅលើបុគ្គល ដោយកំណត់ពីទឹកប្រាក់យ៉ាងតិចចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាម៉េរិក ឬ ២៥០,០០០ (ពីររយហាសិបពាន់) ដុល្លារអាម៉េរិក ទៅតាមករណីនីមួយៗ ដែលបានកំណត់ក្នុងបណ្ណសន្យារ៉ាប់រង ហើយនៅក្នុងបញ្ញត្តិការងារក៏មានដែរ ដូចជាប្រការ៨ និង ប្រការ១១ នៃប្រកាសស្តីពីគ្រោះថ្នាក់ការងារ ដែលអាចធ្វើជាមូលដ្ឋានក្នុងការពិចារណា[១១១]។ ក្នុងករណីនេះ រដ្ឋ ឬ ស្ថាប័នសាមី អាចអនុវត្តទៅតាមរូបមន្តខាងក្រោមនេះ ដែលជាវិធានពិសេស នៃច្បាប់ការងារកម្ពុជា។

**ផលប្រយោជន៍ដែលទទួលបានពីការងារ៖** ជនរងគ្រោះមានការងារ ប៉ុន្តែ មិនអាចធ្វើការងារបានក្នុងអំឡុងពេលនោះ។ ចំណូលមូលដ្ឋាន (ចំណូលដែលត្រូវទទួលបានពីការងារ) អំឡុងពេលអវត្តមាន ប្រពន្ធ កូន និង ប្រសិនបើ ជនរងគ្រោះបានស្លាប់ គឺចំណូលមូលដ្ឋាន ដែលត្រូវបានទទួល ហើយពេលវេលាត្រូវចាត់ទុកថា អំឡុងពេលដែលជនរងគ្រោះអាចធ្វើបានរហូតដល់ចូលនិវត្តន៍។

មួយវិញទៀត ការគណនានេះ ជាការរាប់បញ្ចូលការចំណាយផ្សេងៗនាពេលអនាគត ផងដែរ ដែលយើងចាត់ទុកថា ជាផលប្រយោជន៍នាពេលអនាគត។ ទោះបីជាដូច្នេះក៏ដោយ ការចាត់ទុកថា ជាសំណងនៃការខូចខាតផ្នែកសម្ភារៈ ត្រូវរម្លស់នូវការចំណាយសម្រាប់ការរស់នៅ (ចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃ) របស់ជនរងគ្រោះ ហើយអំឡុងពេលដែលអាចធ្វើការបាន ឬ អំឡុងពេលសម្រាកពីការងារ ត្រូវអនុវត្តតាមរូបមន្ត Leibniz ដែលជាវិធានទទួលបានផលប្រយោជន៍រយៈពេលវែង នាពេលអនាគតផ្តល់ឱ្យក្នុងពេលបច្ចុប្បន្នតែម្តង ហើយចាំបាច់ត្រូវតែដកដើម្បីកុំឱ្យទទួលបាននូវប្រាក់ខ្ពស់ហួសហេតុ[១១២]។

**រូបមន្ត៖** ប្រាក់ចំណូលមូលដ្ឋាន × អនុបាតនៃការបាត់បង់សមត្ថភាព × អំឡុងពេលដែលជនរងគ្រោះអាចធ្វើការបានរហូតដល់ចូលនិវត្តន៍

[១១១] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង ផ្សេងទៀត, ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, (ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ,២០១៦,), ភាគ២, ទំព័រ២២១

[១១២] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង ផ្សេងទៀត, ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, (ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ,២០១៦,), ភាគ២, ទំព័រ២២០

**ខ.១.៤.២.២.ផ្លូវចិត្ត**

ព្យសនកម្មផ្លូវចិត្ត គឺជាការខូចខាតទាំងឡាយណា ដែលប៉ះពាល់ដល់សិទ្ធិក្រៅបេតិកភណ្ឌ ដូចជា កិត្តិយស ឈ្មោះ ជីវភាពឯកជន ឬ ដល់មនោសញ្ចេតនា ដូចជា ទុក្ខព្រួយ ដែលបណ្តាលមកពីការបាត់បង់មនុស្ស ឬ វត្ថុជាទីស្រឡាញ់[១១៣]។

នៅពេលដែលជនរងគ្រោះ ទាមទារសំណងផ្លូវចិត្ត មិនតម្រូវឱ្យបង្ហាញភស្តុតាងជាក់លាក់ ពីចំនួននៃសំណងនោះទេ ពីព្រោះមិនអាចទៅរួច ហើយចំនួនជាក់លាក់ត្រូវកំណត់ដោយតុលាការ ប៉ុន្តែ ជនរងគ្រោះ ឬ អ្នកមានសិទ្ធិទាមទារ ត្រូវបង្ហាញពីភាពឈឺចាប់ ទំនាក់ទំនងគ្រួសារ សកម្មភាពនានា ដែលជាអនុស្សាវរីយ៍ ជាមួយគ្នាពីមុន រូបភាព អារម្មណ៍ខ្លោចផ្សាការបាក់ទឹកចិត្តជាអាទិ៍[១១៤]។

| |
|---|
| **រូបមន្តៈ** ផលប្រយោជន៍ដែលត្រូវបានទទួលពីការងារ = ប្រាក់ចំណូលមូលដ្ឋាន × ពេលវេលាសរុប ដែលមិនបានបំពេញការងារ |

រាល់សេចក្តីសម្រេចចំនួនទឹកប្រាក់ ដែលត្រូវសងទៅជនរងគ្រោះ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម ជនរងគ្រោះ ឬ អ្នកមានសិទ្ធិទាមទារ ពុំអាចធ្វើការទាមទារ ចំនួនសំណងទៅតាមគំនិតរបស់ខ្លួន ពីរដ្ឋ ឬ ស្ថាប័នសាមីឡើយ។

**ខ.២.ការទាមទារសំណងរបស់បុគ្គល ក្រៅពីជនរងគ្រោះ**

ការទាមទារសំណងរបស់បុគ្គល ក្រៅពីជនរងគ្រោះ អាចជាសហពទ្ធ សាច់ញាតិ ជាដើម ដែលការទាមទារ អាចជាការទាមទារ ការខូចខាតសតិអារម្មណ៍ (ខ.២.១.) ការទាមទារពីជីវព្រឹត្ត (ខ.២.២.) ទាមទារលើសោយហ៊ុយបុណ្យសព (ខ.២.៣.) ជាដើម។

**ខ.២.១.សំណងនៃការខូចខាតសតិអារម្មណ៍**

សំណងច្រើនប្រភេទ ដែលត្រូវបានទាមទារ ដោយបុគ្គលក្រៅពីជនរងគ្រោះ ដូចជា សហពទ្ធ ញាតិ សាច់សាលោហិតនៃសព។

ការទារសំណងបែបនេះពីរដ្ឋ នៅស្រុកបារាំង "**កុងសីដេតា (Conseil d'Etat)**" ច្រើនតែរឹងរូស មិនព្រមទទួលស្គាល់ ឱ្យមានសំណងដល់ទុក្ខសោក ដែលបណ្តាលមកពីការស្លាប់សាច់ញាតិជិតផ្ទាល់។ "កុងសីដេតា" យល់ព្រមឱ្យមានសំណងដល់ការចំណាយសព្វសារពើ ក្នុងពេលធ្វើបុណ្យសព និង ឱ្យមានការជួយឧបត្ថម្ភ ជាប្រាក់កាសដល់គ្រួសារនៃអ្នកស្លាប់ ដើម្បីចិញ្ចឹមជីវិត ពីព្រោះការស្លាប់នាំឱ្យបាត់បង់ធនធានដើម្បីរស់។ ប៉ុន្តែ រឿង**ទុក្ខសោក** មិនអាចយកមកគិតបន្ថែមពីលើនេះបាន

[១១៣] ញឹក វុទ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ១៩

[១១៤] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង ផ្សេងទៀត, ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, (ភ្នំពេញៈ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ,២០១៦,), ភាគ២, ទំព័រ២២១

ឡើយ។ គេយល់ថា "ទឹកភ្នែកមិនអាចដូរនឹងទឹកប្រាក់បានទេ"។ ជំហររបស់ "កុងសីដេតា" ត្រូវមតិអ្នកច្បាប់ និង មតិសាធារណៈ ទិតៀនរិះគន់យ៉ាងខ្លាំង ដោយគេមិនអាចយល់បានថា តើហេតុអ្វីបានជាអ្នករងគ្រោះដែលមិនស្លាប់ ហើយគ្រាន់តែពិការ "កុងសីដេតា" សុខចិត្តយល់ព្រមឱ្យមានសំណងស្រាប់តែដល់អ្នករងគ្រោះដល់ស្លាប់ បែរជាគ្មានសំណងទៅវិញ។ វាជាការប្រមាថដល់តម្លៃនៃជីវិតមនុស្ស។

បន្ទាប់ពីមានការទិតៀន "កុងសីដេតា" ក៏បានចាប់ផ្តើមសុខចិត្តឱ្យមានការសងសាច់ញាតិជិត របស់សពអ្នករងគ្រោះ ជាប្រាក់បន្ថែមបន្តិចបន្តួច លើទឹកប្រាក់ដែលសងសម្រាប់ធ្វើបុណ្យសព ដោយថែងថា "សម្រាប់កង្វល់ផ្សេងៗ ដែលកើតមានក្នុងការរស់នៅ" ប៉ុន្តែ ដោយប្រកាន់ខ្ជាប់ថា ការឈឺចាប់ទុក្ខសោក មិនអាចគិតជាប្រាក់សម្រាប់សងបានឡើយ"។

លុះដល់ឆ្នាំ១៩៦១ "កុងសីដេតា" បានសម្រេចទទួលយល់ព្រមឱ្យមានសំណង ជាប្រាក់ដល់ព្យសនកម្មផ្លូវចិត្ត ដែលកើតមកពីទុក្ខសោក ថ្វីបើគ្មានការខូចខាតខាងផ្លូវកាយ ឬ សម្ភារៈ អ្វីក៏ដោយ។ សេចក្តីសម្រេចនេះ ចេញតាមសាលដីកា "ឡឺទីស្សឺរ៉ង់ (Le tisserand)" ដែលមានខ្លឹមសារដូចតទៅ[១១៦]។

ថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៥៥ រថយន្តធំ "ការមីញ៉ុង" របស់ក្រសួងសាធារណការ មួយបានបុកទោចក្រយានយន្តមួយដែលមានឈ្មោះ " ប៉ូលឡឺទីស្សឺរ៉ង់ ( Paul Letisserand) ជាអ្នកបើក ដោយមានដាក់កូនស្រីតូចមួយអាយុ៧ ឆ្នាំឌុបជាមួយផង បណ្តាលឱ្យស្លាប់ទាំងពីរនាក់ ឪពុកកូន នៅនឹងកន្លែង។ ប្រពន្ធរបស់ "ប៉ូលឡឺទីស្សឺរ៉ង់" បានប្តឹងទារសំណងពីរដ្ឋការ ចំពោះការខូចខាតសម្ភារៈ និង បាត់បង់ស្វាមីទុកចោលឱ្យខ្លួននៅថែរក្សាកូនតូចៗ៣ នាក់ទៀតតែម្នាក់ឯង។ ពាក្យបណ្តឹងនេះ ពុំមានបញ្ហាអ្វីទេ ពីព្រោះក្រសួងសាធារណការ ត្រូវតែសងការខូចខាតទាំងអស់ គឺគិតរួមទាំងទោសចក្រក្រយានយន្ត ការបាត់បង់ផលទុន និង កង្វល់គ្រប់យ៉ាង ក្នុងជីវិតរស់នៅផង។

ប៉ុន្តែ ឪពុករបស់ "ប៉ូលឡឺទីស្សឺរ៉ង់" ឈ្មោះ " កាមីយ ឡឺទីស្សឺរ៉ង់" ក៏បានធ្វើពាក្យប្តឹងសុំឱ្យ រដ្ឋការសងជំងឺចិត្ត ដែលបណ្តាលមកពីការស្លាប់កូនគាត់ និង ចៅស្រីគាត់ ពីព្រោះ "កាមីយ" កើតទុក្ខ-សោកយ៉ាងខ្លាំងណាស់។ ឈ្មោះ "កាមីយ" គ្មានខូចខាតខាងសម្ភារៈបន្តិចបន្តួចណាសោះ ហើយក៏មកប្តឹង ទារសំណងពីព្យសនកម្មផ្លូវចិត្តនឹងគេដែរ។ តើចំពោះករណីនេះ ចៅក្រមត្រូវគិតយ៉ាងដូច-ម្តេច? ពីព្រោះវាជារឿងពិបាកមួយយ៉ាងធំ ដែលត្រូវដោះស្រាយ កុងសីដេតា ក៏ធ្វើការប្រជុំធំ គឺមហា-សន្និបាតពេញអង្គមួយ។ តាំងពីមុនរឿងនេះ កុងសីដេតា មិនដែលធ្វើការសម្រេច ឱ្យឃ្លាតចាកពីគោលការណ៍ដែលថា "ទុក្ខសោកមិនអាចជាការខូចខាតដែលឱ្យសងជាប្រាក់បានឡើយ" នោះទេ។

[១១៦] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ បួស្សំ ឡូទឹស,២០១២), ទំព័រ៣៥៨

ស្នងការរបស់រដ្ឋាភិបាលឈ្មោះ "ហឺម៉ាន់" (Heumann) បានពន្យល់អង្គប្រជុំថា ទុក្ខសោកអាចសងជាប្រាក់បាន។ ហេតុអ្វី ក៏ទៅជាមិនបាន? ហេតុអ្វីក៏ទៅជាមានការពិបាកនឹងគិតសំណងជាប្រាក់ ជាងការគិត ចំពោះការឈឺចាប់រាងកាយទៅវិញ? វាគ្មានអ្វីមកគាំពារគំនិតបែបនេះសោះ។ ប្រាកដហើយថា សំណងជាសាច់ប្រាក់មិនអាចលុបបំបាត់ទឹកចិត្តស្តាយស្រណោះកូន ដែលស្លាប់បាត់ទៅហើយទេ ប៉ុន្តែ ទោះបីជាសងនេះមិនគ្រប់គ្រាន់ ក៏វាប្រសើរជាងការមិនព្រមសងសោះនោះដែរ។ ការផ្តល់ប្រាក់សំណង មិនមែនសម្រាប់ទៅជំនួសតម្លៃអ្វីមួយដែលស្មើគ្នានោះទេ ប៉ុន្តែ វានាំឱ្យមានការពេញចិត្ត ឱ្យធូរស្រាលក្នុងចិត្ត ហើយជួនកាល រហូតដល់ឱ្យបាត់អារម្មណ៍ក្រៀមក្រំផង។ ស្នងការ "ហឺម៉ាន់" (Heumann) គិតថា ការសងជាប្រាក់នេះ មិនមានអ្វីផ្ទាំផ្ទួងនឹងសីលធម៌ទេ ពីព្រោះវាគ្រាន់តែជាការជួយសម្រាលផ្លូវចិត្ត ដែលមានវិបត្តិ។ ការឈឺចាប់ ផ្លូវចិត្ត និង ការឈឺចាប់ផ្លូវកាយ នាំឱ្យចុះខ្សោយដូចគ្នា នូវថាមពលក្នុងការធ្វើការងារ។ ស្នងការ "ហឺម៉ាន់" ស្នើថា គួរបោះបង់ចោលទ្រឹស្តីហួសសម័យ ហើយសូមអង្គប្រជុំធ្វើការផ្លាស់ប្តូរយុត្តិសាស្ត្រ ឱ្យសមស្របនឹងការចង់បានសម្បជញ្ញៈ ក្នុងផ្លូវគតិយុត្ត។ "*កុងសីដេតា*" យល់ស្របតាម ហើយក៏បានសម្រេចថា ទុក្ខសោកផ្លូវចិត្តដែលបណ្តាលមកពីការស្លាប់នោះ ជាហេតុនាំឱ្យមានការសងជាប្រាក់ ដល់ព្យសនកម្មផ្លូវចិត្តបាន។ "*កុងសីដេតា*" យល់ថា ត្រូវផ្តល់ជូនឈ្មោះ "កាមីយ ឡឺទីស្សឺរ៉ង់" នូវប្រាក់សងជំងឺចិត្តចំនួន១០០០ ហ្វ្រង់។

យើងកត់សម្គាល់ឃើញថា ទឹកប្រាក់នេះ តិចតួចទេ ពីព្រោះវាមិនមែនជាការទិញលក់ ទឹកភ្នែក។ វាគ្រាន់តែជាវិធីព្យាបាលផ្លូវចិត្ត។ ឈ្មោះ "*កាមីយ*" បានទាមទារសំណងជំងឺចិត្ត ដល់ទៅ ៥,០០០ ហ្វ្រង់ ក្នុងឆ្នាំ១៩៥៥ ប៉ុន្តែ ចៅក្រម សម្រេចឱ្យបានតែ១/៥ (មួយភាគប្រាំ) ប៉ុណ្ណោះ[១១៦]។

ងាកមកច្បាប់កម្ពុជាវិញ មាត្រា៧៦០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី បានចែងថា "*បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅក្នុង១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន*" ។

រដ្ឋ ឬ ស្ថាប័នសាមី ក៏ត្រូវចេញជាសំណង ដល់សាច់ញាតិនៃជនរងគ្រោះ ដូចមានក្នុងច្បាប់ផងដែរ។ ការចេញសងនេះ ក៏មិនមែនចេះតែសង គ្រប់រឿងនោះដែរ ក្នុងករណីដែលរដ្ឋ មើលឃើញថា ជនដែលទារសំណងនោះ គ្មានមនោសញ្ចេតនាអ្វីសោះ ជាមួយជនរងគ្រោះ ក៏រដ្ឋមិនអាចសងការខូចខាតខាងសតិអារម្មណ៍ដែរ។

ចៅក្រម ត្រូវធ្វើការប្រុងប្រយត្ន ចំពោះពាក្យសុំសំណងជំងឺចិត្ត ដែលធ្វើឡើងដោយជនដែលចង់បានតែប្រាក់ ហើយគ្មានឈឺចាប់អ្វីសោះ។ កុងសីដេតា (ប្រទេសបារាំង) ធ្លាប់បានបដិសេធពាក្យ

[១១៦] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញៈ ប្លុស្សុំ ឡូទឹស,២០១២), ទំព័រ៣៦០

សុំសំណង របស់ស្រីម្នាក់ដែលរស់នៅដាច់គ្នាយូរហើយពីប្តី ហើយដល់ប្តីស្លាប់ ទើបលេចមុខមកធ្វើជាយំស្រែក ដើម្បីលក់ទឹកភ្នែក (ក្រពើ)[១១៧]។

**ខ.២.២.ការទាមទារសំណងពីជីវព្រឹត្ត**

មាត្រា៧៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តថា៖ "*បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ច-សន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្ត អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តដែលបុគ្គលដែលទទួលជីវព្រឹត្ត លែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសពជាអាទិ៍*"។ ចំណុចនៃមាត្រានេះ បានចង្អុលបង្ហាញថា សូម្បីតែជីវព្រឹត្ត[១១៨] ដែលត្រូវទទួលអាហារកាតព្វកិច្ច ពីជនរងគ្រោះ ក៏ច្បាប់បានអនុញ្ញាតឱ្យ ធ្វើការទាមទារសំណងការខូចខាតពីរដ្ឋ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះផងដែរ។

**ខ.២.៣.សោហ៊ុយបុណ្យសព**

ដូចបានបង្ហាញខាងលើរួចហើយ សោហ៊ុយបុណ្យនៃជនរងគ្រោះ ក៏ជាកាតព្វកិច្ចរបស់រដ្ឋ ឬ ស្ថាប័នសាមីដែរ។ សាច់ញាតិ ឬ សហពទ្ធ អាចទាមទារសោហ៊ុយបុណ្យសព នេះពីរដ្ឋបាន។

**ខ.៣.កាលបរិច្ឆេទនៃការវាយតម្លៃសំណង និង អាជ្ញាយុកាល**

ក្រោយការវិនិច្ឆ័យសេចក្តី លើពាក្យបណ្តឹងរបស់ជនរងគ្រោះរួចហើយ ជនរងគ្រោះអាចទទួលបានសំណង នៅក្នុងកាលបរិច្ឆេទមួយដែលសមរម្យ (ខ.៣.១.)។ ការដាក់ពាក្យបណ្តឹង ឬ មិនដាក់នោះ ជាសិទ្ធិរបស់ជនរងគ្រោះ ប្រសិនបើ ជនរងគ្រោះបន្លាយពេលវេលាក្នុងការប្តឹង អាចនាំឱ្យផុតអាជ្ញាយុកាលនៃការទាមទារផងដែរ (ខ.៣.២.)។

**ខ.៣.១.កាលបរិច្ឆេទនៃការវាយតម្លៃសំណង**

ការទាមទារជួសជុលសំណងការខូចខាតជាសិទ្ធិរបស់ជនរងគ្រោះ សិទ្ធិទាមទារការជួសជុលនេះ កើតឡើងនៅពេលមានការខូចខាត។ ប៉ុន្តែ ឥណទេយ្យ (Créance) នៃប្រាក់ជំងឺចិត្ត ដែលសម្រេចលើការទទួលខុសត្រូវ គឺមាននៅថ្ងៃចេញសាលក្រម[១១៩]។

---

[១១៧] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្សំ ឡូទឹស,២០១២), ទំព័រ៣៦១

[១១៨] ជីវព្រឹត្ត៖ បុគ្គលដែលបិតក្រោមការទំនុកបម្រុង ម្ហូបអាហារពីបុគ្គលម្នាក់ទៀត, អាហារ, ម្ហូបចំណី, សម្លៀកបំពាក់។

[១១៩] ញឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ២៦

**ការខូចខាតចំពោះទ្រព្យសម្បត្តិ៖** នៅក្នុងករណីនៃការខូចខាតចំពោះទ្រព្យសម្បត្តិចៅក្រមវាយតម្លៃលើតម្លៃនៃការខូចខាត នៅថ្ងៃនៃការកើតឡើងនៃការខូចខាត ក្នុងករណីលើកលែងប្រសិនបើ ជនរងគ្រោះបង្ហាញថា ខ្លួនមិនអាចឱ្យគេធ្វើការជួសជុលបាន ក្នុងករណីនេះចំនួនទឹកប្រាក់សរុបនៃការជួសជុល និង វាយតម្លៃនៅថ្ងៃដែលចៅក្រមសម្រេច។ មូលហេតុអាចមានលក្ខណបច្ចេកទេស (ភាពចាំបាច់ដាក់ឱ្យត្រឹមត្រូវតាមស្ថានដើមវិញ នៃការជាបុព្វហេតុនៃការខូចខាត) មូលហេតុអាចមានលក្ខណគតិយុត្ត (បទបញ្ញាបន្ថយការប្រើគ្រឿងសំណង់ចាំបាច់) ឬ មូលហេតុមានលក្ខណហិរញ្ញវត្ថុ។

ផ្ទុយទៅវិញប្រសិនបើ ការងារជួសជុលអាចធ្វើទៅបាន ប៉ុន្តែ មិនអាចសម្រេចទៅបានដោយសារកម្មសិទ្ធិករ ការងារជួសជុលនេះ នឹងត្រូវវាយតម្លៃនៅថ្ងៃដែលសម្រេចធ្វើបាន។ ដោយសារហេតុផលសមធម៌ ចៅក្រមអាចវាយតម្លៃត្រឹមត្រូវជាងនេះទៀត ក្នុងការពិចារណាលើស្ថានភាពនៅថ្ងៃនៃការចេញសាលក្រម។

**ការខូចខាតដល់មនុស្ស៖** ក្នុងករណីមានការខូចខាតដល់មនុស្សវិញ ចៅក្រមឱ្យតម្លៃពីវិសាលភាពរបស់វានៅថ្ងៃដែលខ្លួនចេញសាលក្រម។ ចៅក្រមគិតគូរពីព្យសនកម្មទាំងស្រុងក៏ដូចជាការយឺតយ៉ាវរបស់ជនរងគ្រោះ ក្នុងការដាក់ពាក្យបណ្តឹង[១២០]។

ក្នុងករណីខ្លះ ព្យសនកម្មអាចរឹតតែធ្ងន់ធ្ងរ ក្រោយចេញសាលក្រមដោយតុលាការ ជា **ឧទាហរណ៍៖** របួសជនរងគ្រោះបណ្តាលឱ្យមានវិបត្តិរាងកាយ ហើយអសមត្ថភាពមួយភាគ នៃការងារទទួលស្គាល់ដោយសាលក្រម ពេលក្រោយមកទៀត អសមត្ថភាពទាំងស្រុង ក្នុងករណីនេះគេទទួលស្គាល់ឱ្យជនរងគ្រោះ អាចទាមទារការសងជំងឺចិត្ត បន្ថែមទៀតបាន។ នេះគឺជាការធ្វើបណ្តឹងជាថ្មីឈរលើមូលដ្ឋាន មានព្យសនកម្មមួយទៀត ខុសពីព្យសនកម្មដែលបានជួសជុល ដោយចារី នៅពេលមានសាលក្រមលើកទីមួយ (Il s´agit d´une nouvelle action en responsabilité, fondée sur un prejudice distinct de celui qui a été réparé lors du premier jugement) [១២១]។

បណ្តឹងរបស់ជនរងគ្រោះ ក្នុងការទាមទារសំណងពីរដ្ឋ មិនមែនចេះតែទាមទារនោះទេ ត្រូវគោរពទៅតាមអាជ្ញាយុកាលនៃការដាក់ពាក្យបណ្តឹងផងដែរ។

---

[១២០] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ៣០៦ និង ៣០៧

[១២១] ញឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ២៦

**ខ.៣.២.អាជ្ញាយុកាល**

ជនរងគ្រោះ មានរយៈពេលក្នុងការទាមទារសំណងនៃការខូចខាត ពីរដ្ឋចំនួន៣ ឆ្នាំ។ ប្រសិនបើ បានដឹងហើយឮហើយ ពីអត្ថិភាពនៃសិទ្ធិ ក្នុងការប្តឹងទាមទារសំណងពីរដ្ឋ ដែលមានរយៈពេល៣ ឆ្នាំ តែមិនប្តឹង នោះនាំឱ្យផុតអាជ្ញាយុកាលនៃការទាមទារ។ ប៉ុន្តែ បើមិនបានដឹងពីអត្ថិភាពនៃសិទ្ធ និង រយៈពេលនៃការទាមទារនោះទេ មាត្រា៧៦៥ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានទុកសិទ្ធិឱ្យជនរងគ្រោះចំនួន១០ ឆ្នាំ ក្នុងការប្តឹងទាមទារសំណង។ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីខាងលើនេះ ហាក់ផ្តល់សិទ្ធិដល់ជនរងគ្រោះច្រើន ក្នុងការទាមទារសំណងនៃការខូចខាត បើយើងក្រឡេកមើលនៅក្នុងក្រឹត្យ-ច្បាប់លេខ៣៨ មាត្រា១៣៥ បានទុកសិទ្ធិឱ្យជនរងគ្រោះប្តឹង មានរយៈពេលតែ៣ ឆ្នាំប៉ុណ្ណោះ មិនមានករណីផ្សេងឡើយ។

**ខ.៤.ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ**

នៅក្នុងរឿងក្តីដែលរដ្ឋមានកាតព្វកិច្ច ត្រូវសងការខូចខាត រដ្ឋមានសិទ្ធិជ្រើសរើសកាលានុវត្តភាពនៅក្នុងការសងការខូចខាតឱ្យទៅឯកជន ដែលតុលាការបានសម្រេចឱ្យសង។ ដោយតុលាការពុំមានសិទ្ធិអំណាចណាមួយ ចាប់បង្ខំរដ្ឋឱ្យសងជាកំហិត ទៅឯកជននៅថ្ងៃណាមួយជាក់លាក់បានឡើយ។ ក៏ប៉ុន្តែ តុលាការអាចដាក់ពិន័យដល់រដ្ឋចំពោះការយឺតយ៉ាវនៅក្នុងការសងការខូចខាតនេះដល់ភាគីឯកជនតែប៉ុណ្ណោះ។

នៅក្នុងប្រទេសនីតិរដ្ឋ អាជ្ញាធររដ្ឋបាលត្រូវតែគោរព និង អនុវត្តន៍នូវរាល់សេចក្តីសម្រេច (សាលក្រម ឬ សាលដីកា) របស់តុលាការ។ ប្រសិនបើ អង្គការនីតិប្រតិបត្តិមិនព្រមអនុវត្តសេចក្តីសម្រេច (សាលក្រម ឬ សាលដីកា) របស់តុលាការនេះ ហើយទៅអនុវត្តសេចក្តីសម្រេចរដ្ឋបាលរបស់ខ្លួន ដែលត្រូវបានតុលាការ ប្រកាសមោឃភាពនោះ មានតែសភាទេ ដែលអាចបង្ខំឱ្យអង្គការនីតិប្រតិបត្តិនេះ គោរពតាមរយៈការកោះហៅរដ្ឋាភិបាល និង បោះឆ្នោតទម្លាក់ជាដើម [១២២]។

ទន្ទឹមនឹងការទទួលខុសត្រូវ លើកំហុសរបស់មន្ត្រីរាជការ ទៅលើជនរងគ្រោះទាំងស្រុង រដ្ឋក៏អាចត្រូវបានកាត់បន្ថយការទទួលខុសត្រូវរបស់ខ្លួនផងដែរ។

កំហុសរបស់មន្ត្រីរាជការ មិនមែនសុទ្ធតែ ជាកំហុសដែលរដ្ឋត្រូវសងការខូចខាតទាំងស្រុងនោះទេ មានលក្ខខណ្ឌមួយចំនួនអាចឱ្យរដ្ឋ បន្ថយការទទួលខុសត្រូវ។

**គ.លក្ខខណ្ឌ នៃការបន្ថយការទទួលខុសត្រូវ**

មានលក្ខខណ្ឌមួយចំនួន ដែលរដ្ឋ ឬ ស្ថាប័នសាមី អាចកាត់បន្ថយការទទួលខុសត្រូវ លើអំពើដែលខ្លួនបានប្រព្រឹត្ត លើជនរងគ្រោះ។ លក្ខខណ្ឌនេះ មានដូចជា៖ ការធានារ៉ាប់រងសង្គម និង

[១២២] ហៀង សាង, នីតិវិវាទរដ្ឋបាល, (ភ្នំពេញ៖ រោងពុម្ពក្រសួងព័ត៌មាន, ២០១៧), ទំព័រ២៤៦

ប្រាក់ចំណេញ (គ.១.), កំហុសរួមរបស់រដ្ឋ និង ជនរងគ្រោះ (គ.២.) កំហុសរួមរបស់រដ្ឋ និង តតិយជន (គ.៣.)ការព្រមព្រៀងរបស់រដ្ឋ និង ជនរងគ្រោះ (គ.៤.)។

**គ.១.ការធានារ៉ាប់រងសង្គម និង ប្រាក់ចំណេញ**

ប្រសិនបើជនរងគ្រោះ ឬ ក្រុមគ្រួសារ បានទទួលប្រាក់ធានារ៉ាប់រងសង្គម ការទទួលខុសត្រូវនឹងត្រូវបានបន្ថយ ឬ/និង ជនរងគ្រោះ បានទទួលផលចំណេញពីអំពើអនីត្យានុកូល ប្រាក់ចំណេញត្រូវបានដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត។ ករណីនេះ មានដូចជា ជនរងគ្រោះ បានស្លាប់នាំឱ្យចំណាយ នាពេលអនាគតសម្រាប់ជនរងគ្រោះគ្មាន ហេតុនេះចំនួនទឹកប្រាក់សន្មតមួយ នៃការចំណាយសម្រាប់ការរស់នៅ នាពេលអនាគត នឹងត្រូវបានបន្ថយចំនួនទឹកប្រាក់នៃសំណង[១២៣]។

**គ.២.កំហុសរួមរបស់រដ្ឋ និង ជនរងគ្រោះ**

នៅក្នុងមាត្រា៧៦៤ នៃក្រមរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ក៏បានបញ្ញត្តដែរថា "*បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬ រីករាលដាលនៃការខូចខាត តុលាការ អាចគិតពិចារណានូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត* "។ ក្នុងចំណុចនេះ មានន័យថា អំពើបង្កឡើងដោយរដ្ឋ ដែលបង្កើតឱ្យមានព្យសនកម្មដល់ជនរងគ្រោះនេះ គឺមានការចូលរួមកំហុស របស់ជនរងគ្រោះផងដែរ។ កំហុសរបស់ជនរងគ្រោះនេះ អាចមានតិច ឬ ច្រើន ទៅតាមស្ថានភាពជាក់ស្តែង ហើយការទទួលខុសត្រូវរបស់រដ្ឋ ក៏អាស្រ័យលើស្ថានភាពកំហុសរបស់ជនរងគ្រោះនេះផងដែរ។ **និទស្សន៍៖** រថយន្តដឹកជញ្ជូនរបស់រដ្ឋមួយគ្រឿង បានបើកបរក្នុងល្បឿន១០០គីឡូម៉ែត្រ/១ម៉ោង នៅទីប្រជុំជន បានបណ្តាលឱ្យបុក ទោចក្រយានយន្តមួយគ្រឿង ដែលកំពុងជិះឆ្លងកាត់ផ្លូវ ដែលមានភ្លើងស្តុបក្រហម។ ក្នុងករណីខាងលើ រថយន្តរបស់រដ្ឋមានកំហុស ព្រោះបានបើកបរក្នុងល្បឿនលឿន ដែលច្បាប់បានហាមឃាត់ ឯជនរងគ្រោះ ក៏មានកំហុសផងដែរ ព្រោះបានជិះឆ្លងកាត់ផ្លូវ ដោយមិនគោរពភ្លើងចរាចរណ៍។ ប្រសិនបើ តុលាការរកឃើញថា រដ្ឋមានកំហុសធ្ងន់ជាង រដ្ឋសងការខូចខាតដល់ជនរងគ្រោះ តែការទទួលខុសត្រូវនេះ ត្រូវបានកាត់បន្ថយ។

**គ.៣.កំហុសរួមរបស់រដ្ឋ និង តតិយជន**

ចំណុចនេះ ក៏មិនខុសពីចំណុចខាងលើ (កំហុសរួមរបស់រដ្ឋ និង ជនរងគ្រោះ) ដែរ គ្រាន់តែត្រង់ចំណុចនេះ គឺជាកំហុសរវាង រដ្ឋ និង តតិយជន។ ដូច្នេះ រដ្ឋ និង តតិយជន ត្រូវសហការគ្នា ក្នុង

[១២៣] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង ផ្សេងទៀត, ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី, (ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ,២០១៦), ភាគ២, ទំព័រ២១៨

ការសងការខូចខាតនានា ដល់ជនរងគ្រោះ។ **និទស្សន៍៖** ជនបង្កអំពើ បានបើកបររថយន្តយ៉ាងលឿន ហើយបានបត់ឆ្វេង ដោយមិនប្រើភ្លើងសញ្ញាជាមុន ភ្លាមនោះ រថយន្តក្រុងរបស់រដ្ឋ ដែលនៅពីក្រោយ បានបើកក្នុងល្បឿនយ៉ាងលឿន ឃើញដូចនេះ មិនអាចចាប់ហ្វ្រាំង ក៏កាច់ចង្កូតទៅបុកបុរស (ក) បណ្ដាលឱ្យស្លាប់។

ក្នុងករណីនេះឃើញថា ជនបង្កអំពើដែលជាតតិយជនក៏មានកំហុស រីឯរថយន្តក្រុង របស់រដ្ឋក៏មានកំហុស ដូចនេះ បុគ្គលទាំងពីរ ត្រូវសហការគ្នាក្នុងការសងការខូចខាត ដល់ជនរងគ្រោះ ដោយផ្អែកទៅតាមស្ថានភាព នៃកំហុសជាក់ស្ដែង។

កំហុសរបស់មន្ត្រីរាជការ ពេលខ្លះក៏អាចនាំឱ្យរដ្ឋគេចផុតពីការទទួលខុសត្រូវទាំងស្រុងដែរ ប៉ុន្តែ ត្រូវមានលក្ខខណ្ឌមួយចំនួនដូចខាងក្រោម។

**ឃ.លក្ខខណ្ឌ នៃការមិនសងការខូចខាត**

មានលក្ខខណ្ឌជាច្រើន ដែលរដ្ឋ ឬ ស្ថាប័នសាមី មិនសងការខូចខាតដល់ជនរងគ្រោះ បើទោះបីជា ជនរងគ្រោះទទួលរងព្យសនកម្ម ដែលកើតចេញពីអំពើផ្ទាល់របស់មន្ត្រីរាជការក៏ដោយ។ លក្ខខណ្ឌនោះមានដូចជា៖ ជាកំហុសទាំងស្រុងរបស់ជនរងគ្រោះ (ឃ.១.) អំពើរបស់តតិយជន (ឃ.២.) កិច្ចការពារជាធម្មានុរូប (ឃ.៣.) ប្រធានសក្តិ (ឃ.៤.) ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ (ឃ.៥.) ស្ថានភាពចាំបាច់ (ឃ.៦.) ការយល់ព្រមពីជនរងគ្រោះ (ឃ.៧.) ការយល់ព្រមពីភយន្តរាយ (ឃ.៨.) ករណីពើបពះ (ឃ.៩.) អំពើរបស់មន្ត្រីរាជការ ជាកំហុសបុគ្គល (ឃ.១០) ការផុតអាជ្ញាយុ-កាល(ឃ.១១.) ការខូចខាតបណ្ដាលមកពីកងទ័ពបរទេសដែលមកស្នាក់ក្នុងប្រទេស (ឃ.១២.) និង ការខូចខាតកើតពីសង្គ្រាមបរទេស (ឃ.១៣.)។

**ឃ.១.កំហុសទាំងស្រុងរបស់ជនរងគ្រោះ**

បើក្រឡេកមើលក្រឹត្យ-ច្បាប់៣៨ មាត្រា១៣៣ កថាខណ្ឌទី២ បានបញ្ញត្តថា "*ជនដែលធ្វើឱ្យមានការខូចខាតដល់អ្នកដទៃ នឹងអាចឱ្យរួចខ្លួនពីការទទួលខុសត្រូវបានប្រសិនបើ: ២.ការ ខូចខាតបណ្ដាលមកពីកំហុសទាំងស្រុងរបស់ជនរងគ្រោះ*"។

ឥរិយាបថរបស់ជនរងគ្រោះនៃការខូចខាត អាចជាបុព្វហេតុ រួចផុតពីការទទួលខុសត្រូវទាំងស្រុង របស់បុគ្គលសាធារណៈ[១២៤]។ ក្នុងករណីនេះ រដ្ឋ ឬ ស្ថាប័នសាមី អាចរួចផុតពីការទទួលខុសត្រូវ លើអំពើរបស់ខ្លួនបាន ដោយមូលហេតុបណ្ដាលមក ពីកំហុសទាំងស្រុងរបស់ជនរង-គ្រោះ។ **ឧទាហរណ៍៖** ជនរងគ្រោះ បានជិះទៅបុកបង្គោលភ្លើងស្តុប ដែលបានដាក់នៅក្បែរផ្លូវប-ណ្ដាលឱ្យខូចខាតជាដំណំ។ រដ្ឋពុំទទួលខុសត្រូវសងការខូចខាត ដល់ជនរងគ្រោះ នៅក្នុងករណីបែបនេះឡើយ ព្រោះជាកំហុសទាំងស្រុងរបស់ជនរងគ្រោះ។

[១២៤] ឌឿក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៩៨

**ឃ.២.អំពើរបស់តតិយជន**

អំពើរបស់តតិយជន ធ្វើឱ្យរដ្ឋរួចផុតពីការទទួលខុសត្រូវរបស់ខ្លួន តែប្រសិនបើ ការទទួលខុសត្រូវនេះ ផ្អែកលើកំហុសដោយរាប់បញ្ចូលទាំងកំហុសធ្ងន់[១២៥]។ **ឧទាហរណ៍៖** ក្រោយពីការងារផ្នែកការដ្ឋានរដ្ឋបានដាក់ស្លាកសញ្ញាគ្រោះថ្នាក់ ដើម្បីឱ្យសាធារណជនមានការប្រុងប្រយត្ន ប៉ុន្តែមានតតិយជនម្នាក់ បានទៅដកស្លាកសញ្ញានោះចេញ បណ្តាលឱ្យបុរសម្នាក់ បើករថយន្តធ្លាក់ចូលទៅក្នុងការដ្ឋាននោះ។

មិនអាចទាល់តែសោះ ជាបុព្វហេតុនៃការរួចផុតពីការទទួលខុសត្រូវ កាលណាការទទួលខុសត្រូវនេះ កើតមានឡើងទាំងគ្មានកំហុស។ ប៉ុន្តែ រដ្ឋបាលប្រើអំណាចប្តឹងឧបាស្រ័យ ប្រឆាំងទាល់នឹងតតិយជនដែលចោទប្រកាន់។ ប៉ុន្តែ អំពើរបស់តតិយជនរួចផុតពីការទទួលខុសត្រូវ ក្នុងករណីនៃការខូចខាត ពីការងារសាងសង់ កាលណាអ្នកម៉ៅការ ត្រូវបានដកហូតបណ្តឹងសុំការធានាប្រឆាំងនឹងតតិយជននេះ ដោយច្បាប់[១២៦]។

**ឃ.៣.កិច្ចការពារជាធម្មានុរូប**

មិនថាផ្នែកព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ឬ ផ្នែករដ្ឋបាល កិច្ចការពារជាធម្មានុរូប គឺជានីតិវិធីពិសេស ដែលអាចធ្វើឱ្យរួចផុតពីការទទួលខុសត្រូវ។ មាត្រា៧៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តថា "*អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើរំលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារ និង កម្រិតនៃអំពើបំពាននោះ*"។

ក្រមព្រហ្មទណ្ឌ របស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៣៣ បានហៅកិច្ចនេះថា ជា**ការការពារស្របច្បាប់** និង បានចែងពីលក្ខខណ្ឌដូចនេះថា "*ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖ បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួនបទល្មើស និង ការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និង ទម្ងន់នៃការឈ្លានពាន* "។ ក្នុងករណីនេះ រដ្ឋ ក៏ពុំទទួលខុសត្រូវលើអំពើរបស់ខ្លួននោះទេ ប៉ុន្តែ វាទាមទារ ឱ្យអំពើបំពានរបស់រដ្ឋនោះ មានរយៈពេលស្របគ្នា និង មានតុល្យភាព នៃវិធីការពារនោះ។ **រយៈពេលស្របគ្នា៖** មានន័យថា រដ្ឋ អាចប្រើកិច្ចនេះ ស្របពេលនឹងហេតុការណ៍ដែលបានកើតឡើង។ មិនត្រូវឱ្យរយៈពេល នៃកិច្ចការពារជាធម្មានុរូប មានគម្លាតឆ្ងាយពីហេតុ-ការណ៍ឡើយ។

---

[១២៥] ឌៀក ពិដោរ, នីតិរដ្ឋបាលទូទៅ, (ភ្នំពេញ, ២០១៥), ទំព័រ២២០

[១២៦] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៩៩

**មានតុល្យភាពនៃវិធីការពារ៖** ឬ អាចហៅម៉្យាងទៀតថា ត្រូវឱ្យមានសមាមាត្រនៃមធ្យោបាយដែលប្រើប្រាស់ ពោលគឺ រដ្ឋមិនអាចប្រើប្រាស់មធ្យោបាយការពារខ្លួន មានវិសមាមាត្រ ទៅនឹងមធ្យោបាយរបស់ភាគីម្ខាងឡើង។ **ឧទាហរណ៍៖** មន្ត្រីនគរបាល ចុះទៅបង្ក្រាប ការប្លន់មួយកន្លែងដែលមានលក្ខណៈជាសន្ទិដ្ឋិភាព និង បំពាក់ដោយអាវុធ។ មន្ត្រីនគរបាល បានបាញ់តបទៅកាន់ក្រុមចោរ តាមវិធីការពារជាធម្មានរូបនេះ បណ្តាលឱ្យស្លាប់ និង របួសជាច្រើននាក់។ អាវុធ ដែលជាមធ្យោបាយប្រើប្រាស់ ក្នុងកិច្ចការពារនេះ ត្រូវតែមានសមាមាត្រ នឹងអាវុធរបស់ក្រុមចោរ ហើយធ្វើការតបត ក្នុងកាលៈទេសៈចាំបាច់បំផុត។

**ឃ.៤.ករណីប្រធានសក្តិ**

មានប្រធានសក្តិកើតឡើង កាលណាព្រឹត្តការណ៍កើតឡើង មិនបានគ្រោងទុកមុន មិនអាចទុបទល់បាន មិនអាចយកឈ្នះបាន ហើយនៅក្រៅឆន្ទៈរបស់ភាគីវត្តមាន។ យុត្តិសាស្ត្រចង្អៀតណាស់៖ ភ្លៀងធំធ្លាក់ខ្លាំងជាប់គ្នា ដោយឡែកមិនមែនជាករណី នៃប្រធានសក្តិទេ។ ប៉ុន្តែ ព្យុះធ្លាក់ខ្លាំងមែនទែន ហើយជាប់ៗគ្នាមិនដាច់ ជាលក្ខណៈដោយឡែក ហើយមិនបានគ្រោងទុកមុន ដោយប្រៀបធៀបទៅនឹងព្យុះ ដែលធ្លាប់មានក្នុងតំបន់ មានលក្ខណៈជាប្រធានសក្តិ[១២៧]។ ការទទួលខុសត្រូវរបស់រដ្ឋ ក្នុងចំណុចនេះ គឺមិនគ្រប់ស្ថានភាពទេ បើទោះបីជាមាន ករណីប្រធានសក្តិនេះក៏ដោយ ឧទាហរណ៍ដូចជា៖ រដ្ឋបានធ្វើការខ្ចីប្រាក់ពីធនាគារ **ក** ពេលត្រលប់ពីខ្ចីមកវិញក៏បានចួបប្រទះនឹងខ្យល់ព្យុះ បានកួចវ៉ាលីល ដែលមានប្រាក់នោះ ចូលទៅក្នុងទន្លេបាត់។ ទោះជាមានហេតុការណ៍បែបនេះក្តី ក៏រដ្ឋត្រូវតែសងប្រាក់ ទៅឱ្យធនាគារ **ក** នោះដែរ។

**ឃ.៥.ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ**

សេចក្តីបង្គាប់ និង អនុញ្ញាតដោយច្បាប់ ព្រមទាំងបទបញ្ជាអាជ្ញាធរស្របច្បាប់ គឺជាបុព្វហេតុដែលយើងទទួលស្គាល់ថា ជាបុព្វហេតុបណ្តាលឱ្យគ្មានការទទួលខុសត្រូវផ្នែកអាជ្ញា និង ផ្នែករដ្ឋប្បវេណី[១២៨]។ មាត្រា៣២ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តថា៖ "*បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងច្បាស់។ ប៉ុន្តែចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖ ១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬ មិនហាមឃាត់ដោយច្បាប់ជាធរមាន។*

[១២៧] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៩៧, ២៩៨

[១២៨] ញឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ៣០

*២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ "*។ **និទស្សន៍៖** មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានថៅក្រមចេញដីកាបង្គាប់ឱ្យចុះទៅឆែកឆេរ នៅគេហដ្ឋានរបស់ លោក **ក** ។ **ក** មិនអាចប្តឹងទាមទារសំណងពីមន្ត្រីនគរបាលយុត្តិធម៌បានឡើយ។ ផ្ទុយទៅវិញ មានបទបញ្ជាមួយចំនួន ដែលចេញដោយមន្ត្រីថ្នាក់កំពូល ក៏មិនអាចរួចផុតពីការទទួលខុសត្រូវបានដែរ ដូចជាបទបញ្ជាទាក់ទងនឹងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម។

ដូចជារឿងក្តី Charlos Guillermo Suárez Mason[១២៩] រឿងក្តី **ការ៉ាហ្ស៊ីក** (Karadzic) និង **បារ៉ៃ-វីហ្សា** (Barayagwiza) ព្រមទាំងរឿងក្តី **ពីណូសេ** (Pinchet) [១៣០] ។ ដូចក្នុងករណីនៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ មន្ត្រីថ្នាក់លើបាន បង្គាប់បញ្ជាឱ្យ លោក **កាំង ហ្កេចអ៊ីវ** ជាមន្ត្រីក្រោមឱវាទធ្វើការកាប់សម្លាប់ដល់ប្រជាជនស៊ីវិល នៅមន្ទីរស២១ អស់ជាច្រើននាក់។ ទាំងនេះមិនត្រូវបានច្បាប់ជាតិ និង អន្តរជាតិទទួលខុសស្គាល់ថា ជាការបញ្ជាស្របច្បាប់ ដែលនាំឱ្យរួចផុតពីការទទួលខុសត្រូវឡើយ តែត្រូវបានចាត់ទុកថា ជា បទល្មើសប្រល័យពូជសាសន៍ទៅវិញ។ បញ្ហានេះ អាចត្រូវបានវិនិច្ឆ័យ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬ តុលាការនានា ដូចជាតុលាការយោធា Nuremberg[១៣១] និង តុលាការយោធា តូក្យូជាដើម[១៣២]។ ចំណែកនៅប្រទេសកម្ពុជាវិញ គឺបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋជន ដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានអនុម័ត និង ប្រកាសឱ្យប្រើប្រាស់ នៅថ្ងៃទី១០ ខែសីហា ២០០១[១៣៣]។

### ឃ.៦.ស្ថានភាពចាំបាច់

ជាស្ថានភាពដែលបុគ្គលម្នាក់ស្ថិតនៅ ហើយដើម្បីចៀសវាងគ្រោះថ្នាក់មួយធ្ងន់ធ្ងរ ក៏បង្កអន្តរាយដែលមានសារៈសំខាន់តូចជាង ដល់អ្នកដទៃ[១៣៤]។ ត្រង់ចំណុចនេះ ក៏អាចជាបុព្វហេតុនៃការមិនទទួលខុសត្រូវរបស់រដ្ឋ ទាំងផ្នែកព្រហ្មទណ្ឌ និង ទាំងផ្នែករដ្ឋប្បវេណី។ ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥ បានបញ្ញត្តថា *"បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖ ១-បទល្មើសត្រូវចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន និង ២-គ្មាន*

---

[១២៩] អ៊ឹង រដ្ឋា, នីតិព្រហ្មទណ្ឌអន្តរជាតិ, បោះពុម្ពលើកទី២, (ភ្នំពេញ, ២០១៣), ទំព័រ៦៥

[១៣០] អ៊ឹង រដ្ឋា, នីតិព្រហ្មទណ្ឌអន្តរជាតិ, បោះពុម្ពលើកទី២, (ភ្នំពេញ, ២០១៣), ទំព័រ៦៨

[១៣១] អនុសញ្ញាទីក្រុងឡុងដ៍ ថ្ងៃទី៨ សីហា ១៩៤៥

[១៣២] ឌៀក ពិដោរ, នីតិអន្តរជាតិសាធារណៈ, (ភ្នំពេញ, ២០១),ទំព័រ២៦៥

[១៣៣] ព្រំ ពិសិទ្ធ. តុលាការកាត់ទោសខ្មែរក្រហម៖ (ភ្នំពេញ, ២០០៤), ទំព័រ ៥៦

[១៣៤] ញឹក វុធ្ធី, នីតិកាតព្វកិច្ច. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២, ទំព័រ ៣០

*វិសមា-មាត្ររវាងមធ្យោបាយ និង ទម្ងន់នៃគ្រោះថ្នាក់* ”។ មាត្រា៧៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តដូច្នេះថា “*អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើរំលោភដែលពុំអាចចៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ* ”។ យោងតាមបទប្បញ្ញត្តិនៃច្បាប់ខាងលើនេះ រដ្ឋមិនទទួលខុសត្រូវលើអំពើរបស់ខ្លួន ក្នុងស្ថានភាពចាំបាច់ឡើយ ប៉ុន្តែ ស្ថានភាពចាំបាច់នេះតម្រូវឱ្យរដ្ឋ ត្រូវតែមានគោលបំណងដើម្បីការពារអ្នកដទៃ និង ទ្រព្យសម្បត្តិ។ល។ ហើយត្រូវមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់។

**ឧទាហរណ៍១៖** សាឡាងរបស់រដ្ឋមួយគ្រឿង ពេលបើកបរដល់កណ្តាលសមុទ្រ ស្រាប់តែផ្អៀងរកកល់លិច ព្រោះមានចំណុះលើសលប់ ដូចនេះ បុគ្គលិកធ្វើការ ក៏សម្រេចចិត្តបោះវត្ថុមួយចំនួន ដែលជារបស់អតិថិជន ចូលទៅក្នុងសមុទ្រខ្លះ។ **ឧទាហរណ៍២ ៖** រថយន្តក្រុងរបស់រដ្ឋ បានបើកបរយ៉ាងលឿន។ ពេលកំពុងបើកបរ ស្រាប់តែឃើញរថយន្តមួយ ឈប់កណ្តាលផ្លូវ រថយន្តក្រុងរបស់រដ្ឋ បានចាប់ហ្វ្រាំង តែមិនស៊ី ក៏សម្រេចចិត្តកាច់ចង្កូតទៅបុករបងផ្ទះ អ្នកជិតខាង។ ក្នុងករណីទាំងពីរខាងលើនេះ ឃើញថា រដ្ឋ ពិតជាមានកំហុសមែន តែដោយសារស្ថានភាពចាំបាច់ រដ្ឋបានបង្កការខូចខាតលើវត្ថុ ដល់ប្រជាពលរដ្ឋ ដូចនេះ រដ្ឋគ្រាន់តែសងការខូចខាត ឬ ជួសជុលវត្ថុដែលបង្កជាព្យសនកម្មប៉ុណ្ណោះ ចំពោះសំណងផ្សេងៗ រដ្ឋមិនទទួលខុសត្រូវឡើយ។

**ឃ.៧.ការយល់ព្រមពីជនរងគ្រោះ**

ជាការសុខចិត្តលើការខូចខាតដោយជនរងគ្រោះ សម្រាប់ការខូចខាតជាសម្ភារៈ ឬ លើរាង-កាយ។ ការយល់ព្រមលើការខូចខាតខាងសម្ភារៈ ធ្វើឱ្យរដ្ឋរួចផុតពីការទទួលខុសត្រូវ។

មាត្រា១៣៤ នៃក្រឹត្យ-ច្បាប់លេខ៣៨ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៨៨ បានបញ្ញត្តថា៖ “*ប្រសិនបើការខូចខាតបានកើតឡើងដោយមានការព្រមព្រៀងពីជនរងគ្រោះ ហើយអំពើនោះគ្មានប៉ះពាល់ ឬ គំរាមកំហែងដល់ប្រយោជន៍សង្គមទេ នោះមិនត្រូវឱ្យមានការជួសជុលសំណងនៃការខូចខាតឡើយ* ”។ មាត្រា៧៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានបញ្ញត្តថា៖ “*អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសម្នាក់អ្នករងគ្រោះ។ ប៉ុន្តែ បទបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយក គ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថា សមហេតុផល*”។ ការយល់ព្រមពីជនរងគ្រោះទាំងឡាយ មិនត្រូវឱ្យមានការទទួលខុសត្រូវពីរដ្ឋឡើយ ដូចជា ពេលធ្វើការវះកាត់ បុគ្គលិកពេទ្យ (រដ្ឋ) បានធ្វើកិច្ចសន្យាយល់

ព្រមពីជនរងគ្រោះ។ ប្រសិនបើ ការយល់ព្រមនេះ មានលក្ខណៈមិនសមហេតុផល ទៅតាមសង្គម ដែលទទួលស្គាល់ រដ្ឋចាំបាច់ត្រូវតែមានការទទួលខុសត្រូវ។

**ឃ.៨.ការយល់ព្រមពីភយន្តរាយ**

លក្ខខណ្ឌនេះ ក៏មានលក្ខណៈស្រដៀង ទៅនឹងលក្ខខណ្ឌខាងលើដែរ (ការយល់ព្រមពីជន-រងគ្រោះ) ដោយគ្រាន់ថា ការយល់ព្រមនេះ គឺយល់ព្រមពីភយន្តរាយ ដែលបានកើតឡើង ក្រោយអំពើរបស់រដ្ឋ។ **និទស្សន៍៖** ក្រសួងអប់រំ យុវជន និង កីឡា បានជ្រើសរើស កីឡាករ ចូលរួមប្រដាល់ជាលក្ខណអន្តរជាតិមួយ។ មុនពេលប្រកួត កីឡាករម្នាក់ៗ បានទទួលយល់ព្រមពីភយន្តរាយទាំងឡាយរួចហើយ ក្រោយការប្រកួត ដូចជា បែកមុខ បែកមាត់ បាក់ធ្មេញ ថ្លោះដៃ គ្រេចជើង។ល។ ព្យសនកម្មនេះ កីឡាករ មិនអាចប្ដឹងទាមទារ ឱ្យក្រសួងជួសជុលសំណងខូចខាតបានឡើយ។

**ឃ.៩.ករណីពើបពះ**

គេហៅ ករណីពើបពះរាល់សម្មតិកម្ម ដែលក្នុងនោះការខូចខាតមានបុព្វហេតុ មួយមិនស្គាល់។ ករណីលើកលែង នៃករណីពើបពះនេះ មិនអាចលើកមកនិយាយបានទេ ក្នុងករណីនៃការទទួលខុសត្រូវពីកំហុស។ ត្រូវញែកឱ្យដាច់ប្រធានសក្តិ និង ករណីពើបពះ ព្រោះករណីពើបពះ មិនមែនជាបុព្វហេតុនៅក្រៅការខូចខាតទេ[១៣៥]។

**ឃ.១០.អំពើរបស់មន្ត្រីរាជការ ជាកំហុសបុគ្គល**

ដូចបានធ្វើការលើកបង្ហាញ នៅផ្នែកខាងលើរួចមកហើយ កំហុសបុគ្គលផ្ទាល់ខ្លួន របស់ភ្នាក់ងារសាធារណៈ ជាកំហុសមិនជាប់នឹងមុខងារ ហើយដែលគេអាចផ្ដាច់ចេញ ពីស្ថាប័នរដ្ឋបាល។ កំហុសដែលប្រព្រឹត្ត ក្រៅកន្លែងធ្វើការក្នុងឋានៈជាបុគ្គលឯកជន ជាកំហុសផ្ទាល់ខ្លួន[១៣៦]។

កំហុសបុគ្គល ឬ កំហុសផ្ទាល់ខ្លួននេះ ក៏អាចនាំឱ្យរដ្ឋរួចផុត ពីការទទួលខុសត្រូវ ក្នុងការសងការខូចខាតទាំងឡាយ ដែលបានកើតមានដល់ជនរងគ្រោះដែរ។ សំណងការខូចខាតក្នុងទីនេះ គឺជាកាតព្វកិច្ចទាំងស្រុង របស់បុគ្គលិករដ្ឋ មិនមែនរដ្ឋឡើយ។ **ឧទាហរណ៍៖ វុធ** ជានគរបាលយុត្តិធម៌ម្នាក់។ ក្រោយពីការងារ **វុធ** បានចូលរួមពិធីជប់លៀងមិត្តភក្តិ ពេលត្រលប់មកវិញ **វុធ** បានបើកបររថយន្ត កៀរបុរសម្នាក់ ដែលកំពុងជិះទោចក្រយានយន្តបណ្ដាលឱ្យបាក់ជើងម្ខាង និង មានរបួសច្រើនកន្លែង ព្រមទាំងមានការខូចខាត ដល់ទោចក្រយានយន្តយ៉ាងដំណំ។ ក្នុងករណីនេះ បុរសជាជនរងគ្រោះ មិនអាចប្ដឹងទាមទារសំណង ការខូចខាតពីរដ្ឋបានឡើយ ព្រោះកំហុសនេះ ជាកំហុសក្រៅម៉ោងបំពេញតួនាទី របស់មន្ត្រីរាជការ ដូច្នេះ រដ្ឋអាចរួចផុតពីការទទួលខុសត្រូវ។

[១៣៥] ឡៅ ពិដោរ, នីតិរដ្ឋបាលទូទៅ, (ភ្នំពេញ, ២០១៥), ទំព័រ២២០

[១៣៦] ឥន យឿន, នីតិវិវាទរដ្ឋបាល, (ភ្នំពេញ, ២០១៦), ទំព័រ៣៣៣

**ឃ.១១.ផុតអាជ្ញាយុកាល**

ជនរងគ្រោះ មានរយៈពេលក្នុងការទាមទារសំណង នៃការខូចខាត ពីរដ្ឋចំនួន៣ ឆ្នាំ។ ប្រសិនបើ បានដឹងហើយឮហើយ ពីអត្ថិភាពនៃសិទ្ធិ ក្នុងការប្តឹងទាមទារសំណងពីរដ្ឋ ដែលមានរយៈ-ពេល៣ ឆ្នាំ តែមិនប្តឹង នោះនាំឱ្យផុតអាជ្ញាយុកាលនៃការទាមទារ។ ប៉ុន្តែ បើមិនបានដឹងពីអត្ថិភាពនៃសិទ្ធិ និង រយៈពេលនៃការទាមទារនោះទេ មាត្រា៧៦៥ នៃក្រមរដ្ឋប្បវេណី បានទុកសិទ្ធិឱ្យជនរង-គ្រោះចំនួន១០ ឆ្នាំ ក្នុងការប្តឹងទាមទារសំណង។ ផុតរយៈពេល១០ ឆ្នាំ ជនរងគ្រោះ លែងមានសិទ្ធិក្នុងការទាមទារហើយ ដូច្នេះ មានន័យថា រដ្ឋ ឬ ស្ថាប័នសាមីរួចផុត ពីការទទួលខុសត្រូវលើសំណងដល់ជនរងគ្រោះផងដែរ។

**ឃ.១២.ការខូចខាតបណ្តាលមកពីកងទ័ពបរទេសដែលមកស្នាក់នៅក្នុងប្រទេស**[១៣៧]

នៅក្នុងសៀវភៅនីតិរដ្ឋបាលទូទៅរបស់បណ្ឌិត សាយ បូរី ពុំបានបញ្ជាក់ទៅលើន័យខាងលើនេះឱ្យបានច្បាស់លាស់នោះទេ។ កម្ពុជា ធ្លាប់មានវត្តមានកងទ័ពបរទេស តាំងពីពេលដែលកម្ពុជាត្រូវបានរំដោះចេញពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានការចូលធ្វើអន្តរាគមន៍ពីសម្នាក់កងទ័ពវៀតណាម ឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩២ ទើបកងទ័ពវៀតណាម បានចេញពីកម្ពុជា បន្ទាប់មកកងទ័ពរបស់អង្គការសហប្រជាជាតិ ដែលហៅកាត់ថា **អ៊ុន តាក់** (UNTAC) បានចូលមកប្រទេសកម្ពុជា ដើម្បីរៀបចំសណ្តាប់ធ្នាប់ និង រៀបចំការបោះឆ្នោតជាសកលមួយនៅឆ្នាំ១៩៩៣។វត្តមានរបស់កងទ័ពវៀតណាម និង កងទ័ពអ៊ុនតាក់នៅកម្ពុជា តែងមានបង្កការខូចខាតដល់ប្រជាពលរដ្ឋ។ ប្រការនេះ រដ្ឋអាចគេចផុត ពីការទទួលខុសត្រូវផងដែរ។

**ឃ.១៣.ការខូចខាតដោយសារសង្គ្រាមបរទេស**

គ្រប់ប្រវត្តិសាស្ត្រនៃសង្គ្រាមទាំងអស់នៅសកលលោក គេតែងសង្កេតឃើញថា ភាពមហន្ត-រាយ ដែលកើតមានឡើងដល់ប្រទេសភាគីនៃសង្គ្រាម មិនត្រឹមតែបង្កព្យសនកម្ម ផ្នែកហេដ្ឋារចនា-សម្ព័ន្ធរបស់រដ្ឋប៉ុណ្ណោះទេ តែជាវិនាសកម្មដ៏ធំធេង ដល់ប្រជាពលរដ្ឋ ដែលព្យសនកម្មមានដូចជា ៖ លើសម្ភារៈ បាត់បង់ផ្ទះសម្បែង ដីធ្លី វត្ថុ។ល។ ខាងរូបរាងកាយ ពិការភាព ស្លាប់បាត់បង់ជីវិត ផ្នែកសតិអារម្មណ៍ បាត់បង់សាច់ញាតិ គ្រួសារ។ល។

ដូចនៅប្រទេសបារាំង ក្នុងសម័យសង្គ្រាមលោកលើកទី១ មានការចូលឈ្លានពាន ដោយកងទ័ពអាល្លឺម៉ង់ (ឆ្នាំ១៩១៤ ដល់ ១៩១៩) បានបង្កឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ ដល់ពលរដ្ឋបារាំង។ ប្រការនេះរដ្ឋការបារាំង ពុំមានលទ្ធភាពក្នុងការសងការខូចខាតឡើយ ព្រោះទើបចេញពីសង្គ្រាម ចំណែកអ្នកដែលមានកាតព្វកិច្ចទទួលខុសត្រូវ គឺរដ្ឋបង្កសង្គ្រាម (អាល្លឺម៉ង់)។ ក្រោយសង្គ្រាមលោកលើកទី១ បានបង្កើតឱ្យមានសន្ធិសញ្ញា វែកសៃ (Versailles) ឡើង ហើយក្នុងសន្ធិសញ្ញា

[១៣៧] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ ប្លុស្បុំ ឡូទឹស,២០១២), ទំព័រ៣៦២

នេះ បានបង្ខំឱ្យប្រទេសអាល្លឺម៉ង់ ត្រូវតែទទួលស្គាល់ការទទួលខុសត្រូវ របស់ខ្លួននៅក្នុងការបង្កសង្គ្រាម[១៣៨]។ សន្ធិសញ្ញាវែកសៃ ត្រូវបានទទួលយកដោយប្រទេសអាល្លឺម៉ង់ដ៍ តាមរយៈសភា **វៃម៉ារ (Weiar)** ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩១៩។ តាមរយៈសន្ធិសញ្ញានេះ ប្រទេសអាល្លឺម៉ង់ដ៍ ដែលជាមេដើមនៃសង្គ្រាមលោកលើកទី១ និង ជាប្រទេសដែលទទួលបរាជ័យ ត្រូវបំពេញនូវកាតព្វកិច្ចមួយចំនួន ដូចជា ត្រូវប្រគល់ទឹកដី Alsace និង Lorraine ទៅឱ្យប្រទេសបារាំងវិញ ប្រទេសអាល្លឺម៉ង់ដ៍ត្រូវសន្យាសង និង ជួសជុលរាល់ការខូចខាតទាំងឡាយ ដែលបណ្តាលមកពីសង្គ្រាម ពិសេសប្រជាជនស៊ីវិល[១៣៩]។ល។

ក្នុងទម្រង់ ថ្វីត្បិតតែ រដ្ឋបរទេស (អាល្លឺម៉ង់ដ៍) មិនបានសងការខូចខាត ដោយផ្ទាល់ទៅប្រជាពលរដ្ឋ (បារាំង) ដែលខ្លួនបង្កសង្គ្រាមក៏ពិតមែន តែបានសងការខូចខាតដោយប្រយោល តាមរយៈតំណាងនៃរដ្ឋទទួលរងគ្រោះ។ កន្លងមក បញ្ហាសង្គ្រាមនេះ ត្រូវបានប្រទេសមួយចំនួនក្នុងតំបន់បានអនុម័តច្បាប់នានា ដើម្បីគ្រប់គ្រង ប្រសិនបើ រដ្ឋណាមិនគោរពទៅតាមលក្ខខណ្ឌ ដែលបានកំណត់ នាំឱ្យការទទួលខុសត្រូវ កាន់តែមានបន្ទុកធ្ងន់មួយកម្រិតទៀត។ លិខិតូបករណ៍ទាំងនោះមានដូចជា៖

- សេចក្តីប្រកាសទីក្រុងបារីស ឆ្នាំ១៨៥៦ ស្តីពីកម្រិតនៃការធ្វើសង្គ្រាមតាមសមុទ្រ។
- អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៨៦៥ ស្តីពីការសង្គ្រោះមនុស្ស និង ជនរងគ្រោះតាមសមរភូមិ។
- អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៨៩៩ ស្តីពីទំនាក់ទំនងរវាងរដ្ឋធ្វើសង្គ្រាម និង វិធីដោះស្រាយ។
- អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩០៧ ស្តីពីសិទ្ធិ និង កាតព្វកិច្ចនៃរដ្ឋក្នុងសមរភូមិ និង រដ្ឋអព្យាក្រឹត្យក្នុងសង្គ្រាម និង ការគ្រប់គ្រងប្រភេទ នៃសព្វាវុធដែលប្រើប្រាស់ក្នុងសង្គ្រាម។
- អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩២៩ ស្តីពីការព្យាបាលជំងឺ និង ជួយសង្គ្រោះឈ្លើយសឹក។
- ធម្មនុញ្ញអាត្លង់ទិក ឆ្នាំ១៩៤១ ដោយប្រធានាធិបតីអាម៉េរិក លោក **ហ្វ្រង់គ្លីន រ៉ូស្វែល** និង នាយករដ្ឋមន្ត្រីអង់គ្លេស **វិនស្តុន ឆឺឈីល** អំឡុងសង្គ្រាមលោកលើកទី២[១៤០]។ល។

ការរួចផុតពីការទទួលខុសត្រូវនេះ មិនមានលក្ខណៈដាច់ខាតឡើយ ពោលគឺ រដ្ឋសាមី ក៏នឹងមានការសងការខូចខាត ឬ ផ្តល់ជាអំណោយដល់ពលរដ្ឋ ដោយផ្អែកទៅតាមគោលការណ៍សមធម៌ (Équité) និង ភាពជាអាណាព្យាបាលលើប្រជាពលរដ្ឋ។ ប៉ុន្តែ គោលការណ៍ខាងលើនេះ អាចនាំឱ្យរដ្ឋមិនអាចគេចផុតពីការទទួលខុសត្រូវឡើយ ប្រសិនបើ ឈរលើទ្រឹស្តី**រាជសក្តិ (Fait du Prince)** ដែលវា ជាគោលការណ៍ខាងរដ្ឋបាលសុទ្ធសាធ។

[១៣៨] អ៊ុន យ៉េត, កម្រងព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រសកលលោក, (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៥), ទំព័រ ៨៦

[១៣៩] ខៀវ ថវិកា, នីតិព្រហ្មទណ្ឌអន្តរជាតិ, (ភ្នំពេញ៖ គីម សូគិ, ២០១១) ទំព័រ១០២

[១៤០] នៅសកភាជ, ទំនាក់ទំនងអន្តរជាតិ៖ ទ្រឹស្តី និង ជាក់ស្តែងនិយម (ភ្នំពេញ៖ Makara Delivering Agency. MIDA, ២០១៥), ទំព័រ ១៤៨

ទ្រឹស្តីរាជសក្តិ ជាអំពើទាំងឡាយណា ដែលប្រព្រឹត្តឡើង ដោយភាគីដែលមានអំណាចសាធារណៈ ដើម្បីផ្លាស់ប្តូរលក្ខខណ្ឌ នៃកិច្ចសន្យា ជាឯកតោភាគី។ ទ្រឹស្តីនេះ មាននៅក្នុងរឿងក្តីមួយ នៅក្រុង " ប៊ិកដូ " (Bordeaux)។ អាជ្ញាធរក្រុង "ប៊ិកដូ" បានធ្វើកិច្ចសន្យាសម្បទានសេវាឧស្ម័នចែកចាយលក់ឱ្យសាធារណជនមួយ ជាមួយនឹងក្រុមហ៊ុនមួយឈ្មោះ "ក្រុមហ៊ុនធំបំភ្លឺក្រុងប៊ិកដូ" (Campagnie Gérérale d'éclairage de Bordeaux) ក្នុងខែមករា ឆ្នាំ១៩១៥។ តម្លៃធ្យូង ខែមករា ១៩១៥ ស្មើនឹង៣៥ ហ្វ្រង់ ក្នុងមួយតោន នៅពេលចុះកិច្ចសន្យា។ ដោយសារសង្គ្រាម ទ័ពអាល្លឺម៉ង់ដ៍បានកាន់កាប់គ្រប់តំបន់ ដែលមានធ្យូងទាំងអស់ ហើយអំពើនេះ បានបណ្តាលឱ្យតម្លៃធ្យូងឡើងថ្លៃជាលំដាប់។ នៅខែមីនា ១៩១៦ តម្លៃធ្យូងឡើងដល់១១៧ ហ្វ្រង់ ក្នុង១ តោន គឺ ជាងបីដងក្នុងតម្លៃឆ្នាំ ១៩១៥។ ចៃដន្យសេដ្ឋកិច្ចនេះធ្ងន់ធ្ងរណាស់ ហើយក៏មិនមែនជារឿងចៃដន្យ ដែលគេអាចបង្ការទុកជាមុនបានដែរ។ សង្គ្រាមជាកាលៈទេសៈពិសេស សម្រាប់ស្ថានភាពសេដ្ឋកិច្ច ដែលគ្មាននរណាអាចប៉ាន់ស្មានបាន ឱ្យត្រឹមត្រូវកើតឡើយ។

ក្រុមហ៊ុននោះ ក៏ធ្វើសំណើទៅអាជ្ញាធរក្រុង "ប៊ិកដូ" សុំតម្លើងថ្លៃលក់ឧស្ម័ន និង សុំឱ្យរដ្ឋាភិបាល ជួយទប់ទល់ការខាតបង់ផង ដោយបានលើកហេតុផលគ្រប់សព្វ។ អាជ្ញាធរក្រុង "ប៊ិកដូ" មិនយល់ព្រម ឱ្យតម្លើងថ្លៃលក់ ពីព្រោះគេចាត់ទុក ជាការធម្មតារបស់អ្នករកស៊ី គឺមានខាត មានចំណេញ។ ក្រុមហ៊ុនត្រូវតែចេះគិតប៉ាន់ស្មានទុកជាមុន មុននឹងយល់ព្រមតម្លៃជាមួយអាជ្ញាធរ។ បើក្រុមហ៊ុន ធ្វើការគណនាខុស វាជារឿងផ្ទាល់របស់ក្រុមហ៊ុន រដ្ឋការមិនត្រូវដឹងឮទេ។

ចំពោះសេចក្តីសម្រេចមិនយល់ព្រមនេះ ក្រុមហ៊ុនមិនសុខចិត្តហើយក៏ប្តឹងទៅ "ក្រុមប្រឹក្សាប្រេហ្វេចទារ" (Conseil de préfecture) ដែលសម័យនោះ ជាតុលាការរដ្ឋបាលជាន់ដំបូង។ គេអាចប្តឹងឧទ្ធរណ៍ទៅ "កុងសីដេតា" ដែលជាអ្នកសម្រេចកាត់ចុងក្រោយ។ រឿងនេះ ឡើងដល់ "កុងសីដេតា"។ "កុងសីដេតា" យល់ឃើញថា ក្រុមហ៊ុននោះ ពុំដែលបានឈប់បម្រើសេវាឧស្ម័ន ដូច្នេះ ពុំដែលមានកំហុសជាមួយនឹងខសន្យា។ រីឯការសុំតម្លើងថ្លៃលក់ និង សុំឱ្យរដ្ឋការជួយសង្គ្រោះ ដល់ការខាតបង់ ដែលបណ្តាលមក ពីហេតុក្រឡាប់ចាក់នៃស្ថានភាពសេដ្ឋកិច្ច ក្នុងពេលសង្គ្រាមនេះ ជាការសមហេតុផល។ ការឡើងចុះតម្លៃតាមទីផ្សារធម្មតា ឬ តាមកាលៈទេសៈសេដ្ឋកិច្ចធម្មតា គេទុកជាការចៃដន្យសេដ្ឋកិច្ចធម្មតាហើយពេលនោះ ក្រុមហ៊ុនពុំត្រូវសុំតម្លើងថ្លៃអ្វីមែន។ ប៉ុន្តែ នេះជាស្ថានភាពសង្គ្រាម ដែលធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចក្រឡាប់ចាក់ ពុំអាចនឹងប៉ាន់ស្មានបាន ពេលចុះកិច្ចសន្យានោះ។ "កុងសីដេតា" ក៏បានសម្រេចឱ្យក្រុង "ប៊ិកដូ" ជួយសង្គ្រោះក្រុមហ៊ុន ដោយសងការខាតបង់មួយភាគធំ និង ឱ្យគិតគូរឿងតម្លើងថ្លៃឧស្ម័នឡើងវិញ ដើម្បីឱ្យក្រុមហ៊ុនអាចបម្រើសេវាសាធារណៈ បន្តទៅទៀតបាន[១៩១]។

[១៩១] សាយ បូរី, នីតិរដ្ឋបាលទូទៅ, បោះពុម្ពលើកទី៤, (ភ្នំពេញ៖ បួស្សំ ឡូទឹស, ២០១២) ទំព័រ ៣៨៤

ក្រោយការវិនិច្ឆ័យសេចក្ដីចប់សព្វគ្រប់ហើយ មន្ត្រីរាជការ អាចប្រឈមមុខជាមួយនឹងរដ្ឋ ឬ ស្ថាប័នសាមី ក្នុងករណី ដែលមន្ត្រីរាជការរូបនោះ បានធ្វើកំហុសនោះធ្ងន់ធ្ងរ។

**ខ.ទំនាក់ទំនងរវាងរដ្ឋ និង មន្ត្រីរាជការ ក្រោយសំណងការខូចខាត**

ក្រោយការទាមទារសំណងការខូចខាត ពីរដ្ឋចប់សព្វគ្រប់ហើយ គឺឈានដល់ដំណាក់កាលមួយទៀត ដំណាក់កាលនេះ មិនមានជាប់ពាក់ព័ន្ធទៅនឹងភាគីជនរងគ្រោះនោះទេ តែវាជាប់ទាក់ទងផ្ទាល់រវាងមន្ត្រីរាជការ ឬ បុគ្គលិក និង រដ្ឋ ឬ ស្ថាប័នសាមី។ លក្ខខណ្ឌនេះ គឺស្ថិតក្នុងស្ថានភាពមួយដែលព្យសនកម្មកើតចេញពីកំហុសធ្ងន់ធ្ងរ របស់មន្ត្រីរាជការ ដូចនេះ នាំឱ្យរដ្ឋត្រូវធ្វើការទាមទារសំណងមកវិញ បន្ទាប់ពីបានធ្វើការជម្រះរឿងក្តីជាមួយជនរងគ្រោះ។ បើក្រឡេកមើល មាត្រា៧៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចែងថា "ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការចៀសវាងនូវលទ្ធផលមានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន"។ បទបញ្ញត្តិខាងលើនេះ បានចង្អុលបង្ហាញយ៉ាងច្បាស់ថា បើមន្ត្រីរាជការ ប្រព្រឹត្តកំហុសមានសភាពធ្ងន់ធ្ងរ រដ្ឋអាចទារសំណងពីមន្ត្រីរាជការនោះវិញ។ ដោយឡែកមាត្រានេះ មិនបានកំណត់និយមន័យ នៃការបំពានករណីយកិច្ច ដែលមានសភាពធ្ងន់ធ្ងរ ឱ្យបានច្បាស់លាស់នោះទេ ដូចនេះនាំឱ្យពិបាកក្នុងការបកស្រាយ ហើយករណីនេះ វាអាស្រ័យទៅលើការវិនិច្ឆ័យទាំងស្រុងរបស់ចៅក្រម ដែលកំណត់ថាកំហុសបែបណាចាត់ចូលជាកំហុសធ្ងន់ (ង.១.) ? ហើយ កំហុសបែបណា ដែលចាត់ចូលជាកំហុសស្រាល? ម្យ៉ាងវិញទៀត បើក្នុងករណីជាកំហុសព្រហ្មទណ្ឌ (ង.២.) ប្រព្រឹត្តឡើងដោយមន្ត្រីរាជការតើរដ្ឋ ឬ ស្ថាប័នសាមី ត្រូវមានការទទួលខុសត្រូវយ៉ាងដូចម្ដេច?

**ខ.១.កំហុសធ្ងន់ធ្ងរ**

សញ្ញាណនៃកំហុសធ្ងន់ធ្ងរ ដែលប្រព្រឹត្តឡើងដោយមន្ត្រីរាជការ បើក្រឡេកមើលរដ្ឋធម្មនុញ្ញគឺមានបញ្ញត្តពីបញ្ហានេះ។ មាត្រា១២៦ កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ញត្តថា "ក្នុងករណីនេះ និង ក្នុងករណីធ្វើខុសជាទម្ងន់ ក្នុងការបំពេញការងាររបស់ខ្លួនរដ្ឋសភាអាចសម្រេចប្ដឹងទៅតុលាការមានសមត្ថកិច្ច"។ យោងតាមបទបញ្ញត្តិនេះ រដ្ឋអាចធ្វើការទាមទារ សំណងពីមន្ត្រីរាជការ បានក្នុងលក្ខខណ្ឌ ទី១ ៖ មន្ត្រីរាជការប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ទី២ ៖ កំហុសនោះ ប្រព្រឹត្តក្នុងពេលបំពេញការងារ។ បើក្រឡេកមើលប្រទេសបារាំង រហូតដល់ឆ្នាំ១៩៥១ ការទទួលខុសត្រូវរបស់មន្ត្រីរាជការ ចំពោះរដ្ឋបាលទាំងនៅក្នុងករណី ដែលមន្ត្រីរដ្ឋការបានបង្កការខូចខាតចំពោះរដ្ឋបាល ក៏ដូចជា ក្នុងករណីដែលការត្រួតគ្នានៃការទទួលខុសត្រូវ ដែលរដ្ឋបាលត្រូវទទួលទណ្ឌកម្មទាំងអស់។ ក្នុងករណី ចុងក្រោយ ជាពិសេស រដ្ឋ មិនអាចងាកបកមកប្រឆាំងនឹងភ្នាក់ងារ ដើម្បីទទួលបានការសងទាំងស្រុង ឬ ដោយផ្នែកនៃចំនួនទឹកប្រាក់ ដែលរដ្ឋត្រូវចេញសង

នោះទេ។ កាលនោះប្រព័ន្ធនេះអាក្រក់ខ្លាំងណាស់ ការទទួលខុសត្រូវត្រួតគ្នាវាជាទូទៅ ទៅហើយ។ ក្នុងឆ្នាំ១៩៥១ យុត្តិសាស្ត្រ បានកំណត់នូវវិធានថ្មី ក្នុងសេចក្តីសម្រេចដ៏សំខាន់ពីរ (Ass, 28 juillet 1951, Laruelle, Rec., 464 Defville, Rec., 464) ដែលបានបញ្ចប់របបដែលបានកើតឡើង ដោយយុត្តិសាស្ត្រ Pelletier។

- ការជ្រើសរើសដោយជនរងគ្រោះ ប្រើក្នុងករណីមានការត្រួតគ្នា ទាក់ទងតែនៅនឹងវិភាគទាន បណ្តោះអាសន្ន។
- វិភាគទានស្ថាពររបស់រដ្ឋបាល និង របស់ភ្នាក់ងារអាចត្រូវដោះស្រាយ ដោយចៅក្រមរដ្ឋ-បាល ដោយគិតពីអត្ថិភាព និង ភាពធ្ងន់ធ្ងរ នៃកំហុសរៀងខ្លួន ដែលបានកត់ហេតុ ក្នុងរឿងក្តីនីមួយៗ។
- ភ្នាក់ងារសាធារណៈ ត្រូវទទួលខុសត្រូវជាទឹកប្រាក់ចំពោះរដ្ឋបាល ពីកំហុសដែលខ្លួនបានប្រព្រឹត្ត កាលណាកំហុសនោះ មិនជាប់ទាក់ទងនឹងសេវា។
- បណ្តឹងឧបាស្រ័យ របស់រដ្ឋបាលប្រឆាំងនឹងភ្នាក់ងារ មិននាំឱ្យមានការជំនួសសិទ្ធិជនរង-គ្រោះទេ។ ជនរងគ្រោះ អាចប្តឹងផ្ទាល់ប្រឆាំងនឹងភ្នាក់ងារ[១៤២]។

**ខ.២.កំហុសព្រហ្មទណ្ឌ**

ជាដំបូងរាល់កំហុសព្រហ្មទណ្ឌ ដែលជាបទឧក្រិដ្ឋ ឬ បទមជ្ឈិម គួរតែជាកំហុសជាបុគ្គល ព្រោះគេមិនអាចគិតថា សេវាកម្មនៃមន្ត្រីសាធារណៈម្នាក់ តម្រូវឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ។ កំហុសព្រហ្មទណ្ឌមួយចំនួន មិនមែនជាកំហុសជាបុគ្គលទេ។

រាល់បទល្មើសព្រហ្មទណ្ឌ មិនចាំបាច់កើតចេញពីកំហុសជាបុគ្គលនោះទេ។ មានបទល្មើសព្រហ្មទណ្ឌមួយចំនួន ជាផលវិបាកនៃកំហុសរបស់សេវា។ ជាអាទិ៍ ករណីនៃបទមជ្ឈិម នៃការធ្វេស-ប្រហែស។ ការភន្តច្រឡំជាធម្មតានៃការប្រកាន់ឥរិយាបថក្នុងពេលធ្វើការ មិនមែនជាកំហុសជាបុគ្គលទេ។ ឧទាហរណ៍ ការក្លែងបន្លំនៃប្លង់កាន់កាប់ដី ដើម្បីអាចផ្តល់លិខិតអនុញ្ញាតសាងសង់។ រាល់កំហុស ជាបុគ្គលមិនមែនសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌនោះទេ។ មានតែតុលាការព្រហ្មទណ្ឌប៉ុណ្ណោះ ដែលជាចៅក្រម នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ ជាញឹកញាប់ណាស់ បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តឡើង ដោយមន្ត្រីរាជការ ដោយមានជាប់ទាក់ទង ជាមួយនឹងសេវា របស់ខ្លួនជាកំហុសជាបុគ្គល។ ប៉ុន្តែ ភ្នាក់ងារសាធារណៈ ដែលកំពុងកាន់មុខងារ ឬ ចេញពីតំណែង ហើយដោយយោងតាមលក្ខន្តិកៈរបស់ខ្លួនមានសិទ្ធិទទួលបាន ការការពារពីស្ថាប័នរបស់ខ្លួន ក្នុងករណីដែលពួកគេធ្វើជាកម្មវត្ថុ នៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ នៅឱកាសនៃហេតុការណ៍ដែលគ្មានលក្ខណៈជាកំហុសជាបុគ្គល។

[១៤២] ឡៅ ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៧៦ ដល់ ទំព័រ២៧៧

ការទទួលខុសត្រូវព្រហ្មទណ្ឌ នៃភ្នាក់ងារសាធារណៈបានរីកចម្រើនថ្មីៗនេះច្រើន ក្នុងប្រទេសបារាំង ជាមួយនឹងច្បាប់នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ដែលទាមទារឱ្យមានកំហុសខ្លាំងរបស់ចារីប្រយោល នៃបទល្មើសខាងកំហុស នៃការធ្វេសប្រហែស។ មាត្រា១២១៣ នៃក្រមព្រហ្មទណ្ឌបារាំងចែងយ៉ាងដូចនេះថា ខាងបទមជ្ឈឹមនៃការធ្វេសប្រហែស រូបវន្តបុគ្គល ដែលមិនបានបង្កការខូចខាតដោយផ្ទាល់ទេ ប៉ុន្តែ បានបង្កើត ឬ បានរួមចំណែកបង្កើតស្ថានភាព ដែលអាចឱ្យសម្រេចបាន នៃការខូចខាត ឬ ដែលមិនបានចេញវិធានការ ដើម្បីចៀសវាងវាត្រូវទទួលខុសត្រូវពីបទព្រហ្មទណ្ឌ ប្រសិនបើ គេរកឃើញថា ពួកគេបានរំលោភយ៉ាងច្បាស់ក្រឡែត នូវកាតព្វកិច្ចដោយឡែក នៃការប្រយត្នប្រយែង ឬ រំលោភកាតព្វកិច្ច នៃសន្តិសុខចែងដោយច្បាប់ ឬ បទបញ្ជា ឬ ប្រព្រឹត្តកំហុសជាក់លាក់ ហើយដែលបង្ហាញនូវហានិភ័យចំពោះអ្នកដទៃ ដោយធ្ងន់ធ្ងរដែលខ្លួនមិនអាចមិនដឹងបានទេ។ ភាពទន់ភ្លន់នៃវិធាន នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ ឆ្លើយតបទៅនឹងការព្រួយបារម្មណ៍ របស់ភ្នាក់ងារប្រឈមទៅនឹងការកើនឡើង នៃការចោទប្រកាន់ ក្នុងការបំពេញមុខងាររបស់ពួកគេ[១៩៣]។ អំពើរបស់មន្ត្រីរាជការ ដែលមានលក្ខណៈជាកំហុសព្រហ្មទណ្ឌ ពេលខ្លះរដ្ឋ ក៏ត្រូវមានការទទួលខុសត្រូវផងដែរ ដែលការទទួលខុសត្រូវនេះ ស្តែងចេញផ្នែកសំណងរដ្ឋប្បវេណី ចំណែកទោសព្រហ្មទណ្ឌ គឺមន្ត្រីរាជការទទួលខុសត្រូវ។

អំពើអនីត្យានុកូល របស់មន្ត្រីរាជការ ត្រូវបានកើតមានឡើងជាហូរហែ នៅក្នុងប្រទេសកម្ពុជា ដែលអំពើខ្លះត្រូវបាន ជនរងគ្រោះប្តឹងទាមទារសំណង រីឯអំពើដែលជាកំហុសខ្លះទៀតជនរងគ្រោះ មិនបានធ្វើការប្តឹងផ្តល់អ្វីឡើយ។ ខាងក្រោមនេះ គឺជាសាលដីកា របស់តុលាការកំពូលចាប់ពីឆ្នាំ១៩៩៥ រហូតមកដល់ឆ្នាំ២០០៦ ដែលត្រូវបានលើកយកមកពិភាក្សា ពាក់ពន្ធទៅនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ។

## ផ្នែកទី៣
## សាលដីកា ទាក់ទងនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ

ក្នុងប្រទេសកម្ពុជា បានលេចចេញសញ្ញាណមួយ ដែលប្រជាពលរដ្ឋ ចាប់ផ្តើមប្តឹងតវ៉ាទាមទារ ពីសម្មាក់រដ្ឋ ឱ្យមានការទទួលខុសត្រូវ លើអំពើរបស់មន្ត្រីរាជការ ដែលនាំឱ្យមានការប៉ះពាល់ ផ្សេងៗដល់ខ្លួន។ សញ្ញាណថ្មីនេះ ប្រជាពលរដ្ឋបានធ្វើការប្តឹងទាមទារ ទាំងផ្នែករដ្ឋប្បវេណី (កថាភាគទី១) ដែលមានដូចជា សំណងការខូចខាត ការលុបចោលប្រកាស សេចក្តីសម្រេចផ្សេងៗ និង ផ្នែកព្រហ្មទណ្ឌ (កថាភាគទី២) ប្តឹងសុំឱ្យមន្ត្រីរាជការទទួលខុសត្រូវព្រហ្មទណ្ឌ និង សំណងផ្សេងៗ ជាដើម។ ការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌរបស់មន្ត្រីរាជការនៅកម្ពុជា ពុំសូវលេចចេញជាករណី ដែលរដ្ឋត្រូវមានកាតព្វកិច្ចទទួលសំណង ផ្នែករដ្ឋប្បវេណី ជួសមន្ត្រីរាជការប៉ុន្មានទេ ព្រោះ

[១៩៣] ឌៀក ពិដោរ, ទ្រឹស្តីរដ្ឋបាលសាធារណៈ, (ភ្នំពេញ៖ ឈីវទីម៉ិច គ្រុប, ២០១០), កណ្ឌទី១, ទំព័រ២៦៩ ដល់ ទំព័រ២៧០

កំហុសរបស់មន្ត្រីរាជការភាគច្រើន សុទ្ធសឹងតែជាកំហុសបុគ្គលផ្ទាល់ មិនជាប់ពាក់ព័ន្ធនឹងរដ្ឋ ឬ ស្ថាប័នសាធារណៈ។

## កថាភាគទី១

## សាលដីកាតុលាការកំពូល សំណុំរឿងរដ្ឋប្បវេណី

រឿងក្ដីជាច្រើន ដែលទាក់ទងរវាងរដ្ឋ ឬ ស្ថាប័នសាធារណៈ និង បុគ្គលឯកជន ត្រូវបានវិនិច្ឆ័យក្នុងសំណុំរឿងរដ្ឋប្បវេណី (ក)។ ថ្វីបើ រឿងក្ដីទាំងអស់នេះ ត្រូវបានដាក់ក្នុងសំណុំរឿងរដ្ឋប្បវេណី ក៏ពិតមែន តែតាមពិត វាមានទាក់ទងនឹងវិវាទផ្នែករដ្ឋបាល (ខ) ជាច្រើន ដែលទាំងអស់នេះ សុទ្ធសឹងតែត្រូវញែកឱ្យបានច្បាស់ រវាងកំហុសរដ្ឋប្បវេណី និង កំហុសរដ្ឋបាល។

### ក.សាលដីកាតុលាការកំពូល សំណុំរឿងរដ្ឋប្បវេណី

រឿងក្ដីតុលាការកំពូល ដែលប្រជាពលរដ្ឋប្ដឹង រដ្ឋ ឬ ស្ថាប័នសាធារណៈ ចាប់តាំងពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០៦ ហាក់បីដូចជា មានចំនួនតិចតួចនៅឡើយ។ ហើយអ្វីដែលកាន់តែតិចតួច ជាងនេះទៅទៀត គឺរឿងក្ដី ដែលទាក់ទងទៅនឹងចំណុចនេះ ភាគតិចណាស់ ដែលតុលាការ បានសម្រេចឱ្យរដ្ឋចាញ់ក្ដី។ តុលាការកំពូល សម្រេចឱ្យរដ្ឋចាញ់ក្ដី និង ធ្វើសំណងការខូចខាតជូនប្រជាពលរដ្ឋ លើរឿងក្ដីមួយចំនួន ដូចមានក្នុងសាលដីកាលេខ២៧៥ (ក.១.) សាលដីកាលេខ១០ (ក.២.) សាលដីកាលេខ៣០ (ក.៣.) សាលដីកាលេខ៧៣ (ក.៤.)។

#### ក.១.សាលដីកាលេខ២៧៥ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៦ របស់តុលាការកំពូល[១៤៤]

សាលដីកាខាងលើនេះ ដោះស្រាយរឿងក្ដី ដែលកើតឡើងរវាងប្រជាពលរដ្ឋទាំង១១ គ្រួសារ ជាមួយនឹងរដ្ឋអំណាចខណ្ឌស្ទឹងហាវ លើវិវាទពាក់ព័ន្ធនឹងដីធ្លីទំហំ១១៤.៣៣២ ម$^{២}$ ដែលអភិបាលខណ្ឌស្ទឹងហាវ បានហាមឃាត់ ប្រជាពលរដ្ឋទាំង១១ គ្រួសារ មិនឱ្យធ្វើអាជីវកម្មលើដីនោះ ដោយសំអាងថា ដីនោះជាដីទុកបម្រុងរបស់រដ្ឋ។

ឈ្មោះ *ឯក សុផល* តំណាងឱ្យប្រជាពលរដ្ឋទាំង១១ គ្រួសារ បានដាក់ពាក្យបណ្ដឹងទៅតុលាការក្រុងព្រះសីហនុ។ តុលាការក្រុងព្រះសីហនុ បានសម្រេចថា ដីទំហំ១១៤.៣៣២ ម$^{២}$ ជាដីបម្រុងទុករបស់រដ្ឋ ហើយតុលាការ បានបង្ខំឱ្យពលរដ្ឋប្រគល់ដីនោះ ជូនអភិបាលខណ្ឌ និង ធ្វើការរុះរើសំណង់ ផ្ទះសម្បែងចេញជាបន្ទាប់។ លោក *ឯក សុផល* បានប្ដឹងមិនសុខចិត្ត ទៅសាលាឧទ្ធរណ៍។ សាលាឧទ្ធរណ៍ បានសម្រេចដូចគ្នា ទៅនឹងតុលាការក្រុងព្រះសីហនុដែរ។ លោក *ឯក សុផល* តំណាងឱ្យប្រជាពលរដ្ឋទាំង១១ គ្រួសារ បានសម្រេចចិត្តប្ដឹងសាទុក្ខទៅ តុលាការកំពូលទៀត។ តុលាការកំពូល សម្រេចមោឃភាពសាលដីការដ្ឋប្បវេណីលេខ១២០ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៦

[១៤៤] សូមមើល សាលដីកាលេខ២៧៥ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៦ របស់តុលាការកំពូល ក្នុងឧបសម្ពន្ធទី២ លេខ២.១.

របស់សាលាឧទ្ធរណ៍ចោលទាំងមូល។ តុលាការ បានបង្គាប់ឱ្យរដ្ឋអំណាចខណ្ឌស្ទឹងហាវ សងប្រាក់ទៅឱ្យ ឈ្មោះ *ឯក សុផល* ចំនួន១៩.០០០ (មួយម៉ឺនប្រាំបួនពាន់) រៀល។

រឿងក្តីក្តាំ ជាមួយស្ថាប័នរដ្ឋនេះ ប្រជាពលរដ្ឋទាំង១១ គ្រួសារ ហាក់ដូចជាមានសភាពក្លាហានហ៊ានប្តឹងតវ៉ា លើសេចក្តីប្រកាសរបស់អភិបាលខណ្ឌស្ទឹងហាវ លើការយកដីទំហំ១១៤.៣៣២ ម$^២$ ជាដីបម្រុងរបស់រដ្ឋ។ តាមពិតទៅដីទំហំ១១៤.៣៣២ ម$^២$ នោះ ប្រជាពលរដ្ឋ បានបង្កបង្កើនផល មុនសេចក្តីប្រកាសរបស់ខណ្ឌស្ទឹងហាវ ដែលកំណត់ទុកដីកើតហេតុ ទាំងមូលជាដី បម្រុងរដ្ឋ ឆ្នាំ១៩៩១ ទៅទៀត។ ដូចនេះ តុលាការកំពូល សុំបង្វិលរឿងនេះ ទៅឱ្យសាលាឧទ្ធរណ៍ ជំនុំជម្រះជាថ្មីឡើងវិញ ដើម្បីធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ និង កំណត់ពីម្ចាស់កម្មសិទ្ធិឱ្យបានច្បាស់លាស់ថែមទៀតលើដីទាំងនោះ។

**ក.២.សាលដីកាលេខ១០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការកំពូល[១៤៥]**

សាលដីការលេខ១០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការកំពូលរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា បានវិនិច្ឆ័យលើរឿងក្តី រវាងក្រុមហ៊ុនឯកជន ជាមួយនឹងស្ថាប័នរដ្ឋ ពាក់ព័ន្ធទៅនឹងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចាប់ឃាត់ទុកនូវទំនិញនាំចូល ៧ មុខ របស់ក្រុមហ៊ុន គឹម ហាប់ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៥ បានចោទប្រកាន់ពីបទរត់គេចពន្ធ និង នាំទំនិញខុសច្បាប់។ លោក *ជ័យ សំរិទ្ធិ* តំណាងក្រុមហ៊ុន *គឹម ហាប់* បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ។ តុលាការក្រុងភ្នំពេញ បានសម្រេចបង្គាប់មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យប្រគល់ទំនិញចំនួន ៧ មុខ ទៅឱ្យក្រុមហ៊ុន គឹម ហាប់ វិញ ដោយបង្គាប់ឱ្យក្រុមហ៊ុន គឹម ហាប់ បង់ពន្ធជូនរដ្ឋ តាមតម្លៃប្រកាស និង តាមតម្លៃអត្រាឆ្លងកាត់។ ព្រមទាំងលុបសេចក្តីសម្រេចលេខ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រង់ប្រការមួយ "១" ចំណុច ក និង ប្រការ "៣" ចំណុច ក ចោលជាអសារបង់។ លោក *ស ហូរ* (តំណាងក្រសួង) បានដាក់ពាក្យបណ្តឹង ទៅសាលាឧទ្ធរណ៍។ សាលាឧទ្ធរណ៍ បានសម្រេចបដិសេធសាលក្រម របស់តុលាការក្រុងភ្នំពេញចោល។ សម្រេចតម្កល់សេចក្តីសម្រេចលេខ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទុកជាត្រឹមត្រូវតាមច្បាប់ ប៉ុន្តែ អំពីការផាកពិន័យលើបារី និង សម្ភារៈផ្សាយពាណិជ្ជកម្ម និង រថយន្តចង្កូតឆ្វេង៦ គ្រឿង ត្រូវលើកចោល។ ឈ្មោះ *ស ហូរ* បានដាក់ពាក្យបណ្តឹងសាទុក្ខ ទៅតុលាការកំពូលជាបន្តទៀត។ តុលាការកំពូល បានសម្រេច តម្កល់សាលដីកា របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។ លើសពីនេះ តុលាការសម្រេចបង្គាប់ឱ្យក្រុមហ៊ុន គឹម ហាប់ បង់ពន្ធសមាមាត្រមួយភាគរយ លើចំនួនទឹកប្រាក់ផាកពិន័យ លើម៉ាស៊ីនភ្លើង៥៦ គ្រឿង $\frac{\text{២៨.៩២៨ ដុល្លារអាម៉េរិក×១}}{\text{១០០}}$ : ២៨.៩២៨ ដុល្លារអាម៉េរិក។

[១៤៥] សូមមើល សាលដីកាលេខ១០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការកំពូល ក្នុងឧបសម្ពន្ធទី២ លេខ២.២.

ក្នុងសេចក្ដីសម្រេច របស់តុលាការកំពូលរាជធានីភ្នំពេញ មិនបានបង្គាប់ឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សងការខូចខាត ដល់ក្រុមហ៊ុនឯកជននេះឡើយ ដោយហេតុមកពីក្រុមហ៊ុន ពុំបានទាមទារលើការខូចខាតផ្សេងៗ គ្រាន់តែឱ្យក្រសួង ប្រគល់នូវទំនិញមកខ្លួនវិញប៉ុណ្ណោះ។

**ក.៣.សាលដីកាលេខ៣០ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការកំពូល**[១៨៦]

នៅក្នុងឆ្នាំ២០០០ មានសាលដីកាមួយទៀត របស់តុលាការកំពូលរាជធានីភ្នំពេញ ដែលវិនិច្ឆ័យលើរឿងក្ដីរវាងក្រុមហ៊ុនវិនិយោគឯកជន ជាមួយនឹងសាលាខេត្តបាត់ដំបង ពាក់ព័ន្ធនឹងការបង្កើតស្តង់ត្រីថ្មី នៅខេត្តបាត់ដំបង។ រឿងរ៉ាវនេះ មានសេចក្ដីដូចតទៅ : កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ ក្រុមហ៊ុនវិនិយោគទុនអាជីវកម្ម "*ភាស៊ីស្តង់ត្រីស្រស់*" របស់អ្នកស្រី ជា ឆវិល័យ បានចុះកិច្ចសន្យាជាមួយអភិបាលខេត្តបាត់ដំបង ដោយមានការឯកភាពរបស់ក្រសួងសេដ្ឋកិច្ច ស្តីពីការវិនិយោគទុនអាជីវកម្មភាស៊ីស្តង់ត្រីស្រស់ (ទឹក-គោក) ខេត្តបាត់ដំបង។ តាមខ្លឹមសារនៃកិច្ចសន្យាខាងលើត្រង់ប្រការ២ ចំណុចទី៤ គឺ ភាគី (ក) អភិបាលខេត្តបាត់ដំបងបានអះអាងទប់ស្កាត់ មិនអនុញ្ញាតឱ្យមានបង្កើតស្តង់ត្រីថ្មីបន្ថែមទៀត ក្នុងខេត្តបាត់ដំបង។ មានន័យថា មានតែស្តង់ត្រីរបស់ក្រុមហ៊ុនខ្លួនតែម្នាក់គត់ ដែលមានសិទ្ធិធ្វើអាជីវកម្ម តាមកិច្ចសន្យាក្នុងខេត្តបាត់ដំបង។ ប៉ុន្តែអភិបាលខេត្ត បែរជាអនុញ្ញាតឱ្យឈ្មោះ សុខ សុខុន បង្កើតស្តង់ត្រីមួយទៀត ដែលមានទីតាំងនៅជិតក្រុមហ៊ុនរបស់ខ្លួន តាមដីកាសម្រេចលេខ១៤៥ ស.ស ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧។ ការនេះ គឺអភិបាលខេត្ត បានបំពានលើកិច្ចសន្យា ដែលបានធ្វើជាមួយក្រុមហ៊ុនរបស់ខ្លួន និង បណ្ដាលឱ្យបាត់បង់ផលប្រយោជន៍របស់ក្រុមហ៊ុនវិនិយោគទុនអាជីវកម្ម "*ភាស៊ីស្តង់ត្រីស្រស់*" យ៉ាងធ្ងន់ធ្ងរ។ ឈ្មោះ "ប៊ូ សារុន" (មេធាវីការពារឱ្យសាលាខេត្តបាត់ដំបង) បានប្ដឹងសុំឱ្យតុលាការខេត្តបាត់ដំបងបង្វែរសមត្ថកិច្ច នៃរឿងក្ដីរដ្ឋប្បវេណីលេខ១៣១ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៨ នេះ ឱ្យទៅជាសមត្ថកិច្ចសាច់រឿងវិវាទរដ្ឋបាល ដោយផ្អែកតាមគោលការណ៍ នៃនីតិសាធារណៈគឺ៖

១-បណ្ដឹងសុំឱ្យខេត្តគោរពកិច្ចសន្យា រវាងនីតិបុគ្គលសាលាខេត្ត និង រូបវន្តបុគ្គលឯកជន នោះជាវិវាទរដ្ឋបាល ព្រោះនីតិបុគ្គលសាធារណៈ មិនអាចមកទទួលខុសត្រូវរដ្ឋប្បវេណី ឬកាតព្វកិច្ចណាមួយ ជាមួយភាគីរូបវន្តបុគ្គលឯកជនបានឡើយ។ ម៉្យាងទៀត កិច្ចសន្យានេះ ធ្វើដោយខុសវិន័យពីនីតិវិធីរដ្ឋបាល ការងារនេះអាចបញ្ជាក់បានដោយអភិបាលខេត្ត និង មន្ត្រីដែលមានសមត្ថកិច្ចរបស់សាលាខេត្តជាបន្ទាល់។

២-ចំពោះការប្ដឹងរម្លាយ ដីកាសម្រេចលេខ១៤៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ នោះ គឺជាវិវាទរដ្ឋបាលពេញលេញ១០០% មិនអាចបំភន្តថា ជាវិវាទផ្សេងបានទេ ដែលបច្ចុប្បន្ននេះ វាស្ថិតនៅក្នុងសមត្ថកិច្ចសាច់រឿងវិវាទរដ្ឋប្បវេណីទៅវិញ។

---

[១៨៦] សូមមើល សាលដីកាលេខ៣០ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការកំពូល ក្នុងឧបសម្ពន្ធទី២ លេខ២.៣.

៣-ការប្ដឹងសុំឱ្យ សុខ សុខុន រុះរើស្ដង់ត្រីថ្មីចេញនោះ ក៏ជាវិវាទនៃសមត្ថកិច្ចសាច់រឿងរដ្ឋបាលយ៉ាងពេញលេញដែរ ព្រោះថា ភាគីទាំង២ មិនអាចទំនាក់ទំនងរដ្ឋប្បវេណីកាតព្វកិច្ចអ្វីរវាងគ្នាដាច់ខាត ព្រោះថា ស្ដង់ត្រីអ្នកស្រី សុខ សុខុន កើតឡើងតាមច្បាប់ជាធម្មានុរូប។

តុលាការខេត្តបាត់ដំបង បានសម្រេចបដិសេធចោលពាក្យបណ្ដឹងរបស់ឈ្មោះ "ប៊ូ សារុន"។ ក្រោយមក ឈ្មោះ "ប៊ូ សារុន" នេះ បានដាក់ពាក្យបណ្ដឹងទៅសាលាឧទ្ធរណ៍។ សាលាឧទ្ធរណ៍បានចេញសេចក្ដីសម្រេច តម្កល់សាលក្រមតុលាការបាត់ដំបង ទុកជាបានការពេញទាំងមូល។ ក្រោយមកទៀត ឈ្មោះ "ប៊ូ សារុន" បានប្ដឹងសាទុក្ខទៅតុលាការកំពូលបន្តទៀត។ តុលាការកំពូល បានសម្រេចតម្កល់សាលដីកា សាលាឧទ្ធរណ៍ទុកជាបានការដដែល។

ក្នុងរឿងក្ដីខាងលើនេះ សាលាខេត្តបាត់ដំបង បានចុះកិច្ចសន្យាទ្វេភាគី រវាងរដ្ឋ-ឯកជនលើការវិនិយោគផ្ដាច់មុខ នូវស្ដង់ត្រីក្នុងតំបន់ ដោយឡែកសាលាខេត្ត បានរំលោភលើកិច្ចសន្យាអនុញ្ញាតឱ្យមានការវិនិយោគស្ដង់ត្រីផ្សេងទៀត នាំឱ្យបាត់បង់ប្រយោជន៍របស់ក្រុមហ៊ុនវិនិយោគ-ទុនអាជីវកម្ម "*ភាសីស្ដង់ត្រីស្រស់* "។ រឿងក្ដីនេះ តុលាការកំពូល បានសម្រេចឱ្យក្រុមហ៊ុនឯកជនឈ្នះទាំងស្រុង លើនីតិបុគ្គលសាធារណៈ។

**ក.៤.សាលដីកាលេខ៧៣ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ របស់តុលាការកំពូល**[១៩៧]

សាលដីកានេះ តុលាការកំពូលរាជធានីភ្នំពេញ បានកាត់ក្ដីឱ្យប្រជាពលរដ្ឋឈ្នះក្ដី លើស្ថាប័នរដ្ឋ។ ដើមហេតុនៃរឿងក្ដីនេះ កើតចេញពីការចុះកិច្ចសន្យាយល់ព្រម ដោយអាជ្ញាធរខេត្តកំពតនូវអាជីវកម្មសត្តឃាតដ្ឋានមួយកន្លែង។ បន្ទាប់ពីបានត្រូវរ៉ូវគ្នាហើយអស់ ស្រាប់តែក្រសួងមហាផ្ទៃ បានចេញប្រកាសបដិសេធអាជីវកម្មរបស់ឈ្មោះ *ហ៊ួ ប៊ុណ្ណារិទ្ធិ* តាមប្រកាសលេខ០៩៨ ប្រ.ក.អធិ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៦។

រឿងក្ដីនេះ បានដំណើរការរហូតដល់តុលាការកំពូល។ តុលាការកំពូលបានសម្រេច រក្សាប្រកាសលេខ០៨៩ ប្រ.ក. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់ក្រសួងមហាផ្ទៃ ស្ថិតនៅជាធរមានដដែល មានន័យថា សម្រេចហាមឃាត់មិនឱ្យមានការធ្វើអាជីវកម្មសត្តឃាតនៅខេត្តកំពត ក្រោមមូលហេតុបណ្ដាលឱ្យខូចដល់បរិស្ថាន។ ក្រៅពីនេះ តុលាការកំពូលបានបង្គាប់ឱ្យអាជ្ញាធរខេត្តកំពតធ្វើសំណងការខូចខាតដល់ឈ្មោះ *ហ៊ួ ប៊ុណ្ណារិទ្ធិ* ចំនួន១០៨.០០០.០០០ (មួយរយប្រាំបីលាន) រៀល។ បើពិនិត្យមើលសាលដីការនេះឱ្យបានល្អិតបន្តិចឃើញថា ឈ្មោះ *ហ៊ួ ប៊ុណ្ណារិទ្ធិ* ជាអាជីវករមិនមានកំហុសសោះឡើយ ព្រោះបានធ្វើការស្នើសុំលិខិតអនុញ្ញាតសាង់សង់សត្តឃាតដ្ឋានត្រឹមត្រូវ ទៅតាមនីតិវិធីដែលមានចែងក្នុងច្បាប់។ អ្នកដែលមានកំហុស គឺមន្ត្រីអាជ្ញាធរខេត្ត ដែលបានសម្រេចអនុញ្ញាតឱ្យមានការសាងសង ដោយមិនបានពិចារណាឱ្យបានសព្វគ្រប់ ពីផលប៉ះពាល់

[១៩៧] សូមមើល សាលដីកាលេខ៧៣ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ របស់តុលាការកំពូលក្នុងឧបសម្ពន្ធទី២ លេខ២.៤.

ផ្នែកបរិស្ថាន ក្រោយមកទើបមាន១៤ អង្គភាពដទៃ សុំឱ្យក្រសួងមហាផ្ទៃ ទប់ស្កាត់ការសាងសង់នេះ។

ការសម្រេចឱ្យអាជ្ញាធរខេត្តកំពត សងការខូចខាតដល់ជនរងគ្រោះ គឺជាការត្រឹមត្រូវណាស់ ព្រោះជាកំហុសរបស់ស្ថាប័នរដ្ឋ ដែលនាំឱ្យមានការខាតបង់ផ្សេងៗ លើគម្រោងសាងសងសត្តឃាតដ្ឋាននេះ។ សាលដីកាខាងលើនេះ មានរឿងក្តីខ្លះ ពាក់ព័ន្ធទៅនឹងវិវាទរដ្ឋបាលសុទ្ធសាធផងដែរ។

**ខ.សាលដីកាតុលាការកំពូល សំណុំរឿងរដ្ឋប្បវេណី ទាក់ទងនឹងរដ្ឋបាល**

តាមពិតទៅ សញ្ញាណរដ្ឋបាល បានលាយឡំគ្នាក្នុងផ្នែករដ្ឋប្បវេណីដែរ ព្រោះថា ព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានតុលាការរដ្ឋបាល នៅដាច់ដោយឡែកពីតុលាការស៊ីវិល ដូចជាប្រទេសបារាំងឡើយ។ ដើម្បីសម្រួលដល់បញ្ហានេះ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីអង្គការចាត់តាំងតុលាការថ្មី មានមាត្រា៨៧ ចែងថា "*ក្នុងករណីមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាល ត្រូវប្រគល់ឱ្យតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និង សភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់* "។ មាត្រា៨៩ វាក្យខណ្ឌទី៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការចែងថា "*នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ការជំនុំជម្រះក្តីរឿងរដ្ឋបាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និង បទប្បញ្ញត្តិច្បាប់ផ្សេងៗទៀតជាធរមាន*"។ មាត្រានេះពុំបានបញ្ជាក់ប្រភេទ នៃវិវាទរដ្ឋបាលណាមួយឡើយ។ ជារួមមកក្នុងច្បាប់ថ្មីនេះ សាលាដំបូងរាជធានី-ខេត្ត ត្រូវតែពិនិត្យ និង កាត់ក្តីរឿងបទរំលោភអំណាច និង ប្រកាសមោឃភាព ចំពោះសេចក្តីសម្រេចរដ្ឋបាលគ្រប់ប្រភេទ រាប់ចាប់តាំងពីដីកា និង សេចក្តីសម្រេចរបស់ឃុំ-សង្កាត់ ឡើងទៅដល់ដីកា និង សេចក្តីសម្រេចរបស់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រកាស អនុក្រឹត្យ និង ព្រះរាជក្រឹត្យដូចគ្នាដែរ[១៤៧]។

ខាងក្រោមនេះ ជាការលើកយកសាលដីកា របស់តុលាការកំពូលរាជធានីភ្នំពេញ ដើម្បីយកមកញែកនូវករណីផ្នែករដ្ឋបាល ដែលលាយឡំជាមួយរដ្ឋប្បវេណី។ សាលដីកានេះដូចជា៖ សាលដីកា លេខ៧៣ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ របស់តុលាការកំពូល (ខ.១.) សាលដីកាលេខ១០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការកំពូល (ខ.២.)

**ខ.១.សាលដីកាលេខ៧៣ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ របស់តុលាការកំពូល**

ក្នុងករណីសិក្សាសាលដីកាខាងលើនេះ តុលាការកំពូលបានសរសេរថា សំណុំរឿងរដ្ឋប្បវេណី លេខ១៥៧ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ប៉ុន្តែ ធាតុពិតរឿងនេះ ជារឿងក្តីរដ្ឋបាល ដោយសារតែជាប់បណ្តឹងឧបាស្រ័យ ពីបទរំលោភអំណាច ដែលភាគីបានស្នើសុំឱ្យលុបចោលប្រកាសរបស់អាជ្ញាធររដ្ឋគឺ ក្រសួងមហាផ្ទៃ។ ដំណើរការរឿងក្តីនេះ ជាយុត្តិសាស្ត្រមួយ ដែល

[១៤៧] គន យឿន, នីតិវិវាទរដ្ឋបាល, (ភ្នំពេញ, ២០១៦), ទំព័រ១៤០

តុលាការសាលាដំបូងបានលុបចោលប្រកាស របស់ក្រសួងមហាផ្ទៃ។ រីឯសាលាឧទ្ធរណ៍ លេខ៦៨ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ បានសម្រេចតម្កល់ប្រកាសរបស់ក្រសួងមហាផ្ទៃ ទុកជាបានការតាមផ្លូវច្បាប់ ចំណែកតុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ទុកជាបានការផងដែរ។

ថ្វីត្បិតតែ ក្នុងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ និង តុលាការកំពូល មិនបានបញ្ញត្តលុបចោល កិច្ចសន្យារបស់ពាណិជ្ជករ (លោក ហ៊ូ វណ្ណារិទ្ធិ) ជាមួយអាជ្ញាធរខេត្តកំពត ក៏ពិតមែន តែកិច្ចសន្យា ពុំមានសុពលភាពឡើយ។ នេះជាសេចក្តីសម្រេចផ្នែករដ្ឋបាល ដែលត្រូវបាន សាលាឧទ្ធរណ៍ និង តុលាការកំពូល ប្រកាសលុបចោល។

**ខ.២.សាលដីកាលេខ១០ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការកំពូល**

នៅក្នុងសាលដីកាខាងលើនេះ ក៏មានជាប់ទាក់ទងខ្លាំងនឹងរដ្ឋបាលដែរ ពោលគឺ តុលាការក្រុងភ្នំពេញ បានសម្រេចលុបសេចក្តីសម្រេចលេខ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រង់ប្រការមួយ "១" ចំណុច ក និង ប្រការ "៣" ចំណុច ក ចោលជាអសារបង់។ នៅសាលាឧទ្ធរណ៍វិញ សម្រេចតម្កល់សេចក្តីសម្រេចលេខ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទុកជាត្រឹមត្រូវតាមច្បាប់ ប៉ុន្តែ អំពីការផាកពិន័យលើបារី និង សម្ភារៈផ្សាយពាណិជ្ជកម្ម និង រថយន្តចង្កូតឆ្វេង៦ គ្រឿង ត្រូវលើកចោល។ តុលាការកំពូល បានសម្រេចតម្កល់សាលដីកា របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

សេចក្តីសម្រេចរបស់តុលាការក្រុងភ្នំពេញ ក្នុងការលុបចោលសេចក្តីសម្រេច របស់ក្រសួង-សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសេចក្តីសម្រេចផ្នែករដ្ឋបាល។ ចំណែកសាលាឧទ្ធរណ៍ និង តុលាការកំពូល មិនបានសម្រេចលុបចោលសេចក្តីសម្រេចរបស់ក្រសួងទេ តែបានបដិសេធ លុបចោលដោយផ្នែកនូវការផាកពិន័យលើបារី និង សម្ភារៈផ្សាយពាណិជ្ជកម្ម និង រថយន្តចង្កូតឆ្វេង៦ គ្រឿង ត្រូវលើកចោល។

ក្រៅពីសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី ចំណុចដែលពាក់ព័ន្ធនឹងមន្ត្រីរាជការ គឺមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌផងដែរ។

## កថាភាគទី២

## សាលដីកាតុលាការកំពូល សំណុំរឿងព្រហ្មទណ្ឌ

កំហុសរបស់មន្ត្រីរាជការ ដែលទាក់ទងនឹងព្រហ្មទណ្ឌ ពេលខ្លះនាំឱ្យរដ្ឋទទួលខុសត្រូវផងដែរ (ក) តែពេលខ្លះទៀត រដ្ឋអាចរួចផុតពីការទទួលខុសត្រូវ (ខ) វាអាស្រ័យលើស្ថានភាពនៃកំហុសជាក់ស្តែងរបស់មន្ត្រីរាជការនោះ។

**ក.រឿងក្តីដែលនាំឱ្យរដ្ឋទទួលខុសត្រូវ**

**សាលដីកាលេខ១៣ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការកំពូល**[១៤៩]

សាលដីការខាងលើនេះ មិនជាប់ពាក់ព័ន្ធនឹងកំហុសព្រហ្មទណ្ឌរបស់មន្ត្រីរាជការទេ តែជាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដោយមន្ត្រីផ្នែកគយ ទៅលើក្រុមហ៊ុនឯកជនមួយ បិតក្រោមការ ជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌ។

រឿងក្តីនេះ ត្រូវបាននាយកទីចាត់ការគយ និង រដ្ឋាករ ប្តឹងក្រុមហ៊ុនឯកជនមួយ ឈ្មោះ *តៃ សេងហេង* ពីបទនាំចូលទំនិញគេចពន្ធ។ ក្រុមហ៊ុន *តៃ សេងហេង* ជាក្រុមហ៊ុននាំរថយន្ត ចូលក្នុងប្រទេសកម្ពុជា។ ទីចាត់ការគយ និង រដ្ឋាករនេះ បានចេញលិខិតលេខ១៣៨.៩៥គរ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ សំណើបង្កសំណុំរឿងចោទប្រកាន់ លើរថយន្តល្មើសច្បាប់ចំនួន០៩ គ្រឿង ដើម្បីដាក់ជូនតុលាការរឹបអូស ជាសម្បត្តិរដ្ឋ ដោយសំអាងលើកំណត់ហេតុល្មើសច្បាប់គយលេខ.០០២-២១-៩៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៥ របស់គណៈកម្មការចម្រុះអន្តរក្រសួងបិទច្រកស្រែអំបិល លិខិតលេខ៣៨៧ សជណាពស ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៣ របស់គណៈរដ្ឋមន្ត្រីស្តីពីករណីបញ្ឈប់ការនាំចូល និង ការប្រើប្រាស់រថយន្តចង្កូតស្តាំ និង មាត្រា២៤ នៃច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និង នាំចូល។

តុលាការខេត្តកោះកុង បានសម្រេចផ្តន្ទាទោសឈ្មោះ *ឆាង គា* តំណាងក្រុមហ៊ុន *តៃ សេងហេង* ដោយរឹបអូសរថយន្តទេសចរណ៍ចំនួន០៩ គ្រឿងជាសម្បត្តិរដ្ឋ។ ឈ្មោះ *ឆាង គា* នេះបានសម្រេចប្តឹងទៅកាន់សាលាឧទ្ធរណ៍ មិនសុខចិត្តនឹងសាលក្រមតុលាការខេត្ត។ សាលាឧទ្ធរណ៍ បានសម្រេចបដិសេធសាលក្រមព្រហ្មទណ្ឌ របស់តុលាការខេត្តកោះកុងចោល ហើយបង្គាប់ឱ្យនាយកដ្ឋានគយ និង រដ្ឋាករ ប្រគល់ប្រាក់ថ្លៃលក់ឡាយឡុងរថយន្តចំនួន០៨ គ្រឿង ទៅក្រុមហ៊ុន *តៃ សេងហេង* វិញ។ ដោយសារតែសាលដីកាសាលាឧទ្ធរណ៍ សម្រេចឱ្យថ្លៃរថយន្ត ដែលខាងរដ្ឋាករ គយបានលក់នោះថោកពេក មិនស្មើតម្លៃរថយន្តដើមផង ហើយតុលាការមិនសម្រេចឱ្យមានសំណងការខូចខាត និង ជំងឺចិត្តតាមសំណូពរបស់ខ្លួនផង ទើបឈ្មោះ *ឆាង គា* តំណាងឱ្យក្រុមហ៊ុន សម្រេចដាក់ពាក្យបណ្តឹងសាទុក្ខ ទៅតុលាការកំពូល តែត្រូវតុលាការកំពូលបដិសេធការប្តឹងតវ៉ានេះ តុលាការទទួលស្គាល់សាលដីកាសាលាឧទ្ធរណ៍ត្រឹមត្រូវដដែល។

ក្រុមហ៊ុនឯកជន បាននាំរថយន្តដែលរដ្ឋបានហាមឃាត់ក៏ពិតមែន ប៉ុន្តែ ការដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រេចលក់ឡាយឡុងរថយន្តហាមឃាត់របស់ក្រុមហ៊ុននោះ គឺជាការរំលោភទៅលើមាត្រា១៦ ចំណុចទី៥ មាត្រា១៩ និង មាត្រា២៤ នៃច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និង នាំចូល។ ប្រការនេះ តុលាការកំពូលគ្រាន់តែបង្គាប់ឱ្យក្រសួង ប្រគល់ប្រាក់បានមកពីការលក់

[១៤៩] សូមមើល សាលដីកាលេខ១៣ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៥ របស់តុលាការកំពូល ក្នុងឧបសម្ពន្ធទី២ លេខ២.៧.

ឡាយឡុងប៉ុណ្ណោះ ប៉ុន្តែ ពុំមានការបង្គាប់សំណាងអ្វីផ្សេងឡើយ។ ត្រឹមចំណុចនេះ ក៏អាចសន្និដ្ឋានបានថា នាយកទីចាត់ការគយ និង រដ្ឋាករ បានរំលោភបំពានលើច្បាប់ជាធរមាន ដែលជាកំហុសមួយបង្កជាព្យសនកម្ម ដល់ភាគីក្រុមហ៊ុនឯកជន ដោយក្រុមហ៊ុននេះ បានខាតបង់ទៅលើតម្លៃប្រាក់ដើមនៃទំនិញរបស់ខ្លួន បន្ទាប់ពីបានលក់ឡាយឡុង ដោយទីចាត់ការគយ និង រដ្ឋាករ និង ការខូចខាតផ្សេងៗទៀត។

**ខ.រឿងក្តីដែលនាំឱ្យរដ្ឋរួចផុតពីការទទួលខុសត្រូវ**

**ខ.១.សាលដីកាលេខ២០៨ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការកំពូល(១៩០)**

រឿងក្តីនេះ កើតចេញពីទំនាស់ដីធ្លី ដែលភាគីម្ខាងឈ្មោះ *ម៉ែន ឈន* បានធ្វើការរុះរើរបងផ្ទះឈ្មោះ *ឃី ង៉ែត* ដោយសំអាងលើសេចក្តីសម្រេចរបស់ក្រុង ប្រគល់កន្ទុយដីឱ្យទៅឈ្មោះ *ម៉ែន ឈន* ប៉ុន្តែ សេចក្តីសម្រេចនេះមិនទាន់បានដាក់ឱ្យអនុវត្តនៅឡើយទេ។ ការរុះរើនោះទៀតសោត ឈ្មោះ *ម៉ែន ឈន* បាននាំកងកម្លាំងនគរបាលប្រដាប់អាវុធទៅជាមួយផងដែរ ដែលមានលោក *ព្រំ ម៉ាឡា* ជាអនុប្រធាននគរបាលប៉ុស្តិ៍ទួលទំពូង២ ចុះទៅជាមួយផងដែរ។ រឿងក្តីនេះ ត្រូវបានតុលាការកំពូលសម្រេចចាត់ទុកថា ជាអំពើបំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជាជន តាមក្រមព្រហ្មទណ្ឌអន្តរកាល និងបង្គាប់ឱ្យជនល្មើស សងសំណងខូចខាតខាងសម្ភារៈ និង ជំងឺចិត្តដល់ជនរងគ្រោះ។ អង្គហេតុនេះបានកើតឡើងរវាងបុគ្គលឯកជន និង បុគ្គលឯកជនក៏ពិតមែន តែក្នុងដំណើររឿង ឃើញថា មានការចូលរួមដោយបំពាន ពីសម្នាក់មន្ត្រីនគរបាល ក្នុងការចុះរុះរើទ្រព្យសម្បត្តិឯកជន។ ក្នុងសាលដីកាបើទោះបីជាពុំបានធ្វើការចោទប្រកាន់អ្វីដល់មន្ត្រីនគរបាលក៏ពិតមែន តែយើងសូមច្បិចយកចំណុចនេះ មកពន្លាត ព្រោះមានការទាក់ទងនឹងអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ។ ចំពោះបញ្ហាខាងលើនេះ លោក *យួន សុផុន* ជាប្រធានសង្កាត់ទួលទំពូង២ បានថ្លែងថា "កន្លងមកខ្លួនបានដឹងថា ក្រុងបានចេញសេចក្តីសម្រេចប្រគល់កន្ទុយដីឱ្យទៅឈ្មោះ *ម៉ែន ឈន* តែសេចក្តីសម្រេចនេះពុំទាន់អនុ-វត្តទេ ដោយភាគីម្ខាងទៀតប្តឹងតវ៉ានឹងសេចក្តីសម្រេចនេះ។ កន្លងមកខ្លួនពុំដែលចាត់ឱ្យបុគ្គលិករបស់ខ្លួនឱ្យទៅអនុវត្តសេចក្តីសម្រេចរបស់ក្រុងឱ្យ *ម៉ែន ឈន* ទេ។ តែខ្លួនឮប្រធានក្រុមឈ្មោះ *ឡុង ម៉ុក* ប្រាប់ថា ឃើញមានកម្លាំងយោធាខ្លះ ស៊ីវិលខ្លះចុះទៅធ្វើរបងនៅផ្ទះ *ម៉ែន ឈន* កាលពីអាទិត្យមុន"។

ករណីខាងលើនេះ ប្រធានសង្កាត់ ពុំបានចេញបញ្ជាណាមួយ ដល់មន្ត្រីថ្នាក់ក្រោម ឱ្យ អនុវត្តសេចក្តីសម្រេចរបស់សាលាក្រុងឡើយ ជាក់ស្តែងឃើញថា អនុប្រធានប៉ុស្តិ៍បែរជាចុះទៅអនុវត្តផ្ទាល់ តាមការស្នើសុំរបស់ជនល្មើសទៅវិញ នេះសបង្ហាញឱ្យឃើញ ពីការបំពានមុខនាទីរបស់ខ្លួនយ៉ាងពិតប្រាកដ។

(១៩០) សូមមើល សាលដីកាលេខ២០៨ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ក្នុងឧបសម្ពន្ធទី២ លេខ២.៦.

**ខ.២.សាលដីកាលេខ១៣ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ របស់តុលាការកំពូល(១៥១)**

រឿងក្តីនេះ កើតចេញពីការឈ្លោះទាស់ទែងគ្នា រវាងមន្ត្រីនគរបាលសន្តិសុខព្រំដែន ជាមួយនឹងប្រធានភូមិ។ ភាគីឈ្មោះ *ងិន ហ៊ីន* ជាមន្ត្រីនគរបាលសន្តិសុខព្រំដែន បានបាញ់រះលើផ្ទះប្រធានភូមិចំនួន៨ គ្រាប់ តែមិនមានការរងរបួសឡើយ។ ក្រោយកើតហេតុ មាននគរបាលពីរនាក់ចុះមកសម្របសម្រួល តែត្រូវឈ្មោះ *ងិន ហ៊ីន* នេះបាញ់ឱ្យរបួសធ្ងន់ធ្ងរផងដែរ។ តុលាការក្រុងភ្នំពេញ បានសម្រេចចោទប្រកាន់ឈ្មោះ *ងិន ហ៊ីន* ពីបទប៉ុនប៉ងធ្វើមនុស្សឃាត បន្ទាប់មកទៀតមានការប្ដឹងផ្តល់គ្នា ឡើងរហូតដល់តុលាការកំពូលក្រុងភ្នំពេញ។

ត្រង់ចំណុចនេះឃើញថា ឈ្មោះ *ងិន ហ៊ីន* ជាមន្ត្រីសន្តិសុខព្រំដែន តែបានប្រព្រឹត្តបទ-ល្មើសមួយក្រៅការងារតួនាទីរបស់ខ្លួន។ អំពើនេះ គឺជាកំហុសបុគ្គលសុទ្ធសាធ របស់មន្ត្រីរាជការមិនជាប់ពាក់ព័ន្ធនឹងរដ្ឋ ឬ ស្ថាប័នសាធារណៈឡើយ។ រាល់ការទទួលខុសត្រូវ ទាំងផ្នែកព្រហ្មទណ្ឌ និង ផ្នែករដ្ឋប្បវេណី គឺជាបន្ទុកទាំងស្រុង របស់មន្ត្រីរូបនេះ។

(១៥១) សូមមើល សាលដីកាលេខ១៣ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ របស់តុលាការកំពូលក្នុងឧបសម្ពន្ធទី២ លេខ២.៥.

# សេចក្ដីសន្និដ្ឋាន

ពាក្យថា "រដ្ឋសងរាស្ត្រ" ពុំមានសោះឡើយ នៅក្នុងសង្គមខ្មែរ នាសម័យបុរាណ បើទោះបីជាមន្ត្រីធ្វើកំហុសដល់រាស្ត្រយ៉ាងណាក៏ដោយ។ បើឆ្លងកាត់តាមការស្រាវជ្រាវ នូវប្រភពឯកសារប្រវត្តិ-សាស្ត្រនានាកន្លងមក យើងឃើញថា រដ្ឋរកយុត្តិធម៌ជូនរាស្ត្រ ក្នុងករណីកំហុសព្រហ្មទណ្ឌ ដែលបង្កដោយពួកមន្ត្រីនាម៉ឺនតែប៉ុណ្ណោះ ករណីនេះ ជាសញ្ញាណទាក់ទងនឹងកំហុសបុគ្គល នាពេលបច្ចុ-ប្បន្ន។ ប៉ុន្តែ ទោះបីជាមានការខូចខាតយ៉ាងណាក៏ដោយ ឱ្យតែកំហុសនោះ ជាប់ពាក់ព័ន្ធនឹងរដ្ឋព្រះមហាក្សត្រនោះ ពុំត្រូវបានសងការខូចខាតឡើយ។

បន្ថែមជាងនេះទៅទៀត នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជា មានប្រព័ន្ធច្បាប់ទាក់ទងទៅនឹងការទទួលខុសត្រូវលើកំហុស របស់មន្ត្រីរាជការ ពុំសូវមានបទដ្ឋានគតិយុត្តសម្បូរបែបឡើយ។ យើងសង្កេតឃើញមានចែងខ្លះៗ នៅក្នុងរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី និង បញ្ញត្តិខ្លះៗទៀត ក្នុងច្បាប់ផ្សេ-ងៗ។ បទដ្ឋានគតិយុត្តដែលបានលើកឡើងខាងលើនេះ ក៏ពុំទាន់មានភាពដាច់ណាត់ និង ច្បាស់-លាស់។ ប្រការទាំងនេះ សុទ្ធតែជា រនាំងដល់ដំណើរការ ដែលធ្វើឱ្យរដ្ឋមិនអាចស្វែងរកពន្លឺ នៃនីតិរដ្ឋបានឡើយ។ ម៉្យាងទៀត ការអនុវត្តទាក់ទងកន្លងមក របស់មន្ត្រីតុលាការ ក៏ពុំអាចធ្វើការញែកឱ្យបានច្បាស់លាស់ រវាងសំណុំរឿងរដ្ឋបាល និង សំណុំរឿងស៊ីវិលនោះដែរ។ ដោយហេតុថា តុលាការរដ្ឋបាល នៅលាយឡំជាមួយតុលាការស៊ីវិលនៅឡើយ ដែលទាំងនេះជាបញ្ហា នាំឱ្យតុលាការ ជួបភាពលំបាកផ្សេងៗ។

បើសំអាងលើការស្រាវជ្រាវ លើសាលដីការបស់តុលាការកំពូល ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០៦ ដែលមានប្រមាណជា១.០២០ (មួយពាន់ម្ភៃ) សាលដីកានោះ បង្ហាញឱ្យឃើញថា ភាគច្រើននៃបណ្ដឹង របស់ប្រជាពលរដ្ឋ ភាគតិចណាស់ ដែលប្ដឹងរដ្ឋ។ អ្នកដែលប្ដឹងនោះភាគច្រើន គឺជាពាណិជ្ជករ អាជីវករ ដែលសុទ្ធតែជាបុគ្គលសម្បូរធនធានខាងទឹកប្រាក់ យើងសង្កេតឃើញ មានប្រជាពលរដ្ឋដែលមានមុខរបរជាកសិករខ្លះដែរ បានប្ដឹងរដ្ឋ តែភាគច្រើនពុំសូវឈ្នះរដ្ឋនោះឡើយ។ កត្តាទាំងនេះ យើងក៏មិនហ៊ានសន្និដ្ឋានថា រដ្ឋយកចិត្តយកថ្លើមពួកអ្នកមានទាំងនោះដែរ តែនិយាយបែបនេះ ក៏សក្ដិសមម៉្យាងដែរ ព្រោះកម្ពុជាចាប់ពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០០៦ កម្ពុជាមានការអភិវឌ្ឍតិចតួចណាស់ យើងត្រូវការអ្នកវិនិយោគទុនច្រើន ចូលមកក្នុងប្រទេស ដើម្បីលើកស្ទួយការអភិវឌ្ឍឱ្យមានវឌ្ឍនភាព ដូច្នេះ ក៏កំហុសដែលរដ្ឋបង្កឡើងមួយចំនួន រដ្ឋសុខចិត្តធ្វើស្របតាមពួកអ្នកវិនិយោគទុនធំៗទាំងនោះ តែមិនមែនគ្រប់ករណីទេ។ ចំណែកឯ ប្រជាពលរដ្ឋកសិករ ប្ដឹងរដ្ឋ មិនសូវឈ្នះនោះ ក៏មិនមែនមានន័យថា ឃើញក្រ កាត់ឱ្យចាញ់នោះដែរ វាអាស្រ័យលើរឿងក្ដីជាក់-ស្ដែង។

ទោះជា មានការប្តឹងពីប្រជាពលរដ្ឋ ចំពោះរដ្ឋកន្លងមកក៏ពិតមែន តែការប្តឹងនេះ បើធៀបទៅនឹងសាលដីកាតុលាការកំពូលប្រមាណជា១.០២០ មានជាងដប់សំណុំរឿងប៉ុណ្ណោះ ដែលប្រជាពលរដ្ឋ ប្តឹងរដ្ឋ ហើយមានតែ៤-៥ សំណុំរឿងប៉ុណ្ណោះ ដែលប្រជាពលរដ្ឋឈ្នះរដ្ឋ។ ជាក់ស្តែង កំហុសដែលប្រព្រឹត្តឡើង ដោយមន្ត្រីរាជការ មានចំនួនច្រើនករណី តែមានពលរដ្ឋតិចតួចបំផុត ដែលហ៊ានប្តឹង នេះអាចជាគំនាបខាងផ្លូវចិត្ត និង កត្តាផ្សេងៗទៀត ដូចជាមិនសូវយល់ដឹងពីសិទ្ធិរបស់ខ្លួនជាដើម។ ដូចនៅក្នុងរឿងក្តី របស់លោក ប៊ិន សំណាង និង លោក សុខ សំអឿន ក្រោយតុលាការរកឃើញថា លោកទាំងពីររូប ពុំមានទោស តុលាការកំពូលសម្រេចដោះលែងលោក ប៊ិន សំណាង និង លោក សុខ សំអឿន ជាស្ថាពរដោយគ្មានលក្ខខណ្ឌ បន្ទាប់ពីបានបើកសវនាការកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣[១៥២]។ សេចក្តីសម្រេចនេះ ពុំមានបង្គាប់ឱ្យខាងតុលាការ ឬ ខាងរដ្ឋ ធ្វើការសងការខូចខាតដល់ជនរងគ្រោះឡើយ ម្យ៉ាងទៀត ក៏ពុំឃើញភាគីខាងជនរងគ្រោះ ប្តឹងទាមទារសំណងការខូចខាតនេះដែរ។ ករណីនេះ គឺជាការទទួលរងសម្ពាធផ្នែកផ្លូវចិត្តពីសម្នាក់ជនរងគ្រោះ ដែលលែងចង់ទទួលបានសំណងជំងឺចិត្តពីរដ្ឋ សុំឱ្យតែខ្លួនមានសេរីភាពប៉ុណ្ណោះ។

ដូច្នេះ យោងតាមការបកស្រាយខាងលើនេះ យើងអាចសន្និដ្ឋានបានថា កម្ពុជាពុំទាន់មាននិយតភាព នៃវិធានការទាក់ទងទៅនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ ឱ្យបានល្អគ្រប់គ្រាន់នៅឡើយទេ។ ដោយឡែក ចំពោះដំណើរការនីតិវិធីនៃរឿងក្តីពាក់ព័ន្ធទៅនឹងអំពើអនីត្យានុកូល របស់មន្ត្រីរាជការ អនុលោមទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ ចំណុចដែលខ្វះខាតផ្សេងៗទៀត អាចយកវិធាន និង យុត្តិសាស្ត្ររបស់បរទេសមកអនុវត្តបាន។ កម្ពុជានៅមានការខ្វះខាត មន្ត្រីជំនាញពាក់ព័ន្ធនឹងករណីខាងលើនេះច្រើនណាស់ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋហាក់ដូចជានៅមានអារម្មណ៍ខ្លាចរាជការ មិនហ៊ានចេញមុខតវ៉ាពីការខូចខាតរបស់ខ្លួនឡើយ ម្យ៉ាងទៀត ប្រជាពលរដ្ឋពុំយល់ដឹង ពីអត្ថិភាពនៃសិទ្ធិរបស់ខ្លួនផងដែរ។

[១៥២] គេហៈទំព័រអាស៊ីសេរី, ចុះថ្ងៃទី០៩ សីហា ២០១៣, https://www.rfa.org/khmer/news/law/supreme-court-release-bornsamang-and-soksameurn-09252013034938.html (ដកស្រង់ ២៥ មិថុនា ២០១៨)

# អនុសាសន៍

អនុសាសន៍ចុងក្រោយ ដើម្បីឱ្យដំណើរនៃនីតិវិធីទាក់ទងទៅនឹង**អំពើអនីត្យានុកូល របស់មន្ត្រីរាជការ** ប្រព្រឹត្តទៅល្អប្រសើរ រដ្ឋ ឬ អង្គការនីតិបញ្ញត្តិ ត្រូវតែអនុម័ត វិធានច្បាប់ពាក់ព័ន្ធទៅនឹងបញ្ហាខាងលើនេះ ឱ្យបានគ្រប់គ្រាន់ ព្រោះដូចបានធ្វើការបកស្រាយ និង លើកបង្ហាញខាងលើស្រាប់ថា វិធាន មានចំនួនតិចតួច និង មិនកំណត់ពីនិយមន័យ ក៏ដូចជា នីតិវិធីឱ្យបានច្បាស់លាស់ឡើយ។ តុលាការកម្ពុជាគប្បីសិក្សា និង យកតាមនូវវិធាន និង យុត្តិសាស្ត្របរទេស ដូចបានលើកឡើងក្នុងសារណាស្រាប់ ដើម្បីធ្វើជាដើមទុន ក្នុងការយកមកអនុវត្តនៅប្រទេសកម្ពុជា។ តុលាការត្រូវមានឯករាជ្យភាព និង មានតម្លាភាពផងដែរ ចំពោះដំណើរការនៃរឿងក្ដីនីមួយៗ មិនត្រូវឈរលើទឹកប្រាក់ ឬ មើលឃើញតែពីផលចំណេញ ដល់រដ្ឋប៉ុណ្ណោះទេ ត្រូវឈរលើគោលការណ៍សិទ្ធិមនុស្ស និង អព្យាក្រឹតភាពជាធំ។

អ្វីដែលជាចំណុចចម្បង អាត្មាភាពទាំងពីររូប សូមស្នើសុំដល់ប្រមុខដឹកនាំ មេត្តាគួរតែបង្កើតឱ្យមានតុលាការរដ្ឋបាលមួយដាច់ដោយឡែក ពីតុលាការដទៃទៀត ព្រោះដំណើរការកន្លងមកនេះទៅលើភាពមិនដាច់ដោយឡែក នៃតុលាការរដ្ឋបាល បាននាំឱ្យមានបញ្ហាជាច្រើន ដូចបានរៀបរាប់ខាងលើនេះស្រាប់។ ម៉្យាងវិញទៀត មន្ត្រីរាជការ នៅពេលដែលខ្លួនមានកំហុស មិនត្រូវប្រើគ្រប់រូបភាពណាមួយ ដើម្បីធ្វើជាគំនាប ទៅកាន់ប្រជាពលរដ្ឋនោះឡើយ។ មន្ត្រីរាជការ ត្រូវទទួលស្គាល់នូវកំហុសរបស់ខ្លួន ត្រូវមានជាសំណងសមរម្យជូនទៅពលរដ្ឋ នៅពេលដែលខ្លួនប្រព្រឹត្តកំហុស ធ្វើបែបនេះ នឹងនាំឱ្យសង្គមមានយុត្តិធម៌ មានតម្លាភាព និង ភាតរភាពរវាងគ្នានឹងគ្នា។ កត្តាទាំងអស់នេះហើយ នឹងធ្វើឱ្យប្រទេសកម្ពុជា អាចទទួលបានការទាក់ទាញពីវិនិយោគិនបរទេសធំៗ មកដាក់ទុននៅកម្ពុជា ហើយនឹងធ្វើឱ្យប្រទេសកម្ពុជា ឈានជើងចូលដល់យុគសម័យទំនើបមួយ ដូចប្រទេសអភិវឌ្ឍផ្សេងទៀត ក្នុងសកលលោក។

# គន្ថនិទ្ទេស

## ក.លិខិតបទដ្ឋានគតិយុត្តជាតិ

### ក.១.រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញ, លេខ ១.០៤២ ក.ទ.ទ, ០៦ កក្កដា ១៩៥៩។
- រដ្ឋធម្មនុញ្ញ, បញ្ញត្តិលេខ ១៩/៧២-បសខ, ១០ ឧសភា ១៩៧២។
- រដ្ឋធម្មនុញ្ញ, អនុម័ត ១៤/ធ្នូ/១៩៧៥, ៥ មករា ១៩៧៦។
- រដ្ឋធម្មនុញ្ញ, អនុម័ត ២៥/មិថុនា/១៩៨១, ២៥ មិថុនា ១៩៨១។
- រដ្ឋធម្មនុញ្ញ, អនុម័ត ៣០/មេសា/១៩៨៩, ៣០ មេសា ១៩៨៩។
- រដ្ឋធម្មនុញ្ញ, អនុម័ត ២១/កញ្ញា/១៩៩៣, ២៤ កញ្ញា ១៩៩៣។

### ក.២.ក្រម

- ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/២១ ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

### ក.៣.ច្បាប់

- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។
- ច្បាប់ស្តីពីវិនិយោគ, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣។
- ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០។
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/ករម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។

### ក.៤.វិធានគតិយុត្តផ្សេងៗ

- ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣, ០១ ធ្នូ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។
- ក្រឹត្យ-ច្បាប់លេខ ៣៨/ក្រ.ច/, ២៨ តុលា ១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។
- សេចក្តីសម្រេចស្តីពី តួនាទី និង ភារកិច្ចរបស់គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងអង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា, លេខ ០០១/រស/, ០៩ មករា ២០១៤។

## ខ.សាលដីកាតុលាការកំពូល

### ខ.១.សំណុំរឿងព្រហ្មទណ្ឌ

- សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ ១៣, ១៥ ធ្នូ ១៩៩៥។
- សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ ១៣, ១៥ ធ្នូ ១៩៩៥។

- សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ ០៨, ២៨ មីនា ១៩៩៧។

**ខ.២.សំណុំរឿងរដ្ឋប្បវេណី**

- សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ ៥១, ២៧ កុម្ភៈ ១៩៩៦។
- សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណីលេខ ២៤៥, ២៩ តុលា ១៩៩៦។
- សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ ៣០, ២២ កុម្ភៈ ២០០០។
- សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ ៧៣, ០៦ មេសា ២០០០។

**គ.លិខិតូបករណ៍អន្តរជាតិ**

- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស, លេខ ២១៧A (III), ១០ ធ្នូ ១៩៤៨។
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, លេខ ២១០៦ A (XX),០៤ មករា ១៩៦៩។
- អនុសញ្ញាទីក្រុងឡុងដ៍ London Convention ៨/សីហា/១៩៤៥។
- លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, ទីក្រុងរ៉ូម, ១៧/កក្កដា/១៩៩៨។
- សាលដីការអង់ហ្គេ (Aguet), ០៣ កុម្ភៈ ឆ្នាំ១៩១១។

**ឃ.ស្នាដៃនិពន្ធជាភាសាខ្មែរ**

- កាន ច័ន្ទមេត្តា, កើត រិទ្ធិ, ចាំង ស៊ីណាត, ថេង ច័ន្ទសង្វារ, បេអាទ្រីស បាលីវេ និង ឡូអ៊ីក អាវីឡាណឺដា. សេចក្តីផ្តើមនៃនីតិកម្ពុជា. ភ្នំពេញ៖ ក្រុមសហប្រតិបត្តិការសកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង។
- ក្រសួងមហាផ្ទៃ. ការិយាល័យប្រជាពលរដ្ឋ, បោះពុម្ពលើកទី២. ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១០។
- ក្រសួងមហាផ្ទៃ. សៀវភៅណែនាំស្តីពី នីតិវិធី និង បែបបទនៃការសម្រុះសម្រួលដោះ-ស្រាយពាក្យបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ, បោះពុម្ពលើកទី២. ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, ២០១០។
- ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅ សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជា-ជីវៈតុលាការ. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១-២. ភ្នំពេញ, ២០១៣។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. សេចក្តី-ពន្យល់ អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៨, ភាគ១។
- ខៀវ ថវិកា. នីតិព្រហ្មទណ្ឌអន្តរជាតិ, បោះពុម្ពលើកទី២. ភ្នំពេញ៖ គីម សួគ៌, ២០១១, ភាគ២
- ក្រុមជនុំទំនៀមទម្លាប់ខ្មែរ. ប្រជុំរឿងព្រេងខ្មែរ, ភាគ៣. ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋ-ប្បវេណី, ភាគ៣ : គន្លឹទី៥, ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០។

- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ, ក្រសួងយុត្តិធម៌, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និង តុលាការ, ២០១៦, ភាគ២។
- ជុំ ចាន់វិត្ថា. កម្រងការងារប្រតិបត្តិ នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី២. ភ្នំពេញ៖ គីម ឡុង, ២០១១។
- ញឹក វុធ្វី. "នីតិកាតព្វកិច្ច." មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. ភាគ២។
- ឌឿក ពិដោរ. នីតិរដ្ឋបាលទូទៅ, ភ្នំពេញ,២០១៥។
- ឌឿក ពិដោរ. នីតិអន្តរជាតិសាធារណៈ, ភ្នំពេញ, ២០១០។
- ឌឿក ពិដោរ. ទ្រឹស្តីរដ្ឋបាលសាធារណៈ. ភ្នំពេញ៖ ឈីរទីម៉ិច គ្រុប, ២០១០, កណ្ឌទី១។
- តុលាការកំពូល. ព្រឹត្តបត្រសាលដីកាះប្រចាំត្រីមាស, លេខ៥, ត្រីមាសទី១. ភ្នំពេញ៖ តុលាការកំពូល, ១៩៩៦។
- នៅ សករាជ. ទំនាក់ទំនងអន្តរជាតិ៖ ទ្រឹស្តី និង ជាក់ស្តែងនិយម. ភ្នំពេញ៖ Makara Delivering Agency. MIDA, ២០១៥។
- ពៅ សារឿន. ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា. ភ្នំពេញ៖ ២០១០។
- ព្រំ ពិសិទ្ធ. តុលាការកាត់ទោសខ្មែរក្រហម៖ ១. តុលាការអន្តរជាតិ ២- អំណាចអង្គការអន្តរជាតិ, ភ្នំពេញ, ២០០៤, ទំព័រ, ២០០៤), ទំព័រ ៥៦
- មីសែល ត្រាណេ. ប្រវត្តិនៃព្រះរាជាណាចក្រកម្ពុជា៖ ការគ្រប់គ្រងរដ្ឋនាសម័យអង្គរ ពីស.វ.ទី៩ ដល់ទី១៤, បោះពុម្ពលើកទី២. ភ្នំពេញ, ២០១៤។
- រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល. កម្រងអត្ថបទច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីរាជការស៊ីវិល. ភ្នំពេញ៖ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, ២០១០។
- រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត. នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារ. ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧។
- រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត. នីតិព្រហ្មទណ្ឌទូទៅ. ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១២។
- លេខាធិការដ្ឋានអង្គការសហប្រជាជាតិ ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា. សិទ្ធិមនុស្ស៖ កម្រងឯកសារ នៃឧបករណ៍អង្គការសហប្រជាជាតិ (ប្រែជាភាសាខ្មែរ)។
- វ៉ាន់ ច័ន្ទតារា. នីតិសិទ្ធិមនុស្ស. ភ្នំពេញ, ២០១៤។

- សាយ បូរី. នីតិរដ្ឋបាលទូទៅ. បោះពុម្ពលើកទី៤. ភ្នំពេញ៖ ប្លូស្សំ ឡូទឹស,២០១២។
- សាយ បូរី. វិទ្យាសាស្ត្ររដ្ឋបាល. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៧។
- សួន ឱសថ. កិច្ចសន្យារដ្ឋបាល ជាមួយនីតិវិធីរដ្ឋបាល. ភ្នំពេញ, ព.ស.២៥៥៥ គ.ស. ២០១១។
- ហៃល ចំរើន. មរតកយុត្តិធម៌ខ្មែរ. ភ្នំពេញ៖ រោងពុម្ពភ្នំពេញ, ២០០៩-២០១០។
- ហៀង សាង. នីតិវិវាទរដ្ឋបាល. ភ្នំពេញ៖ រោងពុម្ពក្រសួងព័ត៌មាន, ២០១៧។
- អ៊ុន យ៉េត. កម្រងព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រសកលលោក. ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៥។
- អ៊ឹង វដ្ឋា. នីតិព្រហ្មទណ្ឌអន្តរជាតិ, បោះពុម្ពលើកទី២. ភ្នំពេញ, ២០១៣។
- អ៊ឹង វដ្ឋា. នីតិអន្តរជាតិសាធារណៈ, បោះពុម្ពលើកទី៦. ភ្នំពេញ, ២០១២។
- អេង សុត. ក្រមព្រហ្មទណ្ឌ, បោះពុម្ពលើកទី២. ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ព.ស.២៥០៧ គ.ស.១៩៦៤។
- ឥន យឿន. នីតិវិវាទរដ្ឋបាល. ភ្នំពេញ, ២០១៦។
- ឥន យឿន. នីតិមុខងារសាធារណៈ. ភ្នំពេញ,២០១១។


## ខ.វចនានុក្រម និង សទ្ទានុក្រម


- ឆយ អូន, ជា ចន្ថា, អ៊ិត មល្លិកា និង នួន ធីរិទ្ធ. សទ្ទានុក្រមបច្ចេកសព្ទ. ភ្នំពេញ, ២០១៨។
- ទីស្តីការគណៈរដ្ឋមន្ត្រី. សទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង រដ្ឋប្បវេណី និង នីតិវិធី-រដ្ឋប្បវេណី. ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧។
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច. សទ្ទានុក្រម បារាំង-ខ្មែរ នៃពាក្យច្បាប់. ភ្នំពេញ, ២០០៥។
- សម្តេចសង្ឃរាជ ជួនណាត. វចនានុក្រមខ្មែរ. ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧។
- ហ៊ីង ធីឫទ្ធិ. វចនានុក្រមច្បាប់, បោះពុម្ពលើកទី៣. ភ្នំពេញ ២០១០។


## ច.គេហៈទំព័រ


- គេហៈទំព័រហ្វ្រេសអាស៊ី.http://freshnewsasia.com:81/index.php/en/localnews/20759-2016-03-25-07-43-25.html (ដកស្រង់, ថ្ងៃទី១៧ ឧសភា ២០១៨)។
- គេហៈទំព័រកម្ពុជាថ្មី. ចុះ៥/ឧសភា/២០១៥ http://kampucheathmey.com/kpt/archives/6574 (ដកស្រង់, ថ្ងៃទី១៧ ឧសភា ២០១៨)។
- គេហៈទំព័រ តុលាការICJ. web: www.icj-cij.org/en/case/50/judgments ដកស្រង់ ២៤ មិថុនា ២០១៨។
- គេហៈទំព័រ វីគីភីឌា. Web: www.en.m.wikipedia.org/wiki/barcelona_traction ដកស្រង់ ២៤ មិថុនា ២០១៨។

- គេហៈទំព័រUN, web: www.un.org/depts/dpko/missions/untac.htm ដកស្រង់ ២៤ មិថុនា ២០១៨។
- គេហៈទំព័រអាស៊ីសេរី,https://www.rfa.org/khmer/news/law/supreme-court-release-bornsamang-and-soksameurn-09252013034938.html (ដកស្រង់ ២៥ មិថុនា ២០១៨)
- គេហៈទំព័រ, http://www.uniset.ca/naty/maternity/nottebohm.htm (ដកស្រង់ ២០ មិថុនា ២០១៨)។
- គេហៈទំព័រ, http://manusama.com/2016/11/22/classic-cases-barcelona-traction-case-1970/ (ដកស្រង់ ២០ មិថុនា ២០១៨)។
- គេហៈទំព័រ, https://www.legifrance.gouv.fr/affichJuriAdmin.do?idTexte=CETATEXT000007605886 (ដកស្រង់ ១៦ កក្កដា ២០១៨)។

# បញ្ជីរាយនាម ឧបសម្ពន្ធ

**ឧបសម្ពន្ធទី១**

ទម្រង់ ពាក្យបណ្ដឹងដាក់ទៅការិយាល័យប្រជាពលរដ្ឋ

**ឧបសម្ពន្ធទី២**

២.១.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ២៧៥

២.២.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ១០

២.៣.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ៣០

២.៤.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ៧៣

២.៥.សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ១៣

២.៦.សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ០៨

២.៧.សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ១៣ (១៩៩៨)

**ឧបសម្ពន្ធទី៣**

៣.១.រឿងក្ដី Barcelona Traction

៣.២.រឿងក្ដី blanco

# ឧបសម្ពន្ធទី១

## ១.១.ទម្រង់ ពាក្យបណ្ដឹងដាក់ទៅការិយាល័យប្រជាពលរដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹង**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ--------------------------- សញ្ជាតិ---------- ឆ្នាំកំណើត---------
មុខរបរបច្ចុប្បន្ន-----------------------------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ----------
ផ្លូវលេខ----------- ក្រុម---------- ភូមិ--------------------- ឃុំ សង្កាត់----------------
ស្រុក ក្រុង ខណ្ឌ---------------------- រាជធានី ខេត្ត ----------------------

**សូមគោរពជូន**
**លោក លោកស្រីប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ..........**

**<u>កម្មវត្ថុ:</u>** ពាក្យបណ្ដឹងអំពី--------------------------------------------------។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមជម្រាបជូនថា :

១. ករណីបានកើតឡើង : ( បរិយាយហេតុការណ៍បានកើតឡើង ដែលបានមើលឃើញ ឬដឹង)
---------------------------------------------------------------------------
---------------------------------------------------------------------------

២. នៅពេលណា? កន្លែងណា? កើតឡើងដូចម្ដេច?
---------------------------------------------------------------------------
---------------------------------------------------------------------------

៣. នរណាអ្នកប្រព្រឹត្ត? ឈ្មោះអ្វី? តួនាទី? អាសយដ្ឋាន?
---------------------------------------------------------------------------
---------------------------------------------------------------------------

៤. នរណាបានឃើញហេតុការណ៍នេះ? ឈ្មោះអ្វី? តួនាទី? អាសយដ្ឋាន?
---------------------------------------------------------------------------
---------------------------------------------------------------------------
---------------------------------------------------------------------------

១០

៥. សូមបញ្ជាក់អំពីភស្តុតាងដូចជា ឈ្មោះឯកសារ អ្នកកាន់កាប់ឯកសារ ទីកន្លែង ( ប្រសិនបើដឹងអំពីភស្តុតាង ឬឯកសារ)
-----------------------------------------------------------------------
-----------------------------------------------------------------------
-----------------------------------------------------------------------
-----------------------------------------------------------------------

៦. សូមផ្តល់ឯកសារពាក់ព័ន្ធនឹងករណីខាងលើនេះ( ប្រសិនបើមាន)
-----------------------------------------------------------------------
-----------------------------------------------------------------------

អាស្រ័យហេតុនេះ សូមលោកប្រធានការិយាល័យប្រជាពលរដ្ឋ មេត្តាជួយសម្រុះសម្រួល ដោះស្រាយឬ អន្តរាគមន៍តាមសំណើខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ នាងខ្ញុំ ។

ធ្វើនៅថ្ងៃទី........ ខែ.............ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

__បញ្ជាក់ :__ ការិយាល័យប្រជាពលរដ្ឋ ត្រូវរក្សាការសម្ងាត់ជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដែលដាក់ពាក្យប្តឹង ឬបានរាយការណ៍ ។

១១

## ២.២.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿងរដ្ឋប្បវេណី
លេខ : ១០
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦

សាលដីកា

លេខ : ៥១
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦

តាងនាមប្រជាពលរដ្ឋខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៦ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ចាន់ សុក ជាប្រធាន
២-លោក ប៉ែន ស៊ិន ជាចៅក្រម
៣-លោក វៀល មួន ជាចៅក្រម
៤-លោក ស៊ិន ឌឹម ជាចៅក្រម
៥-លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី កញ្ញា សេន សុខា

តំណាងមហាអយ្យការលោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ឆ្នាំ១៩៩៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤០០ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ស ហួរ ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ របរកស៊ីធ្វើការនៅទីចាត់ការគយ ទីលំនៅសព្វថ្ងៃផ្ទះលេខ៨៨បេ ក្រុមទី៣៧ សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ *ស ហ៊ីម* "រ" ម្តាយឈ្មោះ *យឹម អាត* "រ"។ តំណាងឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ជ័យ សំរិទ្ធិ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ ជាតំណាងក្រុមហ៊ុនគឹមហាប់ ទីលំនៅសព្វថ្ងៃផ្ទះលេខ១០ ផ្លូវលេខ២៨៥ ខណ្ឌទួលគោក ក្រុងភ្នំពេញ។

តាមបណ្តឹងសាទុក្ខលេខ៣២១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់នាយកដ្ឋានគយ និង រដ្ឋាករ បានប្តឹងមិនសុខចិត្តនឹង សេចក្តីសម្រេចនៃសាលដីកា លេខ៤២២ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១០ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៥ របស់ឈ្មោះ *ជ័យ សំរិទ្ធិ* តំណាងក្រុមហ៊ុន *គឹម ហាប់* ជាដើមចោទប្តឹងពីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុទាមទារ :

១-បដិសេធ សេចក្តីសម្រេចលេខ០០៤ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រង់ប្រការមួយ "១" ចំណុច ក។

២-ទាមទារយកទំនិញ៧មុខ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឃាត់ទុកសុំបង់ពន្ធជូនរដ្ឋតាមតម្លៃប្រកាស និង តាមតម្លៃអត្រាឆ្លងកាត់។ ទំនិញ៧ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាប់ឃាត់ទុកកាលពីថ្ងៃទី ៣០ មករា ឆ្នាំ១៩៩៥ រួមមាន :

១.រថយន្តថ្មីចង្កូតឆ្វេង " *ហុងដាអាកកត* " ចំនួន០៦ គ្រឿង

២.ម៉ាស៊ីនភ្លើង ចំនួន៥៦ គ្រឿង

៣.បារី ៥៥៥ ចំនួន២.០០០ប៊ិច

៤.បារីម៉ាក សេរិនឌីយាមង់ ចំនួន៤១២០ប៊ិច

៥.បារីម៉ាក ដុនហ៊ិល ចំនួន៧០ប៊ិច

៦.បារីម៉ាក រ៉ុតមិន ចំនួន៣០ប៊ិច

៧.សម្ភារៈសម្រាប់ផ្សាយពាណិជ្ជកម្ម ចំនួន៩០កញ្ចប់។

ខ្លួនអះអាងថា ក្រុមហ៊ុនរបស់ខ្លួន មិនដែលរកស៊ីគេចពន្ធ ឬ គេចពន្ធម្តងណាឡើយ ជាក់ស្តែងកាប៉ាល់ឈ្មោះ *ហេរុណា* នោះនាំទំនិញចូលមកក្រុមហ៊ុន ខ្លួនបានទៅជំរាបជូនលោកនាយកគយដើម្បីសុំតម្លៃបង់ពន្ធរួចទើបបង្វែសាច់ប្រាក់ចូលរតនាគារជាតិ ចំនួន ៤១៥.០០០.០០០ (បួនរយដប់ប្រាំលាន) រៀល។

បានឃើញសាលក្រមលេខ ៧៧ "គ" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៥ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

២-ទទួលស្គាល់ការផ្ទេរសិទ្ធិ របស់ក្រុមហ៊ុនគឹមហាប់ ឱ្យលោក *លុយ ចាន់ផល* ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

៣-ទទួលស្គាល់ លោក *ស ហូរ* តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមលិខិតចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៥ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

៤-បង្គាប់មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យប្រគល់ទំនិញចំនួន៧មុខ មានៈ

១.រថយន្តថ្មីចង្កូតឆ្វេង " *ហុងដាអាកកត* " ចំនួន០៦ គ្រឿង

២.ម៉ាស៊ីនភ្លើង ចំនួន៥៦ គ្រឿង

៣.បារី ៥៥៥ ចំនួន២.០០០បិច

៤.បារីម៉ាក សេរិនឌីយាមង់ ចំនួន៥១២០បិច

៥.បារីម៉ាក ដុនហិល ចំនួន៧០បិច

៦.បារីម៉ាក រ៉ុតមិន ចំនួន៣០បិច

៧.សម្ភារៈសម្រាប់ផ្សាយពាណិជ្ជកម្ម ចំនួន៩០កញ្ចប់។

ឱ្យទៅក្រុមហ៊ុនគឹមហាប់វិញ ដោយបង្គាប់ឱ្យក្រុមហ៊ុន គឹមហាប់ បង់ពន្ធជូនរដ្ឋ តាមតម្លៃប្រកាស និងតាមតម្លៃអត្រាឆ្លងកាត់។

៥-លុបសេចក្តីសម្រេចលេខ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រង់ប្រការមួយ "១" ចំណុច ក និង ប្រការ ៣ ចំណុច ក ចោលជាអាសារបង់។

៦-បង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ១៨០០ (មួយពាន់ប្រាំបីរយ) រៀល រង្វាន់ខាងក្រឡាបញ្ជីកាន់ហិបប្រាក់២០០ (ពីររយ) រៀល រង្វាន់សាក្សី ២.០០០ (ពីរពាន់) រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៣.០០០ (បីពាន់) រៀល បូករួម ៧.០០០ (ប្រាំពី) រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០ (ប្រាំពីពាន់) រៀល ដែលដើមចោទបានបង់ទុករួចជាស្រេច។

-កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បង់ប្រាក់ ៧.០០០ (ប្រាំពីរពាន់) រៀល ទៅដើមចោទវិញ។ និងឱ្យបង់ពន្ធសមាមាត្រ ១ភាគរយ លើពន្ធ ដែលក្រុមហ៊ុន គឹមហាប់ បង់ពន្ធជូនរដ្ឋ។ ប្រាក់នេះ ត្រូវបង់ ចូលថវិការដ្ឋ ៨០ ភាគរយ និងបាន ជារង្វាន់ក្រឡាបញ្ជីទូទៅប្រទេស ២០ភាគរយ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខគូរភាគី សម្រេចបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេល២ ខែ ចាប់តាំងពីថ្ងៃនេះតទៅ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៩គ ចុះថ្ងៃទី៣៨ ខែសីហា ឆ្នាំ១៩៩៥ របស់លោក *ស ហួរ* ដែលប្តឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណី លេខ៧៧ "គ" ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូល។

បានឃើញបណ្តឹងឧទ្ធរណ៍ លេខ៤៧ "គ" ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៥ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ បានប្តឹងជំទាស់ត្រង់ចំណុចវិនិច្ឆ័យសេចក្តីទាំងមូល។

បានឃើញសាលដីការលេខ ៤២២ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១-ទទួលបណ្តឹងឧទ្ធរណ៍ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង បណ្តឹងឧទ្ធរណ៍ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់។

២-សម្រេចបដិសេធ សាលក្រមលេខ៧៧ "គ" ចុះថ្ងៃទី២៦ កក្កដា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញចោល។

៣-សម្រេចតម្កល់សេចក្តីសម្រេចលេខ ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទុកជាត្រឹមត្រូវតាមច្បាប់ ប៉ុន្តែអំពីការផាកពិន័យលើបារី និង សម្ភារៈផ្សាយពាណិជ្ជកម្ម និង រថយន្តចង្កូតឆ្វេង៦គ្រឿង ត្រូវលើកចោល។

៤-សម្រេចឱ្យក្រុមហ៊ុនគឹមហាប់ បង់ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន១៣.០០០ (មួយម៉ឺនបីពាន់) រៀល គឺពន្ធចុះបញ្ជីក្តី ពន្ធហ្មឹង ២.៥៥០ (ពីរពាន់ប្រាំរយ) រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០ (បួនរយហាសិប) រៀល ចំណាយលើការប្រគល់លើការកោះ ៥.០០០ (ប្រាំពាន់) រៀល និង អាជ្ញាធរតុលាការ ៥.០០០ (ប្រាំពាន់) រៀល បូករួម ១៣.០០០ (មួយម៉ឺនបីពាន់) រៀល។

-បង្គាប់ឱ្យក្រុមហ៊ុនគឹមហាប់ បង់ពន្ធសមាមាត្រ។

៥-សាលដីការនេះ ប្រកាសនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ បើកផ្លូវសារទុក្ខ កំណត់២ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

បានឃើញបណ្តឹងសាទុក្ខលេខ៣២១ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់ឈ្មោះ *ស ហួរ* និង លិខិតលេខ ១៦៤៤ គ.រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់នាយកដ្ឋានគយ និង រដ្ឋាក ប្តឹងមិនសុខចិត្ត នឹងសេចក្តីសម្រេចត្រង់ចំណុចទី៣។

បានឃើញសារណាចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់ទីចាត់ការគយ និង រដ្ឋាករ។

បានឃើញសារណាតប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់ឈ្មោះ *ជ័យ សំរិទ្ធិ* ជាតំណាងឱ្យក្រុមហ៊ុនគឹមហាប់។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា:

-យល់ឃើញថា រឿងក្តីនេះ ជាប្រភេទរឿងក្តីរដ្ឋបាល ដោយភាគីម្ខាង ជាតំណាងឱ្យស្ថាប័នរដ្ឋ មានវិវាទ ជាមួយ ភាគីម្ខាងទៀតជាក្រុមហ៊ុនឯកជន។ នេះជាវិវាទរដ្ឋបាល សុំមោឃៈភាពសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋ ហើយដែលតាមមាត្រា១០៩ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចូលជាសមត្ថកិច្ចរបស់សាលាជម្រះក្តីបច្ចុប្បន្ន។

-យល់ឃើញថា មានកិច្ចសន្យាអន្តរជាតិទំនិញ ដែលមានរាយមុខក្នុងនិវេទនបណ្ណ ដោយក្រុមហ៊ុនគឹមហាប់ជាមួយអ្នកលក់នៅសឹង្ហបុរី តាមនិមិត្តសញ្ញា CIF (Cost Insurance Freight) ដោយសរុបទាំងថ្លៃទិញ (Cost) ទាំងថ្លៃធានារ៉ាប់រង (Insurance) និង ទាំងថ្លៃដឹកជញ្ជូន។ រថយន្ត ២៧គ្រឿង ចង្កូតស្តាំមិនមែនជា រថយន្តរបស់ក្រុមហ៊ុនគឹមហាប់ទេ ដោយនាពេលសវនការនៅ សាលាឧទ្ធរណ៍ អ្នកបើកកប៉ាល់បានបំភ្លឺច្បាស់ថា ក្រុមហ៊ុន VASAN SHIPPING & TRADING PTE.LTD បានប្រាប់ខ្លួនឱ្យប្រគល់ទំនិញនេះទៅឱ្យឈ្មោះ *ងួន រីវ* នៅពេលមកដល់កម្ពុជា។

-យល់ឃើញថា ការពិគ្រោះថ្លៃពន្ធនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥ ជាការសឱ្យឃើញថា ទំនិញពិតជា និង ចូលមកព្រះរាជាណាចក្រកម្ពុជាមែន ហើយម្ចាស់ទំនិញមានឆន្ទៈស្មោះត្រង់ បង់ពន្ធគយមែន។

-យល់ឃើញថា ការគិតគូរថ្លៃពន្ធទៀតសោតក៏មិនមែនជាគិតលេខក្រៅផ្លូវការ យកជាការក៏បាន ឬ មិនយកជាការក៏បាននោះទេ ពីព្រោះមន្ត្រីគយជាន់ខ្ពស់ បានបញ្ជាក់ថ្លៃពន្ធ បានចុះហត្ថលេខា ហើយថែមទាំងបានវាយត្រាជាផ្លូវការថែមទៀត។

-យល់ឃើញថា អំពីរថយន្ត *ហុកដា* ចង្កូតឆ្វេង សេរី៩៤ ចំនួន៦គ្រឿង តុលាការក្រុងភ្នំពេញក៏ដូចជាតុលាការឧទ្ធរណ៍ ដែលមិនចាប់កំហុសពីក្រុមហ៊ុននោះ ជាការត្រឹមត្រូវហើយ។ ដោយយល់ឃើញថា ក្រុមហ៊ុនគឹមហាប់ នាំរថយន្តថ្មីប្រភេទនេះ ចូលជាច្រើនលើកមកហើយ ហើយតាមធម្មតាពេលរថយន្តមកដល់ដៃទើបគយចុះទៅពិនិត្យ និង តម្រូវឱ្យបង់ពន្ធតែម្តង ដោយមិនចាំបាច់ពិគ្រោះតម្លៃជាមុនទេ។ អង្គការគយ និង រដ្ឋាករ ក៏បានឆ្លើយទទួលស្គាល់នៅមុខតុលាការរួចហើយដែរ។

-យល់ឃើញថា តាមគោលការណ៍នៃច្បាប់លើកលែងតែមានសេចក្តីសម្រេចផ្សេងទៀត ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បើទំនិញនៅមានគ្រប់ចំនួនទាំងអស់ ហើយឥតបានត្រូវចាប់នៅពេលកំពុងគេចវេសរត់ពន្ធជាក់ស្តែងទេ នោះមិនអាចចាត់ទុកជារត់គេចពន្ធបានឡើយ។

-យល់ឃើញថា ការលើកឡើងតាមមាត្រា១៣វាក្យខណ្ឌទី៥ នៃច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ នាំចូល ដែលជាសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសេចក្តីសម្រេចចុងក្រោយបង្អស់មិនអាចតវ៉ាបានទៀតទេ នោះពុំទាន់មានលក្ខណៈត្រឹមត្រូវទេ ពីព្រោះថា ខ្លឹមសារនៃមាត្រានៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលរដ្ឋសភា បានអនុម័ត នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ បាននិរាករណ៍ដោយខ្លឹមសារនៃមាត្រា១៣ វាក្យខណ្ឌទី៥

នៃច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ នាំចូល រួចហើយដោយមាត្រា២៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាចែងថា "*បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍*"។

មហាអយ្យការសន្និដ្ឋានសូមឱ្យតុលាការកំពូលសម្រេចតម្កល់សាលដីការដ្ឋបាលលេខ៤២២ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និង គតិច្បាប់។

បានស្តាប់របស់ចម្លើយ លោក *ស ហូរ* ដែលបានឆ្លើយនៅពេលសវនការថា : ខ្លួនសូមឱ្យមាន ការសម្រេចមួយយ៉ាងត្រឹមត្រូវ ពីព្រោះថា ការសម្រេចរបស់សាលាឧទ្ធរណ៍គឺ មានភាពពុំត្រឹមត្រូវ ដូច្នេះ ទីចាត់ការគយ សូមធ្វើសំណូមពរ ឯកឧត្តមប្រធានតុលាការ ធ្វើការស៊ើបអង្កេតពិចារណា ស្រាវជ្រាវឡើងវិញ អំពីបញ្ហាទាំងអស់ ដែលបានលើកក្នុងសារណាគឺ ធ្វើយ៉ាងណាឱ្យមានការជំនុំ ជម្រះជាថ្មី។ ប៉ុន្តែផាកពិន័យលើបារី សម្ភារៈផ្សាយពាណិជ្ជកម្ម និង រថយន្តចង្កូតឆ្វេងចំនួន៦គ្រឿង ដែលបានលើកចោលក្នុងសាលដីកាលេខ ៤៤២ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ គឺជាការពុំត្រឹមត្រូវ តាមគតិច្បាប់ និង ច្បាប់ពន្ធនាំចេញ នាំចូល។

បានស្តាប់ចម្លើយរបស់លោក *ជា ប៉េងឈាង* ដែលបានឆ្លើយនៅពេលសវនាការថា : ខ្លួនជា អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និង ជាអ្នកចូលរួមក្នុងប្រតិបត្តិការចុះចាប់ផ្ទាល់។ ដូចដែល មហាអយ្យការ និង ចៅក្រមរបាយការណ៍ បានលើកឡើងហើយ អំពីព្រឹត្តការណ៍នោះរឿងនេះ លោក *ស ហូរ* បានលើកឡើងហើយដែរ គឺមានតុលាការថ្នាក់ក្រោម ធ្វើការវិនិច្ឆ័យជាបន្តបន្ទាប់មក ហើយ ប៉ុន្តែ ខ្លួនសុំធ្វើការបំភ្លឺបន្ថែមនៅអង្គជំនុំជម្រះ អំពីដំណើររឿងដូចតទៅ :

ក.- កប៉ាល់ *ហេរុណា* ដែលជាមធ្យោបាយដឹកទំនិញ ត្រូវបានតុលាការថ្នាក់ក្រោម ទទួល ស្គាល់ថាជាកប៉ាល់ខុសច្បាស់ ហើយត្រូវបានរឹបអូសជាសម្បត្តិរដ្ឋ។

- នាវិកទាំង ១០រូប ដែលជាអ្នកទទួលខុសត្រូវ និងកាន់កាប់នៅលើនាវានោះ ត្រូវផ្តន្ទាទោស ដាក់ពន្ធ និង ព្យួរទោសរួចហើយ។

-រថយន្តចង្កូតស្តាំ ២៧គ្រឿង ត្រូវបានតុលាការធ្វើកំណត់ត្រាទុក "ហើយរថយន្តចង្កូតស្តាំ ២៧គ្រឿងនេះ កាលដោះស្រាយនៅតុលាការថ្នាក់ក្រោម ក៏ដូចជានៅសាលាឧទ្ធរណ៍ ទទួលស្គាល់ ថាជារបស់លោកគឹមហាប់ពិតប្រាកដ"។

-តុលាការថ្នាក់ក្រោមបានផាកពិន័យ លើម៉ាស៊ីនភ្លើងទាំង៣៦គ្រឿងរួចហើយ នេះជាចំណុច ដែលតុលាការទទួលស្គាល់ថា ជាបទល្មើសរត់ពន្ធ ហើយក៏ត្រូវតុលាការផ្តន្ទាទោសតាមច្បាប់ហើ យ។

ខ.-តុលាការថ្នាក់ក្រោម ទុកថាជាទំនិញស្របច្បាប់ដូចមានខាងក្រោម :

រថយន្ត៦គ្រឿង សម្ភារៈផ្សាយពាណិជ្ជកម្ម បារីចំនួន៩១កាតុង បារី៦២១៨ ប៊ិច ក្នុងនោះមាន បារី៥៥៥ ចំនួន២.០០០ប៊ិច ត្រូវបានក្រុមហ៊ុនឃុបឃិតជាមួយម្ចាស់ផ្ទះ ដែលជាអ្នកស៊ីឈ្នួលថែរក្សាវត្ថុតាង របស់ក្រសួងសេដ្ឋកិច្ច មានលិខិតកិច្ចសន្យាតាមផ្លូវច្បាប់ បានលួចបារីទាំងនេះ ទៅលក់ ដើម្បីបំបាត់វត្ថុតាង នេះជាកំហុសមួយបន្ថែមទៀតទៅលើបទល្មើសរត់ពន្ធ ហើយរឿងនេះក្រសួងសេដ្ឋកិច្ច លោកនាយកទីចាត់ការគយ និង រដ្ឋាករ បានប្តឹងទៅតុលាការភ្នំពេញរួចហើយ ប៉ុន្តែរហូតមកដល់ពេលនេះ មិនទាន់មានចម្លើយយ៉ាងណាទេ។ ហេតុនេះសូមអង្គជំនុំជម្រះបានជ្រាប។

ដូច្នេះខ្លួនយល់ថាទំនិញទាំងអស់ដែលនៅលើនាវា ដែលមានចុះក្នុងបណ្ណគឺជាទំនិញ របស់ក្រុមហ៊ុនគឹមហាប់ទាំងអស់ ម្យ៉ាងទៀតសូមឱ្យតុលាការចាប់អារម្មណ៍លើមធ្យោបាយដឹកជញ្ជូន ដែលខុសច្បាប់ គឺដឹកទំនិញល្មើសច្បាប់មួយចំនួនរបស់ក្រុមហ៊ុនគឹមហាប់ តែហេតុអ្វីក៏បារីត្រូវជាទំនិញត្រូវច្បាប់ទៅវិញ? ខ្លួនសុំសំណូមពរឱ្យតុលាការកំពូល សម្រេចតម្កល់សេចក្តីសម្រេចលេខ០០៩ សសរ.សហវខ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំងស្រុងទុកជាត្រឹមត្រូវតាមច្បាប់។

បានស្តាប់ចម្លើយរបស់លោក *សា វ៉ាក់ ខាន់* ដែលបានឆ្លើយនៅពេលសវនាការថា : ក្រោយពីបានស្តាប់របាយការណ៍ និង សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ ខ្លួនអាចដឹងថា ការសម្រេចសេចក្តី និង ទៅជាយ៉ាងណាហើយ ប៉ុន្តែខ្លួនៅតែមិនទាន់អស់ចិត្ត ខ្លួននៅមានចំណុចជំទាស់ជាច្រើន ពីព្រោះថា សេចក្តីសន្និដ្ឋានពុំទាន់សមស្របក្នុងប្រព័ន្ធច្បាប់ទេ។

ខ្លួនចាប់អារម្មណ៍ថា កិច្ចសន្យារបស់ក្រុមហ៊ុននេះ មិនមែនជាកិច្ចសន្យាអន្តរជាតិទេ។ តាមការពិតក្រុមហ៊ុនគឹមហាប់ ពុំបានបង្ហាញកិច្ចសន្យាណាមួយឡើយ នៅសាលាឧទ្ធរណ៍ ចំណុចណាគាត់យល់ព្រម ទើបគាត់យល់ព្រម ដូចជារថយន្តចង្កូតស្តាំ២៧គ្រឿង ជាឈ្មោះរបស់គាត់ ជាកិច្ចសន្យាអន្តរជាតិដែរ ដូច្នេះ ត្រូវទទួលស្គាល់ថា អ្វីនៅក្នុង និងជាការត្រឹមត្រូវ។

-ក្រុមហ៊ុនគឹមហាប់ថា បានត្រៀមលុយបង់ពន្ធជាប្រការមិនត្រឹមត្រូវ តាមនីតិវិធីរតនាគារ ក៏ដូចជាធនាគារដែរព្រោះគ្រាន់តែជាបញ្ជីលុយបញ្ញើពីរតនាគារជាតិ ទៅបញ្ជីបញ្ញើគណនីរតនាគារក្រុងព្រះសីហនុ គឺរដ្ឋមិនហ៊ានប៉ះពាល់ប្រាក់បញ្ញើរបស់គាត់ទេ មានន័យថានេះមិនមែនជាសុច្ឆន្ទៈរបស់គាត់ក្នុងការបង់ពន្ធឡើយ។

-តាមលិខិតណែនាំរបស់សម្តេចក្រុមព្រះ គឺគាំទ្រសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទាំងស្រុង ប៉ុន្តែតុលាការដូចជាមិនសូវយចិត្តទុកដាក់ឡើយ។ ក្រុមហ៊ុនគឹមហាប់គ្មានសុច្ឆន្ទៈក្នុងារបង់ពន្ធឡើយ។ បើកុំតែក្រុមប្រតិបត្តិចុះទៅពិនិត្យ ឃើញកប៉ាល់លួចចូលមកដោយគ្មានច្បាប់ ទម្លាប់ខុសនឹងច្បាប់អន្តរជាតិ ហើយលួចផ្ទេរទំនិញនៅពេលយប់ នៅកន្លែងដែលហាមឃាត់នោះ កុំអីទំនិញទាំងនោះនឹងរត់រួចពន្ធអស់ហើយ។ នៅសាលាឧទ្ធរណ៍ ជារឿងមួយអយុត្តិធម៌ ដែល

ហៅតែក្រុមហ៊ុនផ្សេង ពុំពាក់ព័ន្ធនឹងក្រុមហ៊ុនគឹមហាប់មកសួរ ដែលមិនអាចយកជាការបាន ឯគណៈកម្មការចម្រុះ ចុះចាប់ផ្ទាល់មិនបានហៅមកសួរទេ។

-មហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន ទំនិញនាំចេញ នាំចូលទុកជាមោឃៈ ហើយចំណុចនេះខ្លួនសុំជំរាបថា ក្រសួងហិរញ្ញវត្ថុ ជារដ្ឋាភិបាល និង រដ្ឋសភា នៅតែទទួលស្គាល់ច្បាប់នេះ នៅជាធរមាននៅឡើយ សម្រាប់សកម្មភាពក្រសួង ហិរញ្ញវត្ថុ គ្រប់គ្រងលើកិច្ចការគយ។ តាមមាត្រា៣ នៃច្បាប់តុលាការទាំងពីរថ្នាក់បានរំលោភ ព្រោះថាច្បាប់នេះពាក់ព័ន្ធនឹងច្បាប់គយ ប៉ុន្តែពេលពិភាក្សាពុំបាននឹងឃើញអ្វីបន្តិចពីច្បាប់គយឡើយ។ ក្រុមហ៊ុនគឹមហាប់ បានសារភាពអស់ហើយ តែការសម្រេចបែជាទៅជូរទៅវិញ។ តាមលិខិតរបស់ឯកឧត្តម *ចែម សួន* បានយកចិត្តទុកដាក់លើបញ្ហាវត្ថុតាង រឿងនេះក្រុមហ៊ុនគឹមហាប់ បានរំលោភយកវត្ថុតាងទាំងអស់។ ចំពោះទំនិញទាំងអស់មាន រថយន្តចង្កូតស្តាំ២៧គ្រឿង រថយន្តហុងដាចង្កូតឆ្វេង៦គ្រឿង ម៉ាស៊ីនភ្លើង៥៦គ្រឿង បារី៦.២១៨ ប៊ិចសម្ភារៈផ្សាយពាណិជ្ជកម្មចំនួន៩១កាតុង នាវិក១០នាក់ នាវាដែក១គ្រឿង គឺជាចំណុចសំខាន់នៃការកាត់ក្តី ខ្លួនសូមគាំទ្រថានេះជាអំពើរត់ពន្ធ ហើយតុលាការទាំងពីរថ្នាក់ កន្លងមកបានរឹបអូសយកកប៉ាល់នេះ ដោយចាត់ទុកកប៉ាល់នេះ ប្រព្រឹត្តអំពើរត់ពន្ធ ដែលបានឃុំខ្លួននាវិកទាំង១០រូបនេះ ជាអ្នករួមចំណែកក្នុងការប្រព្រឹត្តអំពើរត់ពន្ធ ហេតុអ្វីក៏ថាក្រុមហ៊ុនមិនដឹងអ្វីសោះព្រោះទំនិញជារបស់ក្រុមហ៊ុនគឹមហាប់ រថយន្តចង្កូតស្តាំ២៧គ្រឿង និង ម៉ាស៊ិនភ្លើង៥៦គ្រឿង ជារបស់រត់ពន្ធ បង្ខំឱ្យបង់ពន្ធ ចុះទំនិញពីរមុខទៀតម្តេចក៏មិនមែនជារបស់រត់ពន្ធ?

តំណាងអយ្យការបានឆ្លើយតប ច្បាប់ពន្ធលើទំនិញនាំចូលមិនមែនទុកជាមោឃៈទាំងស្រុងទេ។ ច្បាប់នេះនៅតែជាធរមានបញ្ញត្តិដដែល ប៉ុន្តែគំនិតដែលយើងបកស្រាយនេះ គឺបកស្រាយលើសមត្ថកិច្ចនៃការប្តឹងដែលជាប្រភេទរឿងក្តីរដ្ឋបាល ដោយភាគីម្ខាងជាតំណាងឱ្យស្ថាប័នរដ្ឋ មានវិវាទជាមួយភាគីម្ខាងទៀតជាក្រុមហ៊ុនឯកជន។ ក្រុមហ៊ុនឯកជនតវ៉ាពីសេចក្តីសម្រេចរបស់ក្រួសងហិរញ្ញវត្ថុដែលដាក់ពិន័យលើទំនិញរបស់ខ្លួនដោយបំពានច្បាប់។ នេះជាវិវាទរដ្ឋបាលសុំមោឃៈភាពសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋ ហើយដែលតាមមាត្រា១០៩ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីនៃរដ្ឋកម្ពុជាក៏បាននិយាយអំពីសមត្ថកិច្ចតុលាការខេត្តក្រុងជំនុំជម្រះរឿងក្តីរដ្ឋបាលផងដែរ។

បានស្តាប់ចម្លើយរបស់លោក *ជ័យ សំរិទ្ធិ* ដែលបានឆ្លើយនៅពេលសវនាការថា : ខ្លួនបានស្តាប់សំដីរបស់មន្ត្រីជាន់ខ្ពស់ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឃើញថា មានសេចក្តីអង់អាចខ្ពង់ខ្ពស់ហ៊ានលះបង់ឧបសគ្គទាំងអស់រហូតដល់ចៅក្រមកាត់ពីរកន្លែងហើយគាត់ថាឥតប្រយោជន៍ដូច្នេះសវនាការថ្ងៃនេះ ប្រហែលជាសមត្ថភាពរបស់ចៅក្រម តុលាការមិនស្មើនឹងគាត់ទេ ព្រោះគាត់ហ៊ានឱ្យតម្លៃមុន ហើយមិនតែប៉ុណ្ណោះ គាត់ថាតុលាការប្រហែលជាខ្វះគតិច្បាប់។ ខ្លួនសុំបំភ្លឺថា ឯក

ឧត្តមជាស្ថាប័នរដ្ឋ ហើយតុលាការជាស្ថាប័នរដ្ឋ ហើយឯករាជ្យ ដូច្នេះសូមអង្គតុលាការជួយរកការពិតឱ្យខ្លួនផង ព្រោះខ្លួននាំទំនិញមិនមែនតែថ្ងៃនេះទេ គឺនាំមកមានរយៈពេល៩.៥ ឆ្នាំហើយ ឯកុងត្រារថយន្តចង្កូតឆ្វេងនោះ ក្រុមហ៊ុនគឹមហាប់ នាំផ្តាច់មុខចូលស្រុកខ្មែរ ឯបារី៥៥៥ ក្រុមហ៊ុន*អានគូ* នាំចូលផ្តាច់មុខ ចំណែកបារីហ្សេត គឺក្រុមហ៊ុន *ថៃប៊ុនរុង* មានសិទ្ធិនាំចូលផ្តាច់មុខ។ តែខ្លួននាំចូល ២.០០០ប៊ិចដោយមានត្រា និង ហត្ថលេខា *អានគូ* ស្រេចដូច្នោះ តាមច្បាប់ទំនិញនាំចេញនាំចូលវិញ គឺពេលណាទំនិញនាំចូលដល់កំពង់ផែ ពេលនោះទើបមន្ត្រីពន្ធ និង គយ ចូលទៅពិនិត្យទំនិញនៅលើកំពង់ផែនោះ ពិនិត្យើយទើបឱ្យនាំចេញជាចុងក្រោយ ចំពោះលុយដែលដាក់ចូលក្នុងក្រុមហ៊ុននោះបើខ្លួនមានគំនិតចង់គេចពន្ធ ខ្លួនមិនបាច់ប្រាប់ថាមានបារី ២.០០០ប៊ិច ដល់ពេលពិនិត្យនៅតែ ២.០០០ប៊ិច មានលើស ឬ ខ្វះឯណា។ ចំពោះទំនិញដទៃទៀតគឺមានគ្រប់ចំនួនដែលខ្លួនមានជាគោលការណ៍ ចំពោះកប៉ាល់នោះខ្លួនមិនដឹងថាមកទេ ហើយខ្លួនមិនបានឃុបឃិតជាមួយកប៉ាល់នាំទំនិញចេញដូចដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចោទប្រកាន់នោះទេ ព្រោះគ្មានវត្ថុតាងណាដែលជាសំអាង ទីកន្លែងខុសច្បាប់នោះផង ហេតុនេះ បើសិនជាចាប់ទំនិញខ្លួន ខ្លួនសូមទាមទាររកវត្ថុតាង។ ឯកឧត្តមគាត់មានប្រសាសន៍ថា ក្រុមហ៊ុនគឹមហាប់បានទៅលួចយកវត្ថុតាងចំនួន ២.០០០ ប៊ិច សូមតុលាការជួយ ពិចារណាផងព្រោះថាបារី ២.០០០ប៊ិច មិនមែនតិចដូចក្រដាស់មួយសន្លឹកតូចឯណា បើដាក់ឡានកាម៉ាសវិញមិនតិចឡានទេ ហើយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកដឹកតាំងពីកណ្តាលសមុទ្រមកការពារតើ រឿងអីបានជាដឹកចេញពីក្នុងឃ្លាំងអស់ហើយមកឆ្លើយដាក់ខ្លួនវិញ? ដូច្នេះ ហើយខ្លួនសុំឱ្យតុលាការរកវត្ថុតាងឱ្យខ្លួនផង ចំពោះពាក្យថាកប៉ាល់ខ្លួននេះរត់ពន្ធ ខ្លួនសូមរកវត្ថុតាងបើគ្មានទេខ្លួនពុំទទួលខុសត្រូវឡើយ ម៉្យាងទៀតខ្លួនមានលិខិតអនុញ្ញាតចុះហត្ថលេខាដោយលោក *ស ហួរ* ឱ្យបង់ពន្ធជាបណ្តោះអាសន្ន ហេតុអីថាមិនបានការ។

ការស្តាប់ចម្លើយរបស់លោក *សារ៉ាក់ ចាន់* ដែលបានឆ្លើយនៅពេលសវនាការថា : ខ្លួនមិនបានមើលងាយតុលាការទេ ខ្លួនចង់តែចង់បកស្រាយបន្ថែម ដែលតំណាងក្រុមហ៊ុន គឹមហាប់ គាត់ថាចង់រកវត្ថុតាងនៅកណ្តាលសមុទ្រនោះ។ វត្ថុតាងគឺនៅលើកំណត់ហេតុនេះព្រោះសមាសភាពចម្រុះ បានទៅចុះចាប់ ធ្វើកំណត់ហេតុនេះ ហើយម្ចាស់កប៉ាល់ក៏បានសារភាពដែរ ក្នុងនេះមានរថយន្តចង្កូតស្តាំបីគ្រឿង ក្នុងចំណោមរថយន្តចង្កូតស្តាំ ៥៦គ្រឿង ចំណែកបារី ២.០០០ប៊ិច គឺមានការផ្ទេរពីឃ្លាំងទៅឱ្យក្រុមហ៊ុនគឹមហាប់រួចហើយ មានកំណត់ហេតុត្រឹមត្រូវ។

បានស្តាប់ចម្លើយរបស់លោក *ជា ប៉េងឈាង* ដែលបានឆ្លើយនៅពេលសវនាការថា: ប្រសិនបើក្រុមហ៊ុនគឹមហាប់ ថាកិច្ចសន្យានេះ ជាកិច្ចសន្យាអន្តរជាតិមែន កប៉ាល់*ហៀវណា* ប្រព្រឹត្តអំពើរត់ពន្ធ គប្បីក្រុមហ៊ុនគឹមហាប់ ត្រូវប្តឹងទាមទារពីក្រុមហ៊ុនស៊ីឈ្មួលដឹកជញ្ជូន ពីបរទេសប្រព្រឹត្តអំពើល្មើសច្បាប់ ចំពោះបារី ២.០០០ប៊ិច ដែលក្រុមហ៊ុនគឹមហាប់បានទៅទិញពីក្រុមហ៊ុន *គី មិច*

នោះក្រសួងចាត់ទុកថា ជាអំពើល្មើសច្បាប់ចង់បំផ្លាញវត្ថុតាង។ ឯការកសាងសំណុំរឿងនេះគឺមានទំនិញរត់ពន្ធពិតប្រាកដមែន។

បានស្តាប់ចម្លើយរបស់លោក *ជ័យ សំរិទ្ធិ* ដែលបានឆ្លើយនៅពេលសវនាការថា : សូមឱ្យតុលាការមេត្តាពិចារណាតាមផ្លូវច្បាប់ព្រោះទំនិញមានក្នុងបញ្ជីស្រាប់ សុទ្ធតែជាទំនិញមានការអនុញ្ញាតត្រឹមត្រូវ ហើយសូមបង់ពន្ធលើទំនិញទាំង ពីរមុខនេះ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>តុលាការកំពូល</u>

-យល់ដឹងថា បណ្តឹងសារទុក្ខលេខ៣២១ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ របស់នាយកទីចាត់ការគយ និង រដ្ឋាករ តំណាងឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពុលអាចលើករឿងនេះមកជំនុំជម្រះតាមមាត្រា១៨ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថា សារណាចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់ទីចាត់ការគយ និង រដ្ឋាករបានលើកឡើងថា តាមនីវេទបណ្ណ "*ម៉ានីហ្វេស្ត*" ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៥ ទំនិញដែលផ្ទុកលើនាវា*ហេវុណា* ទាំងអស់ជាទំនិញរបស់ក្រុមហ៊ុនគឹមហាប់ ក្នុងនោះមានទំនិញហាមឃាត់ក្នុងការនាំចូលទៀតផង។

ការលើកឡើងនេះគឺប្រាសចាកពីការពិតទេ ពីព្រោះលោក UTHEIN.SHWE ជាអ្នកដឹកនាំនាវានិង លោក *ងួន រីន* ជាម្ចាស់រថយន្តចង្កូតស្តាំបានឱ្យដឹងថា រថយន្តចង្កូតស្តាំ ២៧គ្រឿងដែលជាទំនិញហាមឃាត់នោះពុំមែនជារបស់ក្រុមហ៊ុនគឹមហាប់ទេ។ រីឯទំរង់ *ម៉ានីហ្វេស្ត* នេះពុំអាចយកជាភស្តុតាងបានដែរដោយមានចុះហត្ថលេខាតែម្ចាស់នាវាតែម្នាក់គត់។

-យល់ឃើញថា ទីចាត់គយនិងរដ្ឋាករ បានលើកឡើងក្នុងសារណា ការពិគ្រោះតម្លៃទំនិញអាចយកជាការបានលុះត្រាណាដែលទំនិញបាននាំចូលតាមតម្រាបផ្លូវដែលរដ្ឋបានកំណត់ចូលចតនៅកំពង់ផែស្របច្បាប់។

ការលើកឡើងនេះពុំមានលក្ខណៈត្រឹមត្រូវពីព្រោះនាវា *ហេវុណា* មិនមែនជានាវារបស់ក្រុមហ៊ុនគឹមហាប់ ទេ គឺគ្រាន់តែជានាវាដែលម្ចាស់ទំនិញនៅសិង្ហបុរីជួលដឹកទំនិញមប្រគល់ឱ្យក្រុមហ៊ុនគឹមហាប់ នៅកំពង់ផែក្រុងព្រះសីហនុប៉ុណ្ណោះ។ ដូចនេះក្រុមហ៊ុនគឹមហាប់ ហាក់ទទួលដឹងឮតែនៅពេលដែលទំនិញមកដល់កំពង់ផែទេ ពីព្រោះការទិញលក់នេះធ្វើតាមរូបភាពសីហ្វ (CIF) ។ រីឯបញ្ហា

ផ្ទុកទំនិញខុសច្បាប់ ឬ ការរៀបចំទំនិញលើនាវា ឬ ក៏ការធ្វើចរាចរត្រូវឬខុសតម្រាយផ្លូវ មិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុន គឹមហាប់ឡើយ។

-យល់ឃើញថា សារណាបានលើកបន្ថែមទៀតថា ទំនិញរបស់ក្រុមហ៊ុនគឹមហាប់ នៅលើនាវា *ហេរុណា* តាម *ម៉ានីហ្វេស្ត* ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៥ ក្រុមហ៊ុន គឹមហាប់ ពុំបានពិគ្រោះតម្លៃលើរថយន្តហុងដា ០៦គ្រឿង និង ម៉ាស៊ីនភ្លើង ៥៦គ្រឿងទេ។ ការលើកឡើងនេះពុំត្រឹមត្រូវទេពីព្រោះការមិនបានពិគ្រោះតម្លៃជាមុននេះ ពុំអាចចាត់ទុកថា ជាការប៉ុនប៉ងរត់គេចពន្ធបានឡើយ ពីព្រោះមុន និង ក្រោយពេលកើតហេតុ ការនាំចូលរថយន្តប្រភេទនេះ ពុំបានពិគ្រោះតម្លៃជាមុនទេរីឯម៉ាស៊ីនភ្លើងទើបនាំចូលលើកទី១ ក៏អាចយកតាមទម្លាប់នៃការនាំចូលរថយន្តបានដែរ។

-យល់ឃើញថា ទីចាត់ការគយ និង រដ្ឋាករដែលបានលើកឡើងក្នុងសារណាថា ក្រុមហ៊ុនគឹមហាប់បានធ្វើលិខិតសារភាព និងសុំបង់ពិន័យរួចហើយនោះ ក្រុមហ៊ុនគឹមហាប់បានឆ្លើយបំភ្លឺនៅតុលាការថ្នាក់ក្រោមហើយថា បានជាសុំបង់ផាកពិន័យពីព្រោះធម្មតាអ្នករកស៊ីគេមិនចង់មានទំនាស់ជាមួយរដ្ឋ ម្យ៉ាងហើយម្យ៉ាងទៀតទោះបីខាតខ្លះ ក៏គេចង់សម្រួលដើម្បីកុំឱ្យខាតពេលវេលារកស៊ី។ ការសុំបង់ផាកពិន័យ មិនមែនបានន័យថាទំនិញរត់ពន្ធទេ។ ការឆ្លើយបំភ្លឺនេះគឺមានលក្ខណៈសមហេតុសមផលហើយ។

-យល់ឃើញថា ការដែលទីចាត់ការគយ និង រដ្ឋាករលើកឡើងក្នុងសារណានូវចំណុចចុងក្រោយថា សាលាឧទ្ធរណ៍បានសម្រេចសេចក្តីដោយផ្ទុយនឹងច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ នាំចូលត្រង់មាត្រា១៣ វាក្យខណ្ឌចុងក្រោយនៃចំណុចទី២, មាត្រា១៧ វាក្យខណ្ឌទី៥ ,មាត្រា២១ វាក្យខណ្ឌទី២ និង មាត្រា២៤ នោះ ជាការភន្តច្រឡំទាំងស្រុងពីព្រោះថា :

-មាត្រា១៣ ស្តីពីការតម្រូវឱ្យបង់ពន្ធជាមុនក្នុងពេលរង់ចាំការសម្រេចរបស់តុលាការដែលថាសាលាឧទ្ធរណ៍សម្រេចខុសនោះពុំមែនជាកំហុសរបស់សាលាឧទ្ធរណ៍ទេ ដោយសារទីចាត់ការគយ និង រដ្ឋាករពុំបានសុំឱ្យតុលាការសម្រេចអំពីបញ្ហានេះ ពីព្រោះតុលាការពុំមានសិទ្ធិសម្រេចអំពីអ្វីដែលគូភាគីមិនបានសុំឡើយ។

-មាត្រា១៧ វាក្យខណ្ឌទី៥ ដែលថាសេចក្តីសម្រេចរបស់ក្រសួងហិរញ្ញវត្ថុជាសេចក្តីសម្រេចចុងក្រោយបង្អស់នោះ ពុំអាចបដិសេធសមត្ថកិច្ចរបស់តុលាការបានទេ ពីព្រោះមាត្រា០៩ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និង មាត្រា៦ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីបានជូនសមត្ថកិច្ចនេះឱ្យតុលាការរួចហើយ។

មាត្រា២១ និង ២៤ ដែលស្តីពីទោសបញ្ញត្តិនោះគឺពុំអាចយកទៅអនុវត្តលើក្រុមហ៊ុន គឹមហាប់បានទេ ដោយសារក្រុមហ៊ុននេះពុំមានកំហុសដែលត្រូវចោទប្រកាន់ពីបទប៉ុនប៉ង ឬ បានរត់គេចពន្ធឡើយ ជាក់ស្តែងគឺនៅកំពង់ផែទំនិញរបស់ក្រុមហ៊ុនគឹមហាប់ មានគ្រប់ចំនួនគ្មានលើស

គ្មានខ្វះ គឺត្រឹមត្រូវតាមបញ្ជីផ្ទុកទំនិញ (Rill) ហើយក្រុមហ៊ុនក៏បានពិគ្រោះតម្លៃពន្ធ និង បានបង្វែរលុយចូលគណនីរបស់សាខាគយ នៅក្រុងព្រះសីហនុរួចហើយព្រមទាំងបានជួលឱ្យក្រុមហ៊ុន *ម៉េង ស្រ៊ាង* ឱ្យទៅចាំដឹកយកទំនិញពីផែក្រុងព្រះសីហនុមកភ្នំពេញទៀតផង។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បានសម្រេចឱ្យផាកពិន័យលើម៉ាស៊ីនភ្លើង ៥៦ គ្រឿង នោះក៏ពុំមានលក្ខណៈត្រឹមត្រូវដែរ ក៏ប៉ុន្តែដោយសារក្រុមហ៊ុនគឹមហាប់ ពុំបានប្តឹងសាទុក្ខមកនោះ តុលាការកំពូលពុំគប្បីលើកមកពិចារណាឡើយ។

-យល់ឃើញថា សាលាឧទ្ធរណ៍ពុំបានសម្រេចឱ្យបានច្បាស់លាស់អំពីចំនួនទឹកប្រាក់ដែលត្រូវគិតពន្ធសមាមាត្រទេ។ ប៉ុន្តែ ដោយសារបញ្ហានេះជារឿងនៃអង្គច្បាប់សុទ្ធសាធ តុលាការកំពូលអាចសម្រេចបានដោយគិតយកចំនួនទឹកប្រាក់ផាកពិន័យលើម៉ាស៊ីនភ្លើង ២៨.៩២៨ ដុល្លារអាមេរិកដែលមាននៅក្នុងតារាងគណនាប្រាក់ពន្ធ និង ប្រាក់ពិន័យរបស់ទីចាត់ការគយ និង រដ្ឋាករចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ១៩៩៥។

-យល់ឃើញថា ការលើកឡើងរបស់តំណាងក្រសួងហិរញ្ញវត្ថុនាសវនាការនេះសុទ្ធតែជារឿងនៃអង្គហេតុដែលតុលាការថ្នាក់ក្រោមបានពិចារណារួចហើយ តុលាការកំពូលពុំចាំបាច់លើកយកមកពិចារណាទៀតឡើយ។

-យល់ឃើញថា សាលដីកាលេខ ៤២២ ចុះថ្ងៃទី០៣ តុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៥ របស់ទីចាត់ការគយ និង រដ្ឋាករជាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែ បដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាលេខ៤២២ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូល ១៨.០០០រៀល ដែលលោក *ជ័យ សំរិទ្ធិ* តំណាងក្រុមហ៊ុនគឹមហាប់បានបង់ជូលគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្មឹងចំនួន ៤.០០០ (បួនពាន់) រៀល ប៉ុន្តែ ប្រាក់នេះត្រូវកាត់ចំនួន ៨០០ (ប្រាំបីរយ) រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់។

-ចំណាយកិច្ចប្រគល់ដីកាកោះ ២.០០០ (ពីរពាន់) រៀល សរុប ១៦.០០០ (មួយម៉ឺនប្រាំមួយពាន់) រៀល នៅសល់ ៣.០០០ (បីពាន់) រៀលបង្វិលឱ្យម្ចាស់ដើមវិញ ហើយតម្រូវឱ្យ

តំណាងក្រសួង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសងប្រាក់ ១៦.០០០រៀលទៅលោក *ជ័យ សំរិទ្ធិ* វិញ។

-បង្គាប់ឱ្យក្រុមហ៊ុនគឹមហាប់ បង់ពន្ធសមាមាត្រមួយភាគរយលើចំនួនទឹកប្រាក់ផាកពិន័យលើម៉ាស៊ីនភ្លើង ៥៦ គ្រឿង $\frac{\text{២៨.៩២៨ ដុល្លារអាម៉េរិក} \times \text{១}}{\text{១០០}}$ : ២៨៩ ២៨ ដុល្លារអាម៉េរិក។

## ២.៣.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ៣០

- 25 -

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ ១៤ប្រ.

ចុះថ្ងៃទី២៩ខែមករាឆ្នាំ១៩៩៩

សាលដីកា

លេខ : ៣០

ចុះថ្ងៃទី២២ខែកុម្ភៈឆ្នាំ២០០០

នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១_ | ឯកឧត្តម | ឌិត | មុន្ទី | ប្រធាន |
| ២_ | លោក | ប៉ែន | ស៊ុន | ចៅក្រម |
| ៣_ | លោក | ឡៀល | មួន | ចៅក្រមរបាយការណ៍ |
| ៤_ | លោក | ជីវ | កេង | ចៅក្រម |
| ៥_ | លោក | ស៊ិន | ខឹម | ចៅក្រម |

ក្រឡាបញ្ជី

លោក ហេ វ៉ាត់ថន

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ១០ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៩៥១ ចុះថ្ងៃទី ០១_១២_៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខ លោក ប៊ូ សារុំន ( ជាមេធាវី និងតំណាងឱ្យសាលាខេត្តបាត់ដំបង ) ។

និងចុងបណ្តឹងសាទុក្ខ អ្នកស្រី ឆ វិល័យ អាយុ៤១ឆ្នាំ ជាតិខ្មែរ មានទីលំនៅៗ ផ្ទះលេខ ៤៣៥ ក្រុម១៣ ភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ( តំណាងឱ្យក្រុមហ៊ុនវិនិយោគទុន អាជីវកម្មផាសុី ស្តង់ត្រី ខេត្តបាត់ដំបង ) ។

មានលោក ផា ផេង ជាមេធាវី

តតិយជន : អ្នកស្រី សុខ សុខុន អាយុ ៤៨ឆ្នាំ ជាតិខ្មែរ ទីលំនៅៗផ្ទះ

៧

-- 26 --

លេខ ១៧២ ក្រុម៤០ ភូមិ២០ឧសភា ឃុំស្វាយពោធិ៍ ស្រុកស្វាយពោធិ៍ ខេត្តបាត់ដំបង ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចលេខ ១១៦២ ស.វ របស់តុលាការខេត្តបាត់ដំបង ។

បានឃើញបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោក ប៊ូ សាវុន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ១០ ចុះថ្ងៃទី០៤ ខែមករាឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៤ប្រ. ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៥_៧_៩៨ អ្នកស្រី ជា ឆវិល័យ ប្តឹងថា កាលពីថ្ងៃទី២០_០១_៩៧ ក្រុមហ៊ុនរបស់អ្នកស្រី បានចុះកិច្ចសន្យាជាមួយអភិបាលខេត្តបាត់ដំបង ដោយមានការឯកភាពរបស់ក្រសួងសេដ្ឋកិច្ច ស្តីពីការវិនិយោគទុនអាជីវកម្មផាស៊ីស្តង់ត្រីស្រស់ ( ទឹក_គោក ) ខេត្តបាត់ដំបង ។

តាមខ្លឹមសារ នៃកិច្ចសន្យាខាងលើត្រង់ប្រការ២ ចំណុចទី៤ គឺភាគី ( ក ) អភិបាលខេត្តបាត់ដំបងបានអះអាងទប់ស្កាត់មិនអនុញ្ញាតិឱ្យមានបង្កើតស្តង់ត្រីថ្មីបន្ថែមទៀតក្នុងខេត្តបាត់ដំបង ។ មានន័យថា មានតែស្តង់ត្រីរបស់ក្រុមហ៊ុនខ្លួនតែម្នាក់គត់ ដែលមានសិទ្ធិធ្វើអាជីវកម្ម តាមកិច្ចសន្យាក្នុងខេត្តបាត់ដំបង ។ ប៉ុន្តែអភិបាលខេត្តបែរជា អនុញ្ញាតិឱ្យអ្នកស្រីសុខ សុខុន បង្កើតស្តង់ត្រីមួយទៀតដែលមានទីតាំងនៅជិតក្រុមហ៊ុនរបស់ខ្លួន តាមដីកាសំរេចលេខ ១៤៥ស.ស ចុះថ្ងៃទី ១៧_១២_៩៧ ។ ការនេះគឺអភិបាលខេត្តបានបំពានលើកិច្ចសន្យា ដែលបានធ្វើជាមួយក្រុមហ៊ុនរបស់ខ្លួន និង បណ្តាលឱ្យបាត់បង់ផលប្រយោជន៍របស់ក្រុមហ៊ុនខ្លួនយ៉ាងធ្ងន់ធ្ងរ ។

តាមបណ្តឹងចុះថ្ងៃទី ២៩_១០_៩៨ លោក ប៊ូ សាវុន មេធាវីការពារឱ្យសាលាខេត្តបាត់ដំបង បានបញ្ជាក់ថា : ខ្លួនជាមេធាវីការពារឱ្យនីតិបុគ្គលសាលាខេត្តបាត់ដំបង សុំប្តឹងតុលាការខេត្តបាត់ដំបង បង្វែរសមត្ថកិច្ច នៃរឿងក្តីរដ្ឋប្បវេណីលេខ ១៣១ ចុះថ្ងៃទី ៣០_៧_៩៨ នេះ ឱ្យទៅជាសមត្ថកិច្ចសាច់រឿង វិវាទរដ្ឋបាលដោយផ្អែកតាមគោលការណ៍ នៃ នីតិសាធារណៈ គឺ

១_ បណ្តឹងសុំឱ្យខេត្តគោរពកិច្ចសន្យា រវាងនីតិបុគ្គលសាលាខេត្ត និង រូបវន្តបុគ្គលឯកជននោះជាវិវាទរដ្ឋបាល ព្រោះនីតិបុគ្គលសាធារណៈមិនអាចមកទទួលខុសត្រូវរដ្ឋប្បវេណី ឬកាតព្វកិច្ចណាមួយជាមួយភាគីរូបវន្តបុគ្គល ឯកជនបានឡើយ ។

ម៉្យាងទៀតកិច្ចសន្យានេះ ធ្វើដោយខុសវិន័យពីនីតិវិធីរដ្ឋបាល នៃរបៀបរៀបការងារ ។ ជំទាញទៀតផង - ការងារនេះអាចបញ្ជាក់បានដោយអភិបាលខេត្ត និង មន្ត្រីដែលមានសមត្ថកិច្ចរបស់សាលាខេត្តជាបន្ទាល់ ។

២_ ចំពោះការប្ដឹងរំលោភ ដីកាសំរេចលេខ១៤៥ ចុះថ្ងៃទី ១៧_១២_៩៧ នោះគឺជាវិវាទរដ្ឋបាលពេញលេញ១០០% មិនអាចបំភ័ន្តថា ជាវិវាទផ្សេងបានទេ ដែលបច្ចុប្បន្ននេះវាស្ថិតនៅក្នុងសមត្ថកិច្ចសាច់រឿងវិវាទរដ្ឋប្បវេណីទៅវិញ ។

៣_ ការប្ដឹងសុំឱ្យ សុខ សុខុន រុះរើស្តង់ត្រីថ្មីចេញនោះ ក៏ជាវិវាទ នៃសមត្ថកិច្ចសាច់រឿងរដ្ឋបាលយ៉ាងពេញលេញដែរ ព្រោះថា ភាគីទាំង២ មិនអាចទំនាក់ទំនងរដ្ឋប្បវេណីកាតព្វកិច្ចអ្វីរវាងគ្នាដាច់ខាត ព្រោះថា ស្តង់ត្រី អ្នកស្រី សុខ សុខុន កើតឡើងតាមច្បាប់ជាធម្មានុរូប ។

បានឃើញសេចក្ដីសំរេចលេខ ១១៦២ ស.វ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៩៩៨ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

_ បដិសេធចោលនូវពាក្យបណ្ដឹងអំពីទម្រង់ច្បាប់ ចុះថ្ងៃទី២៩_១០_១៩៩៨ របស់លោកមេធាវី ប៊ូ សារ៉ុន ដោយខុសនឹងគតិច្បាប់ ។

តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្ដី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨_២_១៩៩៣ និង បញ្ញត្តិមាត្រា ១០៩ នៃរដ្ឋ_ធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១០២ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការខេត្តបាត់ដំបង បានប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចលេខ ១១៦២ស.វ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៩៨ របស់តុលាការខេត្តបាត់ដំបង ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១០ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ចំពោះមុខមេធាវីការពារដើមចោទ កំពាំងមុខក្ដី ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១_ ទទួលបណ្ដឹងឧទ្ធរណ៍លេខ១០២ ចុះថ្ងៃទី ២៩_១០_១៩៩៨ របស់លោកប៊ូ សារ៉ុន មេធាវីការពារក្ដី ជូនសាលាខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទំរង់ តែត្រូវបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ ដំកល់សេចក្ដីសំរេចលេខ ១១៦២ ស.វ ចុះថ្ងៃទី ២៩_១០_៩៨ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៤៥១ ចុះថ្ងៃទី០១_១២_១៩៩៨ របស់សាលាឧទ្ធរណ៍ទៅតុលាការខេត្តបាត់ដំបង ដើម្បីជំនុំជំរះ ដល់រឿងអង្គសេចក្ដី ។

៤_ វិបរូសប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាត់ហិបប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប១៣.០០០រៀល។

-- ២៨ --

៥- សាលដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះមានបណ្តឹងសាទុក្ខក៏ដោយ ។

៦- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារដើមចោទ កំបាំងមុខចុងក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២២ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោក ប៊ូ សារ៉ុន បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១០ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា .
- សាលដីការដ្ឋប្បវេណី របស់សាលាឧទ្ធរណ៍ បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

ក្រឡាបញ្ជីអានសារណារបស់លោក ប៊ូ សារ៉ុន

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ជា សេង នៅពេលជំនុំជំរះថា: រឿងនេះកើតឡើងពីលោកចៅហ្វាយខេត្ត មិនគោរពតាមកិច្ចសន្យា ដោយលោកចៅហ្វាយខេត្តបានចេញសេចក្តីសំរេចឱ្យបង្កើតស្តង់ត្រីមួយកន្លែងហើយ ក្រោយមកទៀតក៏ចេញសេចក្តីសំរេចឱ្យបង្កើតស្តង់ត្រីមួយកន្លែងទៀតដោយមិនគោរពតាមកិច្ចសន្យារបស់ខ្លួន ។

ចំពោះខ្ញុំជាមេធាវីឱ្យ ( ចុងបណ្តឹងសាទុក្ខ ) ពុំមានយោបល់អ្វីទៀតទេ ព្រោះមានលិខិតលេខ ៩២ ចុះថ្ងៃទី ១៧-២-៩៩ របស់តុលាការកំពូលមួយហើយ ។

សូមក្រុមប្រឹក្សាពិនិត្យ និង សំរេច តាមការគួរ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់លោកមេធាវី ប៊ូ សារ៉ុន នឹងសេចក្តីសន្និដ្ឋាន របស់លោកមេធាវី ជា សេង.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោកមេធាវី ប៊ូ សារ៉ុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

៩៧

-- ២១ --

- យល់ឃើញថា ទោះបីរឿងនេះ ជារឿងរដ្ឋប្បវេណីក្តី រឿងរដ្ឋបាលក្តីក៏តុលាការមានសមត្ថកិច្ចជំនុំជំរះដែរ ដូចដែលកំណត់នៃមាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- យល់ឃើញថា លោកប៊ូ សារ៉ុន បានធ្វើសារណាការពារក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខលោក ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែល...សំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទំរង់និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខលោកមេធាវី ជា ផេង កំបាំងមុខលោក

មេធាវី ប៊ូ សារ៉ុន ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១- ទទួលបណ្តឹងសាទុក្ខលេខ២២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោកមេធាវី ប៊ូ សារ៉ុន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១០ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកប៊ូ សារ៉ុន បានបង់រួចហើយគឺៈ

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈឆ្នាំ២០០០។

## ២.៤.សាលដីកាតុលាការកំពូល, សំណុំរឿងរដ្ឋប្បវេណី លេខ៧៣

- ៣៦ - 1

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

******

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៥៧ **នាមនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ១៩៩៩ តុលាការកំពូល

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែ មេសាឆ្នាំ ២០០០

លេខ ៧៣ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០០០

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ឌិត** | **មុន្នី** | ជាប្រធាន |
| ២- | លោក | ប៉ែន | ស៊ុន | ជាចៅក្រម |
| ៣- | លោក | វឿល | មួន | ជាចៅក្រម |
| ៤- | លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៥- | លោក | ជីវ | កេង | ជាចៅក្រមរបាយការណ៍ |
| ៦- | លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៧- | លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៨- | លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៩- | លោក | យស់ | សួខឿន | ជាចៅក្រម |

ក្រឡាបញ្ជី

លោក ឡេវ ដាណា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៦៨ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៥ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ហ៊ូ ប៊ុណ្ណារិទ្ធិ ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ មានទីលំនៅ ភូមិទី៦ ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។ ឪពុកឈ្មោះហ៊ូ ប៉េងណាំ " ស " ម្តាយឈ្មោះ គីម ស៊ុយ " ស " ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ប៊ុល លឹម តំណាងក្រសួងមហាផ្ទៃ ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីក្រសួងមហាផ្ទៃ មានទីលំនៅ ផ្ទះលេខ ៩៨ ផ្លូវ ១៤១ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ កុយ ឈុន តំណាងអភិបាលខេត្តកំពត ភេទប្រុស មុខរបរ មន្ត្រីសាលាខេត្ត ទីលំនៅភូមិកំពង់បាយ ឃុំកំពង់បាយ ស្រុកកំពត ខេត្តកំពត ។

៧

កម្មវត្ថុបណ្តឹង : ប្តឹងសុំចូលតតិយជន និង សុំតម្កល់ប្រកាសលេខ ០៨៩ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

បានឃើញបណ្តឹងសាទុក្ខ លេខ ១០៦ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់លោក ហ៊ូ ប៊ុណ្ណារិទ្ធិ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៦៨ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៧ ចុះថ្ងៃទី ១៦ខែ មិថុនាឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ១០-៥-៩៦ របស់ដើមចោទ លោក ហ៊ូ ប៊ុណ្ណារិទ្ធិ បញ្ជាក់ថាខ្លួនមិនចង់មានរឿងជាមួយ អាជ្ញាធរខេត្តទេ ប៉ុន្តែក្នុងការចុះកិច្ចសន្យាធ្វើអាជីវកម្មសត្តឃាតដ្ឋាននៅខេត្តកំពត ដោយខ្លួនជាអ្នកសង់សត្តឃាតដ្ឋាននេះ ខ្លួនបានបំពេញសំណុំបែបបទត្រឹមត្រូវតាមលំដាប់ថ្នាក់ រហូតបានបើកឱ្យប្រើប្រាស់ជាផ្លូវការ ស្រាប់តែក្រសួងមហាផ្ទៃ ចេញប្រកាសបដិសេធអាជីវកម្មស្របច្បាប់របស់ខ្លួនចោលតាមប្រកាសលេខ ០៩៨ ប្រ.ក.អធិ ចុះថ្ងៃទី ១០-២-៩៦ ។ ក្នុងរឿងនេះ ខ្លួនសំណូមពរសុំឱ្យតុលាការ សំរេចបដិសេធប្រកាសរបស់ក្រសួងមហាផ្ទៃចោលជាអសារបង់ ហើយអនុញ្ញាតិ ឱ្យខ្លួនធ្វើអាជីវកម្មតទៅទៀត ព្រោះថាអាជ្ញាធរខេត្តបានចុះកិច្ចសន្យា ជាមួយខ្លួនអស់ហើយ។ បើពុំដូច្នេះទេសុំឱ្យខេត្តសងមកវិញ នូវសោហ៊ុយបង់ខាតផ្សេងៗ ។

បានឃើញ សាលក្រមលេខ៥៦ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ តុលាការខេត្តកំពតដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- បង្គាប់ឱ្យភាគី " ក " អនុវត្តកិច្ចសន្យា ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការសាងសង់ទីសត្តឃាដដ្ឋានខេត្តកំពតបន្តទៀត ។

៣- បដិសេធប្រកាសលេខ ០៨៩ ប្រក អធិ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ របស់ក្រសួងមហាផ្ទៃចោលជាអសារបង់ ដោយប្រកាសនេះគ្មានតម្លៃតាមផ្លូវច្បាប់ ។

៤- ឱ្យឈ្មោះ កុយ ឈុន បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជី ៩០០៛ ពន្ធហ្វ៊ីង ៩០០៛ រង្វាន់ក្រឡាបញ្ជីហិបប្រាក់ ២០០៛ ប្រាក់ចំណាយលើដីកាកោះ ៥០០០៛ សរុប ៧០០០៛ ។ ប្រាក់នេះត្រូវកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទបានបង់រួចហើយ តែត្រូវសងទៅដើមចោទវិញ ។

៥- សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ប្រកាសជាសាធារណៈចំពោះមុខគូក្តី សំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេល ២ខែ គិតចាប់ពីពេលនេះតទៅ ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៤-០២-៩៧ក្រសួងមហាផ្ទៃដោយមានលោក ម៉ុង កេសាណា ជាតំណាង បានប្តឹងសុំចូលជាតតិយជនក្នុងរឿងសត្តឃាដដ្ឋានខេត្តកំពត ពីព្រោះថា តុលាការបានសំរេចសេចក្តីពីរឿងទំនាស់សត្តឃាដដ្ឋានខេត្តកំពត មានពាក់ព័ន្ធដល់ប្រកាសលេខ ០៨៩ ប្រក.អធិ ចុះថ្ងៃទី ១០-០២-៩៦

៣៧

របស់ក្រសួងមហាផ្ទៃ ។

បានឃើញ សាលក្រមរបៀបលេខ ២០ ចុះថ្ងៃទី ២៨-៣-៩៧ តុលាការខេត្តកំពត បានសំរេចចាត់របៀប :

បង្គាប់ឱ្យលោក ឡុង កេសាណា តំណាងក្រសួងមហាផ្ទៃ ធ្វើការសំរបសំរួលជាមួយលោកអភិបាលខេត្តកំពត ក្នុងរយៈពេលមួយខែ ដើម្បីឱ្យបានឯកភាពគ្នាលើចំណុចណាមួយ ក្នុងចំណុចទាំងពីរខាងលើ គិតចាប់ពីពេលនេះតទៅ ។

បានឃើញ សាលក្រមលេខ ៣៧ ចុះថ្ងៃទី ១២-៨-៩៧ របស់តុលាការខេត្តកំពត សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងតវ៉ារបស់ក្រសួងមហាផ្ទៃ សុំចូលជាតតិយជន តំណាងដោយ លោក ឡុង កេសាណា ទុកជាត្រឹមត្រូវតាមទំរង់ តែលើកចោលដោយទាស់ នឹងគតិច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៥៦ ចុះថ្ងៃទី ០៤-១១-៩៦ របស់តុលាការខេត្តកំពត ដែល ជាសាលក្រមដើម ទុកជាបានការពេញទាំងមូល ចាប់ពីពេលនេះតទៅ ។

៣- សាលក្រមនេះ មិនព្យួរសាលក្រមដើម ដើម្បីបង្អង់មិនឱ្យអនុវត្តឡើយ ទោះសាលក្រមនេះ កំពុងស្ថិតក្នុងរយៈពេលប្តឹងឧទ្ធរណ៍ក៏ដោយ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ ប្រាក់នេះ ១៨០០៛ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីង ២០០៛ រង្វាន់ក្រឡាបញ្ជីហិបប្រាក់ និង៥០០០៛ ចំណាយលើដីកាកោះ ។

សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈប្រកាសជាសាធារណៈ ចំពោះមុខគូក្តីសំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេល ២ខែ គិតចាប់ពីពេលនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៧ របស់លោក ឡុង កេសាណា តំណាងក្រសួងមហាផ្ទៃ ប្តឹងមិនសុខចិត្ត និងសាលក្រមលេខ ៣៧ ចុះថ្ងៃទី ១២-៨-៩៧ លើសេចក្តីសំរេចទាំងមូល និង បណ្តឹងឧទ្ធរណ៍លេខ ៣២ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៧ របស់លោក ហ៊ូ ប៊ុណ្ណរិទ្ធី ប្តឹងមិនសុខចិត្ត និងសាលក្រមលេខ ៣៧ ចុះថ្ងៃទី ១២-៨-៩៧ លើត្រង់ចំណុចមិនសុខចិត្តនឹងតតិយជនឈ្មោះ ឡុង កេសាណា ដែលប្តឹងឱ្យខូចផលប្រយោជន៍របស់ខ្លួន និងសុំឱ្យតតិយជន ឡុង កេសាណា សងជម្ងឺចិត្ត និង ការខាតបង់ផ្សេងៗ ចំនួន ១០០.០០០៛ ។

បានឃើញ សាលដីការរបៀបលេខ ១៤០ ចុះថ្ងៃទី ២៩ ខែ ធ្នូឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- បង្អង់ការកាត់សេចក្តី និង កោះហៅគ្រប់ភាគីឱ្យចូលសវនាការលើកក្រោយ ។

២- បង្គាប់ឱ្យភាគីជូនភស្តុតាងបន្ថែម បើសិនជាមាន ។

បានឃើញ សាលដីកាលេខ ២៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៨ របស់សាលា

៣៧

ឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ក/- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ របស់លោក ឡុង កេសាណា តំណាងឱ្យក្រសួងមហាផ្ទៃ ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

ខ/- ទទួលបណ្តឹងឧទ្ធរណ៍របស់លោក ហ៊ូ ប៊ុណ្ណារិទ្ធី ត្រង់ចំណុចមិនសុខចិត្ត នឹងការទាមទារចូលជាគតិយជនរបស់ក្រសួងមហាផ្ទៃ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ តែត្រង់ចំណុចទាមទារជម្ងឺចិត្ត ពីតំណាងក្រសួងមហាផ្ទៃ តុលាការមិនពិចារណាទេ ព្រោះផ្ទុយពីទំរង់ និង គតិច្បាប់ ។

២-ក/- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥៦ ចុះថ្ងៃទី ០៤-១១-៩៦ ដែលជាសាលក្រមដើម របស់តុលាការខេត្តកំពត ទុកជាត្រឹមត្រូវ និង បានការពេញទាំងមូល ។

ខ/- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣៧ ចុះថ្ងៃទី ១២-៨-៩៧ របស់តុលាការខេត្តកំពត ទុកជាបានការ លើកលែងចំណុចទី៣ នៃសាលក្រមនេះ ត្រូវលប់ចោល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោក ហ៊ូ ប៊ុណ្ណារិទ្ធី បានបង់រួចហើយ គឺពន្ធហ្វីង និង ពន្ធចុះបញ្ជីក្តី ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០៛ និងចំណាយលើអាជ្ញាធរ តុលាការ៥.០០០៛ សរុប ១៣.០០០៛ ។ កាលបើផុតកំណត់ប្តឹងសាទុក្ខ ឬ សាលដីកាចូលជាស្ថាពរ បង្គាប់ឱ្យលោក ឡុង កេសាណា តំណាងក្រសួងមហាផ្ទៃ សងប្រាក់១៣.០០០៛នេះ ទៅលោក ហ៊ូ ប៊ុណ្ណារិទ្ធី វិញ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះ មុខគូភាគី ហើយបើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលពីរខែ ។

បានឃើញបណ្តឹងសាទុក្ខ លេខ ៤៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ របស់លោក កុល វីរក្ស តំណាងឱ្យក្រសួងមហាផ្ទៃ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៤ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីកាលេខ ១៤១ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខ ៤៣ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ របស់លោក កុល វីរក្ស តំណាងឱ្យក្រសួងមហាផ្ទៃ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ ២៤ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១០១ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលលោក ហ៊ូ ប៊ុណ្ណារិទ្ធី បានបង់រួចហើយ គឺ :

៧៧

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ១៩៩៨ ។

បានឃើញ ដីកាបញ្ជូន លេខ ៣៤២/៩៨ សរណ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល បង្វិលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះ សារឡើងវិញ ។

បានឃើញ សាលដីការបៀបលេខ ១៣ ចុះថ្ងៃទី ០៩-២-៩៩ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- បញ្ចូលអាជ្ញាធរខេត្តកំពត តំណាងដោយឈ្មោះ កុយ ឈុន ជាគូក្តីខាងចុងចម្លើយ ក្នុងរឿងក្តីនេះ ។

២- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី ។

បានឃើញ សាលដីកាលេខ ៦៨ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- ទទួលជំនុំជំរះរឿងក្តីនេះ សារឡើងវិញ តាមអំណាចសាលដីកាលេខ ១៤១ /១៦-៦-៩៨ របស់តុលាការកំពូល ។

២- បដិសេធសាលក្រមលេខ ៥៦/៤-១១-៩៦ របស់តុលាការខេត្តកំពតចោលជាអសារបង់ ។

៣- បដិសេធសាលក្រមលេខ៣៧/១២-៨-៩៧ របស់តុលាការខេត្តកំពតចោលជាអសារបង់ ។

៤- រក្សាប្រកាសលេខ ០៨៩ ប្រក. ចុះថ្ងៃទី ១០-២-៩៦ របស់ក្រសួងមហាផ្ទៃ ស្ថិតនៅជាធរមានដដែល តាមបញ្ញត្តិមាត្រា ២ អនុក្រឹត្យលេខ ១៦អនក្រ. ចុះថ្ងៃទី ២០-១២-៩៣ មាត្រា ១០-១១ ក្រឹត្យច្បាប់លេខ ០៧ក្រច. ចុះថ្ងៃទី ១៣-៧-៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធី នៃការធ្វើច្បាប់ និងបទបញ្ជា ។

៥- បង្គាប់ឱ្យអាជ្ញាធរខេត្តកំពត សងសំណងការខាតបង់ដល់ឈ្មោះ ហ៊ូ ប៊ុណ្ណារិទ្ធី ចំនួន ១០៨.០០០.០០០រៀល ។ សំណូមពរលើសពីនេះបដិសេធចោល ។

៦- បង្គាប់ឱ្យឈ្មោះ ហ៊ូ ប៊ុណ្ណារិទ្ធី បង់ប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វីង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥០០០រៀល និង លើអាជ្ញាធរ តុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

៧- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះ មុខគូភាគី បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខ លេខ ១០៦ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់លោក ហ៊ូ ប៊ុណ្ណារិទ្ធិ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៦៨ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ១៤-៦-១៩៩៩ របស់ឈ្មោះ ហ៊ូ ប៊ុណ្ណារិទ្ធិ

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ :

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៨ ចុះថ្ងៃទី ០៩-០២-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ហ៊ូ ប៊ុណ្ណារិទ្ធិ ជាចុងចម្លើយ និង ម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា : កន្លងមកអភិបាលខេត្តកំពតអនុញ្ញាតិឱ្យ ខ្ញុំសាងសង់ រហូតដល់សម្ពោធឱ្យប្រើប្រាស់ទៀត ។ ការសាងសង់នេះ ពេលសាងសង់ គេឥតមានមកតវ៉ាអ្វីទេ ដល់ពេលខ្ញុំសង់ហើយ ស្រាប់តែគេប្តឹងយកតែម្តង ។

១- សុំបដិសេធប្រកាសលេខ ០៨៩ របស់ក្រសួងមហាផ្ទៃ ។

២- សុំឱ្យតុលាការតំកល់សាលក្រមរបស់ខេត្ត ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ប៉ុល លឹម តំណាងក្រសួងមហាផ្ទៃ ជាដើមចោទ និង ចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា : ការដោះស្រាយមិនសមស្របរបស់ខេត្ត សាលាខេត្តក៏សរសេរលិខិតមួយទៅក្រសួងមហាផ្ទៃ ដើម្បីសុំយោបល់សំរេច ។ សាលាខេត្តបានសំរេចជួបជាមួយអង្គភាពពាក់ព័ន្ធដោយមាន ១៤ អង្គភាព ចូលរួមក្នុងសាលាខេត្ត ដោយផ្អែកលើរបាយការណ៍របស់ខេត្ត សំណូមពររបស់អង្គប្រជុំ និង លិខិតរបស់ក្រសួងបរិដ្ឋានសុំឱ្យក្រសួងមហាផ្ទៃ ទប់ស្កាត់ការសាងសង់នាំឱ្យខូចបរិដ្ឋាន ក៏ខេត្ត នៅតែមិនធ្វើតាមគតិច្បាប់ ។ ទើបក្រសួងមហាផ្ទៃចេញប្រកាសលេខ ០៨៩ លុបចោលលិខិតទាំងឡាយ ដែលខេត្តចេញដោយរំលោភលើអនុក្រឹត្យលេខ ១៦ ចុះថ្ងៃទី ២០-១២-៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ ។ នៅពេលកំពុងដោះស្រាយ ទីសត្តឃាតដ្ឋាននោះ មិនទាន់សាងសង់ទេ ទើបតែសែងសសរទៅដាក់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ កុយ ឈុន តំណាងអភិបាលខេត្តកំពត ជាចុងចម្លើយនិង ម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា : ក្នុងនាមខ្លួនជាតំណាងខេត្ត គឺសុំឱ្យឯកឧត្តម មេត្តាសំរេចតាមច្បាប់ចុះ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបាន ស្តាប់ចម្លើយដោះសារ របស់គូភាគី និង តតីយជន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

៣៧

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០៦ចុះថ្ងៃទី ០៦-០៤-៩៩ របស់លោកហ៊ូ ប៊ុណ្ណារិទ្ធិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា សាលាឧទ្ធរណ៍បានសំរេចរក្សាទុកនូវប្រកាសលេខ ០៨៩ ប្រក. ចុះថ្ងៃទី ១០-០២-៩៦ របស់ក្រសួងមហាផ្ទៃឱ្យនៅជាធរមាន ដែលបញ្ជាក់ថា មិនអនុញ្ញាតិឱ្យបង្កើតសតឃាតដ្ឋាន នៅទីតាំងទំនាស់ តាមមតិក្នុងសាលដីកាទី១ លេខ ១៤១ ចុះថ្ងៃទី ១៦-៦-៩៨ របស់តុលាការកំពូលហើយ ប៉ុន្តែសាលាឧទ្ធរណ៍បានសំរេចបញ្ចូលអាជ្ញាធរខេត្តកំពតមកជាតតិយជន និង បង្គាប់ឱ្យអាជ្ញាធរខេត្តកំពតសង ការខូចខាតដល់លោក ហ៊ូ ប៊ុណ្ណារិទ្ធិ ចំនួន ១០៨ លានរៀល ដែលជាមធ្យោបាយថ្មីដែលតុលាការកំពូល ពុំទាន់បានពិចារណា នៅក្នុងសាលដីកាទីមួយ របស់ខ្លួននៅឡើយ ។

- យល់ឃើញថា លោក ហ៊ូ ប៊ុណ្ណារិទ្ធិ បានលើកឡើងក្នុងសារណា ចុះថ្ងៃទី ២៨-៨-៩៩ របស់លោកថា បើលោក ពុំបានធ្វើអាជីវកម្មតាមកិច្ចសន្យាទេនោះ លោកសុំឱ្យអាជ្ញាធរខេត្តសងការខូចខាត របស់លោក ក្នុងការខាតបង់រយៈពេល ៥ឆ្នាំ គិតជាទឹកប្រាក់ 591.804.000រៀល ។ សំណូមពរនេះពុំទាន់ មានមូលដ្ឋានច្បាស់លាស់ទេ ពីព្រោះថា តាមលិខិតលេខ ពិសេស ចុះថ្ងៃទី ០១-០២-៩៦ របស់អភិបាល ស្រុកកំពង់បាយបញ្ជាក់ថា លោកហ៊ូ ប៊ុណ្ណារិទ្ធិ អភិបាលខេត្តកំពតបានព្រមព្រៀងគ្នាលើតម្លៃ 108លានរៀល ហើយ ដូច្នេះតុលាការកំពូល គប្បីពិចារណា និង សំរេចតាមការព្រមព្រៀងគ្នានេះ ។

- យល់ឃើញថា សាលដីកាវដ្ឋប្បវេណីលេខ ៦៨ ចុះថ្ងៃទី ០៩-០២-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទម្រង់ ទាំងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី និង តតិយជន

១- ទទួលបណ្តឹងសាទុក្ខលេខ ១០៦ ចុះថ្ងៃទី ០៦-៤-៩៩ របស់លោក ហ៊ូ ប៊ុណ្ណារិទ្ធិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាវដ្ឋប្បវេណីលេខ ៦៨ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកហ៊ូ ប៊ុណ្ណារិទ្ធិ បានបង់រួចហើយគឺ:

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

បង្គាប់ឱ្យអាជ្ញាធរខេត្តបង់ពន្ធសមាមាត្រ ១% លើចំនួនទឹកប្រាក់ ដែលត្រូវសងទៅលោក ហ៊ូ ប៊ុណ្ណារិទ្ធី ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី 06 ខែ មេសាឆ្នាំ 2000 ។

## ២.៥.សាលដីកាតុលាការកំពូល, សំណុំរឿងព្រហ្មទណ្ឌ លេខ១៣

– 281 –

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*******

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខ ០៦
ចុះថ្ងៃទី២១ មិថុនា ១៩៩៥

សាលដីកា
លេខ ១៣
ចុះថ្ងៃទី ១៥ ធ្នូ ១៩៩៥

ក្នុងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ១៩៩៥ ដោយមានសមាសភាពដូចតទៅ ៖

១– ឯកឧត្តម ចាន់ សុខ ប្រធាន
២– លោក ឈឹម ស៊ីផល ចៅក្រម
៣– លោក ម៉ែន ស៊ីន ចៅក្រម
៤– លោក ឡាក់ គឹមសាន ចៅក្រម
៥– លោក យស់ សុខឿន ចៅក្រម

ក្រឡាបញ្ជី លោក ឡោ ជុនធី

តំណាងមហាអយ្យការ លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២៧ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៥ នៃសំណុំរឿងព្រហ្មទណ្ឌលេខ១១៤ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៩៤ របស់សាលាឧទ្ធរណ៍ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា កាលពីថ្ងៃទី២៦ ធ្នូ ១៩៩៣ ប្រព្រឹត្តនៅឃុំទួលសង្កែ ស្រុកឫស្សីកែវ ក្រុងភ្នំពេញ ។.

ម្ចាស់បណ្តឹងសាទុក្ខ អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍

ជនជាប់ចោទឈ្មោះ ទិន ហ៊ន ភេទ ប្រុស អាយុ ៤៦ ឆ្នាំ ជាតិ ខ្មែរ កើតនៅឃុំចិតា ស្រុក ព្រែកប្បាស ខេត្ត តាកែវ មុខរបរ ជានគរបាលសន្តិសុខព្រំដែន ទីលំនៅមុនចាប់ខ្លួន នៅផ្ទះលេខ២២១ ក្រុម៤ ឃុំទួលសង្កែ ស្រុកឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះទិន ហៀង (ស) ម្តាយឈ្មោះ សួន លី (រ) ប្រពន្ធឈ្មោះ គង់ ស៊ីផាន មានកូន០៥នាក់ ទោសពីមុនគ្មាន ។

ជនរងគ្រោះឈ្មោះ សួរ សុខវណ្ណា ភេទប្រុស អាយុ ២៤ ឆ្នាំ ជានគរបាលប៉ុស្តិ៍ទួលសង្កែ ស្រុកឫស្សីកែវ ក្រុងភ្នំពេញ ។

ជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះមាស សាវ៉ាត ភេទប្រុស អាយុ២៦ ឆ្នាំ ជានគរបាលប៉ុស្តិ៍ ទួលសង្កែ ស្រុកឫស្សីកែវ ក្រុងភ្នំពេញ ។

-២៩២-

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះសួរ សាវឌី ភេទស្រី អាយុ ៤៣ ឆ្នាំ ត្រូវជាបងជនរងគ្រោះ ឈ្មោះ សួរ សុវណ្ណា ។

តាមបណ្ដឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៥ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលមានសេចក្ដីថា " មកពីដីកាបញ្ជូនរឿងទៅ តុលាការជំនុំជំរះរបស់ចៅក្រមស៊ើបសួរ លេខ៤៤៩៣ ឥព្រ ចុះថ្ងៃទី០៩ កញ្ញា ១៩៩៤ និងសាលក្រមតុលាការក្រុងភ្នំពេញលេខ៣៦៤ ចុះថ្ងៃទី២៧ កញ្ញា ១៩៩៤ ដែលសំរេចសេចក្ដីពីបទប៉ុនប៉ងធ្វើមនុស្សឃាតកាលពីថ្ងៃទី២៦ ធ្នូ ១៩៩៣ តាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ កញ្ញា ១៩៩២ បទល្មើសដែលអយ្យការមិនបានចោទប្រកាន់ ។ អយ្យការចោទប្រកាន់ពីបទបង្ករបួសស្នាម ដោយចេតនា ។ "

<u>ដំណើររឿងមានដូចតទៅ</u> ៖

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៨កុម្ភៈ១៩៩៤របស់នាង សួរ សាវឌី អាយុ៤៣ឆ្នាំ ត្រូវជាបងជនរងគ្រោះឈ្មោះ សួរ សុវណ្ណា ភេទប្រុស (នគរបាលប៉ុស្តិ៍ទួលសង្កែ) ។

ដោយកាលពីថ្ងៃទី២៦ធ្នូ១៩៩៣ វេលាម៉ោងម្ភៃនៅភូមិទួលគោក មានទំនាស់គ្នារវាងគ្រួសារ ប៉ុល ឌឹម ជាប្រធានភូមិទួលគោក នឹងគ្រួសារឈ្មោះ ខិន ហ៊ិន ជានគរបាលនៅនាយកដ្ឋានសន្តិសុខព្រំដែន ( នៅពេលថ្ងៃប្រពន្ធនឹងប្រពន្ធឈ្លោះប្រកែកជេរគ្នារួចមក ) ។

នៅពេលយប់នោះ ហិន ហ៊ិន បានចេញពីលេងភ្លេងទាំងស្រវឹងមកដល់ផ្ទះរករឿងប្រពន្ធ វាយធប់ប្រពន្ធដើម្បីសួររកកាំភ្លើងលាក់នៅឯណា ទារយកសោរចាក់ទូរ ប្រពន្ធពុំព្រមឱ្យ ជននោះក៏វាយទូរយកកាំភ្លើងAKទៅបាញ់ផ្ទះប្រធានភូមិអស់៨គ្រាប់តែពុំបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់នរណាម្នាក់ឡើយ ។ បន្ទាប់មកឈ្មោះ ប៉ុល ឌឹម បានឱ្យក្មួយខ្លួនទៅប្ដឹងនគរបាលប៉ុស្តិ៍ទួលសង្កែ ។ មួយសន្ទុះក្រោយមក នគរបាលប៉ុស្តិ៍ទួលសង្កែក៏បានចុះមកដល់កន្លែងកើតហេតុមានឈ្មោះសួរ សុវណ្ណានិងឈ្មោះមាស សាវ៉ាត ដើម្បីសំរុះសំរួល ។ នៅពេលដែលទៅដល់ផ្ទះជនល្មើស ជននេះបានភ្ញាក់អ្នកទាំងពីរហើយឱ្យដាក់អាវុធចុះ ក្នុងខណៈនោះ ខិន ហ៊ិន បានបាញ់រះលើអ្នកទាំងពីររូប បណ្ដាលឱ្យម្នាក់ឈ្មោះមាស សាវ៉ាត ត្រូវពីរគ្រាប់ ឯម្នាក់ទៀតឈ្មោះសួរ សុវណ្ណា ត្រូវ១៦គ្រាប់( ដៃឆ្វេង៤គ្រាប់ ជើងឆ្វេង៦គ្រាប់ មិនអាចតភ្ជាប់បានត្រូវបានគ្រូពេទ្យកាត់ កំភេះគូថឆ្វេងធ្លាយទៅពោះ៣គ្រាប់ និងដៃស្ដាំ៣គ្រាប់ ) ។

ជនរងគ្រោះឈ្មោះ សួរ សុវណ្ណា ឆ្លើយថា៖ " .... មានការនិយាយគ្នាបានទេ គាត់ថាខ្លួនជាបក្សពួកប្រធានភូមិ រួចហើយជនល្មើសក៏រះកាំភ្លើងមកលើខ្លួន ខ្លួនបានសំពះអង្វរគាត់ថា ខ្លួនជាភ្នាក់ងារនគរបាលទេ ពេលបាញ់ហើយខ្លួនសំពះអង្វរអ្នកបាញ់ឱ្យទុកជីវិតឱ្យខ្លួន តែគេមិនស្ដាប់ខ្លួន ខ្លួនបានលូនមកពួននៅជិតបង្គន់អ្នកបាញ់ ហើយឈ្មោះនេះក៏បានតាមបាញ់ខ្លួននៅជិតបង្គន់នោះទៀត "។( ឯកសារលេខ៣៥ )

* បានឃើញតំណាងអយ្យការ អមតុលាការក្រុងភ្នំពេញបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ នៅចំពោះមុខសវនាការ កន្លងមកនេះផ្អែកតាមចម្លើយជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី និង

_ 283 _

សាក្សីចំពោះ បានបញ្ជាក់យ៉ាងច្បាស់ ពីសកម្មភាពជនជាប់ចោទឈ្មោះ ទិន ហ៊ិន នេះគឺពិតជាមានបំណង ប៉ុនប៉ងធ្វើមនុស្សឃាតពិតប្រាកដមែន ។ ការប្រព្រឹត្តរបស់ជនជាប់ចោទ គឺអាវុធអាកា ក្នុងមួយពព្រិចភ្នែក ជនជាប់ចោទបានធ្វើឱ្យជនរងគ្រោះដែលជាកងកម្លាំងនគរបាលបុស្តិ៍ទួលសង្កែត្រូវពិការអស់មួយជីវិត ហេតុដូចនេះ តាងនាមអយ្យការ ខ្ញុំសូមតម្កល់ការចោទប្រកាន់នៅដដែលនិងសូមឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

* បានឃើញតុលាការក្រុងភ្នំពេញ បានសំរេចសេចក្តីចំពោះមុខក្តីតាមអំណាចសាលក្រម ព្រហ្មទណ្ឌលេខ៣៦៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១_ផ្តន្ទាទោសឈ្មោះទិន ហ៊ិន ភេទប្រុស អាយុ៤៦ឆ្នាំ ដាក់ពន្ធនាគារចំនួន១២ឆ្នាំ គិតចាប់តាំងថ្ងៃឃុំខ្លួន " ថ្ងៃឃុំខ្លួនថ្ងៃទី០៤មករា១៩៩៤ " ពីបទ " ប៉ុនប៉ងធ្វើមនុស្សឃាត " ប្រព្រឹត្តនៅ ក្រុងភ្នំពេញកាលពីថ្ងៃទី២៦ធ្នូ១៩៩៣ តាមបញ្ញត្តិមាត្រាទី៣២នៃក្រមព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០កញ្ញា១៩៩២។

២_ម៉ូតូម៉ាកហុងដាឌីលុចសេ៩០មួយគ្រឿង ត្រូវរឹបអូសធានាសំណង ។

៣_ឱ្យឈ្មោះទិន ហ៊ិន សងសំណងរដ្ឋប្បវេណីឈ្មោះស្វេរ សាវឌី ចំនួន១៥.០០០.០០០៛ " ដប់ប្រាំលានរៀលគត់ " ជម្ងឺចិត្តប្រាំលានរៀល " ៥.០០០.០០០៛ " សំណូមពរលើសពីនេះ បដិសេធចោល ។ និងសងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះមាស សាវ៉ាត ចំនួន២ជីចឹងមាស " ពីរជីចឹងមាស "ករណីមិនសងត្រូវដាក់គុកបង្ខំរូបកាយតាមច្បាប់ស្តីពីការដាក់គុកបង្ខំរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ។

៤_សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខក្តីបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេល២ខែ ចាប់ តាំងពីថ្ងៃនេះតទៅ ។

ដោយអាងហេតុថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះទិន ហ៊ិន ពិតជាមានបំណងប៉ុនប៉ង ធ្វើមនុស្សឃាតប្រាកដមែន បទល្មើសព្រហ្មទណ្ឌមានចែងនិងផ្តន្ទាទោសតាមមាត្រាទី៣២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ កញ្ញា ១៩៩២ ។

សាលក្រមនេះត្រូវបានឈ្មោះទិន ហ៊ិន ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ១៦៦ ចុះថ្ងៃ ទី១១ វិច្ឆិកា ១៩៩៤ លើសេចក្តីវិនិច្ឆ័យនៃសាលក្រមទាំងមូល ។

* បានឃើញតំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ធ្វើសេចក្តីសន្និដ្ឋានថា ៖

_យល់ឃើញថាដីកាលេខ៤៤៩៣តប្រ/៩_៩_៩៤ របស់ចៅក្រម ស៊ើបអង្កេតបញ្ជូនជនល្មើស ឈ្មោះទិន ហ៊ិន ទៅតុលាការជំនុំជំរះពីបទមនុស្សឃាតដោយចេតនាតាមបញ្ញត្តិមាត្រា៣២នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ចុះថ្ងៃទី១០កញ្ញា១៩៩២ ដោយគ្មានសម្រេចកែប្រែបទល្មើស បង្ករបួសស្នាមគ្មានអង្កេតបំពេញទម្រង់ការ ស្វែងរកភស្តុតាងអំពីបទល្មើសប្រើប្រាស់អាវុធខុសច្បាប់ និងគ្មានសម្រេចអំពីបទល្មើសនេះសោះឃើញថាខុស នឹង នីតិវិធីស៊ើបអង្កេត ។

_យល់ឃើញថាអំពើល្មើសប្រព្រឹត្តដោយឈ្មោះទិន ហ៊ិននៅថ្ងៃទី២៦ធ្នូ១៩៩៣មានបីបទល្មើសៈ

១_ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាលើរូបឈ្មោះមាស សាវ៉ាត ដែលអយ្យការចោទជា បង្ករបួសស្នាម ។

២_ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាលើរូបកាយឈ្មោះសួរ សុខណ្ណា

៣_ប្រើប្រាស់អាវុធដោយគ្មានច្បាប់អនុញ្ញាតនិងប្រើប្រាស់អាវុធ ដែលយកមកប្រព្រឹត្តិបទល្មើស ខាងលើ ។

ព្រោះជនរងគ្រោះសុទ្ធតែទទួលព្យសនកម្មជាភស្តុតាងបញ្ជាក់សិទ្ធិទាមទារសំណងនិងជម្ងឺចិត្ត ប៉ុន្តែដីការបស់ចៅក្រមបញ្ជូនរឿងទៅជំនុំជំរះក្តីសាលាក្រមក្តី ខ្វះសេចក្តីបញ្ជាក់អំពីបទល្មើសទាំងនេះឱ្យបានច្បាស់លាស់ទាំងស្រុង ។

* បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៧ ចុះថ្ងៃទី០៥ ឧសភា ១៩៩៥របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១_ទទួលបណ្តឹងឧទ្ធរណ៍របស់ជនល្មើសឈ្មោះខិន ហ៊ីន ចុះថ្ងៃទី១១វិច្ឆិកា១៩៩៤ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២_សំរេចមិនជំនុំជំរះរឿងព្រហ្មទណ្ឌនេះដល់អង្គសេចក្តីដោយទុកអំណាចឱ្យមហាអយ្យការអមសាលាឧទ្ធរណ៍ប្តឹងសាទុក្ខ ។

៣_សំរេចបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១១៤ ចុះថ្ងៃទី០៥_១២_៩៤ ទៅឱ្យមហាអយ្យការអមសាលាឧទ្ធរណ៍ដើម្បីចាត់ការតាមច្បាប់ ។

៤_សាលដីកានេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

សាលាឧទ្ធរណ៍សំរេចយ៉ាងដូចនេះដោយអាងហេតុថា ៖

_លិខិតចោទប្រកាន់របស់អយ្យការ ចុះថ្ងៃទី០៤មករា១៩៩៤ បានសុំឱ្យចៅក្រមស៊ើបអង្កេតលើបទល្មើសបង្ករបួសស្នាម និងប្រើប្រាស់អាវុធខុសច្បាប់តាមបញ្ញត្តិមាត្រា៤១និង៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលប្រព្រឹត្តិដោយជនល្មើស ខិន ហ៊ីន ។

ក្នុងដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ៤៩៣នព្រ ចុះថ្ងៃទី០៩កញ្ញា១៩៩៤ ចៅក្រមស៊ើបអង្កេតបានកំណត់បទល្មើសប្រព្រឹត្តដោយឈ្មោះខិន ហ៊ីន ជាបទមនុស្សឃាតដោយចេតនាតាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តែចៅក្រមស៊ើបអង្កេតមិនបានកែប្រែបទល្មើស ហើយក៏មិនបានបញ្ជាក់អំពីមូលហេតុនៃការកែប្រែនេះនៅក្នុងដីកាបញ្ជូនរឿងទៅឱ្យព្រះរាជអាជ្ញាពិនិត្យលេខ៤៣៦០នព្រ ចុះថ្ងៃទី០១កញ្ញា១៩៩៤ " មាត្រា៩២ វាក្យខណ្ឌទី២ ទី៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើនៅថ្ងៃទី០៨កុម្ភៈ១៩៩៣ "។

_ក្នុងករណីកែប្រែបទល្មើសពីបទបង្ករបួសស្នាមដែលជាបទមជ្ឈិមទៅជាបទធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋនោះចាំបាច់ទាមទារឱ្យមានការចោទប្រកាន់ថ្មី និងការសួរចម្លើយថ្មី ទៅលើជនជាប់ចោទពីបទឧក្រិដ្ឋនេះ " មាត្រា៩៣ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ " ។

_ចៅក្រមស៊ើបអង្កេតពុំបានអង្កេតស្វែងរកភស្តុតាងអំពីបទល្មើសប្រើប្រាស់អាវុធខុសច្បាប់ដែលត្រូវបានកំណត់ ក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ហើយគ្មានបានសំរេចអំពីបទល្មើសនេះសោះ " មាត្រា៧០ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ " ។

--

_សាលក្រមព្រហ្មទណ្ឌលេខ៣៦៤ ចុះថ្ងៃទី២៧កញ្ញា១៩៩៤របស់តុលាការក្រុងភ្នំពេញ មានលក្ខណៈមិនត្រឹមត្រូវតាមទំរង់ច្បាប់ ហេតុដូច្នេះសាលាឧទ្ធរណ៍គប្បីមិនជំនុំជំរះវិវាទលើអង្គសេចក្តី ដោយទុកអំណាចឱ្យមហាអយ្យការ អមសាលាឧទ្ធរណ៍ប្តឹងសាទុក្ខទៅតុលាការកំពូលដើម្បីបដិសេធនីតិវិធីខុសច្បាប់ ។

* បានឃើញបណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី០៩ ឧសភា ១៩៩៥ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ធ្វើឡើងតាមកំណត់ច្បាប់ ។

* បានឃើញសារណាចុះថ្ងៃទី០៤ មករា ១៩៩៤ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ជាម្ចាស់បណ្តឹងសាទុក្ខលើកឡើងថា ៖

_អយ្យការ អមតុលាការក្រុងភ្នំពេញបានធ្វើសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី០៤មករា១៩៩៤ សុំឱ្យចៅក្រមស៊ើបអង្កេតលើជនល្មើសឈ្មោះខិន ហ៊ិន ពីបទបង្ករបួសស្នាម និងប្រើប្រាស់អាវុធខុសច្បាប់ប្រព្រឹត្តនៅថ្ងៃទី២៦ធ្នូ១៩៩៣នៅភ្នំពេញ បទល្មើសនិងទោសចែងក្នុងមាត្រា៤១និង៥៤ នៃច្បាប់ព្រហ្មទណ្ឌ ចុះថ្ងៃទី១០កញ្ញា ១៩៩២ ប៉ុន្តែចៅក្រមស៊ើបអង្កេតសំរេចបញ្ជូនឈ្មោះខិន ហ៊ិន ទៅតុលាការព្រហ្មទណ្ឌជំនុំជំរះពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា បទល្មើសចែងក្នុងមាត្រា៣២ ច្បាប់ព្រហ្មទណ្ឌ ចុះថ្ងៃទី១០កញ្ញា១៩៩២ ដោយគ្មានកែប្រែបទមជ្ឈិម ទៅបទឧក្រិដ្ឋប៉ុនប៉ងធ្វើមនុស្សឃាតឡើយ ពិសេស គ្មានសុំឱ្យអយ្យការចោទប្រកាន់បទឧក្រិដ្ឋថ្មីនេះ ។

ដីកាបញ្ជូនរឿងទៅជំនុំជំរះរបស់ចៅក្រមស៊ើបអង្កេតលេខ៤៤៩៣គព្រចុះថ្ងៃទី០៩ កញ្ញា ១៩៩៤ បានបំពានបញ្ញត្តិមាត្រា៩៣ ។

ចៅក្រមស៊ើបអង្កេតបានរំលោភអំណាចរបស់អយ្យការដែលបានសុំឱ្យស៊ើបអង្កេតលើជនល្មើស. ក្នុងបទប្រើប្រាស់អាវុធខុសច្បាប់ដែលជាអំពើល្មើស នឹងបញ្ញត្តិមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០_ខែកញ្ញា_ឆ្នាំ១៩៩២ ប៉ុន្តែចៅក្រមស៊ើបអង្កេតគ្មានសំរេចអ្វីទាំងអស់ ដែលជាការរំលោភនឹងបញ្ញត្តិមាត្រា៩០ និង៩២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

_អំពើប្រព្រឹត្តរបស់ជនល្មើសឈ្មោះខិន ហ៊ិន កាលពីថ្ងៃទី២៦ខែធ្នូឆ្នាំ១៩៩៣មានបីបទល្មើស

១_ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា និងអាវុធលើរូបឈ្មោះ មាស សាវ៉ាន ។

២_ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា និងអាវុធលើរូបឈ្មោះ សូរ សុខណ្ណា ។

៣_ប្រើប្រាស់អាវុធដោយគ្មានច្បាប់អនុញ្ញាត ។

_យល់ឃើញថា សាលក្រមតុលាការក្រុងភ្នំពេញលេខ៣៦៤ ចុះថ្ងៃទី២៧ខែកញ្ញាឆ្នាំ១៩៩៤ ដែលសំរេចសេចក្តី ដោយហេតុមានដីកាបញ្ជូនរឿងរបស់ចៅក្រមស៊ើបសួរលេខ៤៤៩៣គព្រចុះថ្ងៃទី៩ខែកញ្ញាឆ្នាំ១៩៩៤ ដែលជាដីកាសំរេចរំលោភបញ្ញត្តិច្បាប់ចែងខាងលើ ដែលជាឯកសារមានមោឃភាព ដូច្នេះសាលក្រមនេះ ក៏គ្មានតម្លៃជាសាលក្រមត្រឹមត្រូវ ដែលគួរតែបដិសេធចោល និងបដិសេធចោលនូវលិខិតដែលមានមោឃភាពមុនៗមកហើយនោះដែរ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់តំណាងមហាអយ្យការ ឡើងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ថា ៖

១- រឿងនេះខុសនីតិវិធីទំនាស់នឹងមាត្រាដូចចៅក្រមរបាយការណ៍បានលើកឡើងស្រាប់ ។

២- ករណីដែលសាលាឧទ្ធរណ៍ បានសំរេចប្រគល់សមត្ថកិច្ចឱ្យមហាអយ្យការ អមសាលាឧទ្ធរណ៍ ធ្វើបណ្តឹងសាទុក្ខនោះគឺជាការផ្ទុយពីគតិច្បាប់ទាំងស្រុង។អាស្រ័យហេតុនេះ មហាអយ្យការអមតុលាការកំពូល សុំស្នើបដិសេធសាលដីកាសាលាឧទ្ធរណ៍ទុកជាមោឃៈហើយបញ្ជូនរឿងឱ្យសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋាន របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ " ៤៧/២ "

បានស្តាប់សេចក្តីសន្និដ្ឋាន ការពាររបស់លោក ខុច ខន្ធា ជាមេធាវីជនជាប់ចោទថា ៖

- ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញបានធ្វើសេចក្តីសន្និដ្ឋានពីបទបង្ករបួសស្នាមនិងប្រើប្រាស់អាវុធខុសច្បាប់បញ្ជូនឱ្យចៅក្រមស៊ើបអង្កេត ។ ចៅក្រមស៊ើបអង្កេតចប់ បញ្ជូនទៅពិនិត្យដោយពុំបានសុំកែប្រែបទសន្និដ្ឋានទោសអ្វីទេ ។ ឯព្រះរាជអាជ្ញាពុំបានតំរូវឱ្យចៅក្រមស៊ើបអង្កេតស៊ើបសួរបន្ថែមលើចំណុចដែលខ្លួនចង់កែប្រែពីបទចោទដោយគ្រាន់តែចារលើដីកាជូនពិនិត្យ ចោទពីបទប៉ុនប៉ងធ្វើមនុស្សឃាតទៅវិញ ។

- ចៅក្រមស៊ើបអង្កេតបានធ្វើដីកាជូនរឿងទៅជំនុំជំរះដោយសន្និដ្ឋានពីបទចោទមនុស្សឃាតទៅវិញ ។

- ចៅក្រមជំនុំជំរះបានជំនុំជំរះលើបទប៉ុនប៉ងធ្វើមនុស្សឃាត ដែលជាបទឧក្រិដ្ឋមួយថ្មី តាមចំណារ របស់ព្រះរាជអាជ្ញា ។

ប្រការនេះវាខុសនឹងនីតិវិធីព្រហ្មទណ្ឌមាត្រា៧០,៧១,១០៥និង១០៦ហាក់ដូចពុំបានធ្វើការស៊ើបអង្កេតលើបទល្មើសប៉ុនប៉ងធ្វើមនុស្សឃាតបន្តិចឡើយ ចៅក្រមជំនុំជំរះក៏ធ្វើការជំនុំជំរះលើបទប៉ុនប៉ងធ្វើមនុស្សឃាតដែលជាបទឧក្រិដ្ឋមួយថ្មីខុសពីដីកាសន្និដ្ឋាន ឱ្យស៊ើបសួរដែលជាបទមជ្ឈិម ។ ការផ្លាស់ប្តូរបទចោទពីបទមជ្ឈិមទៅបទឧក្រិដ្ឋត្រូវតែមានការសន្និដ្ឋានចោទឱ្យស៊ើបសួរថ្មីពីព្រះរាជអាជ្ញា តែការនេះពុំបានអនុវត្តទេ ដូច្នេះតុលាការក្រុងភ្នំពេញ ធ្វើការជំនុំជំរះ លើបទឧក្រិដ្ឋមួយ ដោយពុំបានស៊ើបអង្កេតសោះ ។

ហេតុដូចនេះ ខ្ញុំបាទសុំការអនុញ្ញាតលើកឡើងដល់អង្គហេតុបន្តិចគឺរឿងនេះកើតឡើងពីទំនាស់រវាងប្រពន្ធប្រធានភូមិ និងប្រពន្ធជនជាប់ចោទ កាលពីពេលថ្ងៃ ដល់យប់ជនរងគ្រោះបានចូលទៅក្នុងផ្ទះ ជនជាប់ចោទ ដោយគ្មានសញ្ញា ហើយជនល្មើសក៏បាញ់ទាំងការភ័ន្តច្រឡំលើជននោះ ។ នៅក្នុងក្រមព្រហ្មទណ្ឌសង្គមចាស់ មានចែងអំពីការចូលក្នុងលំនៅស្ថានគេដោយគ្មានការអនុញ្ញាតជាមុននោះគឺជាការ ការពារស្របច្បាប់របស់កូនក្តីខ្ញុំបាទ ។ ម្យ៉ាងទៀតកូនក្តីខ្ញុំជាប៉ូលីសប្រាកដជាជំនាញក្នុងការបាញ់ឱ្យចំចំណុចស្លាប់ តែនេះបាញ់រហូតដល់ទៅ១៦គ្រាប់ មិនស្លាប់ នេះសរបញ្ជាក់ឱ្យឃើញថាកូនក្តីខ្ញុំពុំមានបំណងសំលាប់មនុស្សឡើយ គឺគ្រាន់ជាអំពើការការពារខ្លួនស្របច្បាប់ ដោយបាញ់ជនរងគ្រោះផ្តួៗ មិនអាចឱ្យជនរងគ្រោះតដៃបាន ។ កូនក្តីខ្ញុំពុំបានដឹងទេថា អ្នកទាំងពីរជានគរបាលឡើយ ព្រោះពេលថ្ងៃមានការឈ្លោះគ្នាម្តងហើយ ។

ហេតុដូច្នេះ ខ្ញុំបាទជាមេធាវី សូមសំណូមពរ ដល់ក្រុមប្រឹក្សាចៅក្រម តុលាការកំពូល បដិសេធចោល សាលក្រមតុលាការថ្នាក់ក្រោម និងសូមឱ្យស៊ើបអង្កេតរឿងនេះឡើងវិញ ព្រោះកូនក្តីខ្ញុំពុំមានចេតនាប៉ុនប៉ងសំលាប់មនុស្ស ដូចការផ្តន្ទាទោសនៅតុលាការថ្នាក់ទី១នោះទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា ៖

ក្នុងករណីដែលលោកមេធាវី បានលើកពីករណីការការពារស្របច្បាប់នោះ ខ្ញុំក្នុងនាមព្រះរាជអាជ្ញា មហាអយ្យការ អមតុលាការកំពូល ពុំទាន់មានយោបល់អ្វីទៀតទេពីព្រោះចៅក្រមស៊ើបអង្កេតពុំទាន់បានស៊ើបអង្កេតជាថ្មីពីបទឧក្រិដ្ឋនេះនៅឡើយទេ ។ ដូច្នេះសូមឱ្យតុលាការកំពូលគ្រាន់តែបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល ហើយបង្វិលឱ្យសាលាឧទ្ធរណ៍ជំនុំជំរះ ទុកលទ្ធភាពឱ្យព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ និងចៅក្រមស៊ើបអង្កេត ឬចំណាត់ការរបស់សាលាឧទ្ធរណ៍យ៉ាងណានោះ គឺចាត់ការបន្តទៀតចុះ ។

- ក្រោយពបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន ការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៥ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី ។
- យល់ឃើញថា ព្រះរាជអាជ្ញា អមតុលាការក្រុងភ្នំពេញ ដែលបានផ្តើមចោទប្រកាន់បទល្មើសថ្មី រួចបញ្ជូនសំណុំរឿង និង ជនជាប់ចោទទៅជំនុំជំរះ ,ហើយតុលាការក្រុងភ្នំពេញក្រោយពីបានឃើញសេចក្តីសន្និដ្ឋានចោទប្រកាន់ថ្មីរបស់ព្រះរាជអាជ្ញា ពុំបានធ្វើការស៊ើបអង្កេតតាមបទល្មើសថ្មីនោះ ជាការបំពានទៅនឹងមាត្រា៧០,៩៣,១០៤ និងមាត្រា១០៧ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ។
- យល់ឃើញថា តាមមាត្រា១៦៣ និងមាត្រា១៩២ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជំរះគ្រប់ចំណុចទាំងអស់នៃអង្គហេតុនិងអង្គច្បាប់ដែលតុលាការជាន់ក្រោម បានពិនិត្យ។ ដូចនេះសាលាឧទ្ធរណ៍ដែលសំរេចមិនសំរេចយល់អង្គសេចក្តីនោះពុំបានបំពេញភារកិច្ច តាមសមត្ថកិច្ចរបស់ខ្លួនឡើយ ។ ព្រោះថាតុលាការក្រុងភ្នំពេញបានកំណត់ទោសជនជាប់ចោទជាបទឧក្រិដ្ឋរួចទៅហើយ ។

_ 288 _

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវីជនជាប់ចោទ

១_ ទទួលបណ្តឹងសាទុក្ខលេខ១០៨ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៥ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២៧ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ០៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥ ។

# ឧបសម្ពន្ធទី៣

## ៣.១.រឿងក្តី BARCELONA TRACTION

When teaching international law there are always cases that are mentioned, but never truly discussed. We either just quote a few sentences, or only refer to them as a source for a point to be made. These could, in good conscience, be called Classic Cases, but not too many people have actually delved into them. I think. I also thought that the Barcelona Traction-case is one of those cases. But when I started reading the case in depth, I kind of understood why not too many people actually read the damn thing. I, for one, had troubling going through economic principles and corporate structures. Or I was just distracted for a couple of days.

**BARCELONA TRACTION, LIGHT & POWER COMPANY**

Belgium tried to exercise a right of diplomatic protection on behalf of the Belgian shareholders of the Barcelona Traction, Light & Power Company. This company was registered and had its head office in Canada. It operated a number of subsidiaries in Spain, under Spanish law, through which it provided electricity in Spain. The Belgian shareholders, or rather sterling bondholders, were paid interest on their bonds through foreign currency transfers from the subsidiaries to Barcelona Traction (you still with me?). Question: In this triangular relationship, can Belgium actually bring a claim against Spain for damages to the Belgian bondholders? Because they had invested in a Canadian company, not a Spanish one. According to the International Court of Justice, Belgium could only do so if the company ceased to exist, or if the company's national state lacks the capacity to act on behalf of the company.

**NATIONALITY OF CORPORATIONS**

For diplomatic protection, the injured persons must have the nationality of the state doing the protection, but these persons must also use, exhaust all the legal remedies available in the state where they were actually injured. For individuals, we used to refer to the Nottebohm-case – another Classic Case. But we look to the Barcelona Traction-case as the source for the rule determining the nationality of corporations. The Court recited the 'traditional rule' that diplomatic protection can only be exercised by the state where it is registered and has its registered office. Barcelona Traction was a Canadian company. And that was that. That is one of the main reasons we use the Barcelona Traction-case.

**OBLIGATIONS ERGA OMNES**

So there is more. Even more so in passing, by way of a so-called obiter dictum, the Court distinguished between different kinds of obligations. In the Barcelona Traction-case, the Court explained that some international legal obligations are so important that all States have an interest in their protection. Prohibitions on genocide, slavery, racial discrimination are examples of what are called obligations erga omnes. When such obligations are violated, all States have a right to hold the offending State

accountable and legally responsible. But 'obligations the performance of which is the subject of diplomatic protection are not of the same category.' Great. And the Court moves on to say more relevant things.

**INVESTMENT TREATIES**

The Court eventually decided that Belgium did not have standing, was not allowed to bring a claim. Only Canada could, although not on behalf of its Belgian shareholders. Canada would have been able to exercise diplomatic protection for Canadian shareholders. But these days, as the Court also noted, the protection of investors – like shareholders – is regulated through bilateral investment treaties. And these include investor-state dispute settlement through arbitration, as is now included in the proposal for TTIP. I thought I'd throw that one in there[១៩៣].

## ៣.២.រឿងក្ដី BLANCO

Le : 16/07/2018

Tribunal des conflits

**N° 00012**

Publié au recueil Lebon

M. Mercier, rapporteur

M. David, commissaire du gouvernement

lecture du samedi 8 février 1873

**REPUBLIQUE FRANCAISE**

**AU NOM DU PEUPLE FRANCAIS**

Vu l'exploit introductif d'instance, du 24 janvier 1872, par lequel Jean Y... a fait assigner, devant le tribunal civil de Bordeaux, l'Etat, en la personne du préfet de la Gironde, Adolphe Z..., Henri X..., Pierre Monet et Jean A..., employés à la manufacture des tabacs, à Bordeaux, pour, attendu que, le 3 novembre 1871, sa fille Agnès Y..., âgée de cinq ans et demi, passait sur la voie publique devant l'entrepôt des tabacs, lorsqu'un wagon poussé de l'intérieur par les employés susnommés, la renversa et lui passa sur la cuisse, dont elle a dû subir l'amputation ; que cet accident est imputable à la faute desdits employés, s'ouïr condamner, solidairement, lesdits employés comme co-auteurs de l'accident et l'Etat comme civilement responsable du fait de ses employés, à lui payer la somme de 40,000 francs à titre d'indemnité ;

Vu le déclinatoire proposé par le préfet de la Gironde, le 29 avril 1872 ; Vu le jugement rendu, le 17 juillet 1872, par le tribunal civil de Bordeaux, qui rejette le déclinatoire et retient la connaissance de la cause, tant à l'encontre de l'Etat qu'à l'encontre des employés susnommés ; Vu l'arrêté de conflit pris

[១៩៣] គេហៈទំព័រ, http://manusama.com/2016/11/22/classic-cases-barcelona-traction-case-1970/ (ដកស្រង់ ២០ មិថុនា ២០១៨)

par le préfet de la Gironde, le 22 du même mois, revendiquant pour l'autorité administrative la connaissance de l'action en responsabilité intentée par Y... contre l'Etat, et motivé : 1° sur la nécessité d'apprécier la part de responsabilité incombant aux agents de l'Etat selon les règles variables dans chaque branche des services publics ; 2° sur l'interdiction pour les tribunaux ordinaires de connaître des demandes tendant à constituer l'Etat débiteur, ainsi qu'il résulte des lois des 22 décembre 1789, 18 juillet, 8 août 1790, du décret du 26 septembre 1793 et de l'arrêté du Directoire du 2 germinal an 5 ; Vu le jugement du tribunal civil de Bordeaux, en date du 24 juillet 1872, qui surseoit à statuer sur la demande ; Vu les lois des 16-24 août 1790 et du 16 fructidor an 3 ; Vu l'ordonnance du 1er juin 1828 et la loi du 24 mai 1872 ;

Considérant que l'action intentée par le sieur Y... contre le préfet du département de la Gironde, représentant l'Etat, a pour objet de faire déclarer l'Etat civilement responsable, par application des articles 1382, 1383 et 1384 du Code civil, du dommage résultant de la blessure que sa fille aurait éprouvée par le fait d'ouvriers employés par l'administration des tabacs ;

Considérant que la responsabilité, qui peut incomber à l'Etat, pour les dommages causés aux particuliers par le fait des personnes qu'il emploie dans le service public, ne peut être régie par les principes qui sont établis dans le Code civil, pour les rapports de particulier à particulier ;

Que cette responsabilité n'est ni générale, ni absolue ; qu'elle a ses règles spéciales qui varient suivant les besoins du service et la nécessité de concilier les droits de l'Etat avec les droits privés ;
Que, dès lors, aux termes des lois ci-dessus visées, l'autorité administrative est seule compétente pour en connaître ;
DECIDE : Article 1er : L'arrêté de conflit en date du 22 juillet 1872 est confirmé. Article 2 : Sont considérés comme non avenus, en ce qui concerne l'Etat, l'exploit introductif d'instance du 24 janvier 1872 et le jugement du tribunal civil de Bordeaux du 17 juillet de la même année. Article 3 : Transmission de la décision au garde des sceaux pour l'exécution.

**Abstrats :** 17 COMPETENCE - Responsabilité.
60 RESPONSABILITE DE LA PUISSANCE PUBLIQUE - Enfant blessé par une imprudence des employés de l'Etat - Action contre les employés et contre l'Etat comme civilement responsable.

**Résumé :** 17, 60 Un enfant, qui passait sur la voie publique devant l'entrepôt des tabacs de Bordeaux, a été renversé par un wagon que les employés de l'Etat ont poussé de l'intérieur de l'établissement ; il a dû subir l'amputation. - Le père de l'enfant intente une action en dommages-intérêts contre lesdits employés et contre l'Etat solidairement comme civilement responsable du fait de ses agents par application des articles 1382, 1383, 1384 du Code civil. L'autorité administrative est-elle seule compétente pour statuer sur la demande d'indemnité en tant que dirigée contre l'Etat, alors même que cette demande est fondée non pas sur l'exécution ou l'omission de certaines mesures administratives, - mais bien sur une faute ou une négligence qui serait personnelle aux agents de l'Etat dans l'emploi auquel ils sont préposés ? - Rés. aff.. - La responsabilité, qui peut incomber à l'Etat pour dommages causés aux particuliers par le fait des personnes qu'il emploie dans le service public, n'est pas régie par les principes établis dans le Code civil pour les rapports entre particuliers : elle n'est ni générale, ni absolue : elle a ses règles spéciales qui varient suivant les besoins du service et la nécessité de concilier les droits de l'Etat avec les droits privés[១៥៨].

[១៥៨] គេហៈទំព័រ, https://www.legifrance.gouv.fr/affichJuriAdmin.do?idTexte=CETATEXT000007605886 (ដកស្រង់ ១៦ កក្កដា ២០១៨)